Chan Bophal
Roland-Meyer‘s Saramani-Danseuse-Cambodgienne
Khmer UI version created by Angkor Database, Nov. 2025

ក្រុងភ្នំពេញ៖ តួសំណប់ព្រះការុណាព្រះស៊ីសុវត្ថិព្រះចៅក្រុងកម្ពុជា
រឿង «សារ៉ាម៉ានី» និពន្ធដោយជនជាតិបារាំង ឈ្មោះ “រ៉ូឡង់ ម៉ីយែរ” ចាងហ្វាងវិចិត្រសិល្បៈប្រចាំប្រទេសកម្ពុជា
កាលដំនាន់ប្រទេសយើង ស្ថិតនៅក្រោមអាណាព្យាបាលបារាំងនៅឡើយ ដោយដាក់ចំណងជើងថា «SARAMANI, DANSEUSE KHMERE» បោះពុម្ពផ្សាយក្នុងឆ្នាំ ១៩១៩។ “រ៉ូឡង់ ម៉ីយែរ” ធ្លាប់រស់នៅក្នុងប្រទេសយើងអស់ ពេលដ៏យូរ ធ្លាប់ចេញ-ចូលវាំងស្តេចខ្មែរជាញឹកញាប់ ទើបអាចស្គាល់ និង ដឹងជីវភាពស្តេចបានជាក់លាក់ល្អយ៉ាងនេះ។ សោតឯ ដំណើររឿង ខ្ញុំបានសាកសួរចាស់ទុំជ្រើននាក់ ដែលធ្លាប់រស់នៅក្នុងវាំង ឃើញថា សុទ្ធសឹងជារឿងពិត រហូតដល់តួអង្គ ក្នុងរឿង ក៏សុទ្ធជាមនុស្សដែលធ្លាប់ បានរស់នៅកាលដំនាន់នោះមែន ។...៕
ការផ្សាយរបស់ទស្សនាវដ្តីអង្គរវត្ត បោះពុម្ពផ្សាយដោយបណ្ណាគារអង្គរ
ដំកល់ទុកនៅបណ្ណាល័យជាតិបារាំងក្រុងប៉ារីស និង នៅបណ្ណាល័យខ្មែរក្រុងភ្នំពេញ
ISBN 10: 99950-59-03-7
ISBN 13: 978-99950-59-03-3

កំណត់ ការបោះពុម្ព

សារ៉ាម៉ានី ជាប្រលោមលោកនិពន្ធដោយ Roland MEYER ជាភាសាបារាំង "SARAMANI, DANSEUSE KHMERE" បោះពុម្ពផ្សាយនៅភ្នំពេញ នាឆ្នាំ ១៩១៩ ។ លោក រ៉ូឡង់ ម៉ីយែរ ជាចាងហ្វាងវិចិត្រសិល្បៈ ប្រចាំប្រទេសកម្ពុជា ធ្វើការនៅស្រុកខ្មែរ ធ្លាប់ចេញចូលវាំងស្តេចខ្មែរ និង បានរស់នៅយ៉ាងយូរនៅស្រុកខ្មែរ។ នេះជាកត្តា ដ៏សំខាន់អនុញ្ញាតឲ្យ លោកនិពន្ធសៀវភៅនេះឡើង ប្រកបដោយខ្លឹមសារដ៏ល្អ រៀបរាប់ពីជីវភាពព្រះរាជវង្ស នៃព្រះមហាក្សត្រខ្មែរ នៅក្នុងវាំង ពីជីវភាពរាស្ត្រខ្មែរ ពីសង្គមខ្មែរនៅសម័យនោះ ពីចំណាប់អារម្មណ៍ នៃ សារ៉ាម៉ានី នារីខ្មែរសាមញ្ញម្នាក់ ដែលបានធ្វើដំណើរតាមកប៉ាល់ទឹក ឆ្លងកាត់មហាសាគរ ច្រើនថ្ងៃ ច្រើនយប់ មុននឹងបានមកដល់ និង ស្នាក់អាស្រ័យមួយរយៈពេលដ៏ខ្លី នៅស្រុកបារាំង។

សៀវភៅនេះ ជាកញ្ចក់មួយ ដែលជនជាតិបារាំងម្នាក់ ហ៊ាននិយាយពីសង្គមខ្មែរ ក្នុងរជ្ជកាលព្រះបាទ ស៊ីសុវត្ថិ (១៩០៤ - ១៩២៧) ក្នុងរយៈពេលដែលប្រទេសខ្មែរយើង កំពុងស្ថិតនៅក្រោមអាណាព្យាបាលបារាំងនៅឡើយ។

ដើម្បីសង្កត់ន័យទៅលើខ្លឹមសារ នៃ សៀវភៅនេះ ដែលអ្នកស្រី ចន្ទ បូផល បានបកប្រែជាភាសាខ្មែរដ៏ល្អ និង បានបោះពុម្ពផ្សាយនៅភ្នំពេញ ពីឆ្នាំ ១៩៧១ ទស្សនាវដ្តីអង្គរវត្ត បានផ្សាយឡើងវិញនៅ ប៉ារីស នៅឆ្នាំ ១៩៩៦ និង រៀបចំបោះពុម្ពជាសៀវភៅផ្សាយនៅឆ្នាំនេះ ដោយមានដាក់បញ្ចូលរូបថតស្រុកខ្មែរមួយចំនួន ថតនៅរជ្ជកាលនៃព្រះមហាក្សត្រខ្មែរ ព្រះបាទ នរោត្តម និង ព្រះបាទ ស៊ីសុវត្ថិ។ គឺ សៀវភៅនេះតែមួយគត់ ដែល សម្តេច នរោត្តម សីហនុ បានយកទៅតាមព្រះអង្គ ពេលដែល ព្រះអង្គ បានការអនុញ្ញាតពី ប៉ុល ពត ឲ្យ ព្រះអង្គ យាងចេញពីក្រុងភ្នំពេញ ទៅក្រុងប៉ៃលិន នៅ ថ្ងៃទី ៦ មករា ១៩៧៩ ដើម្បីទៅការពារ អាសន: “កម្ពុជា ប្រជាធិបតេយ្យ” នៅអង្គការសហប្រជាជាតិ ពេលដែលទ័ពយួនវាយលុក និង កាន់កាប់កម្ពុជា មួយរយៈពេលនោះ។ ការបោះពុម្ពនៅប៉ារីសនេះ កើតឡើងបានដោយការខ្នះខ្នែងរបស់ លោក ទីន ប៊ុន ហេង ជាអ្នកបង្កើតតួអក្សរខ្មែរផ្ទាល់តែម្តង ព្រមជាមួយការរៀបចំទំព័រ ឌីស៊ីអិតស៊ីអាង ផ្តល់គុណភាពដ៏ល្អដល់សៀវភៅនេះឡើង៕

បោះពុម្ពផ្សាយនៅ ខែ កក្កដា គ.ស ២០០០ ព.ស ២៥៤៤ ដោយទស្សនាទានថ្មី អង្គរវត្ត

ANGKOR BOOK SHOP
#143Eo, rue Khemarak Phoumin (St. 130), Phsar Chas, Phnom Penh
Angkor Vat,
ISBN 2-9524557-9-1
ISSN 1162-1660

Year of first publication: **1971**

បុព្វកថា

ក្រោយពីបានចុះផ្សាយ ចប់សព្វគ្រប់តាមទំព័រ នៃ សារពាត៌មានរដ្ឋ «ប្រយោជន៍ខ្មែរ» រៀងរាល់ថ្ងៃ ចាប់តាំងពីលេខ ១៥៩ ចេញថ្ងៃទី ១៥ តុលា ១៩៧០ រហូតដល់លេខ ២៥១ ចេញថ្ងៃទី ២២ មករា ១៩៧១ ខ្ញុំក៏ បានរៀបចំចងក្រងរឿង « សារ៉ាម៉ានី» នេះ ជាសៀវភៅឡើង ដើម្បីជា កិច្ចគោរពតាមសំណូមពរ នៃ អស់លោក-មិត្តអ្នកអានជាច្រើន ដែលបាន យកចិត្តទុកដាក់អានរឿងនេះជាប់រហូតមក ហើយបានធ្វើលិខិតមកសុំឲ្យ ខ្ញុំរៀបចំបោះពុម្ពផ្សាយជាសៀវភៅ ដើម្បី ស្រួលរក្សាទុក។

រឿង «សារ៉ាម៉ានី» និពន្ធដោយជនជាតិបារាំង ឈ្មោះ "រ៉ូឡង់ ម៊ីយែរ" ចាងហ្វាងវិចិត្រសិល្បៈប្រចាំប្រទេសកម្ពុជា កាល ជំនាន់ប្រទេស យើង ស្ថិតនៅក្រោមអាណាព្យាបាលបារាំងនៅឡើយ ដោយដាក់ ចំណងជើងថា «SARAMANI, DANSEUSE KHMERE» បោះពុម្ព ផ្សាយក្នុងឆ្នាំ ១៩១៩។ "រ៉ូឡង់ ម៊ីយែរ" ធ្លាប់រស់នៅក្នុងប្រទេសយើងរស់ ពេលដំបូរ ធ្លាប់ចេញ-ចូលវាំងស្តេចខ្មែរជាញឹកញាប់ ទើបអាច ស្គាល់ និង ដឹង ជីវភាពស្តេចបានជាក់លាក់ល្អយ៉ាងនេះ។ សោត ឯដំណើររឿង ខ្ញុំបានសាកសួរចាស់ទុំច្រើននាក់ ដែលធ្លាប់រស់នៅក្នុងវាំង ឃើញថា សុទ្ធសឹងជារឿងពិត រហូតដល់តួ អង្គក្នុងរឿង ក៏សុទ្ធជាមនុស្សដែលធ្លាប់ បានរស់នៅកាលជំនាន់នោះមែន ។

ឆ្លៀតឱកាសនេះ ខ្ញុំសូមជម្រាបបញ្ជាក់ជាថ្មីម្តងទៀតថា ក្នុងការប្រែ សំរួលពីភាសាបារាំងមកជាភាសាជាតិយើង តែងតែមានការឆ្គៃ ពាក្យ- ពេចន៍ ឃ្លា ប្រយោគ ខ្លះជាធម្មតា ប៉ុន្តែទោះជាយ៉ាងណា ក៏ខ្ញុំឥតមាន ចែមចយសាច់រឿង ឬ ពន្លើសពាក្យសំដី ដើម្បីញុំងសាច់រឿងឲ្យឃើញ សម្បើមនោះដែរ ។

ចន្ទ បូផល

ADB Note: the Khmer translation started from p. 94 (end of 7th paragraph) and ended on p. 173 (end of 3d para) in the 1919 French edition.

គងពីរអន្លងលាន់ឮឡើង ដោយមានស្នូរបីអន្លងទៀតឮខ្លាំងជាងមុនបន្តិច បន្តីតាមក្រោយ.. គង ស្ងាត់មួយរយៈ ហើយបន្ទាប់មកសម្លេងភ្លេងពិណពាទ្យដ៏សែនលន្លង់លន្លោច ប្រៀបបានសម្លេងទឹព្ យរសាត់ចេញពីវាំងចតុមុខមក បណ្តោសអង្គែលសង្កាត់កំពង់ផែទាំងមូល ឲ្យដេកលង់លក់ស្ងាត់ឈឹង កណ្តាលរាត្រីដ៏ភ្លឺត្រចះត្រចង់។

សារ៉ាម៉ានី អង្គុយលើគ្រែនាងនួន កំពុងចាក់ដំរអារយ៉ាងស្ងៀមស្ងាត់ក្បែរចង្កៀងប្រេងកាត។ នាងដើប មុខឡើងក្រចៀកប្រុងស្តាប់ ទឹកមុខញញឹម ហើយនាងទម្លាក់ដៃទាំងពីរដែលកាន់ប្រដាប់ចាក់នោះទៅលើជង្គង់។ នៅពេលឮសម្លេងភ្លេងពិណពាទ្យ អនុស្សាវរីយ៍ នៃ រឿងរ៉ាវពីអតីតកាលទាំងប៉ុន្មាន ក៏លេចឡើង យ៉ាងច្បាស់នៅចំពោះមុខនាង ញ៉ាំងចិត្តនាងឲ្យប្រែជាស្រពោនភ្លាមមួយរំពេច។ នាងពោលឡើងដោយ សម្លេងញ័រៗ

~ ពួកល្ខោនមកប្រជុំគ្នានៅលើឆាកហើយ... ខ្ញុំស្រណោះកាលខ្ញុំនៅរ៉ាំណាស់!

កម្លោះ ក៏ដូចជាភ្ញាក់បន្តិចដែរ នៅពេលតន្ត្រីចាប់ប្រគុំឡើង ។ គេដាក់ស្លាបប៉ាកកាចុះ ភៀសសៀវភៅ ដាក់នៅលើតុ ដែលជាកន្លែងធ្វើការ និង ជាកន្លែងនៃពន្លឺក្តីសង្ឃឹមតែមួយគត់របស់គេចេញពីមុខបន្តិច.... ហើយចោលក្រសែភ្នែករំលងក្បាលភរិយា ជាញ៉ោះទៅរកូបថតព្យួរជាប់នឹងជញ្ជាំងស្លឹក ដែលជារូប សារ៉ាម៉ានី កាលនាងទើបនឹងមានវ័យដប់បួនឆ្នាំនៅឡើយ ស្លៀកពាក់ជាអ្នករ៉ាំល្ខោនហួង ពាក់មកុដមាស ស្អាតប្រិមប្រិយ៍ ដូចទេពអប្សរក្នុងរឿងព្រេងនិទាន ។

ឥឡូវបួនឆ្នាំកន្លងផុតមកហើយ ចាប់តាំងពីពេលដែល សារ៉ាម៉ានី ចាកចេញពីវាំងមក បន្តកជាស្ត្រីមេផ្ទះ បានធ្វើឲ្យចរិតនាងប្រែប្រួលប្លែកពីមុនស្ទើរតែទាំងអស់ ។

កម្លោះ និង សារ៉ាម៉ានី គូស្វាមី-ភរិយាវ័យក្មេងនេះ បានមកសង់ផ្ទះនៅជិតវាំងហួង ក្នុងសង្កាត់ កំពង់ផែ ដែលជាកេរ្តិ៍ដំណែលដ៏មានតម្លៃ រកអ្វីមកប្រៀបឲ្យស្មើពុំបាន នៃ ភូមិខ្មែរបុរាណ ហើយគេទាំង ពីរនាក់ អង្គុយធ្វើការទល់មុខគ្នាក្បែរចង្កៀងប្រេងកាតនៅក្នុងផ្ទះស្លឹកតូចច្រឡឹងនេះ ដោយមានលាក់ទុក ក្នុងផ្នត់គំនិត នូវរឿងដ៏មានតម្លៃបំផុតពុំដាយនឹងមាននរណាបានដឹងឡើយ គឺរឿងពិត នៃ បុគ្គលម្នាក់ មានឋានៈជាស្តេចគ្រប់គ្រងប្រទេសជាតិ ហើយដែលត្រូវបានអ្នកជនៃទៅគោរពស្តើព្រះអាទិទេព ។

ពេលនេះ ជាខែភទ្របទ... ពិធីបុណ្យចំរើនព្រះជន្មស្តេច បានទាក់ទាញនាម៉ឺនយ៉ាងច្រើនកុះករ មកពី គ្រប់ ខេត្ត-ខ័ណ្ឌ ឲ្យមកជួបជុំគ្នាក្នុងរាជធានី ដើម្បីធីកទឹកសម្បថ និង ចូលរួមក្នុងពិធីបុណ្យតាំងតុ។

ល្ងាចនេះ មានរ៉ាំល្ខោនហួងនៅខាងក្រៅវាំង ជូនសាធារណជនទស្សនាកំសាន្តផង។

កម្លោះ បើកចំហសៀវភៅត្រង់ទំព័រមួយ ដែលសរសេរមិនទាន់ចប់នៅឡើយ ហើយបណ្តែតអារម្មណ៍ ឲ្យរសាត់អណ្តែតទៅឆ្ងាយ.... ឆ្ងាយតតព្រំដែនក្នុងពិភព នៃក្តីស្រមៃដ៏ធំល្វឹងល្វើយ។

លោក! (សារ៉ាម៉ានី ឧទានតិចៗ ទម្លាយបរិយាកាសស្ងប់ស្ងាត់ ដោយសណ្តូកដៃទន់ងរលូនទៅ លើតុ) លោកគិតពីរឿងអីហ្នឹង? លោកនឹកទៅដល់រឿងរ៉ាវចាស់ដូចខ្ញុំដែរឬអ្វី? លោកញញឹមសួតអញ្ចឹង បានសេចក្តីថា លោកស្រឡាញ់ខ្ញុំមែនទែន ឬមួយក៏ លោករឭកទៅស្រុកកំណើតរបស់លោក? ខ្ញុំឃើញ តែលោកគិត, ឃើញតែលោកសរសេរ! លោកគូសក្រមេក្រវាមដូចជើងក្តាម ក្នុងសៀវភៅជំនេះរាប់ឆ្នាំ ហើយ តើលោកធ្វើការដើម្បីនរណា? លោកសម្លឹងមើលទៅឆ្ងាយលន្លង់លន្លោចអញ្ចឹង ខ្ញុំអត់យល់អីសោះ ទេ... យីអើ! កាលណាទើបលោកបង្រៀនឲ្យខ្ញុំចេះភាសាលោក ក្រាន់នឹងខ្ញុំអាចអង្គុយកំដរមើលលោក ធ្វើការពេលយប់បានផង?

សារ៉ាម៉ានី អគ្គិលខ្លួនទៅចុងត្រែ នាងយកដៃទាញស្បែស្តើងដែលគ្របដណ្តប់លើខ្លួនចេញ បង្ហាញនូវ គល់សុដនសរលោងដូចម្ជាងសិលា ប្រកបទៅដោយសរសៃខៀវលេចឡើងយ៉ាងច្បាស់ ។ ក្រសែភ្នែក កម្លោះ ប៉ះទង្គិចគ្នានឹងក្រសែភ្នែកនាង ដែលបញ្ចេញរស្មីស្រទន់ជាតំណាង នៃ ទឹកចិត្តស្អាតបរិសុទ្ធ និង សេចក្តីស្នេហាស្មោះត្រង់ ។ កម្លោះ ដាក់ដៃចុះទៅលើគំនរក្រដាសដោយកាយវិការខ្ជិលច្រអូស ហើយ ពោលឡើង:

- នាង! នាងមិនចាំបាច់ដឹងថាខ្ញុំសរសេរពីអ្វី, មិនចាំបាច់រៀនភាសាបារាំងទេ ។ ភាសានេះជាថ្នាំពុល ដ៏សាហាវបំផុតចំពោះស្ត្រីខ្មែរ វានឹងនាំឲ្យនាងស្គាល់ កាយវិការ និង អាកប្បកិរិយាច្រដេងច្រដាង ដែល នាងមិនធ្លាប់ដឹង វានឹងនាំឲ្យនាងកើតគំនិត និង ពុតត្បុតអាក្រក់ ដែលភាសានាងពុំអាចថ្លែងចេញជា ពាក្យសំដីបាន។ កម្រមានស្ត្រីខ្មែរណាដែលអាចទប់ទល់នឹងថ្នាំពុលនេះបានណាស់!... ខ្ញុំសរសេរដើម្បី អ្វី? នាង! ខ្ញុំគិតដើម្បីអ្វី? ខ្ញុំបាននិយាយប្រាប់នាងច្រើនដងហើយតើ! ខ្ញុំបាននិយាយប្រាប់នាងថា ខ្ញុំចង់ សរសេររឿបរាប់ ពីសម្រស់, ពីសីលធម៌ នៃ ពូជសាសន៍របស់នាង ដើម្បីបង្ហាញឲ្យពិភពលោកឃើញច្បាស់ ផ្លូវកម្តៃពូជខ្មែរដ៏ចាស់ឃ្លរអង្អែងណាស់មកហើយ, ហើយនរណាអាចដឹងបាននាង? ថ្ងៃណាមួយ ក្រែងលោ ទេវតាលោកប្រទានរង្វាន់ចំពោះការខំប្រឹងប្រែងរបស់យើង ដោយផ្តល់ជាកិត្តិយស និង ជាទ្រព្យសម្បត្តិ ហើយដល់ពេលនោះ យើងនឹងចាកចេញពីខ្នមស្លឹក ដើម្បីទៅសង់ផ្ទះក្បឿង សសរធីកមួយ នៅមាត់ទន្លេ ដោយមានដាំដើមស្លា និង ដើមឈើដទៃទៀត សម្រាប់ជាម្លប់ត្រជាក់ដល់ដីភូមិយើងផង ។

- ណ្តើយ! (សារ៉ាម៉ានី ឱនមុខចុះ ដកដង្ហើមធំ) ខ្ញុំមិនចង់បានទ្រព្យសម្បត្តិដែលនាំឲ្យលោកត្រឡប់ ទៅស្រុកបារាំងវិញទេ ។ ខ្ញុំចង់ឲ្យលោកក្រដូចសព្វថ្ងៃអញ្ចឹងរហូតទៅ ដើម្បីឲ្យលោកនៅតែស្មោះត្រង់នឹង ខ្ញុំ។ ខ្ញុំមិនចង់ឃើញទ្រព្យសម្បត្តិដែលមកធ្វើឲ្យលោកល្អក់ចិត្ត មកបណ្តាច់លោកពីជីវភាពដ៏សុខសាន្ត ដូចយើងរស់នៅសព្វថ្ងៃ ហើយបែរទៅស្រឡាញ់ស្រីសស្អាតដូចសំឡី ទៅរស់នៅក្នុងវិមានដ៏ល្អឆើតឆាយ ក្នុងប្រទេសរបស់លោកវិញនោះទេ... លោកស្តាប់ខ្ញុំណា! ខ្ញុំចង់និយាយប្រាប់លោកពីទុក្ខវេទនារបស់ខ្ញុំ មុនពេលបានមករៀបការជាមួយលោក ។ ខ្ញុំចូលចិត្តចង់ឲ្យប្រវត្តិដ៏ខ្លោចផ្សារបស់ខ្ញុំ ស្ថិតនៅគង់វង្សជានិច្ច សម្រាប់ជាអនុស្សាវរីយ៍ចំពោះរូបលោក កាលណាខ្ញុំស្លាប់ទៅ...។

សារ៉ាម៉ានី ឈប់សៀមមួយសន្ទុះ... សម្លេងតន្ត្រីរសាត់មកតាមកម្លាំងដំនោររាត្រី បបោសអង្អែល សង្កាត់កំពង់ផែ ឲ្យស្រងេះស្រងោចលន្លង់លន្លោច ប្រៀបបានសម្លេងទិព្វ ហើយអតីតអ្នករបាំយើង យកចិត្តទុកដាក់ស្តាប់បទភ្លេងសម្លេងស្រួយស្រិបនេះ ដែលពីដើមវាជាមេដែកអាចទាញកាយវិការនាង ឲ្យពត់ពេនទន់ភ្លន់ ទៅតាមចង្វាក់ដំណើរទេពអប្សរ ដោយចិត្តរំជើបរំជួលស្ទើរតែទប់ខ្លួនពុំជាប់ ។

~ លោក! (សារ៉ាម៉ានី ពោលបន្តទៅទៀត) ពេលនេះហាក់ដូចជាមានប្រផ្នូលអ្វីធ្វើឲ្យដឹងថា យើងនឹង ព្រាត់គ្នានៅពេលឆាប់ៗខាងមុខនេះហើយ ទើបខ្ញុំចង់និយាយរឿងរ៉ាវទាំងអស់ប្រាប់លោក ដែលជាអ្នក ក្រៅក្រងតែមួយគត់លើជីវិតខ្ញុំ ជាស្ត្រីកំព្រា ចង់រើកកាយបង្ហាញលោកនូវកំណប់អនុស្សាវរីយ៍ នៃ ជីវិតខ្ញុំ ដែលលោកពុំទាន់ដឹងនៅឡើយ...។

ពេលស្តាប់ឮសំដីនេះ កម្លោះភ្ញាក់ព្រើត ហើយស្រមោល នៃ គំនិតរវើរាយមិនល្អ ក៏ចាប់ក្របសង្កត់ លើបេះដូងគេឲ្យតឹងស្ទើរប្រេះភ្លាមមួយរំពេច ។ ប៉ុន្តែ សម្លេងភ្លេងពិណពាទ្យលាន់ឡើងយ៉ាងច្បាស់ ក្នុង សភាពស្ងាត់ជ្រងំ នៃ រាត្រីកាល គឺជាសម្លេងទិព្វ អាចរម្ងាប់អស់នូវអារម្មណ៍គាន់តឹងក្រប់បែបយ៉ាង ហើយ កម្លោះ ប្រមូលបានសេចក្តីក្លាហានបន្តិចឡើងវិញ ខំរក្សាសម្លេងឲ្យនឹងន នឹយាយតបទៅភរិយាវិញថា!

- អូន និយាយចុះ ខ្ញុំចាំស្តាប់ហើយ!...

សារ៉ាម៉ានី ផ្អែកខ្នងទៅនឹងជញ្ជាំង ហើយចាប់ផ្តើមនិទានរឿងនាង ដូចតទៅនេះ៖

កាលនោះ ស្តេចសុវណ្ណកោដ្ឋ [១] ឡើងសោយរាជ្យលើប្រទេសកម្ពុជា បានសែសិបប្តាយឆ្នាំហើយ។

មុនមកនៅភ្នំពេញ ខ្ញុំចាំថា ខ្ញុំធ្លាប់បានរស់នៅលើទូកអស់រយៈពេលដ៏យូរ ។ ពុកម៉ែ ហើយនិងខ្ញុំ យើងធ្វើដំណើរតាមផ្លូវទឹកពីតំបន់មួយទៅតំបន់មួយ ក្នានទីដៅជាក់លាក់ឡើយ។ ពូប៉ុល, ពូម៉ែន, ពូកៅ បងប្អូនជីដូនមួយខ្ញុំពីរនាក់ឈ្មោះ មីប៊ុន និង មីហ៊ុន និង ម្តាយវាឈ្មោះ មីងអ៊ូច ឧស្សាហ៍រួមដំណើរជាមួយ យើងណាស់ ជួនកាលជិះទូកតែមួយជាមួយគ្នាទាំងអស់ ជួនកាលគេជិះលើទូកមួយផ្សេងទៀត។

កាលនោះ ខ្ញុំនៅតូចពេក ពុំអាចចាំរឿងរ៉ាវសព្វគ្រប់ទាំងអស់ទេ... ខ្ញុំប្រហែលជាមានអាយុប្រាំពីរឆ្នាំ ដំណាលគ្នានឹងបងប្អូនជីដូនមួយខ្ញុំឈ្មោះ ប៊ុន នោះហើយមើលទៅ។ យើងទាំងពីរនាក់ អង្គុយលេងជាមួយគ្នាលើក្តារកម្រាលទូក ហើយឲ្យតែកើតមានរឿងទាស់ចិត្តបន្តិច ខ្ញុំស្ទុះទៅក្រញៀវ ដាច់មុខ ដាច់មាត់ ភ្លាមមួយរំពេច ព្រោះខ្ញុំនេះឆ្នាស់រកលេខដាក់ស្មាន តាំងពីតូចមក។

ពុក ចែវខាងមុខ ទុកឲ្យម៉ែ ចែវខាងក្រោយ យើងធ្វើដំណើរលក់ដូរ ផ្លែឈើស្រស់ និង ថ្នាំជក់ តាម បណ្តោយមាត់ទន្លេ ហើយយើងទិញមកវិញនូវ អង្ករ និង ត្រីងៀត សម្រាប់ទុកជាស្បៀងបរិភោគ...។

ពីមួយឆ្នាំទៅមួយឆ្នាំ ដីច្រាំងភូមិព្រែកថ្មីរបស់យើង បាក់ធ្លាក់ចុះទៅបាតទន្លេទាំងផ្ទាំងៗ ដើមស្វាយដែលខ្ញុំបានដាំផ្តាំដៃ និង ផ្ទះដែលខ្ញុំធ្លាប់រស់នៅជួបជុំគ្រួសារទាំងអស់គ្នា ក៏វិនាសសាបសូន្យអស់ទៅ សល់នៅតែអនុស្សាវរីយ៍ដ៏មានតម្លៃកាត់ថ្លៃមិនបាន ដែលស្ថិតជាប់ក្នុងអារម្មណ៍ខ្ញុំរហូតទល់ថ្ងៃស្លាប់។

លើផ្ទៃដីដែលជីតាខ្ញុំបោសជ្រះសំអាតរាល់ថ្ងៃ ខ្ញុំលួសមែកឈើតូចៗមកសង់ធ្វើរោងរបាំ សម្រាប់រាំលេងជាមួយពួកម៉ាក ពីព្រោះនេះជាល្បែងដែលខ្ញុំចូលចិត្តជាងគេ។ ក្មេងស្រីៗខ្លះទៀត ចូលចិត្តលេងធ្វើ ការប្តី-ប្រពន្ធ, លេងបិទពួនឬកាត់ជាងចេកមកធ្វើជាសេះរត់បំផាយហុយដ៏ទ្រលោម ។ មានតែខ្ញុំម្នាក់ឯង គត់ ដែលស្រឡាញ់របាំ ចូលចិត្តឲ្យម៉ែងខ្ញុំជាត់ម្សៅឲ្យ ហើយរាំឲ្យឪពុកម្តាយខ្ញុំមើល។ ពុកញញឹមសម្លឹងមើលខ្ញុំ ហើយនិយាយថា:

- ចាំពុកយកកូនឯងទៅឲ្យនៅហាត់រាំក្នុងវាំង ក្រែងលោបានធ្វើលោកឃុន នឹងគេ។

ឮពុកនិយាយអញ្ចឹង ពូម៉ែន និយាយចំអកថា គាត់ទុកឲ្យកូនស្រីគាត់នៅធ្វើការផ្ទះ ក្រាន់នឹងបានបំរើ ទឹកក្តៅ ទឹកត្រជាក់ នៅពេលគាត់ចាស់ជរា ប៉ុន្តែពុកបែរជាស្តីឲ្យ ពូម៉ែន ថាជាមនុស្សអាស្មានិយម ហើយ ថែមទាំងទាយទុកថា ថ្ងៃណាមួយ កូនគាត់នឹងក្លាយមកជាអ្នកបំរើខ្ញុំមិនខាន។ តទៅថ្ងៃក្រោយ រឿងនេះ មានដំណើរសឹងតែដូចពាក្យទំនាយពុកទាំងអស់។

(១) សុវណ្ណកោដ្ឋ ជាមរណនាម នៃ ព្រះបាទនរោត្តម។

ក្រោយបន្តិចមក យើងចាកចេញពីព្រែកថ្មី ដើម្បីចេញដើរលក់ដូរអីវ៉ាន់ជាថ្មីម្តងទៀតនៅម្ដុំទន្លេសាប។ ទូកយើងមានដីក ចេក និង ពោត ហើយជួលសណ្តោងទៅនឹងកប៉ាល់ចិន ធ្វើដំណើរឆ្ពោះទៅខែត្រកំពង់ឆ្នាំង។ នៅនឹងដែកំពង់ឆ្នាំងនេះ យើងយក ចេក, ពោត, ដូរជាមួយឆ្នាំងដី ដែលពុកគិតថា នឹង យកមកលក់បន្តទៀតបានចំណេញច្រើនណាស់។

ពេលត្រឡប់មកវិញ ខ្យល់រហើយបក់ជោកឥតឈប់ឈរ ហើយនៅកន្លែងខ្លះដែលផ្ទៃទន្លេរីកធំ ទូលាយ ដូចដៃសមុទ្រនោះ រលកធំៗចាប់ផ្តើមជោក រុញច្រានទូកទាំងឡាយឲ្យរេចុះរេឡើង ប៉ះទង្គិចគ្នាពេញទន្លេ។ ទូកយើងក៏រសាត់ចង់ទៅប៉ះនឹងទូកប៉ុកចាយដីកទំនិញមួយដែរ ប៉ុន្តែសំណាងល្អបានម្ចាស់ ទូកធំនោះហៅ យើងឲ្យឡើងជិះជាមួយគាត់ទម្រាំស្ងប់ខ្យល់។

ម្ចាស់ទូក ជាអ្នកជំនួញខ្មែរឈ្មោះ ដង្ហៅរស់ រកស៊ីជួញឈើដីកតាមក្បួន ពីស្រុកបរិបូណ៌ និង លង្វែក ទៅលក់ ប៉ុន្តែគាត់មានផ្ទះសម្បែងនៅកៀនស្វាយឯណោះទេ។ គាត់មានកូនប្រុសជំទង់មួយ ទើបនឹង បំបួសនេន ដើម្បីសងគុណឪពុកម្តាយ។ ដង្ហៅរស់ អួតសរសើរពីកូនប្រុសតែមួយរបស់គាត់ខ្លាំងណាស់ ហើយគាត់បានទាំងនិយាយស្ទើរលេងស្ទើរមែន ស្តីចង់ធ្វើដន្លងជាមួយពុកទៀតផង។

មកដល់ភ្នំពេញ ទូកបែកខ្មែកគ្នាអស់ យើងក៏លា ដង្ហៅរស់ បត់ក្បាលទូកទៅឈប់ត្រង់កំពង់វត្តស្វាយពពែ ដើម្បីចូលលេងផ្ទះឪពុកធំខ្លាំម្នាក់ឈ្មោះ អ៊ុម ដែលធ្វើជានាម៉ឺនធំក្នុងវាំង មានដារជាអគ្គមហាសេនា។ ពុកជ្រាប់ឲ្យ ម៉ែ និង ខ្ញុំ នៅចាំក្នុងទូក គាត់ឡើងទៅតែម្នាក់ឯង មានយួរកន្ត្រកដាក់ផ្លែឈើពេញទៅជាមួយផង សម្រាប់ជាបញ្ណើ។ ប៉ុន្តែ ខ្ញុំ មានកំនិតខូច លួចរត់តាមពីក្រោយគាត់ ជាប់រហូត មិនឲ្យគាត់ដឹងខ្លួនឡើយ។

ផ្ទះលោកអគ្គមហាសេនា អ៊ុម ស្ថិតនៅមិនឆ្ងាយប៉ុន្មានពីមាត់ទន្លេ មានរបងថ្មព័ទ្ធជុំវិញ និង សួនច្បារ ពីមុខផង។ ផ្ទះនោះធ្វើពីឈើ មានវាលវាល មានតសំយាកចេញជារោងតូចៗច្រើនទៀត និង រោងធំមួយ ជាបន្ទប់ពិសេសសម្រាប់ក្រុមល្ខោនរបស់គាត់រាំ។ បន្ទាប់ពីក្រុមល្ខោនហួង មានតែក្រុមល្ខោនលោក អគ្គមហាសេនាអ៊ុម នេះហើយដែលល្បីល្បាញជាងគេក្នុងស្រុកខ្មែរ។

ពុកដើរឡើងជណ្តើរ ឆ្លងកាត់វាលទៅអង្គុយចាំត្រង់មាត់ទ្វារបន្ទប់ទទួលភ្ញៀវ។ ខ្ញុំអង្គុយចុះពី ក្រោយខ្នងគាត់ ប៉ុន្តែពុកនៅតែមិនដឹងថា ខ្ញុំមកតាមគាត់ដដែល។ លោកអគ្គមហាសេនា អង្គុយលើកៅអី លាបពណ៌មាស មានសាច់ញាតិអ្នកមកពីងបុណ្យមួយហ្វូងធំ អង្គុយបត់ជើងលើកន្ទេលក្រៀបក្រាពីក្រោយខ្នង។ គ្រាន់តែឃើញផ្ទះធំទូលាយ របៀបរៀបរយ សួនច្បារអីប៉ុណ្ណឹង ខ្ញុំសប្បាយចិត្តចង់រស់នៅ ក្នុងទីនេះស្រេចទៅហើយ។ ខ្ញុំអង្គុយបត់ជើងពួនក្រវៀនក្រោយខ្នងពុក លួចសម្លឹងមើលមុខលោក អគ្គមហាសេនាភ្លឺកៗ.... គាត់ចាស់កោងខ្នង សក់ស្កូវសក្បស្កាត់ជ្រងខ្លី ស្បែកមុខដីវជ្រួញ ពាក់អាវ បំពង់សដៃខ្លី ស្លៀកសារុងសូត្រ។ គាត់និយាយរាក់ទាក់មកកាន់ពុកថា:

- យិនឯង យកផ្លែឈើអស់ហ្នឹងមកផ្ញើរអញហ្ន៎? ប្រពន្ធ-កូនឯង សុខសប្បាយជាទេ?... អើរ៉ិ, ហ្នឹងឯងយកកូនមកឲ្យទៅហាត់រាំជាមួយអញឬអី?

- ប្រជាទម្ចាស់, (ពុកឆ្លើយ) កូនខ្ញុំនៅចាំក្នុងទូកឯណោះ... ខ្ញុំមកពីលក់អីវ៉ាន់ ត្រឡប់ទៅព្រែកថ្មីវិញ គ្រាន់តែរៀងចូលមកលេងនឹងព្រះគុណម្ចាស់មួយភ្លែតប៉ុណ្ណឹងទេ។

- ម៉េចអញ្ចឹង? កូនឯងវានៅក្រោយខ្នងនេះនែ៎, ឯងមើលទៅមើល៍! (លោកអគ្គមហាសេនានិយាយខ្លាំងៗ ព្រមទាំងផ្ទះសំណើចកាច់កកាច់សុរង)។

ពុកបែរមកក្រោយឃើញខ្ញុំអង្គុយច្រង៉ុក ស្រាប់តែបើកភ្នែកធំៗសម្លក់ភ្នែរ ឥតចេញស្តីថាម៉េចទាំងអស់។ សើចអស់ចិត្ត ទើបលោកអគ្គមហាសេនា សួរខ្ញុំ:

- អើនែ, មេនាងឯងចង់ត្រឡប់ទៅព្រែកថ្មីវិញ ឬក៏ចង់នៅជាមួយអ៊ុំ, ហ្អាមេនាង?
- ខ្ញុំចង់....នៅ... (ខ្ញុំឆ្លើយទាំងអឺមអៀម)

ដើម្បីកុំឲ្យបែក ឪពុក-ម្តាយ លោកអ៊ុំបានឲ្យពុកសង់ផ្ទះតូចមួយនៅបណ្តោះអាសន្ន ក្បែរសួនច្បារគាត់ ។

លោកអគ្គមហាសេនា គាប់ចិត្តនឹងខ្ញុំជាងគេ គាត់ស្រឡាញ់ខ្ញុំដូចកូនបង្កើតអញ្ចឹង។ គាត់ទិញ សំពត់ខៀន កាត់អាវវៀលក្លៀកកំណាត់សូត្រ សម្រាប់ឲ្យខ្ញុំស្លៀកពាក់ហាត់រាំរាល់ថ្ងៃ មួយកំនរធំ។ លោកអ៊ុំ រកឈ្មោះដាក់ឲ្យខ្ញុំ នេះមិនពិរោះនោះមិនពិរោះ ទីបំផុតក៏ហៅខ្ញុំថា យើមៗ ជាប់រហូតមក។ ប៉ុន្តែខ្ញុំ មិនរវល់នឹងរឿងរ៉ាវកំប៉ុកកំប៉ុកអស់នេះទេ មួយថ្ងៃៗខ្ញុំគិតតែដើរបេះបោចដំណាំក្នុងសួនច្បារ ឬ សម្លុំពួននៅក្រោមផ្ទះ ទុកឲ្យគេដើរកវីរ៉ក់។ ម្តងនោះ ខ្ញុំធ្វើឲ្យជ្រុះបែកកញ្ចក់ដែលគេតាំងលំអនៅក្នុង បន្ទប់ទទួលភ្ញៀវ ប៉ុន្តែលោកអ៊ុំឥតមានស្តីបន្ទោស ឬ វាយខ្ញុំទេ។ ខ្ញុំឥតខ្លាចលោកអ៊ុំទាល់តែសោះ គឺខ្ញុំស្រឡាញ់គាត់ទុក ស្មើឪពុក។ ខ្ញុំសប្បាយចិត្តណាស់ ដែលបានធ្វើជាកូនអ្នកធំ បានស្គាល់ភាពថ្លៃថ្នូរ នៃ ការរស់នៅក្នុងទីក្រុង បានស្លៀកពាក់ សំពត់-អាវល្អៗ បានពាក់មាសពេជ្រស្រោចខ្លួន និង ជាពិសេសបានហាត់រាំយ៉ាងនេះ។ ខ្ញុំចង់ក្លាយទៅជា លោកឃុន មានរូបសម្បត្តិស្អាតដូចទេពកញ្ញា ធ្វើឲ្យប្រុសៗមើលឃើញតែពី

ចម្ងាយ ហើយចាប់ចិត្តលួចស្រឡាញ់រង្វេងភ្លេចស្មារតីគ្រប់គ្នា។ គំនិតរវើរាយបែបនេះ ធ្វើឲ្យខ្ញុំញញឹមនឹកឃើញសប្បាយតែម្នាក់ឯងដូចមនុស្សឆ្កួត។

ក្រុមល្ខោនលោកអគ្គមហាសេនា មានក្រុសៀមបីនាក់ ជាអ្នកបង្ហាត់ និង ជាប្រពន្ធគាត់ទាំងបីនាក់តែម្តង គឺ អ្នកក្រូជាម, អ្នកក្រូម៉ាឡៃ និង អ្នកក្រូយីម។ បន្ទាប់មកមាន អ្នកភ្លេង, អ្នកចម្រៀង និង កូនល្ខោន ទាំងក្មេង ទាំងចាស់ សុទ្ធតែស្គាត់ជំនាញដូចៗគ្នាទាំងអស់។ បូករួមទាំងអស់ ក្រុមនេះមានគ្នាដល់ទៅជាង មួយរយនាក់។

អ្នកក្រូយីម ជាអ្នកទទួលការៈបង្ហាត់ខ្ញុំ។ រាល់ព្រឹក ខ្ញុំស្លៀកសំពត់ចងក្បិន ពាក់អាវរៀលក្លៀក មានសៀតជ្រាកុលាបមួយទង់នៅនឹងត្រចៀក ពាក់កងជើងមាសធំៗ ដើម្បីហាត់រាំតាមបញ្ជាអ្នកក្រូ។ អ្នកក្រូ ពេញចិត្តនឹងខ្ញុំជាកូនសិស្សពេកណាស់ សមបានដឹងថា លោកអុំស្រឡាញ់ខ្ញុំដូចកូនបង្កើតផង គាត់រីតែ យកចិត្តទុកដាក់បង្ហាត់ខ្ញុំជាងនរណាទាំងអស់។ ប៉ុន្តែ កាលណាខ្ញុំមិនស្ទាប់ប្រុងប្រយ័ត្នធ្វើតាមគាត់ ឬ ពាត់ដៃជើងមិនបានទន់ភ្លន់ដូចគាត់ គាត់យកក្រចកចុច ឬ ក្តិចទាល់តែខ្ញុំស្រក់ទឹកភ្នែក យំអណ្តើតអណ្តក់ភ្លាម មួយរំពេច។ ជាដំបូង ខ្ញុំត្រូវហាត់ធ្វើឲ្យទន់ ក, ស្មា, សន្លាក់ដៃ, ចង្កេះ, ជង្គង់ និង កជើង។ ដងខ្លួនត្រូវ ពាត់ អ៊ែនចុះ អ៊ែនឡើង ទាល់តែទន់ដូចវល្លិ៍ បណ្តាលឲ្យខ្ញុំអស់កម្លាំងស្ទើរទប់ខ្លួនឈរមិននឹង។ ជួនកាលខ្ញុំ ត្រូវឈរជើងមួយបន្ទន់ជង្គង់នៅមុខបន្តិច ជើងមួយទៀតបត់ទៅក្រោយលើកខ្ពស់ ដៃលើកខ្ពស់ហួសដងខ្លួន ថែមទាំងមាន កាន់ដាវ ឬ ផ្កា ដោយពាត់កដៃមកក្រោយទាល់តែចុងក្រចកប៉ះនឹងសាច់កំភួនដៃទៀតផង។ ខ្ញុំសំគាល់ឃើញថា ពីក្រូមួយ ទៅក្រូមួយ ក្បាច់រាំតែងមានការខុសគ្នាបន្តិចៗជានិច្ច គឺម្នាក់ៗចេះតែ ឆ្លៃបន្ថែមបន្តិចទៅតាមការនឹកឃើញរបស់ខ្លួន។ ខ្ញុំបណ្តោយឲ្យអ្នកក្រូយីម កាច់, ពាត់ ដៃ ជើងតាមចិត្ត ប៉ុន្តែ កាលណាគាត់កាច់ឈឺខ្លាំងពេកទ្រាំមិនបាន ខ្ញុំក៏ទ្រហោយង៉ោងឡើង។ កាលណាហាត់ចប់ម្តងៗ អ្នកក្រូ ឬម៉ែ គក់ច្របាចរឹតរួតឲ្យខ្ញុំសព្វដៃជើងខ្លួនប្រាណ ដើម្បីសំរួលសាច់ដុំ។

ពួកយើងជាអស់លោកឃុន ដែលបានហាត់រាំតាំងពីក្មេងអញ្ចឹង យើងពុំបានទុកដាក់ខ្លួនដូចជាស្ត្រី សាមញ្ញជម្មតាទេ។ ការរស់នៅក្នុងវាំង ឃ្លាតដាច់ស្រឡះពីភពខាងក្រៅ បានធ្វើឲ្យយើងផ្លាស់ប្តូរ ចិត្តគំនិត តាំងខ្លួនជារាស្ត្រមានតម្លៃទម្រន់ខ្ពើលធ្វើការ សូម្បីយួរកន្ត្រកទៅផ្សារក៏មិនរួចផង មួយថ្ងៃៗគិតតែសប្បាយ រាំច្រៀង និង សំអិតសំអាងតែងខ្លួនតែប៉ុណ្ណោះ។

ប៉ុន្មានអាទិត្យសោះ ខ្ញុំអាចរៀនចប់ក្បាច់ឆាបបញ្ចោះ និង អាចរាំចូលជាមួយភ្លេងត្រូវតគ្នាខ្លោះ។ អ្នកក្រូ សៀម ញញឹមបឹទមាត់មិនជិត ដើរអួតសរសើរពីខ្ញុំប្រាប់គេប្រាប់ឯងគ្រប់គ្នា។ មកដល់អាយុប្រាំបីឆ្នាំ ខ្ញុំហាត់ ដើរតួបានពីរ គឺមួយជាតួឆ្នា និង មួយទៀតធ្វើជាស្តេចដោះពាក់មុខអាក្រក់អាក្រីក្រខ្លាច។ ខ្ញុំអាចក្រវែងបង វិលខ្ទាល់ដូចកង្ហារយ៉ាងស្ទាត់ជំនាញ ពុំដែលរបូតចេញពីដៃដល់ម្តងណាឡើយ។

ល្ងាចមួយនោះ លោកអគ្គមហាសេនា អនុញ្ញាតឲ្យអ្នកភូមិចូលមើលរបាំដល់ក្នុងបរិវេណផ្ទះគាត់ជាសាធារណៈ។ មនុស្សច្រើនកុះករប្រជ្រៀតគ្នាពេញសួនច្បារ ហៀរទៅដល់ក្រៅរបង, ពុក និង ម៉ែ ក៏បាន នាំយកកែម ពីព្រៃកថ្មី ឲ្យមកមើលខ្ញុំរាំនឹងគេដែរ។ លើសពីនេះទៅទៀត លោកអុំបានអញ្ជើញអ្នករបាំ ក្នុងវាំង ឲ្យមកមើលក្រុមល្ខោនគាត់រាំទៀតផង។ គេទាំងអស់គ្នារេក្រសែភ្នែកតាមសម្លឹងមើលខ្ញុំគ្រប់ ការវិការ ព្រមទាំងជញ្ជក់មាត់សរសើរគ្រប់គ្នា។ នេះជាជោគជ័យលើកទីមួយរបស់ខ្ញុំ!.... ចាប់តាំងពី ពេលនោះមក លោកអុំរីតតែស្រឡាញ់ខ្ញុំលើសដើម ទៅណាមួយដំហានក៏យកខ្ញុំទៅតាមជាប់ជានិច្ច ហើយ គាត់ហាមថា តទៅថ្ងៃក្រោយមិនឲ្យខ្ញុំទៅណាចោលគាត់ជាដាច់ខាត។ គាត់ឧស្សាហ៍ចាត់ខ្ញុំទៅលេងនឹង សម្តេចឧបរាជ (២) ដែលគង់នៅឯវាំងខាងជើងជារឿយៗ ។ ហើយគាត់និយាយប្រាប់ខ្ញុំថា សព្វថ្ងៃ សម្តេចឧបរាជ ចង់សោយរាជ្យខ្លាំងណាស់។

ថ្ងៃមួយ ពុកម៉ែ និង ខ្ញុំ នាំគ្នាមកសំណាក់លេងនៅព្រៃកថ្មីបាន ពីរ-បីថ្ងៃ ទើបនាំគ្នាត្រឡប់មកវិញ ដោយមានបេះផ្លែស្វាយល្អៗដាក់កន្លះទូក ទុកសម្រាប់យកមកផ្ញើលោកអុំ។ ប៉ុន្តែមកដល់ត្រឹមភ្នំពេញ មាន នរណាម្នាក់ស្រែកហៅពុកឲ្យឈប់ ហើយប្រាប់ថា លោកអគ្គមហាសេនា ស្លាប់ទៅហើយ!... មរណភាព នៃ លោកអគ្គមហាសេនា ប្រៀបបានទៅនឹងការរលំរលាយ នៃ បង្គោលដែលជាទីពឹងពាក់អាស្រ័យដ៏កក់ក្តៅ សម្រាប់គ្រួសារខ្ញុំយ៉ាងនោះដែរ...។

(២) សម្តេចឧបរាជ គឺជាងារ ស្តេចស៊ីសុវត្ថិ មុនពេលបានឡើងសោយរាជ្យ ។

ច្រើនខែកន្លងទៅ... យើងចាកចេញពីផ្ទះនៅក្បែរវត្តស្វាយពពៃ មកទិញផ្ទះស្លឹកតូចមួយ នៅម្តុំកំពង់ផែវិញ។ រាល់ថ្ងៃពុកបោសសំអាតតុបតែងផ្ទះ និង ដីភូមិ មិនឲ្យខ្ចីខ្ចាស កូនអ្នកជិតខាង ដែលគេមានសុទ្ធតែផ្ទះក្បឿងសសរធ្មឹកនោះទេ។

ដោយសារខ្មោចលោកអុំមានផ្លាំផ្ញើទុកនឹងគេ ពុកក៏បានចូលធ្វើការនៅក្នុងវាំង ហើយឆ្លៀតពេលទំនេរ គាត់តែងជួយធ្វើការជូនអស់លោកនាម៉ឺនក្នុងវាំង ដែលជាហេតុអាចឲ្យគាត់រកប្រាក់បានច្រើនគួរសម បន្ថែមលើប្រាក់ខែបន្ទិចបន្តួចនោះ សម្រាប់យកមកផ្គត់ផ្គង់គ្រួសារ។

ខ្ញុំមានអាយុមិនទាន់ទាំងគ្រប់ដប់ឆ្នាំស្រួលបួលផង។ ខ្ញុំមិនដឹងថា ជីវភាពនៅក្នុងវាំង សប្បាយ ឬ លំបាកវេទនាយ៉ាងណាទេ ប៉ុន្តែខ្ញុំចេះតែចង់ទៅនៅក្នុងវាំង ព្រោះខ្ញុំចង់ហ៊ីហាស្លៀកសំពត់អាវរាំ តែប៉ុណ្ណោះ។ ខ្ញុំទៅជាធុញទ្រាន់

លែងចង់រស់នៅក្នុងខ្ទមស្លឹក លែងចង់រស់នៅជាមួយឪពុក-ម្តាយ ទោះបីពុកផ្តត់ផ្តង់ខ្ញុំគ្រប់សព្វ មិនដែលឲ្យខ្វះខាតយ៉ាងណាក៏ដោយ។

ប៊ុន និង ហ៊ុន ខុសរ្សាហ៍មកពីព្រែកថ្មី មកលេងនឹងយើងខ្ញុំណាស់ ជួនកាលមកនៅ ពីរ-បីអាទិត្យ ទើបត្រឡប់ទៅវិញ កំមាន។ ពូប៉ុល និង ពូម៉ែន ជាអ្នកបញ្ជោះទូកនាំវាមក ព្រមទាំងនាំយកដំណឹងផ្សេងៗពីស្រុក មកប្រាប់ ពុក-ម៉ែ ផង។ ប៉ុន្តែ ពុកមិនចូលចិត្តឲ្យ ពូប៉ុល និង ពូម៉ែន នៅយូរទេ ពីព្រោះណាមួយផ្ទះ ក៏ចង្អៀត ណាមួយពុកស្អប់ត្រង់គាត់ចូលចិត្តស្លៀកពាក់ខោអាវច្រឡឹកច្រឡំ ឲ្យតែពុកមិននៅ គាត់យក អាវពុកញ្ជូរនៅនឹងស្មែងក្តាន់ពាក់ដើរលេងផ្សារមួយរំពេច។ ចំណែកម៉ែវិញ គាត់ស្រឡាញ់ បង-ប្អូន ជាងប្តី ទៅទៀត សុខចិត្តលក់បញ្ចាំរបស់ទ្រព្យឯងយកលុយឲ្យគេខ្ចី ហើយអ្នកខ្ចីនោះ គីខ្ចីរហូត មិនដែលឃើញ សងវិញឡើយ។

ពេលថ្ងៃទំនេរ មិនដឹងធ្វើអី ខ្ញុំជួយដាំបាយម៉ែ ខ្ញុំដូតទឹកដុះសាប៊ូលាបរមៀតមួយថ្ងៃ ដប់-ម្ភៃដង ទាល់តែពុករកលុយទិញសាប៊ូឲ្យសឹងតែមិនទាន់។ មនុស្សដើរទៅមកតាមផ្លូវកំពង់ដែ តែងត្រូវខ្ញុំចំអក ឡកឡឺយឲ្យ ឬ ជួនកាលខ្ញុំហ៊ានដល់ទៅដេរប្រាស់ឆ្នេះឲ្យគេទៀតផង។ ម្ល៉ោះហើយ នរណា ក៏ខ្លាចរអា ក៏ស្អប់ខ្ញុំដែរ គេចាត់ទុកខ្ញុំដូចជាខ្មោចបិសាចនៅក្នុងភូមិអញ្ចឹង។

មានរឿងរ៉ាវខ្លះក្នុងជីវិតដែលគេពុំអាចបំភ្លេចបានឡើយ..... ថ្ងៃដែលខ្ញុំចាកចេញពីគ្រួសារ ចាកចេញពីខ្ទមកំសត់ដែលខ្ញុំធ្លាប់រស់នៅបានទទួលក្តីស្នេហាពី ឪពុក-ម្តាយ បានទទួលក្តីសប្បាយរីករាយ នៃភាពកុមារ ថ្ងៃនោះផ្ទុតជាប់ច្បាស់ក្រឡែតក្នុងអារម្មណ៍ខ្ញុំ ហាក់ដូចជានៅថ្មីៗនៅឡើយ។

ម៉ែបានទៅពឹង នាងរឿក ជាអ្នករបាំនៅក្នុងវាំង អាយុបងខ្ញុំដប់ឆ្នាំ ឲ្យមកជួយចាត់ចែងនាំខ្ញុំទៅគាល់ហ្លួង។ នាងរឿកនាំយកមកនូវ សំពត់ម៉ដ្ឋពណ៌ស្វាយ អាវរៀលក ដៃខ្លីពណ៌ខ្មៅ បាក់ជរផង ជាសម្លៀកបំពាក់សម្រាប់ហាត់រាំ ជាពិពណ៌លឿង ពានាព័ទ្ធរឿង ទម្លាក់ជាយម្ខាងមកត្រឹមចង្កេះ រយ៉ាមួយគួ ចិញ្ចៀនវែន និង កងជើងមាសធ្ងន់ដូចគេដាក់ខ្នោះជើង។

ស្លៀកពាក់អញ្ចឹងទៅ ខ្ញុំដូចជាហ៊ីហាក្នុងចិត្ត ចុះជណ្តើរយឺតៗយ៉ាងប្រយ័ត្នប្រយែង ខំធ្វើឫកឲ្យដូចជា អស់អ្នកក្នុងវាំងមែនទែន។ ខ្ញុំដើរចន្លោះកណ្តាល ម៉ែ និង បងរឿក បំពង់កសួតចែសរកទឹកមាត់លេបស្ងាន ដោយក្តីរជួលចិត្ត, អារម្មណ៍អណ្តែតត្រសែតចេញពីរាងកាយទៅកាន់ពិភព នៃ ក្តីស្រមៃមើលឃើញតែភាព រុងរឿងថ្លៃថ្នូរ។ បន្តិចទៀតខ្ញុំនឹងក្លាយខ្លួនជាអ្នករបាំរបស់ហ្លួង រាស្ត្រសាមញ្ញលែងហ៊ានហៅខ្ញុំ "មី" គេនឹង ហៅខ្ញុំថា អ្នក ឬ នាង មិនខាន។ ខ្ញុំនឹងមាន មាសពេជ្រ, សំពត់អាវសម្បូរណ៌ហ្លូរហៀរ មានខ្ទុំបំរើសម្រាប់ ឃ្លកន្ត្រកដើរតាមក្រោយ, មានរទេះ, មានដំរី, មានទូកបិទដំបូលសម្រាប់ជិះដើរលេងកំសាន្ត, មានអ្វីៗ ទាំងអស់ សម្រាប់បំពេញសេចក្តីត្រូវការ។

នាឡិកាជ៉ោលធំៗនៅក្នុងទីតាំងស្តេច បន្លឺសូរជ្រាំមួយអន្លងយ៉ាងយឺតៗរបៀបខ្ជិលច្រអូស ហាក់ ធុញទ្រាន់នឹងបំពេញមុខការដដែលៗនេះតាំងពីច្រើនឆ្នាំមកហើយ។ មកដល់ត្រង់ក្លោងទ្វារ ឯងឹតព្រាលៗ នរណាម្នាក់លាន់មាត់និយាយមកកាន់យើង

~ យើ! កូនអ្នកណាហ្នឹង ស្អាតមើលតែទេវតារី?
~ កូនខ្ញុំណា! (ម៉ែប្រញាប់ឆ្លើយទៅវិញយ៉ាងពេញចិត្ត) ខ្ញុំនាំវាទៅថ្វាយហ្លួង។

ខ្ញុំមិនដឹងថា ពាក្យទាំងនេះមានន័យសរសើរមែនទែន ឬ ជាពាក្យចំអកទេ ប៉ុន្តែគ្រាន់តែឮគេនិយាយ អ៊ីចឹង ខ្ញុំទៅជាចេញទឹកមាត់ ។
ខ្ញុំខំលេបវាទៅវិញកុំឲ្យហៀរមកប៉ះម្សៅលាបមុខ ហើយធ្វើមិនឮដើរតាមចន្លោះទេវានិនិថ្នូយ ដែលជាកន្លែងដំកល់បល្ល័ង្កស្តេច និង រោងរបាំ ឆ្ពោះទៅកាន់កន្លែងយាម ត្រង់មាត់ទ្វារព្រលប់។

ពីដើម, កាលនៅក្នុងរាជ្យស្តេច សុវណ្ណកោដ្ឋ តែពេលព្រលប់ភ្លាម គេលែងឲ្យចេញចូលតាមទ្វារនេះ ហើយ។ ប៉ុន្តែសព្វថ្ងៃនេះ ទាល់តែបាញ់កាំភ្លើងម៉ោងជ្រាំបីយប់(៣) ទើបគេលែងឲ្យ ចេញ-ចូល ហើយ គេក៏មិនសូវតឹងតែងប្រយ័ត្នណាស់ណាដែរ។

ក្រុមវាំងចាស់ៗដែលនៅយាមទ្វារ នាំគ្នាសួរដេីបឡើង នៅពេលឃើញយើងទៅដល់ ហើយបន្ទន់ខ្លួន ក្រនៗគោរពម៉ែដោយឃើញគាត់ដើរជាមួយ បងរឿក ដែលជាកូនល្ងោនឃុនព្រះញាតិ។ គេប្រញាប់ បើកទ្វារឲ្យយើងចូល ដោយឥតហ៊ានសួរនាំអ្វីឡើយ។

(៣) កាំភ្លើងបាញ់ម៉ោងជ្រាំបីយប់នេះ ជាសញ្ញាប្រាប់ម៉ោងពេល ដូចជាស៊ីនម៉ោង ១២ ថ្ងៃត្រង់។

ខ្ញុំចុះជណ្តើរថ្ម ពីរ-បីកាំ ហើយឈប់មើងមាំង ភ្នែកសម្លឹងមើលផ្លូវដ៏ស្ងាត់ជ្រងំក្រាលថ្មយ៉ាងស្អាត អម សង្ហាងទៅដោយរបងដែក សួនច្បារ អាងទឹក និង ដើមឈើល្អត្រកាល ប្លែកភ្នែកគួរឲ្យចង់តយកន់។ ស្ត្រី ចាស់កោងខ្នងម្នាក់ ជោះជំហានយឺតៗតម្រង់ទៅរកទ្វារចេញ មានអ្នកបំរើមួយហ្វូងធំកាន់ថាសដាក់ចង្ហាន់ យកទៅប្រគេនព្រះសង្ឃវត្តព្រះកែវ ដើរតាមហូរហែពីក្រោយ។ បងរឿក កេះម៉ែខ្សឹបប្រាប់ថា ស្ត្រីចាស់ ដើរមុខគេនេះជាស្តេច ហើយម៉ែក៏លើកដៃសំពះ

យ៉ាងគួរសមក្រៃលែង។ ឆ្ងាយពីនេះទៅទៀត នៅខាង មុខផ្លូវ ដើមគគីរធំខ្ពស់ដុះតម្រៀបគ្នាជាជួរ មើលពីក្រៅមក ឃើញតែស្លឹកស៊ុបទ្រុបគ្របលើវាំងទាំងមូល។

អស់អ្នក អស់នាង ឬ អ្នករបាំ ឥតពាក់អាវទេ មានតែស្បៃស្តើងដណ្តប់ខ្លួន ដើរលេងប្រសេចប្រសាច ពេញសួនច្បារ។ ខ្លះទៀតប្រជុំគ្នាជាក្រុមៗ ជក់បារីជជែកគ្នាអែប្រមែ និង ខ្លះទៀតដើរទៅដើរមក ញាប់ជើងទំនងជាមានការអីសំខាន់ហើយមើលទៅ។

ដំណាក់ឈើមួយសង់ទាបនឹងដី ប្រកបដោយរានហាលព័ទ្ធជុំវិញ ក៍ស្ថិតនៅជិតដំណាក់ហ្លួង ដូចមហាមន្ទីរដែរ គឺស្ថិតនៅត្រង់កែងផ្លូវធំ និង ផ្លូវក្រាលថ្មមួយទៀត។ កន្លែងនេះ ពិតជាកន្លែងសំខាន់ជាងគេ នៅក្នុងវាំង ព្រោះមនុស្សមានមកប្រជុំគ្នាអ៊ូអរ សោតឯដំណាក់នានាជាច្រើនទៀត ក៍សុទ្ធតែសង់នៅក្បែរនេះដែរ។

ក្រុមវាំងដើរក្រឡឹងជុំវិញដំណាក់ហ្លួង ដៃកាន់ឈើច្រត់ប្រាក់ ជួនកាលរត់ឆ្លេស្លាទៅនេះបន្តិច ទៅនោះបន្តិច ដើម្បីបញ្ជូនបន្តទៅកន្លែងផ្សេងៗ នូវពាក្យបញ្ជាដែលស្តេចអង្គយរដូករណែលនៅត្រង់មាត់ទ្វារ បន្ទប់ហ្លួងនោះ នាំយកមកប្រាប់។ នៅកន្លែងនេះ គេនិយាយគ្នាតិចៗ បញ្ចេញឫកថ្លៃថ្នូរបែបចម្លែក ភ្ជាឲ្យខ្ញុំនឹកខ្ជាសខ្លួនឯងណាស់ដែលមានឫកពារជាអ្នកស្រែសុទ្ធសាធ។ មិនអីទេ! ខ្ញុំនឹងខំរៀនឲ្យទាល់តែចេះ របៀបថ្លៃថ្នូរដូចគេមិនខាន។

ឆ្ងាយបន្តិចទៅទៀត នៅពីក្រោយប្រាសាទបាញ់យ៉ុង ខ្ញុំឃើញផ្ទះឈើធំៗសង់យ៉ាងខ្ជីខ្ជាប់ផុត ទុកសម្រាប់ឲ្យពួកកូនល្ងោនរបស់ឃុនព្រះញាតិ សំណាក់នៅ។ ត្រាន់តែឃើញនៅជិតនោះ មានដើមស្វាយ, ដើមល្វត ខ្ញុំលូចញញឹមក្តួងពោះ ក្របួចមាត់ទុកមុនរួចស្រេចទៅហើយ។ ក្រឡេកទៅខាងណាក៍ឃើញតែ បុប្ផាវិកស្តសស្តាយ ឃើញតែម្លប់ត្រជាក់ នៃដើមរុក្ខជាតិធំៗ ឃើញតែក្បាលម៉ាស៊ីនទឹក ដែលបញ្ចេញ មកនូវទឹកថ្លាឆ្វង់ដូចកញ្ចក់ ឃើញតែផ្លូវថ្លាស្អាតរលីងឆេងគ្មានសំរាមមួយទង ផ្តួយស្រឡះពីវាលចំការ ដែលខ្ញុំធ្លាប់រត់លេងរាល់ថ្ងៃ។

គេនាំយើងចូលដល់ក្នុងដំណាក់ ឃុនព្រះញាតិ ដែលមានហាន:ជាចាងហ្វាងទីពីរ នៃ ក្រុមល្ងោនហ្លួង។ ដំណាក់របស់ឃុនធ្វើអំពីឈើប្រក់ក្បឿង ហើយទូលាយណាស់។ ឃុនចាស់ជ្រុលបន្តិចទៅហើយ បើ សន្និដ្ឋានទៅតាមការដែលអ្នកផងឱនលំទោនគោរពគាត់ក្រៃគ្នានេះ ឃើញថា ឃុនព្រះញាតិ ជាមនុស្ស មានមុខមានមាត់សម្បើមណាស់។ យើងសំពះសួរឃុន រួចថយដើរឱនៗទៅអង្គុយលើកន្ទេល ឆ្ងាយពីកន្លែងឃុន អ្នកបំរើយក កន្ទោរស្ពោះទឹកមាត់ និងហិបស្លាន់មានតម្លៃ មកដាក់ជូនចៅហ្វាយ ហើយថយទៅរិញសុទ្ធតែប្រើអាកប្បកិរិយាគ្រុនៗបែបនេះដូចគ្នាទាំងអស់។ ខ្ញុំររាល់តែជក់ភ្នែកគយគន់មើលរបៀប រៀបចំក្នុងផ្ទះ ពុំបានស្តាប់ម៉ែនិយាយថាអ្វីខ្លះជាមួយឃុនទេ...។

គេយកជើងពានមាសដាក់ ជាច់ដ្កា និង កម្រងដ្កា មកឲ្យខ្ញុំ ហើយទាញដៃខ្ញុំចេញទៅក្រៅ និយាយ ពន្យល់ថា កាលណាគេកេះឲ្យសញ្ជា ខ្ញុំត្រូវយកដង្វាយនេះទៅដាក់ក្បែរព្រះបាទហ្លួង ដោយលត់ជង្គង់ ចុះទៅលើកន្ទេល។ ម៉ែ និង បងរឿក ខ្សឹបប្រាប់ខ្ញុំថា កាលណាហ្លួងសួរខ្ញុំជាភាសាសៀម ខ្ញុំត្រូវឆ្លើយថា ៖ “ព្រះពរម្ចាស់ ខ្ញុំចេះនិយាយតែខ្មែរទេ” ហើយគាត់ឲ្យខ្ញុំអង្គុយលើកាំជណ្តើរទីនាំងមេខលា ចាំទម្រាំហ្លួង ចេញពីសោយអាកៀនក្នុងបន្ទប់នេះមកវិញ។ ខ្ញុំអង្គុយលុតជង្គង់ ងាកមើលទៅក្រោយឥតឃើញម៉ែ ដូចជា ភ័យស្រាលខ្លួន ទំនងអស់សង្ឃឹមបន្តិចផង។ បងរឿក ក្តិចភ្លៅខ្ញុំ ហើយខ្សឹបថា:

~ ដើបឡើងមេនាង! ទៅថ្វាយបង្គំហ្លួងភ្លាមទៅ!

សភាពអ៊ូអរសិបរសៀវក៍កើតមានឡើងក្នុងចំណោម នាម៉ឺន និង ស្រី ដែលប្រមូលផ្តុំគ្នាប្រៀបក្រា នៅមុខទីនាំងមេខលា អង្គុយបត់ជើង កាច់ចង្កេះវៀចក្រដេរមកម្ខាង ដៃលើកសំពះ។ អ្នកដែលអង្គុយ លើកាំជណ្តើរ និង នៅក្នុងបន្ទប់នោះ ក៍ធ្វើកាយវិការដូចគ្នានេះដែរ។

ហ្លួងសុវណ្ណកោដ្ឋ យាងមកដល់មាត់ទ្វារបន្ទប់ដែលមានពន្លឺព្រិលៗ ហើយក្រសែភ្នែកមើលហ្លួង “កូនចៅ” មួយត្រួស។ ហ្លួងចាស់ចំណាស់ទៅហើយ រាងស្គមកំព្រឹង ខ្នងកោងបន្តិច ទ្រោបខ្លួនទៅលើ ឈើច្រត់ស្រោបមាស ខ្លួនទទេមានពានាជាហ៊ូព័ទ្ធឆៀងពីស្មាឆ្វេង ទម្លាក់ជាយមកចង្កេះខាងស្តាំ ចង្កេះរៀវ ស្តេចស្លៀកសំពត់សូត្រសម្បុរស្រអាប់ សក់កាត់ជ្រងខ្លី។

ខ្ញុំខាំមាត់ប្រមូលសេចក្តីក្លាហានដើបឈរឡើង ហើយដើរឱនៗទៅលុតជង្គង់ដាក់ជើងពានផ្កាក្បែរជើង ព្រះអង្គ... ខ្ញុំហាក់ដូចជាដឹងថា ហ្លួងឱនមុខឈ្ងោកសម្លឹងខ្ញុំ។ នៅពេលដែលព្រះអង្គនិយាយពាក្យអ្វីញ៉ាំរៗ ពីរ-បីម៉ាត់ រកតែខ្ញុំស្តាប់មិនបាន ខ្ញុំក៍ឆ្លើយតបទៅវិញថា:

~ ព្រះពរម្ចាស់ ខ្ញុំម្ចាស់ចេះនិយាយតែភាសាខ្មែរទេ។
- ហា ! ហា ! (ហ្លួងសើចតិចៗ) វាកូនអ្នកណាហ្នឹង, រួចវាចង់បានអី?

បងរឿក ឆ្លើយជំនួសខ្ញុំភ្លាម ដោយខ្លាចក្រែងខ្ញុំនិយាយមិនបានសមរម្យ:

- ក្រាបទូល! នាងហ្នឹងកូន នាយយិន ធ្វើទាហានហ្លួង និង នាងឯម, នាងមកសុំចូលរាំល្ខោន ព្រះករុណា។
- ហា ! ហា ! ឲ្យវាចូលជិតបន្តិចមក អញមើលឲ្យច្បាស់បន្តិច ។

ខ្ញុំងើបឈរឡើង ហ្លួងទាញសក់អូសខ្ញុំឲ្យទៅឈរពីមុខកញ្ចក់ ដែលអាចឲ្យខ្ញុំមើលឃើញរូបហ្លួងក្តាប់ សក់បួងដុករបស់ខ្ញុំជាប់។ ហ្លួងសើចរលាក់ញ័រអស់ដងខ្លួន ហើយសួរខ្ញុំថា:

- ឯងស្រឡាញ់អញទេហ៎?

នាងស្រឡាញ់ព្រះអង្គណាស់ក្រាបទូល (បងរឿក ឆ្លើយកាត់ម្តងទៀត ជារបៀបសរសើរលើកដំកើង)។
បងរឿក ភរទេ! តាមពិតខ្ញុំខ្លាចហ្លួងស្មើរាគនោមទៅហើយ ខ្ញុំចង់ឲ្យតែឆាកនេះឆាប់ចប់ស្រឡះទៅ ប៉ុន្តែខ្ញុំក៏មិនហ៊ានបម្រះដែរ បណ្តោយឲ្យហ្លួងផ្ទៀងផ្ទងមើលតាមចិត្ត។ លោកបង្គាប់ថា:

- ហ៎! ឲ្យគេយកប្រាក់បួនណែនមកឲ្យក្មេងនេះ ហើយឲ្យគេចុះឈ្មោះវាក្តងបញ្ជីកូនល្ខោនរបស់ ឃុនថាន់ ផង។ អើនែ៎! ដាក់ឈ្មោះវាថា "ដកណាមយ៉ែម" ណា ! ។

ស្រីម្នាក់ ជាអ្នកកាន់កូនសោ ហើយដែលក្រោយមកខ្ញុំដឹងថាឈ្មោះ ម៉មឡយ ជាអ្នកគាប់នឹងហ្លួង ជាងគេ ប្រញាប់ទូលគាត់ភ្លាម:

- ក្រាបទូល! ឲ្យតែបីណែនគ្រាន់ហើយ ព្រោះវានៅក្មេងណាស់។

ឃើញថា ហ្លួងនៅស្ងៀមសម្តែងការយល់ស្រប គាត់ក៏ដើរដើរចេញទៅក្រៅមួយភ្លែត ហើយត្រឡប់ មកវិញ ព្រមទាំងពោលមកកាន់ខ្ញុំថា:

- អាយុប៉ុនឯង គេឲ្យតែពីរណែនទេ ប៉ុន្តែហ្លួងគាប់ព្រះទ័យនឹងឯងហើយ បានជាប្រទានបីណែន អញ្ចឹង, ម៉េចក៏មិនលុតជង្គង់ថ្វាយបង្គំអរព្រះគុណព្រះអង្គភ្លាមទៅ ! ។

ទោះបីខ្ញុំត្រូវខាតបង់មួយណែន ដោយសារមានអ្នកទូលទាស់យ៉ាងនេះក៏ដោយ ក៏ខ្ញុំនៅតែយល់ថា ប្រាក់បីណែននេះជាព្រះវាជអំណោយមានតម្លៃច្រើនពេកណាស់។ ខ្ញុំលុតជង្គង់ចុះប្រុងថ្វាយបង្គំ ប៉ុន្តែហ្លួង ឃាងចេញទៅដោយបញ្ជាក់ម្តងទៀត:

- យកវាទៅឲ្យនៅជាមួយ នួន ណ៎ា ! ព្រោះគេធ្វើការមឹងម៉ាត់ជាង ញឹក ។

នួន ជាឈ្មោះរបស់ឃុនថាន់ ក្រុល្ខោនក្រុមទីមួយ ចំណែកឯញឹក ជាឈ្មោះឃុនព្រះញាតិ។ សំដី បង្ហាញឲ្យឃើញថា ហ្លួងមិនសូវទុកចិត្តលើអ្នកដែលបានជួយជ្រោមជ្រែងខ្ញុំប៉ុន្មានទេ។ បងរឿក ទាញដៃខ្ញុំ ទៅក្រៅ លួងលោមពន្យល់ថា:

- កុំទៅនៅជាមួយ ឃុនថាន់ អី នៅជាមួយ ឃុនព្រះញាតិ ហ្នឹងហើយ, ឯងកុំភ្លេចណ៎ា! គាត់ជាអ្នក នាំឯងមកថ្វាយហ្លួង។

ពួកល្ខោននាំគ្នាមកចោមរោមខ្ញុំដោយចិត្តច្រណែនឈ្នានិស ចំណែកឯចាស់ៗធ្មេញក្រហុបវិញ ខំសរសើរខ្ញុំ ក្រែងបានម្ហូស្លា។ ពួកម៉ាក់ស្រីរបស់ខ្ញុំម្នាក់ឈ្មោះ ស៊ុន មានផ្ទះនៅជិតគ្នាឯកំពង់ផែ វាចូលមក នៅវាំងមុនខ្ញុំមួយរន្ទាំ, វាសំដែងទឹកមុខមិនពេញចិត្តខ្លាំងណាស់ ដែលឃើញហ្លួងប្រទានលុយខ្ញុំលើសវា មួយណែន។

ម៉ែចេញមកពីកន្លៀតណាមក មុខញញឹមពាក្រាយ ស្រាយកលុយទុក អររខិបរខុបនាំខ្ញុំទៅជម្រាបលា ឃុនព្រះញាតិ។ ឃុន ផ្តាំថា ស្អែកព្រឹកឲ្យម៉ែនាំខ្ញុំមកម្តងទៀត។

នៅពេលដែល ម៉ែ និង ខ្ញុំ ឆ្លងផុតក្លោងទ្វារ នៃ កំផែងសីមា ទីលានកំពង់ផែដ៏ធំទូលាយ លេចឡើងនៅ ចំពោះមុខខ្ញុំ កណ្តាលផ្ទៃអន្ធការ នៃរាត្រីកាល។ ហាក់ដូចជាទម្ងន់អ្វីមួយរបូតខ្សាកចេញពីទ្រូង បណ្តាលឲ្យខ្លួនខ្ញុំប្រែជាស្រាលស្ងើកដូចជានខុសដី។ បន្តិចទៀតខ្ញុំនឹងបានឡើងហាន:ជា លោកឃុន ខ្ញុំនឹងក្លាយទៅជាមនុស្សម្នាក់ផ្សេងទៀត ពុំមែនដូចខ្ញុំសព្វថ្ងៃនេះទេ។ ហ្លួងចិត្តទូលាយប្រទានប្រាក់ច្រើនម្លឹងៗ មិនយូរមិនឆាប់ ឪពុកម្តាយខ្ញុំគង់នឹងបានខ្ពស់មុខ ខ្ពស់មាត់ ពុកអាចនឹងមានលុយទិញអារ កត្រង់ ឡើវប្រាក់ ពាក់ដូចគេមិនខាន។ សម្រាប់រូបខ្ញុំ ខ្ញុំតត្រូវការចង់បានអ្វីទាំងអស់ ខ្ញុំចង់តែម្យ៉ាង គឺថ្ងៃណាមួយខ្ញុំនឹងបានឡើងធ្វើជាតួឯក ល្ខោនហ្លួង រាំនៅចំពោះមុខទស្សនិកជនតែប៉ុណ្ណោះ។ ខ្ញុំស្រមៃឃើញអនាគតភ្លឺស្វាង ប្រកបទៅដោយកិត្តិយស និង ជោគជ័យ ហើយខ្ញុំភ្លេចអស់រលីងនូវរឿងរ៉ាវអតីតកាល ដែលខ្ញុំធ្លាប់ជួបប្រទះកាលរស់នៅ ឯព្រៃកថ្មី។

នៅលើចុងសសរដងកើ ទង់ក្រហមបក់រិចទៅតាមកម្លាំងវាយោ។ ហ្វូងក្អែកហើរត្រឡប់មកកាន់ទ្រនំវិញ បញ្ចេញសំឡេងកោកកាកទ្រហឹងអឺងអាប់... ។

ស្អែកឡើង ខ្ញុំចូលមកនៅជាមួយនឹងឃុនព្រះញាតិ ដែលខំខ្នះខ្នែងខ្លាំងណាស់ ពុំព្រមឲ្យ ឃុនថាន់ ជាគូប្រជែង កេងយកចំណេញក្នុងការបង្ហាត់ខ្ញុំទេ ខ្ញុំសាកសួរគេខ្លះ លួចមើលគេខ្លះ រហូតដល់អាចចេះដឹង ស្គាល់វិធីយ និង របៀបរៀបរយ ក្នុងវាំង បានយ៉ាងឆាប់រហ័ស។

ដូចខ្ញុំស្មានមិនខុសមែន សកម្មភាពអ៊ូអរជាងគេ គឺនៅត្រង់ក្រោយប្រាសាទទាំងប្រាំ ដែលបញ្ចេញតែផ្នែកខាងមុខដ៏ល្អឲ្យគេឃើញនេះឯង។ ផ្លូវតែមួយគត់ដែលនាំឆ្ពោះទៅទ្វារព្រលប់ ដោយកាត់តាមចន្លោះទេវាវិនិច្ឆ័យ និង រោងជាំនោះ បន្តចូលមកក្នុង កាត់តាមចន្លោះប្រាសាទជាញ់យ៉ុង ទីនាំងទក្សិណ និង មហាមន្ទីរ ដែលជាដំណាក់ហ្លួងគង់នៅរាល់ថ្ងៃ ហើយបន្តរហូតដល់កាត់ខ្នែងគ្នាជាមួយផ្លូវធំមួយទៀត។ កន្លែងផ្លូវកែងនេះ ជាទីសប្បាយអ៊ូអរជាងគេ មនុស្សមកជួបជុំគ្នាកុះករ ស្រីៗលក់នំចំណីនៅខាងក្រៅក៏ អនុញ្ញាតឲ្យចូលមកលក់ដល់ទីនេះបានដែរ។ ផ្លូវតូចៗច្រើនទៀត បន្តចេញពីផ្លូវធំ ឆ្ពោះទៅផ្ទះព្រះអង្គម្ចាស់ អស់អ្នកអស់នាង សាវឡីកសាវឡុយ ដែលម្នាក់ៗមាន កិត្តិយស ឬ ទ្រព្យសម្បត្តិ តិចច្រើន ទៅតាមហាន:ខ្លួន ជាឃុន ជាម៉ម...។ ឃុនថាន់ អ្នកគាប់ចិត្តហ្លួងជាងគេ បាននៅក្នុងប្រាសាទមេខលា។ ចំណែក ឃុន ព្រះញាតិ ចៅហ្វាយខ្ញុំ និង ម៉មសួន ជាចាងហ្វាងក្រុមល្ខោនទីបីនោះ នៅក្នុងបន្ទប់ថែរឯណោះទេ។

ឃុន ម៉ម អស់អ្នកអស់នាង ទាំងនេះ ម្នាក់ៗមានខ្ទំបំរើផ្ទាល់ខ្លួនមួយហ្លួង ថែមទាំងដីកជញ្ជួន ឪពុកម្តាយ ទាំងសាច់ញាតិប្រាំពីរសន្តាន មកឲ្យដេកស៊ីលុយហ្លួង ដោយពុំចាំបាច់ធ្វើការអ្វីទៀតផង។

នរណា មានវ័យចាស់ និង មានហាន:ជំ អាចមានសេរីភាព ចេញ-ចូលក្នុងវាំង ដើរទៅលេងផ្សារ ឬ ទៅសុំសីលនៅវត្តជិតៗបាន។ ប៉ុន្តែ ហ្លួងដូចជាមិនសូវរវល់នឹង អ្នកនេះនៅ អ្នកនោះមិននៅ អីប៉ុន្មានទេ យូៗជួបគ្នាម្តង ហ្លួងគ្រាន់តែសួរសុខទុក្ខពីកូនពីចៅតែប៉ុណ្ណោះ។ ឯការជួបគ្នានេះទៀតសោត ទាល់តែត្រូវការ សុំនេះ សុំនោះ ទើបគេទៅគាល់ហ្លួង ហើយខ្ញុំកម្រឃើញហ្លួងប្រកែកថាមិនឲ្យណាស់។ ហាន:អ្នកនៅក្នុង វាំង មានច្រើនពេក សាញ់មិនដឹងជាស៊ីខ្លះទេ ប៉ុន្តែបើនិយាយពីអំណាចត្រួតត្រាលើគេវិញ ស្ថិតនៅក្នុងកណ្តាប់ដៃមនុស្សបីនាក់។ មុនគេបង្អស់គឺ ឃុនថាន់ ចាងហ្វាងល្ខោន មានអំណាចខ្លាំងជាងគេ និង បន្ទាប់មកគឺ ឃុនព្រះញាតិ។ អ្នកទាំងពីរត្រូវចំណាយប្រាក់ច្រើនឥតគណនា ដើម្បីរើសកូនល្ខោនសម្រាប់ ក្រុមផ្ទាល់ខ្លួនម្នាក់ៗ ក្នុងចំណោមក្រុសារអ្នកទីក្រុង ដែលភាគច្រើនមានសុទ្ធតែ ខ្មែរ និង សៀម ចំណែកឯ កូនល្ខោនរបស់ ម៉មសួន អ្នកគាប់ចិត្តហ្លួងជាទីបីនោះវិញ មានសុទ្ធតែក្មេងស្រីកូនកាត់ចិនយួន សម្បុរស្អាតស្អំ ដែលគេយកមកកាត់សក់រៀបសៀម និង ឲ្យស្លៀកពាក់ដូចយើងដែរ។

ឃុនថាន់ អាយុចាស់បន្តិចមែន ប៉ុន្តែហ្លួងនៅតែគាប់ចិត្តនឹងគាត់ជាងគេជានិច្ច ព្រោះគាត់ជាមនុស្សស្លូតស្មោញក្នុងការងារ ព្រមទាំងមានចិត្តទូលាយ ប្រឹងប្រែងបង្ហាត់សិស្សឥតគិតនឿយហត់ និង ចេះធ្វើឲ្យសិស្សគ្រប់គ្នាគោរពស្រឡាញ់។ នេះជាកំហុសធំរបស់ខ្ញុំ ដែលពុំព្រមទៅនៅជាមួយគាត់តាមព្រះរាជបញ្ជា ហើយក្រាញនៅជាមួយ ឃុនព្រះញាតិ ដែលជាហេតុនាំឲ្យខ្ញុំជួបប្រទះនឹងរឿងរ៉ាវល្ងីងជូរចត់ ហើយសេចក្តីសង្ឃឹមថា នឹងបានស្គាល់អនាគតភ្លឺស្វាងនោះ ក៏រលត់រលាយអស់ទៅវិញដែរ។

ឃុនព្រះញាតិ នេះប្រសប់អស្ចារ្យខាងនិយាយលើកជើង ឪពុក-ម្តាយនៃ ក្មេងស្រីៗ ដែលគាត់ចង់ ទាញបញ្ចូលមកក្នុងក្រុមគាត់ ដើម្បីឃាត់ឃាំងកុំឲ្យអ្នកទាំងនោះ យកកូនខ្លួនទៅថ្វាយហ្លួងដោយផ្ទាល់។ ធ្វើយ៉ាងនេះ គាត់អាចកេងយកចំណេញជាប្រយោជន៍ផ្ទាល់ខ្លួន លើប្រាក់រង្វាន់សម្រាប់សិស្សម្នាក់ៗបានយ៉ាងស្រួល, នៅសល់ប៉ុន្មាន គាត់ថែមទាំងយកទៅចងការឲ្យឪពុកម្តាយ ដែលគ្មានដឹងអីសោះទៀតផង។ ប៉ុន្តែ ទម្រាំនឹងខ្ញុំបានដឹងរឿងរ៉ាវអស់ទាំងនេះ វាហួសពេលអស់ទៅហើយ។ ក្មេងស្រីមួយចំនួនដែល គ្រប់អាយុល្មមទៅគាល់ហ្លួងបាន គេបានអំណាចហ្លួងការពារ មិនចាំបាច់រវល់មកហាត់រាំ ក៏អត់មាននរណា ហ៊ានថាអីឲ្យដែរ រហូតដល់អ្នកខ្លះឈប់មករាំសោះតែម្តង ដើម្បីចូលកាន់តំណែងថ្មី ជាអង្គរក្ស និង ជាអ្នក នាំបញ្ជាពីហ្លួង បន្តទៅប្រាប់អ្នកបំរើប្រុសៗនៅខាងក្រៅ។ ខ្ញុំយល់ថា នៅក្នុងវាំងមានតែស្រីអ្នកបំរើហ្លួង នេះទេ ដែលជាមនុស្សមានសំណាងជាងគេ ព្រោះកិច្ចការនេះស្មានងើយហត់អីសោះ ឲ្យតែពូកែ រណបរណិបធ្វើការឲ្យហ្លួងឃើញបន្តិច ច្បាស់ជាបានរង្វាន់ញឹកញាប់ណាស់។

នៅពេលហាត់រាំលើកទីមួយ ខ្ញុំប្រឹងប្រែងយកចិត្តទុកដាក់ជាទីបំផុត។ អ្វីៗដែលខ្ញុំធ្លាប់ហាត់រៀនកាល នៅផ្ទះលោកអ៊ុំអគ្គមហាសេនា ខ្ញុំនៅចាំទាំងអស់ ឥតមានភ្លេចចន្លោះត្រង់ណាឡើយ ជាហេតុធ្វើឲ្យអ្នកគ្រូ ចាស់ៗភ្ញាក់ផ្អើលឆ្ងល់ក្រៃគ្នា។ អ្នកគ្រូសៀមឈ្មោះ សំរិត នោះ ឆ្ងាស់លេខមួយ ឲ្យតែខុសបន្តិច គាត់ ក្តិចក្តៅ លើករំពាត់ផ្តៅកំញើញមួយរំពេច។ កូនសិស្សក្មេងៗ ស្រឡាញ់អ្នកគ្រូក្រើប និង អ្នកគ្រូលួត ជាង ប៉ុន្តែមិនសូវខ្លាច ហើយក៏មិនសូវស្តាប់បង្គាប់គាត់ដែរ។ ដើម្បីបំភ័យយើង អ្នកគ្រូចាស់ៗទាំងនេះ សម្លុតចង់វាយធ្វើបាបយើង តាមរបៀបដែលគេធ្លាប់ប្រើកាលពីដើម សម្រាប់បង្ហាត់ពួកល្ខោន។

ព្រលឹមស្រាងៗឡើង គេនាំគ្នាចុះប្រសាចទៅក្នុងសួនច្បារ ដើម្បីស្រស់ស្រូបបបរ ឬ ទិញនំផ្សេងៗទៀត ដែលអ្នកលក់ខាងក្រៅនាំយកចូលមក។ បន្ទាប់មក គេពាក់អាវរៀលក្លៀកពាណ៌ប្លែកៗគ្នា ស្លៀកសំពត់ខៀន ជាត់ម្សៅ រួចហើយរត់ប្រញាស់ដៅរោងរបាំខាងក្នុង ដើម្បីប្រជុំគ្នាសមរឿង ឯណារ ឬរឿងស្តេចដោះ ទុកសម្រាប់រាំថ្វាយហ្លួងទតក្នុងឱកាសបុណ្យខាងមុខនេះ។

កាលណាឃើញអ្នកគ្រូចាប់កាច់ដៃកាច់ជើងពួកម៉ាកណាម្នាក់ ដែលពាក់ពេនពុំត្រូវតាមចង្អាក់ភ្លេង ខ្ញុំសប្បាយចិត្ត លើចហ៊ោកញ្ជ្រៀវចំអកឲ្យគេ។ រាល់ព្រឹក មានស្ត្រីទាំងហ្វូងៗ ចូលមកមើលយើងសមរបាំ ដែលជាហេតុធ្វើឲ្យខ្ញុំបារម្ភក្នុងចិត្តក្រៃលែង ខ្លាចតែត្រូវរំពាក់ខ្មាសគេ។

វេលាប្រហែលម៉ោង ១០ យើងឈប់ហាត់ អស់កម្លាំងរមួលពោះស្ទើរបោចពោះវៀន។ យើងប្រញាប់ ផ្លាស់សំលៀកបំពាក់ ប្រមូលគ្នាតាមក្រុមទៅងូតទឹកម៉ាស៊ីន ហើយត្រឡប់មកបរិភោគបាយថ្ងៃត្រង់ នៅផ្ទះថៅហ្វាយនាយរៀងខ្លួន ឬនៅក្នុងបន្ទប់ដេកផ្ទាល់ខ្លួន កាលណាឪពុកម្តាយយើងយកបាយពីខាងក្រៅមកឲ្យ។

តាំងពីទើបនឹងមកដល់ដំបូង ខ្ញុំរអៀសខ្លួនពុំចង់រស់នៅដោយសារបាយថៅហ្វាយនាយទេ។ រាល់ព្រឹក ម៉ែតែងយកបាយមកផ្ញើខ្ញុំឥតដែលខានឡើយ។ ថ្ងៃមួយ ម៉ែយកបាយមកមិនទាន់ពេល ហើយខ្ញុំរមួលពោះ ខ្លាំងពេកទ្រាំមិនបានក៏បង្ខំចិត្តធ្វេចភ្នែកលេបបាយជាមួយគេជាមួយឯងទៅ។ មួយម៉ោងក្រោយមក គ្រានតែឃើញម៉ែយួរចានស្រាក់មកដល់ ខ្ញុំមួម៉ៅស្ទុះទៅទាត់ចានស្រាក់ កំពប់បាយសម្លពេញផ្លូវ។

ខ្ញុំឆ្នាស់សម្បើមណាស់! នៅក្នុងវាំង នរណាក៏ឮស្គីឈ្មោះខ្ញុំដែរ។ ក្មេងតូចៗដូចគ្នា ឲ្យតែហ៊ានធ្វើអ្វី ប៉ះពាល់ខ្ញុំបន្តិច ខ្ញុំវាយភ្លាម ទាល់តែឃុនព្រះញាតិ ឬឃុនថាន់ មកឃាត់ទើបឈប់។ ម៉ែឧស្សាហ៍វាយខ្ញុំណាស់ដែរ កាលណាមានគេនិយាយប្រាប់គាត់ថា ខ្ញុំបិនដើរកវឿងឈ្លោះប្រកែក ប៉ុន្តែវាយឯណាទាន់, គាត់គ្រាន់តែយាររំពាត់ ខ្ញុំរត់ប្រូចពួនបាត់ត្រង់កន្លៀតណាមួយ ពុំដាយរកឃើញឡើយ។

ស៊ុន ជាពួកម៉ាកស្រីម្នាក់ ដែល ឪពុក-ម្តាយវា មានផ្ទះនៅក្នុងសង្កាត់កំពង់ផែ ក្បែរផ្ទះខ្ញុំដែរ។ ម៉ែ ឧស្សាហ៍មកសុំយកយើងទាំងពីរនាក់ ទៅលេងផ្ទះណាស់។ បានទំនេរទៅផ្ទះ យើងគិតតែសប្បាយ មុជទឹកទន្លេមួយថ្ងៃរាល់ល្ងាច។

កាលនោះ ដីច្រាំងកំពង់ផែពុំទាន់បាក់នៅឡើយទេ ហើយមានឆ្នេរខ្សាច់មួយដែលជាកន្លែងប្រជុំក្មេងៗ ក្នុងភូមិ មកប្រឡែង ឬ មុជទឹកហ៊ោកញ្ជ្រៀវយ៉ាងសប្បាយរីករាយ។ នរណាហ៊ានមកធ្វើឲ្យល្អក់ទឹកក្បែរ កន្លែងយើងមុជ យើងដេរតែឥតញញើតមាត់, នរណាហ៊ានមកឡេមឡឹមក្បែរទីនាំងផែ យើងដេញទម្លាក់ទឹកភ្លាម។ ស៊ុន មានបងប្រុសម្នាក់ស្លូតណាស់, យើងបានចិត្ត នាំគ្នាធ្វើបាបវាឲ្យយំជារឿយៗ។ ពេលស៊ីបាយ យើងផ្គាប់បានចាក់បាយវាចោល យើងប្រអូសប្រទាញច្រានវាទម្លាក់ទឹក ឬក៏ចាក់រុកវាឲ្យឈ្លោះវាយតប់ ជាមួយកូនគេនៅជិតខាង ដែលមកឆានៅយើង។ យើងស្លៀកសារុងចងក្បឺនកប់ក្រលៀន ខ្លួនទទេប្រៀបបាននឹងបិសាចមែនទែន សូម្បីតែក្មេងប្រុសៗក៏ខ្លាចយើងដែរ។

ជួនកាល យើងប្រមូលគ្នាបានមួយក្រុម ច្រឡឹមដូចយួកូង រត់ចេញប្រសេចប្រសាចពីវាំង ទៅមើលរូបចម្លាក់រឿង រាមកេរ្តិ៍ ឆ្លាក់ជាប់នឹងជញ្ជាំងវិហារ វត្តព្រះគែវ ឬក៏ដើរសម្អាតផ្ទះអ្នកដែលមានដាំផ្កាថា ហ្លួងប្រើ យើងឲ្យមកសុំបេះផ្កា ហើយមិនថាំបាច់ម្ចាស់គេថា ឲ្យឬមិនឲ្យទេ យើងប្រញាយគ្នាបេះបង្អិនបង្អោច របស់គេភ្លាមមួយរំពេច។ កាលណាយើងជួបនឹងពួកក្មេងប្រុស ស្លៀកពាក់ស ពាក់មួកកន្ទេល និង ពាក់ស្បែកជើងឃ្លុប ដើរចេញពីសាលានៅឯសង្កាត់ខាងជើងនោះមក យើងនាំគ្នាស្រែកដេរគេថាអាក្បត់ជាតិ អាខ្ចាំបារាំង ដែលជាហេតុធ្វើឲ្យគេខឹង រត់ដេញតាមប្រជាប់ចាប់ប្រកឹង រហូតទាល់តែដល់ក្លោងទ្វារវាំង។

ពីរ-បីខែកន្លងផុតទៅ យើងនៅតែសមរបាំរាល់ថ្ងៃ រហូតដល់ពេលធ្វើបុណ្យតាំងតុ ដែលឆ្នាំនេះ ក៏ដូចជាឆ្នាំមុនៗដែរ គឺប្រជាពលរដ្ឋក្នុងទីក្រុងសឹងតែទាំងអស់ និង នាម៉ឺនសព្វមុខមន្ត្រី មកពីគ្រប់ខេត្តខ័ណ្ឌ មកប្រជុំគ្នាប្រៀបក្រាកុះករជុំវិញបន្ទប់ខាងក្រៅ។ នេះជាពិធីបុណ្យចំរើនព្រះជន្មចុងក្រោយបំផុតរបស់ ស្តេច សុវណ្ណកោដ្ឋ ហើយគ្មាននរណាចាប់ភ្លឹកគិតថា មរណកាលនៃ ព្រះអង្គ ជិតធ្វើដំណើរមកដល់នោះទេ។ ដោយគ្រាន់តែធ្វើ ក្នុងឱកាសបុណ្យនេះ ខ្ញុំត្រូវចេញវានៅចំពោះមុខសាធារណជនជាលើកដំបូងបំផុត ជាតួរាយរងប៉ុណ្ណោះ។ សម្លៀកបំពាក់តែងខ្លួនរបស់ខ្ញុំ ពុំអាចយកទៅផ្ទឹមនឹងពួកអ្នកល្បីឈ្មោះចាស់ៗ ដែលគេដើរជាតួឯកនោះបានទេ។

ពួកអ្នកគ្រូលុតជង្គង់ក្បែរយើង រៀបចំស្លៀកពាក់ឲ្យ ទាញខ្លឹបត្រង់ណោះបន្តិច ត្រង់ណោះបន្តិច យក មួលមកចាក់ខ្នាស តភ្ជាប់រឿងមុតដល់សាច់ ឬ នរណាស្រែកឈឺអ្វីទាំងអស់។ យើងត្រូវឈរស្លៀកពាក់ របៀបនេះពេញមួយល្ងាច បណ្តាលឲ្យរោយជើងឈរមិននឹង។ ជាពិសេសទៅទៀត យើងត្រូវឈ្មោះ ប្រកាប់ប្រចាក់គ្នា ដណ្តើមគ្រឿងអលង្ការក្រៃនឹង អង្វរអ្នកគ្រូ ដើម្បីឲ្យបានស្លៀកខោអាវល្អមខ្លួន។

ពុទ្ធោអើយ! តែងខ្លួនរបៀបហ្នឹងមួយថ្ងៃ ខ្ញុំសឹងតែទ្រាំមិនបាន។ ណាមួយមួម៉ៅនឹងអ្នកតែងខ្លួន ដែលរវល់ប្រចុបប្រចៃងតែជាមួយអ្នករបាំណា ដែលគ្រូធំៗពេញចិត្តប៉ុណ្ណោះ ចំណែកយើងវិញ គេយកម្ជុលខ្នាស់មកចាក់មុតដល់សាច់ក៏មិនខ្ចីឈឺក្បាលគេផង។ ពួកស្រីធំៗដែលមានដើមទ្រូងពេញ រឹតតែវេទនាណាស់ទៅទៀត ព្រោះគេយកអាវចង្អៀតណែនក្តន់មកឲ្យពាក់រឹតរួតដោះស្ទើរបែក ដើម្បីតែងខ្លួនធ្វើតួប្រុស គេឲ្យស្លៀកខោខ្លីជាំក់អង្កាំ សុទ្ធតែក្អែលក្រខ្វក់បន្តគ្នាពីមួយទៅមួយ ពុំដឹងជាប៉ុន្មានដំណមកហើយ ហើយពុំដែលឃើញបោកគក់ម្តងណាសោះ។ ថ្ងៃណាមួយខ្ញុំតង និងបានជួបប្រទះ ទុក្ខវេទនារបៀបដូចគ្នានេះមិនខាន ដើម្បីតែងខ្លួនឲ្យបានល្អប្រិមប្រិយ៍។

ជួនកាល ស្លៀកពាក់រួចស្រេចជាច់អស់ទៅហើយ សល់តែ លាបម្សៅ គូរចិញ្ចើម រោមភ្នែក លាបបបូរមាត់បន្តិចបន្តួចប៉ុណ្ណោះ ស្រាប់តែឈឺ បត់ជើងតូច បត់ជើងធំ ខ្លាំងមែនទែន ទ្រាំអត់មិនបាន ក្មេងៗក៏ ទ្រហោរយំដោងឡើង, នរណា

ធំប្រកែកតមាត់ជាមួយអ្នកតែងខ្លួន ទាល់តែគេដោះសម្លៀកបំពាក់ចេញ ស្ទើរតែទាំងអស់ ហើយរត់ច្រាសច្រាលទៅដោះទាល់នៅត្រង់កន្លៀតណាមួយសិនពីព្រោះបង្គន់នៅឆ្ងាយពេក ពុំអាចទៅមកបានរហ័សទាន់ចិត្តឡើយ...។

កូនសិស្សខ្លះដែលហាត់ពុំបានស្ទាត់ល្អ ដល់ឮស្នរឮភ្លេង ឃើញភ្លើងព្រោងព្រាត ឃើញមនុស្សឈរមើលគ្រៀបគ្រា វាទៅជាភ័យស្លន់ ឈឺនោមបន្តិច ឈឺដុះបន្តិចអញ្ចឹង តើត្រូវធ្វើម៉េចហ្ន៎ បើជិតដល់ ពេលចេញរាំណាស់ទៅហើយ? ដល់រាន់ខ្លាំងមែនទែន កូនសិស្សហ៊ានជជែកមាត់ប៉ប៉ៃសជាមួយគ្រូ លែងគោតខ្លាចអ្វីទាំងអស់។ ហួសពេលទៅហើយ ទម្រាំតែដោះសម្លៀកបំពាក់ នឹង ស្លៀកមករិញនោះ ពុំដឹងជា កាលណាទើបបានចេញរាំទេ។ ម្ល៉ោះហើយបញ្ហានេះ ត្រូវតែរកផ្លូវដោះស្រាយដោយខ្លួនឯង គឺនរណា ទ្រាំទប់ពុំជាប់ កំផ្លាយនោមទទឹកខោពណ៌បៃតងខ្ចី ឬ ក្រហមនោះដោកហៀរដល់កន្ទេល ប្រឡាក់ដល់ជើង អ្នកគ្រូ ដែលអង្គុយបើកភ្នែកធំៗហួសចិត្តរកស្តីមិនចេញ។ នឹកឃើញអញ្ចឹង ខ្ញុំព្រឺខ្លួនខ្លាចចំលើថ្ងៃស៊ីយ រឿងរ៉ាវនេះវាកើតចំពោះខ្ញុំតែម្តង។

ពេលចេញរាំជិតមកដល់ ខ្ញុំរឹតតែភ័យខ្លាំងឡើងៗ។ ដូចកាលយប់រាំសមជើងនៅក្តងរាំងនោះដែរ ខ្ញុំយកជួបមកអុជដាក់ពី មុខមកុដ មុខស្វាមុខយក្ស សុំឲ្យព្រាយល្ងោនជួយកុំឲ្យទន់ដៃទន់ជើង។ អ្នកគ្រូ សំរិត លើកមកុដខ្ញុំឡើងដាក់កន្សែងយ៉ែនមានចារគាថាលើនោះផងពីខាងក្នុង ទើបបំពាក់ឲ្យខ្ញុំសម្រាប់ការពារ កុំឲ្យស្តេចក្បាច់ណាមួយនៅកណ្តាលឆាក។

ដល់វេនខ្ញុំត្រូវចេញ គេចែកគ្នាតាមរបៀប គឺឲ្យខ្ញុំចេញមុនគេ ហើយបន្តគ្នារហូតដល់អ្នកណាអាយុ ច្រើនជាងគេ ឲ្យនៅក្រោយបង្អស់។ កាលនៅផ្ទះលោកអ៊ុំអគ្គមហាសេនា ខ្ញុំធ្លាប់រាំដើរជាតួសខាន់ៗតែ ម្នាក់ឯងរួចអស់ទៅហើយ, ម្ល៉ោះហើយ គ្រាន់តែភ្លេងចាប់ប្រគុំភ្លាម ខ្ញុំក៏ស្ទុះភ្លែតចេញទៅ ដោយខំពត់ពេន ចលនាដងខ្លួន និង អវយវៈ ឲ្យត្រូវតែខ្នោះតាមចង្វាក់ភ្លេង។ ឃាឃាចាស់ៗដែលអង្គុយបត់ជើងព័ទ្ធជុំវិញឆាក ជជែកគ្នារអ៊ូឡើង ហើយហួងក៏ស្រែកប្រាប់ជាភាសាសៀមទៅកាន់នាម៉ឺនម្នាក់ដែលលុតជង្គង់ក្បែរនោះដែរ។ ខ្ញុំមិនខ្ចីស្តាប់នរណានិយាយថាអ្វីទាំងអស់ រាំទាល់តែគ្រប់មួយជុំឆាក ទើបខ្ញុំត្រឡប់ចូលមកក្តងវិញ ក្តងចិត្តគិតស្មានថានឹងបានទទួលពាក្យកោតសរសើរមិនខាន។ ប៉ុន្តែខ្ញុំបែរជាបានទទួលសំណើចចំអក ឡកឡឺយពីអ្នករាំដូចគ្នា និង រំពាត់ផ្តៅពីអ្នកគ្រូ ជារង្វាន់ទៅវិញ។ ម៉េចក៏ខ្ញុំហ៊ានចេញទៅមុនពេលគេឲ្យ សញ្ញា? ម៉េចក៏ខ្ញុំចេញទៅតែម្នាក់ឯង ពុំព្រមចាំអ្នកឯទៀតផង? ខ្ញុំចង់យកមុខយកមាត់តែម្នាក់ឯង ដើម្បីបំបាក់មុខធ្វើឲ្យហួងខ្នាសភ្នៀវបារាំងឬអ្វី? គេក្តីចមួលភ្លៅខ្ញុំចេញឈាមទាល់តែខ្ញុំយំ។ ពេលនោះ ឃុនថាន់ ចូលមកជិតនិយាយលួងលោមខ្ញុំថា ខ្ញុំធ្លាប់តែរាំម្នាក់ឯង បានជាថ្លោះធ្លោយអញ្ចឹង, ចាប់តាំងពីពេលនេះតទៅ ខ្ញុំត្រូវប្រយ័ត្នមើលគេមើលឯងឲ្យមែនទែន។

ម្តងនេះ ខ្ញុំប្រុងប្រៀបខ្លួនស្រួលបួលចេញរាំជាថ្មីម្តងទៀត ដោយមានគេឯងចេញមកហូរហែតាមក្រោយ ហើយជាំបានប្រព្រឹត្តទៅរហូតដល់ចប់ គ្មានការច្រដេងច្រដាងផ្សេងទៀតឡើយ។ ប៉ុន្តែ ខ្ញុំចងគំនុំនឹងអ្នកគ្រូ សំរិត ដ៏ស្នាស់នោះជាប់រហូត ទើបខ្ញុំប្រកែកលែងព្រមហាត់ជាមួយគាត់។

ខ្ញុំសំណាក់នៅក្តងរោងក្បែរផ្ទះ ឃុនព្រះញាគិ។ ល្ងាចនោះ គេយកពូកមកក្រាលលើក្តារ និង ចងមុងធំវែង ដើម្បីឲ្យពួកល្ងោនទទួលទានដំណេកជាមួយគ្នាទាំងអស់តែម្តង។ ខ្ញុំចូលចិត្តរស់នៅជាមួយគ្នាច្រើន ដូច្នេះ ជាងរស់នៅម្នាក់ឯង ព្រោះខ្ញុំខ្លាចខ្មោចណាស់។

យប់ឡើង នរណាអស់កម្លាំងក៏រួសរាន់ចូលមុងមុនគេទៅ អ្នកខ្លះទៀតនៅ លេងបៀ ឬ ជជែកជារឿងផ្សេងគ្នាអែ រហូតដល់យប់ជ្រៅ។

អ្នកដេកជិតខ្ញុំឈ្មោះរុន ។ គាត់មានអាយុបងខ្ញុំជាងដប់ឆ្នាំ ហើយបានលះបង់ការរាំរែកជ្រុះស្រឡះ ដើម្បីទៅបំរើហួងវិញ។ មិនយូរប៉ុន្មាន គាត់ក៏ចាប់ចិត្តរាប់អានខ្ញុំ ហើយខ្ញុំក៏ស្រឡាញ់គាត់ដូចជាបងស្រីបង្កើតម្នាក់ដែរ ត្រាន់នឹងបានពឹងពាក់គ្នាទៅវិញទៅមកពេលឈឺថ្កាត់យប់ព្រលប់។ ខ្ញុំដេកអោប ឬ គងគាត់បានតាមចិត្ត ព្រោះគាត់ទ្រមក់ដេកណាស់ ទាល់តែកាលណាក្តៅស្អុះ ទើបច្រានខ្ញុំចេញ។ រាល់យប់មុនពេលដេក យើងជជែកគ្នារអ៊ូៗ ពីរឿងរ៉ាវកំប៉ិកកំប៉ុកក្តងរាំង ពីកិច្ចការប្រចាំថ្ងៃ និង ពីកិច្ចការសម្រាប់ថ្ងៃស្អែក រហូតដល់ដេកលក់រៀងខ្លួន។

ព្រឹកមួយនោះ ខ្ញុំភ្ញាក់ពីដេកតាំងពីព្រលឹមខុសធម្មតា។ ដោយធាតុអាកាសរងាធ្វើទុក្ខខ្លាំងពេក ខ្ញុំក៏ទាញភួយពីបងរុន មកដណ្តប់ម្នាក់ឯង ស្រាប់តែឃើញមានឈាមប្រឡាក់ភួយមួយដុំ។ ខ្ញុំភ័យស្លន់ ស្មានថា បងរុន ស្លាប់ឬត្រូវរបួស ក៏តាំងស្រែកឆោឡោ ដើម្បីបង្កើលដាស់អ្នកជិតខាង។ បងរុន ស្ទុះងើបឡើង, ដល់ឮខ្ញុំនិយាយរឿងនេះប្រាប់គាត់យកដៃខ្ទប់មាត់កុំឲ្យខ្ញុំនិយាយតទៅទៀត ហើយដើរទៅផ្លាស់សំពត់ ចេញភ្លាមមួយរំពេច។ គាត់បបួលខ្ញុំដេកទៅវិញ នាំបន្លប់និយាយពីរឿងស្រីទៅបំរើហួង ដែលត្រូវបក់ធ្មិត គក់ច្របាច់ ទាំងយប់ទាំងថ្ងៃ ព្រមទាំងឲ្យដំប្លន្ទាន ថា ថ្ងៃណាមួយខ្ញុំត្រូវរកផ្កាឬផ្លែឈើទៅថ្វាយហួង ដើម្បីបានរង្វាន់ខ្លះផង។ គាត់និយាយទាល់តែខ្ញុំដេកលក់ទៅវិញ។

កន្លងមកពីរ-បីថ្ងៃ ស៊ុន និងខ្ញុំ បានច្បាប់ទៅលេងផ្ទះមួយថ្ងៃ, ពុកក៏បានឈប់ធ្វើការប្រុងប្រៀបចេញទៅផ្ទះដែរ។ ខ្ញុំគ្មានលុយមួយសេនជាប់នឹងខ្លួនសោះ ប៉ុន្តែខ្ញុំប្រាប់ពុកឲ្យទៅផ្សារទិញផ្លែឈើល្អៗ សម្រាប់យកទៅថ្វាយហួង។ ពុកប្រញាប់រត់ទៅផ្សារ ទិញបានផ្លែទទឹមទុំ ព្រមទាំងខ្ចីថាសប្រាក់របស់ ឪពុកម្តាយ ស៊ុន មករៀបចំដាក់យ៉ាងត្រឹមត្រូវទៀតផង។ ត្រឡប់មករាំងវិញ ខ្ញុំប្រថុយចូលទៅក្តងប្រាសាទមេខលា ដែលនៅក្តងនោះ ហួងកំពុងផ្តំសោយអាកៀន

លើក្រែប្រកបទៅដោយចម្លាក់ក្បាច់ក្បរល្អប្រណីត។ ហួងមើលមកឃើញខ្ញុំអង្គុយត្រង់កន្លៀតក្បែរកញ្ចក់ ក៏សួរទៅពួកស្រីអ្នករៀបចំខ្សៀអាកៀន:

~ មីតូចហ្នឹង វាមករកអី?

បងរុន ដែលកំពុងអង្គុយបក់ផ្ទៃតនៅចុងជើងក្រែនោះ ទួលហួងភ្លាម:

- ក្រាបទូល, នាងយ៉ែម ចង់យកផ្លែឈើមកថ្វាយព្រះអង្គ។
- អើ! ឲ្យវាចូលមក ហើយឲ្យគេយកប្រាក់មួយណែនមកឲ្យវាផង។

ស្រីម្នាក់ដែលទទួលវេនកាន់កូនសោក្តងថ្ងៃនោះ នាំយកប្រាក់គ្រប់ចំនួនមកឲ្យខ្ញុំ, ខ្ញុំថ្វាយបង្គំហួង សំដែងទឹកចិត្តក្រែកអរឥតឧបមា។ លោកសម្លឹងមើលខ្ញុំយ៉ាងយូរ ញញឹមបន្តិចព្រមទាំងមានបន្ទូលថា:

~ ម៉េចក៏គេមិនចុះឈ្មោះវាក្តងបញ្ជីអ្នកមកបម្រើអញ? ក្មេងហ្នឹងវាឧស្សាហ៍ណាស់ណា !
~ វានៅក្មេងពេកក្រាបទូល (បងរុន ឆ្លើយ) អាយុមិនទាន់គ្រប់ដប់បួនឆ្នាំស្រួលបួលផង។
~ បើអញ្ចឹង មីតូចឯងទៅវិញចុះ ហើយនែ!... ខំសុំបាយឲ្យឆាប់ធំឡើង ! ។

ខ្ញុំដាយមកកន្លែងដេកវិញ យកលុយលាក់ក្តងហិបនៅក្បាលដំណេក ដើម្បីទុកឲ្យម៉ែ។ នៅពេលជួប ហួងលើកទីពីរនេះ ខ្ញុំមិនសូវភ័យដូចកាលមុនពេកទេ។ ខ្ញុំចាប់ផ្តើមនឹកថា មុខការរបស់ហួង មានត្រឹមតែចែក លុយមាសពេជ្រ ឲ្យស្រីនឹង ក្មេងបំរើព្រះអង្គ ប៉ុណ្ណោះ... ខ្ញុំឧស្សាហ៍ហ៊ានប្រថុយដើរទៅឡេមឡឺមក្បែរ ប្រាសាទមេខលា ដែលឃើញមានអុជភ្លើងភ្លឺ សប្បាយរីករាយអ៊ូអរជានិច្ចទាំងយប់ទាំងថ្ងៃ ហើយដែលនៅក្តងនោះ ហួងរស់នៅប្រកបដោយក្តីសុខកាយសប្បាយចិត្តជាអតិបរមា កណ្តាលចំណោមស្រីបម្រើស្អាតៗ ដែលត្រូវគេផ្លាស់ប្តូរយកអ្នកថ្មីមកជំនួសជារឿយៗ។

ស៊ុន និងខ្ញុំ មានទម្លាប់ទៅលបមើលកិច្ចការក្តងប្រាសាទមេខលា ឥតមានខានមួយយប់ណាឡើយ ដោយនាំគ្នាពួនក្បែរពានហាលខាងក្រោយ ដែលលយចូលទៅដល់ក្តងសួនច្បារ ងងឹតចាក់ភ្នែកមិនយល់។ ខ្ញុំចំអើតមើល ក្បាលសឹងតែមិនដល់ក្តារក្រាលនៃរានហាលនោះផង ប៉ុន្តែបានស្បែងងឹត ជួយបិទបាំងមិនឲ្យអ្នកដើរទៅមកកាត់តាមនេះមើលយើងឃើញឡើយ។

ហួងសោយជាយតិចណាស់ រវល់តែយកស្លាបព្រាចូកជាយជះចោលទៅលើក្តារ ជានិមិត្តរូបដើម្បីធ្វើឲ្យព្រាស្រួសម្បារណ៍ ស្រួរ-អង្គរ បរិភោគ។ មួយថ្ងៃៗ ហួងសោយអាកៀន និង ផ្តំវាល់ល្ងាច ដល់ព្រលប់ធំ ទើបតើនឡើងដើម្បីសោយព្រះស្ងោយតែម្តង។ ព្រះអង្គ ទ្រង់សោយលើតុ ជួនកាលម្នាក់ឯង ជួនកាលមាន ឃុន ឬ ម៉មដែលគាប់ចិត្ត មកអង្គុយកំដរផង។ ស្ត្រីកូនកាត់ចិនយួន និងហ្វីលីពីន ក្រងសក់ទម្លាក់ទៅក្រោយ និង ស្លៀកពាក់តាមរបៀបអឺរ៉ុប ជាអ្នកទទួលថាសប្រាក់ដាក់ម្ហូបពីអ្នកបំរើ យកមករៀបថ្វាយហួង។ ខ្ញុំសង្កេតមើលឃើញម្ហូបទាំងនោះ ជួនកាលធ្វើតាមរបៀបសៀម ជួនកាលតាមរបៀបចិន ឬរបៀបយួន របៀបបារាំង ក៏មានដែរ។ ប្រពន្ធហួងដទៃទៀត អង្គុយបត់ជើងលើកន្ទេលក្រាបផ្ទាល់នឹងក្តារ បរិភោគបាយ យ៉ាងស្ងៀមស្ងាត់។

ដល់ពេលយប់ជ្រៅ ហួងស្លៀកសារុង និង ដណ្តប់ជាហ៊ី ចូលទៅអង្គុយកណ្តាលចំណោមស្រីៗ ស្រែកច្រៀងសក្តវាទីលេងជាមួយគ្នាយ៉ាងសប្បាយរីករាយ ប៉ុន្តែសម្លេងហួងធំក្រលឮខ្លាំងលុបអស់សម្លេងស្រី។ ចំណែកនាម៉ឺន និង ស្រីអ្នកជាំដែលអង្គុយដុំនៅខាងក្រៅនោះវិញ គេនាំគ្នាស្តាប់ចម្រៀងនេះធ្វើភ្នែកមមីរ។

យប់នីមួយៗកន្លងទៅដោយក្តីរីករាយ ក្តងការច្រៀងរាំ ក្តងការជក់អាកៀន ឬ ជារីដែលហួងចែកឲ្យគ្រប់គ្នា ភ្លាន នរណានឹកខ្វាយខ្វល់ព្រួយបារម្ភពីរឿងអ្វីឡើយ។

យប់មួយនោះ ខ្ញុំអើតឡេមឡឺមតាមមើលបងរុន ឃើញគាត់លួចបានទំពីរនៅក្តៅគគុកហុចមកឲ្យខ្ញុំ។ ឆ្លាញ់ទាំងមាត់, ឆ្លាញ់ទាំងក្អែក, ខ្ចីឈរសប្បាយភ្លើតភ្លើនភ្លេចខ្លួន ស្រាប់តែលេចជើងពីរនៅលើរានហាល រឹះជាន់ចំក្បាលខ្ញុំ ហើយភ្លាមនោះ ទឹកនោមក៏ជាញ់ច្រួចពីលើមក ទទឹកស្នាខ្ញុំអស់មួយចំហៀង រកតែខ្ញុំគេចចេញក៏ពុំទាន់។ ខ្ញុំភ្ញាក់ផង ភ័យផង ស្ទុះដាយក្តឹងតតងាកក្រោយ។ ពេលនោះ ខ្ញុំឮសម្លេងហួងស្រែក ឡឡាឡើង ទាំងកណ្តាលយប់ស្ងាត់:

~ មីច្រឡឹមអស់ហ្នឹង វាចង់ឲ្យអញនោមច្រាសក្បាលណាស់ទៅឬអី?

សម្លេងស្រីៗសើចសប្បាយហ៊ោកញ្ជ្រៀវរសាត់មកដល់ត្រចៀកខ្ញុំ នៅពេលដែលខ្ញុំរត់មកដល់កន្លែងដេក ដើម្បីផ្លាស់សម្លៀកបំពាក់ និង យកសាប៊ូទៅមុជទឹកដុះលាងខ្លួនឲ្យជ្រះចង្រៃ។

ពេលវេលាកន្លងទៅយ៉ាងឆាប់រហ័ស... ពិធីបុណ្យមួយ ហើយមួយទៀត ចេះតែមានបន្តបន្ទាប់គ្នា នៅក្តងវាំង ហើយឲ្យតែដល់បុណ្យម្តងៗ ហួងតែងចែកប្រាក់ដល់ ស្រីបំរើ និង ពួករាជាំ ឥតដែលខាន។

ថ្ងៃមួយ ហ្លួងនឹកភ្នកចង់ធ្វើជាអធិបតីក្នុងពិធីកាត់សក់ពួកល្មោនក្មេងខ្លះៗ នៅក្នុងប្រាសាទមេខលា។ អ្នកដែលមានសំណាងត្រូវបានគេជ្រើសរើសមកឲ្យកាត់សក់នៅក្នុងឱកាសនោះគឺ គីញ, ម៉ាលួន, ម៉ែឡន, ចន្ទ, ឡៃសេន និង ខ្ញុំ។ ហ្លួងមើលឃើញសក់បួងជុករបស់ខ្ញុំជំងាងគេ ក៏ស្រាយទម្លាក់សំយាកទៅក្រោយខ្នង។ ទទួលពេលនោះ ពួកព្រាហ្មណ៍ក្រយកកាំបិតកោរមាសមកដល់ពេក ហ្លួងក៏ឱងតតូងឡើង ទាញយកកន្ត្រែមកកាត់ច្រៀបសក់ខ្ញុំ ដាច់រនីញរនុញអស់រលីង។ បន្ទាប់មក ពួកបាគូមកដល់ ចាត់ការកោរសក់ខ្ញុំបង្ហើយ និង ផ្តាំសង្ឃប្រសិទ្ធិ។ ហ្លួងឡើងឈរលើតានម៉ា យកទឹកមន្តមកច្រូចដាក់លើក្បាលយើង ម្នាក់បន្តិច។

ពួកខ្ញុំរវល់ធ្វើការ ពុំបានមកមើលពិធីនេះទាន់ពេលវេលានឹងគេទេ មានតែម៉ែម្នាក់ឯងគត់ ដែលបានមកប្រមូលសក់ខ្ញុំ យកទៅរក្សាទុកយ៉ាងម៉ត់ចត់។ ក្រោយមក ម៉ែប្រាប់ខ្ញុំថា គាត់យកសក់នោះទៅប្រគេន លោកទុកសម្រាប់ចងសាស្ត្រាទៅហើយ។

គេសរសើរសំណាងខ្ញុំគ្រប់គ្នា ព្រោះថា គឺហ្លួងខ្លួនឯង ដែលបានកាត់សក់ខ្ញុំជាសញ្ញាបង្ហាញឲ្យឃើញថា ហ្លួងគាប់ព្រះទ័យនឹងខ្ញុំខ្លាំងណាស់។ បន្ទាប់ពីកាត់សក់រួចហើយ ឃុនថាន់ ឃុនព្រះញាតិ និង អ្នកឯទៀតដែលអង្គុយព័ទ្ធជុំវិញយើងនោះ នាំគ្នាបង្វិលពពិល ហូចបន្តគ្នាពីមួយទៅមួយគ្រប់បីដុំ ទើបគេយក អំបោះនៅមកចងរុំក្បាលយើង ព្រមទាំងហាមថា ទាល់តែគ្រប់មួយខែទើបឲ្យស្រាយចេញ ។ ខាងក្រោយខ្នង យើង មានកូននាម៉ឺនធំៗពីរ-បីនាក់ មកសុំកោរសក់ក្នុងឧកាសជាមួយគ្នានេះដែរ ប៉ុន្តែពួកវាគ្រាន់តែបាន ពួកព្រាហ្មណ៍កោរឲ្យតែប៉ុណ្ណោះ។

យើងកាន់តែធំពេញរូបពេញរាងបន្តិចហើយ... គេអនុញ្ញាតឲ្យយើងទុកសក់វែង លែងឲ្យកោរដូចមុនទៀតហើយ...។ យាយចាស់ៗអង្គុយជជែកគ្នារនៅតាមកាំជណ្តើរដំណាក់ ឲ្យតែឃើញខ្ញុំដើរទៅជិត គាត់និយាយចំអែចំអន់ភ្លាមថា អាយុប៉ិនខ្ញុំល្មមមានប្តីហើយ! ខ្ញុំមិនសូវរវល់យកចិត្តទុកដាក់ស្តាប់សំដីអស់នេះទេ ប៉ុន្តែខ្ញុំចាប់ផ្តើមយល់យ៉ាងច្បាស់នូវរឿងរ៉ាវដែលបណ្តាលឲ្យពួក ប្រុសកម្លោះ ដើរក្រឡឹងជុំវិញវាំង ប្រឹងតាមសម្លក់ស្រីៗដូចឆ្កែតាមសម្លក់ឆ្អឹងស៊ុប។

ពេលមួយនោះ ម៉ែនាំខ្ញុំទៅលេងនឹងពួកម៉ាកស្រីគាត់ម្នាក់ ជាអ្នកភ្លេងនៅឯវាំងសម្តេច ឧបរាជ (៤) ។ ចាប់តាំងពីពេលលោកអគ្គមហាសេនាអ៊ុម ជាឪពុកធំខ្ញុំស្លាប់ទៅ ខ្ញុំខានមកលេងវាំងខាងជើងនេះយូរហើយ។

វាំងរបស់ស្តេចទីពីរនេះ មិនដូចគ្នានឹងវាំងចតុមុខទេ មើលទៅឃើញដូចជាវាំង “អ្នកស្រែ” អញ្ចឹង។ សួនច្បារមានស្មៅដុះទ្រុបទ្រុល ព្រោះគ្មានអ្នកថែទាំ គ្រឿងតុបតែងមិនហ៊ឺហា ផ្ទះនីមួយៗចង្អៀតរើខ្លួន មិនរួច របៀបរបប នៃ ពួកនាម៉ឺន និង ពួករាជាំ ក៏មិនសូវត្រឹមត្រូវ ក្រឡេកទៅកៀនកន្លៀតណា ក៏ឃើញតែគ្រិចស្មោកគ្រោកគួរឲ្យខ្ពើម។

នៅទីនេះ មានក្រុមល្មោនតែមួយគត់ ដែលដឹកនាំដោយ ព្រះអង្គម្ចាស់ក្សត្រីយ៍ ដ៏ល្បីល្បាញឈ្មោះ រ័មធីតា ជាកូនបង្កើតរបស់សម្តេចឧបរាជ។ ក្នុងក្រុមល្មោននេះ នរណាចង់ធ្វើអ្វីក៏ធ្វើទៅ ព្រោះមួយថ្ងៃៗ ម្ចាស់ក្សត្រីយ៍ចាងហ្វាងនោះរវល់តែជក់អាភៀនបង្ហួយដូចឪពុកដែរ ហើយបើនិយាយពីរឿងស្រាវិញ ម្ចាស់ក្សត្រីយ៍ ក៏ពុំមែនអន់ប៉ុន្មានដែរ លេងសុទ្ធតែ “សិច” តែម្តង។ ដល់មានចៅហ្វាយជំជាអ្នកឲ្យ ឧទាហរណ៍អញ្ចឹង កូនចៅក៏ចេះតែនាំគ្នាជក់ ផឹក ឬ លេងបៀ ប៉ោ តាមតម្រាប់ចៅហ្វាយ ដែលជាហេតុនាំឲ្យ កើតការរាយប៉ាយគ្មានសណ្តាប់ធ្នាប់យ៉ាងនេះ។

នៅពេលដែលដឹងថា ខ្ញុំមកថ្វាយបង្គំម្ចាស់ក្សត្រីយ៍ ពួកគេស្រាប់តែនាំគ្នាផ្អើលឈូឆរដកកចំហមាត់ មើលមុខខ្ញុំធ្វើស្លើ ព្រោះពួកគេកម្របានឃើញអ្នករាជាំមែនទែន នៅឯវាំងខាងក្បែងនេះណាស់។ នឹកឃើញ ដល់ពួកអស់ហ្នឹង ខ្ញុំដូចជាខ្មាសគេជួស។ ម្ចាស់ក្សត្រីយ៍អង្គុយស្ងៀចលើកន្ទេល និយាយសួរខ្ញុំថាតើខ្ញុំ ចង់មកនៅជាមួយលោកឬទេ?

ខ្ញុំរកមើលមិនឃើញសម្តេចឧបរាជទេ ប៉ុន្តែកាលពីពេលមកមុនៗ ខ្ញុំធ្លាប់ឃើញ ធ្លាប់ស្គាល់លោក ច្បាស់ណាស់។ លោកមានវ័យចាស់បន្តិចទៅហើយ ព្រមទាំងមានមាឌធំនិង សម្បុរណ៍សាច់ឈាមជាងស្តេចបង ដែលជាហ្លួងសោយរាជ្យ។ លោកដាក់ធ្មេញភ្លុកពីរក្រាស់យ៉ាងល្អប្រណិត ផ្ទៃទិញពីអឺរ៉ុបមក បបូរមាត់ធ្លាក់ សក់សក្បសដូចសំឡី ភ្នែកមុត។

តាមលេចឮពាក្យចចាមអារាមថា សម្តេចឧបរាជ ដូចជាឆ្លួតឡប់ម្តងៗផង គឺមានយប់ខ្លះ លោកស្រាត ខោអាវ លបរត់ចេញទៅក្រៅវាំងតែម្នាក់ឯង ទាល់តែពួកនាម៉ឺនដេញតាមចាប់ប្រអូសប្រទាញ ទើបព្រមចូលមកវិញ។ លោកមានវ័យចាស់បន្តិចមែន ប៉ុន្តែកម្លាំងលោកនៅមាំមួនល្អណាស់។ គេនិយាយប្រាប់ខ្ញុំថា ល្ងាចមួយនោះមានបុរសម្នាក់កាន់ថ្នេងធំ ចូលមកអុកឡកកូនចៅលោកដល់ក្នុងផ្ទៃវាំង លោកក៏ស្ទុះដើរឡើង ប្រើតែខ្សៀអាភៀនប្រយុទ្ធជាមួយជននោះ វាយវាទាល់តែសន្លប់ ហើយបង្គាប់ឲ្យគេយកទៅកាត់កចោលភ្លាមមួយរំពេច។

គេនិយាយពីមាត់មួយទៅមាត់មួយទៀតថា ថ្ងៃណាមួយ សម្តេចឧបរាជ នឹងបានឡើងសោយរាជ្យនៅ វាំងចតុមុខមិនខាន ហើយពួកអ្នកឡេមឡឺមរកបុណ្យសក្តិ ក៏តាំងនាំគ្នាអែបអបយកគាប់គួរតាំងពីឥឡូវ។ នៅជុំវិញហ្លួងចាស់ដែលធ្លាក់ខ្លួនឈឺនោះ ព្រះអង្គម្ចាស់ នាម៉ឺន មន្ត្រី ឃុន ម៉ម នាំគ្នាដណ្តើមកេរ្តិ៍បុណ្យសក្តិ ទុកសម្រាប់ថ្ងៃស្អែករៀងៗខ្លួនរួចស្រេចអស់ទៅហើយ។

(៤) ឧបរាជ នេះ ជាងាររបស់ព្រះបាទ សុីសុវត្ថិ មុនពេលបានឡើងសោយរាជ្យ។

ការដែលនូណាម ជាប្រពន្ធគាប់ចិត្តជាងគេ ដាច់ចិត្តបោះបង់ហ្លួងចោល បានធ្វើឲ្យជម្ងឺព្រះអង្គកាន់តែដុនដាបថែមឡើងទៀតជាលំដាប់ រហូតដល់ហ្លួងខ្លួនឯងក៏ដឹងខ្លួនថា មិនអាចរស់បានយូរតទៅមុខទៀតទេ។

នូណាម ជាកូនអ្នកស្រែសុទ្ធ ប៉ុន្តែបានមកនៅវាំងតាំងពីក្មេង។ គាត់មិនសូវស្អាតប៉ុន្មានទេ ប៉ុន្តែទឹកមុខ មានស្នេហ៍អ្វីម្យ៉ាង គួរឲ្យអ្នកជងស្រឡាញ់រាប់អាន រហូតបានឡើងធ្វើជាតួឯកក្នុងក្រុមល្ខោននៃ ឃុនថាន់ ហ្លួងពេញចិត្តនឹងមើលគាត់រាំតតចេះធុញទ្រាន់ ហើយប្រទានមាសពេជ្រ លុយកាក់ បំពោរបំពេកឲ្យតែគាត់ម្នាក់ ច្រើនឥតឧបមា។

ប៉ុន្តែ នូណាម ស្រឡាញ់តែខ្លួនគាត់ប៉ុណ្ណោះ។ ដោយដឹងថា ហ្លួងជិតអស់បុណ្យ គាត់តែងឆ្លៀតពេល ចេញទៅក្រៅវាំងដើម្បីទៅធ្វើឫកម្ពុ៉ជម្ពក់ដាក់ សម្តេចឧបរាជ នៅឯវាំងខាងជើងនោះទៀត។ សម្តេចឧបរាជ ឈ្លក់នឹងសម្រស់នូណាម ភ្លេចប្រពន្ធចាស់ឈ្មោះប្រឹម ដែលជាស្រីសៀមខ្មៅគគ្រិច ហើយបែរមកគាប់គ្នាជាមួយ នូណាម រហូតដល់មានសន្យាថា នឹងលើកដំកើងគាត់ឲ្យមានអំណាចលើគេមួយវាំង កាលណាខ្លួនបានឡើងសោយរាជ្យទៀតផង។

និយាយពីហ្លួងវិញ ទោះបីឈឺដាបដើរមិនរួចយ៉ាងនេះក្តី ក៏នៅតែឆ្លៀតស៊ើបសួរពីរឿង នូណាមជានិច្ច ក្រាន់តែមិនចេញស្តីថាដូចម្តេច សុកចិត្តសង្ស័កើតទុក្ខតែម្នាក់ឯង។ ថ្ងៃមួយ លោកប្រើគេឲ្យទៅហៅ នូណាម មកគាល់ប៉ុន្តែគាត់នោះចិត្តសើងប្រកែកពុំព្រមមក ដែលជាហេតុបណ្តាលឲ្យហ្លួងខឹងច្រឡោតកូងឡើង បង្គាប់ឲ្យក្រុមវាំងបួននាក់ទៅចាប់ នូណាមមកធ្វើទារុណកម្ម ចងដាក់ឲ្យដេកផ្តាប់មុខលើដី ហើយយករំពាត់ មករាយវាត់បែកឈាមរឡាក់។ នូណាម ឈឺចាប់ខ្លាំងពេក ស្រែកយំរោទិ៍ផ្អើលអស់មួយផ្ទៃវាំង គេចេញមកឈរមើលគ្រៀបគ្រា។ បន្ទាប់មកគេដាក់ច្រវាក់បណ្តើរគាត់យកទៅឃុំនៅក្នុងសាលានាលីយក្ស ដែលជាកន្លែងឃុំឃាំងស្រីមានទោស ស្ថិតនៅឆ្ងាយឯចុងសួនច្បារឯណោះ។

ទារុណកម្មបែបនេះ ខុសប្លាហ៍មានញឹកញាប់ណាស់។ អនុស្សាវរីយ៍ឃោរឃៅជាងគេដែលខ្ញុំចាំមិនភ្លេចនោះ គឺថ្ងៃមួយគេចាប់យកស្រីជាំម្នាក់ឈ្មោះ លន្ធា យកទៅធ្វើទោស។ នាងនោះមានផ្ទៃពោះច្រើនខែហើយ ពុំអាចដេកផ្តាប់មុខកើត គេក៏ជីកដីឲ្យក្រហូងត្រង់ពោះហើយច្រានឲ្យដេក ដើម្បីគេធ្វើទារុណកម្ម យ៉ាងអមនុស្សធម៌ក្រៃលែង ឥតមានក្តីមេត្តាករុណាបន្តិចបន្តួចសោះ។

ការផ្តន្ទាទោសចំពោះ នូណាម គឺជាឧទាហរណ៍សម្រាប់បន្លាចក្មេងជំនាន់ក្រោយ កុំឲ្យយកតម្រាប់តាម។ នឹកឃើញដល់រំពាត់ផ្តៅដងមាសនេះ ខ្ញុំខ្លាចញ័រសាច់ សូម្បីសព្វថ្ងៃនេះដែលខ្ញុំចេញផុតពីវាំង មកហើយក្តី ក៏ខ្ញុំនៅតែនឹកខ្លាចជានិច្ច។

ជីវភាពនៅក្នុងវាំងប្រៃជាស្រពោប់ស្រពោន លែងមានរាំច្រៀងសប្បាយហ៊ោកញ្ជ្រៀវអ៊ីទាំងអស់។ គេឃើញតែព្រះសង្ឃគង់តម្រៀបជាជួរជុំវិញក្រឡាបន្ទំ លើកផ្តិតជាំងភ្នែក សូត្រធម៌ទាំងយប់ទាំងថ្ងៃ។ ទាល់តែដល់ពេលនេះទើបហ្លួងអាចយល់ និង ឃើញនូវសេចក្តីស្មោះត្រង់ពិតប្រាកដនៃ ឃុនថាន់ និង ឃុនព្រះញាតិ ដែលមកចាំគាល់ទាំងយប់ទាំងថ្ងៃ តតកិតនឿយហត់។ ក្សត្រី, ក្សត្រា, អស់អ្នក, អស់នាង ក៏នាំគ្នាមកជួបជុំ ភ្នែកសំឡឹងឆ្ពោះទៅក្រឡាបន្ទំតតបំប្រិចដែរ។

ដល់ពេលស្លឈាមមែនទែន ហ្លួងបង្គាប់ឲ្យគេលើកលោកដាក់លើគ្រែស្នែង សែងចេញទៅក្រៅទាំង យប់អាត្រាត្រងដឹតឈឺង ដើរកាត់ស្មៅព្រៃពាមពើមអស់ចិត្ត ទើបបង្គាប់ឲ្យត្រឡប់មករាជមន្ទីរ ហើយឲ្យគេផ្ទេរលើកដាក់ទៅលើកៅអីមានកង់រុញទៅរុញមកឥតឈប់ឈរ។

សភាពស្ងប់ស្ងាត់ត្រជដណ្តប់ពេញផ្ទៃវាំងទាំងមូល... គេឮតែសូរសម្លេងព្រះសង្ឃសូត្រការតា យ៉ាងលន្ងង់លន្ងោចគួរឲ្យស្រងេះស្រងោចក្រៃលែង និង សម្លេងមនុស្សខ្សឹបខ្សៀវគ្នា។ ហ្លួងលើកដៃឡើងប្រាប់ឲ្យគេនៅស្ងៀម ហើយមានបន្ទូលខ្សាវៗថា :

- អញអត់ភ្លេចទេ!

បន្ទាប់មក លោកហៅ ម៉មសួន មកប្រាប់ឲ្យទៅយកលុយប្រាំរៀលមកថ្វាយ ប៉ុន្តែ ម៉មសួន ទើបនឹងចូលទៅជិតដល់ត្រែ លើកជើងពានថ្វាយ ស្រាប់តែហ្លួងទន់ដៃទម្លាក់លុយទៅលើខ្នើយ ហើយមាត់និយាយថា ដូចម្តេចកំពុងច ងាកបត់កមកខាងឆ្វេងបន្តិច ហើយផុតដង្ហើមទៅ។

រំពេចនោះ សម្លេងទ្រហោយំក៏ផ្ទុះឡើង ទ្រហឹងអឺងអាប់រកស្តាប់ទិសតំបន់អ្វីមិនឮ។ ចំណែកឯក្មេងៗ ឃើញតែគេយំគ្រប់គ្នា មិនយល់រឿងអីសោះ ក៏កើតក្តីភ័តភ័យស្រែកយំងាងនឹងគេដែរ ព្រមទាំងស្រែករកម៉ែ- ឱជួយ។

យើងរត់ប្រសេចប្រសាចតម្រង់ទ្វារព្រលប់ ប៉ុន្តែភ្លាមនោះទ្វារត្រូវគេបិទជិត ហាមមិនឲ្យចេញជាដាច់ខាត។ ពួកស្រីធំៗភ័យជ្រួលច្របល់ជាងគេ រត់ពីកន្លែងមួយទៅកន្លែងមួយ ស្រែកនោឡោថា :

- បន្តិចទៀតគេនឹងចូលប្តូនវាំង ហើយស្ត្រី ទាំងក្មេង ទាំងចាស់ មុខជាត្រូវទាហានចាប់រំលោភលើ រូបកាយ និង សម្លាប់ចោលទាំងអស់គ្នាមិនខាន។ ប្រហែលជាគ្មាននរណាម្នាក់បានរួចរស់ទៅជួបមុខ ម៉ែ-ឪវិញទេ ពីព្រោះស្តេចសុគតហើយ យើងអត់មានស្តេចគ្រប់គ្រងមើលខុសត្រូវដូចមុនទៀតទេ!។

ខ្ញុំពុំបានចាំសព្វគ្រប់ថា ក្នុងពេលចលាចលនេះ កើតមានរឿងរ៉ាវដូចម្តេចខ្លះទេ។ តាមឮគេនិយាយថា ពួកបាវាំង បាននាំគ្នាមកតំនាប់សព ស្តេចសុវណ្ណកោដ្ឋ និង យកមកុដរាជ្យពីក្នុងទីនាំងទេវារិនិច្ឆ័យ ទៅយាង សម្តេចឧបរាជពីវាំងខាងជើង ឲ្យមកគង់នៅវាំងចតុមុខវិញ។

គេឲ្យយើងស្លៀកពាក់ស ព្រមទាំងកោរសក់យើងទាំងអស់គ្នា ទាំងអ្នកបាំ, ទាំងអ្នកបំរើផ្ទាល់។ បន្ទាប់មក មានធ្វើពិធីផ្សេងៗទៀត ដែលមានតែចាស់ទុំប៉ុណ្ណោះត្រូវទៅធ្វើ ហើយព្រះសង្ឃសូត្រព្រះធម្ម ទាំងយប់ ទាំងថ្ងៃ នៅជុំវិញកោដ្ឋមាស ដែលនៅក្នុងនោះគេបញ្ចោះសពហ្លួង ដោយយកកាំបិតកាត់ផ្តាច់ សរសៃដៃ សរសៃជើង ដើម្បីស្រណុកទាញឲ្យអង្គុយរបៀបលុតជង្គង់សំពះ។ កោដ្ឋនេះដំកល់នៅក្នុងប្រាសាទព្រះធម្មសង្វេគ ទុកសម្រាប់ធ្វើបុណ្យបូជានៅឆ្នាំក្រោយ។

លោកមហាមន្ត្រី អ្នកទទួលភារៈមើលរបៀបរៀបរយក្នុងវាំង បានបើកទ្វារវាំងអនុញ្ញាតឲ្យ ឪពុក-ម្តាយ ពួកល្ខោនចូលមកមើលខុសត្រូវ និង ចាត់ចែងរឿងកូនចៅរៀងៗខ្លួន។ ម៉ែចូលទៅគាល់ឃុនព្រះញុតិ ដើម្បីនិយាយចង់យកខ្ញុំទៅនៅផ្ទះវិញ ឲ្យបានទាន់មុនពេលស្តេចថ្មីឡើងសោយរាជ្យ ពីព្រោះខ្ញុំនៅបំរើហ្លួង អស់ពេលជាងមួយឆ្នាំហើយ មិនដែលឃើញបានប្រយោជន៍អ្វីចំពោះខ្លួនឯង ឬ បានប្រាក់កាសគ្រាន់នឹង ជួយទប់ប្រាក់ខែបន្តិចបន្តួចរបស់ពុកសោះ។ ប៉ុន្តែ ឃុន ប្រកែកញ៉ាញ ពុំព្រមឲ្យខ្ញុំចេញពីវាំងដាច់ខាត សុខចិត្តចំណាយលុយហោប៉ៅឯង មួយរយរៀល ឲ្យម៉ែយកទៅជួសជុលផ្ទះ ព្រមទាំងខំលួងលោមអង្វរ ខ្ញុំទន់ឆ្អឹង។

ហ្លួងសុគតមិនបានប៉ុន្មានផង សម្តេចឧបរាជ ដោយមានកូនចៅនាម៉ឺន និង ពួកបាវាំងមួយហ្វូងធំ ហែរហមជូនដំណើរផង ក៏រើតវាំនមកនៅក្នុងវាំងចតុមុខ ដែលជាលំនៅសម្រាប់ហ្លួងសោយរាជ្យនេះវិញ។ សម្តេចឧបរាជ ស្រមៃចង់សោយរាជ្យយូរណាស់មកហើយ ដល់បានសំរេចដូចបំណងអញ្ចឹង វាទៅជាសប្បាយចិត្ត ញញឹមស្នេញបិទមាត់មិនជិត លេចធ្មេញភ្លឺកពីក្រាសមកដូចចង្កងមួយក្ប ។

បើតាមខ្ញុំស្មានមើលទៅ ពេលនេះប្រហែលជាចូលដល់ខែពិសាខហើយ ពីព្រោះខ្ញុំឃើញដើមស្វាយ នៅក្នុងសួនច្បារវាំងចាប់ផ្តើមមានផ្លែទុំគ្រប់តែដើម។ ប៉ុន្មានថ្ងៃក្រោយដែល ស្តេចសុវណ្ណកោដ្ឋ ចូលទីរង្គតទៅ ស្រាប់តែកើតមានខ្យល់ព្យុះសង្ឃរាដ៏ខ្លាំងក្លាអស្ចារ្យ ដែលមួយអាយុមនុស្សកម្រនឹងមាននរណាបានជួបប្រទះណាស់ដូចជាប្រដួលប្រាប់ឲ្យដឹងថា នឹងកើតមានចលាចលវឹកវរក្នុងប្រទេសខ្មែរ ចាប់តាំងពីដើមរជ្ជកាលថ្មីនេះទៅតែម្តង។

ពេលនោះ ជាឱកាសដែលគេត្រូវផ្ទេរទឹករងៃហូរចេញពីសពហ្លួងដក់ក្នុងកោដ្ឋមាសនោះ បញ្ចូលទៅក្នុងថូមួយបិទជិតដើម្បីយកទៅចោលកណ្តាលទន្លេបួនមុខ។ ក្បួនដង្ហែរថូទឹករងៃ មានក្បួន នឹង ទូកជាច្រើន ហែរអធិកអធម៌ចេញពីកំពង់ផែទៅ ទោះបីនាម៉ឺនចាស់ទុំមើលឃើញមេឃបែបមិនស្រួល ខំទទូចឃាត់មិនឲ្យចេញទៅយ៉ាងណា ក៏គ្មាននរណាស្តាប់ដែរ។ ពិធីទម្លាក់ថូក្នុងទឹកមិនទាន់ទាំងចប់ស្រួលបួលផង ខ្យល់ព្យុះក៏ចាប់បោកបក់ឡើងពេញមួយកំណាត់ថ្ងៃ ហើយមួយយប់ទៀត បន្តរហូតដល់ស្អែកឡើងទើបស្ងប់ទៅវិញ។

ទឹកទន្លេដែលទើបនឹងបានទទួលសាច់ឈាមស្តេចខ្មែរថ្មីៗនេះ ក៏ចាប់ផ្តើមហក់កញ្ឆោលបោកបាច បង្កើតជារលកធំៗប៉ុនរលកសមុទ្រ វាយផ្ទប់ច្រាំងបាក់ដីទាំងផ្តាំង។ កប៉ាល់លិចលង់ ទូកត្រូវខ្យល់វាយខ្ទាតឡើងដល់គោក ស្លាប់ជីវិតមនុស្សអស់ជាច្រើន។ ទូកធំៗរបស់ហ្លួងដែលកំពុងតែឡើងអ៊ូ ក៏ត្រូវខ្យល់ព្យុះវាយពន្លិច ដួលដេករលាករលែលពេញផ្នេរខ្សាច់ដែរ។

នៅក្នុងវាំង ផ្លែស្វាយនៅខ្ចីនៅឡើយ ជ្រុះបាចសាចដូចគ្រាប់ភ្លៀងមកលើស្មៅ។ ដើមគគីរដ៏ធំសម្បើមមួយ នៅក្រោយទីនាំងទេវារិនិច្ឆ័យ រលើងគល់រលំសង្កត់បាក់របងប្រាសាទបាញ់យ៉ង អស់មួយចំណែក។ យើងទាំងអស់គ្នាយល់ថា ព្រឹត្តិការណ៍ចម្លែកបែបនេះ ពិតជាកើតឡើងដោយសារកំហឹងព្រះអាទិទេព ពិតប្រាកដណាស់។

ចាប់តាំងពីពេលនោះមក រៀងរាល់ឆ្នាំ ទឹកទន្លេមេគង្គតែងហូរនាំយកដីច្រាំងទាំងផ្តាំងៗទៅជាមួយ ដែលជាហេតុធ្វើឲ្យចម្ងាយពីមាត់ទន្លេមកកំផែងសីមា (៥) កាន់តែរួញខ្លីជាលំដាប់ ហើយថ្ងៃណាមួយ ទន្លេមេគង្គក៏ប្រហែលជានឹងលេបត្រជាក់វាំងទាំងមូល ដែលជាជម្រកដ៏សុខសាន្ត នៃពពកស្តេចខ្ចិលច្រអូស និង នាម៉ឺនឡេមឡឹម គិតតែប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីជាកិច្ចសងសឹកជួសទឹកចិត្តក្តៅក្រហាយ នៃរាស្ត្រខ្មែរ ដែលធ្វើវាសនាលើពួកទាំងនោះ ហើយបើរជាត្រូវពួកនោះ នាំឲ្យជួបតែនឹងទុក្ខវេទនាឥតស្រាកស្រាន្ត។

ជាពិសេសទៅទៀត ក្នុងឆ្នាំរោងនោះ ទឹកទន្លេជន់លិចអស់ដំណាំដាំដុះ ត្រូវនឹងឆ្នាំមុនដែលរីងរាង ធ្វើស្រែមិនបានផលផង រាស្ត្រក៏រឹតតែវេទនាណាស់ទៅទៀត។ នៅជុំវិញវាំងដែលពោរពេញទៅដោយមនុស្ស ខ្វះសមត្ថភាព អំពើអយុត្តិធម៌ អំពើបាប និង ការលបលួចសាហាយស្មន់នឹងគ្នានេះ រាស្ត្រត្រូវរស់នៅវេទនា អត់ឃ្លានដូចសត្វធាតុ ឯការអនាថា គ្មាននរណាមើលខុសត្រូវ ព្រោះហ្លួងប្រថាប់ថា ឲ្យបាវាំងមើលរាស្ត្រ បាវាំងថា ហ្លួងទេដែលជាអ្នកត្រូវគ្រប់គ្រងរាស្ត្រ សម្រេចសម្រួចទៅ គ្មាននរណាដឹងឮអ្វីទាំងអស់។

ប៉ុន្តែ មុនពេលកើតមានព្រឹត្តិការណ៍អស់នេះ គឺគ្រាន់តែហ្លួងសុភតភ្លាម លោកមហាមន្ត្រីដោយមាន ជារាំងម្នាក់ ក្បាលទំពែក ដែកជំមូលដូចត្រីស្ងោរ ជូនដំណើរផង បានចូលមកក្នុងវាំង បើករើកកាយទូរដាក់សម្បត្តិហ្លួង ប្រមូលយក មាសពេជ្រ លុយកាក់ ទាំងអស់ ហើយប៉ុន្មានថ្ងៃក្រោយមក ស្រាប់តែអ្នកទាំងពីរ មានលុយដើរចងការពាសវាលពាសកាលតែម្តង។

សម្បត្តិហ្លួងមួយចំណែក ត្រូវលោកចែកទៅឲ្យ កូនចៅ និង អ្នកបំរើនៃបនិត្យទឹកក្តៅទឹកត្រជាក់ ក្នុងរវាងប៉ុន្មានខែមុនពេលសុគត។ សំបុត្រចែកកេរ្តិ៍មរតកមួយ ដែលគេយកទៅថ្វាយហ្លួងស៊ីញ៉ៅនៅពេលដែល លោកកំពុងឈឺដាបលែងដឹងខ្លួនដឹងជ្រាណទៅហើយនោះ ត្រូវគេយកមកអនុវត្តតាមឥតខ្ចោះ ម្ល៉ោះហើយ កូនស្តេចខ្លះ និង អ្នកខ្លះទៀត គ្មានជាប់ឈាមព្រះញាតិវង្សានុវង្សអ្វីនឹងគេបន្តិចបន្តួចសោះ កំស្រាប់តែ បានទទួលមរតកច្រើនអស្ចារ្យចំណែកឯអ្នកខ្លះទៀត បែរជាវិនាសហិនហោចអស់ផ្ទះអស់សម្បែង ជាហេតុបណ្តាលឲ្យកើតមានការច្រណែនឈ្នានីសគ្នាត្រឡប់ត្រឡិន។ ស្រីបំរើ និង ពួករបាំ ក្តៅក្រហាយណាស់ ដោយខ្លួនម្នាក់ៗបានទទួលតែប្រាក់ ពីរ-បីរៀល ប៉ុណ្ណោះ ក៏តាំងនាំគ្នាទន្ទេញជាប់នឹងមាត់ថា គេចូលមកប្លន់វាំង។ ប៉ុន្តែរឿងចលាចលទាំងនេះ ត្រូវស្ងប់ស្ងាត់ទៅវិញ នៅពេលដែលកើតមានរឿងថ្មីមួយទៀត។

លោកស្នៀន ខៀប កំពៀកសៀវភៅបញ្ជីបួនក្បាល ដើរកោះហៅអ្នករបាំទាំងអស់មកសួរ តើនរណាចង់ចេញពីវាំង? នរណាចង់នៅតទៅទៀត? ភាគច្រើនសម្រេចចិត្តឈប់នៅ ហើយត្រូវគេលុបឈ្មោះចេញពីបញ្ជីឈប់ឲ្យស៊ីប្រាក់ខែវាំង ។ ចំពោះអ្នកណាព្រមនោះ ថីខៀប សម្លឹងមើលតាំងពីក្បាលដល់ចុងជើង ទើបគាត់សំគាល់ថា ៖ មាឌធំ, ក្បាលទេវតា, រាងទាប, ដើមទ្រូងកិន្នរី, ស្អីអញ្ចឹងតរហូតមក។ ដល់វេនខ្ញុំ, ខ្ញុំឆ្លើយថាព្រមនៅ ថីខៀប ក៏និយាយថា៖

- អ្នករបាំ, ក្បាលព្រហ្ម (ហើយសរសេរពាក្យនេះចុះក្នុងបញ្ជី) ។

សំដីនេះ ធ្វើឲ្យខ្ញុំហ៊ឺហាក្នុងចិត្តមិនតិចទេ។

និយាយពីហ្លួងថ្មីនោះវិញ ហាក់ដូចជាមិនទាន់ជឿថា ខ្លួនឯងបានឡើងសោយរាជ្យ ជាស្តេចផែនដី មិនទាន់ជឿថាវាំងចតុមុខនេះជារបស់ខ្លួនផងទេ។ លោកធ្វើឫក រញ៉ាក់រញ៉ែរឲ្យចង់សើច ឃើញបន្ទប់រៀបចំស្អាតបាត ខំឈរមើលភ្លេចខ្លួន ឃើញកម្រាលព្រំ ឃើញខ្នើយ កំណាត់ស្អាតៗ មិនហ៊ានអង្គុយលើ ខ្លាចប្រឡាក់ ព្រមទាំងចេះតែរមើលខ្លួន ខ្លាចខ្មោចហ្លួងសុវណ្ណកោដ្ឋ ជាបងឯងនោះ តាមលង។

បន្ទាប់មក គឺកូនចៅម្ចាស់ក្សត្រីរមធីតា មានស្រីបំរើចាស់ៗគគ្រិចស្មោកគ្រោក ពួករបាំស្លៀកពាក់ រយីរយៃ ហ្លួងកូនស្តេច និង អ្នកបំរើដែលលើកគ្នាពីវាំងខាងជើង ចូលមកលុកលុយវាំងចតុមុខ ដោយម្នាក់ៗមានវេចស្បាយកន្ទេលរហែក តុកៅអីកញ្ចាស់បាក់បែក និង កន្ទោរស្តាន់កំពិតកំពៀវមកជាមួយផង។ ពួកអស់នេះ គ្រាន់តែឃើញរបៀបតុបតែងវាំង ក៏តាំងនាំគ្នាជញ្ជក់មាត់សរសើរសប្បាយចិត្តរីកថ្លើមប៉ុនចង្អេរ។ ជួនកាលខ្ញុំដើរដល់កូនស្តេច ដែលខ្ញុំស្មានថាជាពួកកូនចៅ (៦) កំពុងឈរយាមនោះ ទាល់តែចង់ដួលថ្ងាររក្រោយ ឬ ដើរជាន់ដៃកូនស្តេចតូចៗដែលប្រឡែងគ្នាដេកពេញកណ្តាលផ្លូវ បណ្តាលឲ្យវាយ៉ំថ្លង់រកស្តាប់ ទិសតំបន់អ្វីមិនឮ។

ឃ្លាណាស់ទម្រាំនឹងពួកអស់នេះ ទម្លាប់ខ្លួនបានជាមួយជីវភាពថ្មី ដែលសម្បូរណ៌សប្បាយជាងកាលរស់នៅឯវាំង សម្តេចឧបរាជ។ ហ្លួងថ្មីក៏កាន់តែសុំជាមួយការរស់នៅក្នុងបន្ទប់ថ្មី នៃទីទាំងមេខលា និង ប្រាសាទបាញ់យ៉ុងដែរ។ គេអញ្ជើញ ឃុនថាន់ ឲ្យចេញពីផ្ទះនៅក្បែរទីទាំងមេខលា ដើម្បីទុកកន្លែងនេះឲ្យ ម្ចាស់ក្សត្រីរមធីតា នៅម្តងវិញ។ ម្ល៉ោះហើយ ឃុនថាន់ ត្រូវប្រមូលទ្រព្យសម្បត្តិដ៏ច្រើនមហិមារបស់គាត់ ចាកចេញពីវាំង ទៅសង់ផ្ទះថ្មីមួយទៀតនៅខាងត្បូងទីក្រុង ក្រង់ម្តុំក្បែរវត្តស្វាយពពែ។ នៅទីនោះ គាត់បានចំណាយសម្បត្តិផ្គាល់ខ្លួនកសាងវត្តមួយ សម្រាប់ជាកុសលទៅអនាគតជាតិ ដោយយកឈ្មោះគាត់ដាក់ ជាឈ្មោះវត្ត គឺវត្តថាន់ សព្វថ្ងៃនេះឯង។

ឃុនព្រះញាតិ គ្មានសម្បត្តិសម្បូរណ៌ហូរហៀរដូច ឃុនថាន់ ទេ ម្ល៉ោះហើយផ្ទះគាត់ក៏មិនសូវហ៊ឺហារ គួរឲ្យនរណាចង់ដណ្តើមយកដែរ។ គាត់ប្រគល់កូនល្ងោនផ្គាល់ខ្លួនទាំងអស់ថ្វាយហ្លួងថ្មី ដើម្បីយកចិត្តកុំឲ្យ គេដេញចេញពីវាំង ហើយរស់នៅក្នុងសភាពក្រគោកយ៉ាក គ្មាននរណានឹកនារាប់រកហូតទល់ថ្ងៃស្លាប់។ រឿងវ៉ាស្ទើរកំសត់ ស្ទើរកំប្លែងចេះតែកើតមានប្លែកៗគ្នារាល់ថ្ងៃនៅក្នុងវាំង។

ពួកបារាំងមាននៅក្រៀបក្រា ចាំជួយជ្រោមជ្រែងហ្លួងឲ្យឡើងកាន់អំណាចជាស្តេចផែនដី គឺគេយកទាហានមកឲ្យយាមការពារ និង ធ្វើឫកជាគោរពកោតខ្លាចហ្លួងខ្លាំងណាស់ ដើម្បីជាកិច្ចលើកទឹកចិត្តហ្លួង ក្នុងពេលរង់ចាំទម្រាំដល់ពេលធ្វើបុណ្យរាជាភិសេកតាមទំនៀមទម្លាប់។ គេខិតខំពន្យល់ហ្លួងកុំឲ្យដើរលង ដើងទទេ លើកម្រាលព្រំនៅក្នុងបន្ទប់ទទួលភ្ញៀវ គេទិញស្បែកជើងឃ្លប់ ស្រោមជើង អាវស ថ្វាយហ្លួង គេពន្យល់ហ្លួងឲ្យឈប់ភ័យពីរឿងជំពាក់ប្រាក់គេ និង ហាមមិនឲ្យទៅដាស់ទ្វារថៅកែចិនខ្ចីលុយទាំងយប់អាធ្រាត្រ ដូចពីមុនទៀត។ ហ្លួងមិនបាច់ភ័យព្រួយពីរឿងអ្វីទៀតទេ ចាំតែសោយរាជ្យទៅបានហើយ ដល់ពេលដាច់ខែ គេបើកប្រាក់ខែ បួនម៉ឺនរៀល មកថ្វាយរាល់ខែ។

(៥) កំផែងវាំង ។
(៦) ពួកស្រីៗអ្នកលើកបាយទឹកបំរើហ្លួង ។

ឆ្លៀតឱកាសកើតការរីករាយនៅដើមរដូវកាលថ្មីនេះ ពួកអាណាព្យាបាលបារាំង នាំយកសំបុត្រស្នាម ជាច្រើនដែលគេរៀបចំធ្វើតាំងពីច្រើនឆ្នាំណាស់មកហើយនោះ មកសុំឲ្យហ្លួងស៊ីញ៉ូ ដើម្បីជាផ្តួរក្តងការ ដែលគេជួយជ្រោមជ្រែងឲ្យបានឡើងសោយរាជ្យ។ សំបុត្រស្នាមទាំងនេះ ហ្លួងស៊ីញ៉ូទាំងមិនយល់សេចក្តី គេថាម៉េចផងទេ។ មួយថ្ងៃៗ លោការល់តែរើកកាយ ថតតុ ថតទូ ស្រាប់តែថ្ងៃមួយប្រទះឃើញលិង្គកៅស៊ូ មួយ នៅក្តងថតតុ ដូចបេះបិតនឹងប្រដាប់មែនទែន រីងគួរឲ្យខ្លាច ប្រកបដោយរោមពណ៌ទង់ដែង មើល មួយភ្លែតស្មានថា របស់នេះត្រូវគេកាត់យកមកពីខ្មោចបារាំងណាម្នាក់ ដែលត្រូវគេសម្លាប់ចោលតាមបញ្ហាហ្លួងចាស់។

របស់ចម្លែកអស់នេះ ធ្វើឲ្យហ្លួងសប្បាយចិត្តរកអ្វីមកប្រៀបស្មើគ្មាន។ លោកខំសួរឲ្យគេពន្យល់ពីរបៀប ធ្វើឲ្យដង្ហាល់អគ្គីសនីរិល ពីរបៀបបើកទឹកម៉ាស៊ីន លោកស្ទាបអង្អែលខ្នើយសូត្រ និង អង្គុយទទោកជើង លើកៅអីភ្លេងទិញមកពីអឺរ៉ុប ញញឹមផ្លាក់បបូរមាត់ស្តែស ចេញធ្មេញភ្លឺកទាំងពីរក្រាស។ តើមានប្រយោជន៍ អ្វីនឹងមើលសេចក្តីក្តងសំបុត្រដែលបារាំង “ជាឪ ជាម៉ែ” យកមកថ្វាយទតនោះ? ហ្លួងស៊ីញ៉ូខ្លាច ព្រមទាំង និយាយថា មែរស៊ី !។

ជួនកាល ហ្លួងដូចជាភ្ញាក់ខ្លួន នឿយណាយនឹងពួកបារាំងដែលដណ្តើមយកអំណាចអស់រលីង ធ្វើអ្វីក៏ចាំតែធ្វើតាមបញ្ជាគេ និង ជាពិសេសទៅទៀត ពួកស្បែកសនេះ ពូកែសុំមិនចេះឆ្អែតឆ្អន់សោះ។ សូម្បីតែ បញ្ជីលុយកាក់ផ្ទាល់ខ្លួន ក៏គេមិនឲ្យកាន់កាប់ខ្លួនឯងដែរ ដាច់ខែ ស្មៀនបើកយកមកថ្វាយគ្រប់ចំនួន ហើយបើ ចង់ប្រទានរង្វាន់ឲ្យនរណា ឬទិញរបស់ប្រើប្រាស់បន្តិចបន្តួច ទាល់តែសុំបារាំងជាអ្នកចាំត្រួតគ្រានោះ ឲ្យគេយល់ព្រមសិន។ ដល់ឃើញអញ្ចឹង លោកនឹកស្តាយ ចង់ទាមទារយកអំណាចមកវិញខ្លះដែរ ប៉ុន្តែហួសពេលទៅហើយ។

ទស្សនីយភាពក្នុងវាំងដែលផ្លាប់តែរុងរឿងនោះ ក៏ប្រែជាស្រពាប់ស្រពោនគួរឲ្យអនិច្ចា! សភាពគ្រិច ស្មោកគ្រោក រាតត្បាតសព្វទីកន្លែង ដែលកូនចៅម្ចាស់ក្បត្រីរមធីតារស់នៅ។ គេស្មោះទឹកមាត់ ញើសសម្បោរតែពីសតែពាស យកប្រហុកមកទុកដល់ក្រោមបង្ហួចប្រាសាទបាញ់យុំង ជំក្លិនស្អុយស្មើរ ទ្រាំពុំបាន។ ស្រីអ្នកល្អជា គេចេញពីវាំងអស់ទៅហើយអ្នកនៅសល់ទាំងប៉ុន្មាន បើចង់បានមុខងារថ្លៃថ្នូរ នៅក្នុងក្រមរបាំតែមួយគត់របស់ម្ចាស់ក្បត្រីនោះ ទាល់តែចេះតម្រូវខ្លួនរស់នៅតាមរបៀបថ្មី គឺចេះសរសើរ លើកដើងម្ចាស់ក្បត្រី ចេះរៀបចំខ្សៀអាកៀនថ្វាយ ដូចជាថ្វាយហ្លួងបិតាដែរ ឬ ចេះចាក់ស្រា “សិច” បំពេញកែរ។

ម្ចាស់ក្បត្រី អង្គុយលើកន្ទេល ឬ លើគ្រែកណ្តាលវង់ពួកល្ខោន និង អ្នកបំរើក្តងផ្ទះ ឃុនថាន់ ដែលប្រែជារាយប៉ាយគ្មានសណ្តាបធ្នាប់ ហើយនាំគ្នា ស៊ី ផឹក ជក់ លេងបៀរ ឬ ប្រឡែងគ្នារបៀបប្លែកគួរឲ្យសង្សើយ គឺ អង្អែលច្របាច់ដោះ ពួកក្មេងស្រីជទង់។

បើអង្គុយជិតម្ចាស់ក្បត្រី របូតសារុងកុំធ្វើដឹងខ្លួន មិនបាច់ពាក់អាវទេ ដណ្តប់តែជាហ៊ីស្តើងបានហើយ ហើយគិតតែចាក់ស្រាបំពេញកែវថ្វាយទៅ នោះទើបបានគាប់គួរ។ កាលណាគេផឹកស្រាស្រវឹងហើយ គេដួលដេករដូរណែលលើកម្រាល រហូតសារុងស្រាតនៅខ្លួនទទេ។ ប៉ុន្តែ ដូចជាស្រួលម្យ៉ាងដែរ ព្រោះថា ផ្ទះហ្នឹង នរណាចង់ចេញចូលស្មើណាក៏បាន ទ្វារបើកចំហជានិច្ច មកប្រទះឃើញអី ស៊ីហ្នឹងទៅ ហើយពួកល្ខោនក៏ស្អានរវល់ធ្វើអ្វី ក្រៅពីផ្តាប់ផ្តួនចៅហ្វាយថ្មីនេះដែរ។

យ៉ាន និង ខ្ញុំ យើងមិនសូវចូលចិត្តទៅរើមរវាមក្បែរហ្នឹងទេ។ ខ្ញុំបានទាំងនិយាយប្រាប់ពុកសព្វគ្រប់ ពីរឿងរ៉ាវនៅក្នុងវាំងផង ប៉ុន្តែពុកបង្គាប់ថាឲ្យទ្រាំបន្តិចទៅ ក្រែងលោវាបានធូរស្រាលឡើងវិញ ហើយបើយ៉ាងម៉េចៗ គាត់នឹងមកយកខ្ញុំទៅនៅផ្ទះវិញក្តងពេលឆាប់ៗនេះ។

ចាប់តាំងពីពេលដែល ស៊ុន គេបែកពីខ្ញុំទៅបំរើម្ចាស់ក្បត្រី ដើម្បីប្រាថ្នាបុណ្យសក្តិនោះមក មានតែ យ៉ាន គួរជាខ្ញុំទេដែលបានក្លាយមកជាមិត្តដ៏ល្អម្នាក់។ វាជាកូននាយទាហានហ្លួង ប៉ុន្តែកំព្រា ឪពុកម្តាយស្លាប់ចោលតាំងពីតូច គឺធ្លាប់ជាកូនអ្នកមានពូជអំបូរថ្លៃថ្នូរនឹងគេដែរ ម្ល៉ោះហើយវាមិនសុខចិត្តទៅឡកឡំជាមួយ ពួកកូនចៅម្ចាស់ក្បត្រីជាដាច់ខាត។ ធ្វើម្តេចគ្នាក្រ ស្មានទីពឹង ចេះតែទ្រាំនៅក្តងវាំងទៅ។ យ៉ាន ថែមទាំង ចេះសន្សំប្រាក់ខែដប់រៀលនោះ ទុកបានយ៉ាងច្រើនទៀតផង។ ចំណែកខ្ញុំវិញ ប្រាក់ខែប៉ុនគ្នាដែរ ប៉ុន្តែខ្ញុំទុកឲ្យម៉ែតែបន្តិចបន្តួចប៉ុណ្ណោះ សល់ប៉ុន្មាន ខ្ញុំចំណាយទៅលើនំចំណីខ្ទេចទាំងអស់ ស្មានដែលសល់មួយសេនទេ។

តើខ្ញុំរវល់ព្រួយសន្សំទុកដាក់ធ្វើអ្វី? សំពត់ជាហ៊ី និង កំណាត់ស្រាប់បែបយ៉ាង ហ្លួងបញ្ជាឲ្យគេចែកឲ្យយើងច្រើនណាស់ ប្រើមិនអស់ សល់បានទៅដល់ ប៉ុន និង ហ៊ុន ជាបងប្អូនជីដូនមួយខ្ញុំនៅព្រែកថ្មីឯណោះផង។ វាទាំងពីរនាក់ ឧស្សាហ៍មកលេងនឹងខ្ញុំជាញឹកញយក្តងវាំង ហើយជួនកាលខ្ញុំឃាត់វាឲ្យនៅដេកពីរ- បីយប់ក៏មាន។ ខ្ញុំចង់នាំវាទៅដេកឯផ្ទះម្ចាស់ក្បត្រីរមធីតា ឬ ផ្ទះណាមួយក៏បានដែរ ព្រោះស្មានរណា ត្រួតត្រាទេ ចង់ដេកត្រង់ណាក៏ដេកទៅ។

ថ្ងៃមួយ ស្រាប់តែកើតមានហេតុការណ៍ប្លែកគួរឲ្យខ្ញុំមានសង្ឃឹមថា ក្តីស្រមៃដែលថានឹងបានក្លាយខ្លួនទៅជាតួឯករបាំនោះគង់នឹងបានសំរេចជាមិនខាន។ ពេលនោះ ខ្ញុំត្រូវរាំសមជាមួយអ្នកឯទៀត មុនពេលចូលឆ្នាំថ្មី ដែលគេតម្រូវឲ្យយើងទៅចេញរាំនៅសួនច្បារវត្តភ្នំ។ ព្រះអង្គម្ចាស់ ដួង មធុរា កូនប្រុសរបស់ហ្លួង និង ជាបងម្ចាស់ក្បត្រីរមធីតា បាននាំពួកម៉ាកកម្ល៉ោះៗជាច្រើន ដើម្បីមកមើលយើងរ មកមើលយើងរាំសមនេះ។ តាមសម្តីងមើលខ្ញុំយ៉ាងយកចិត្តទុកដាក់តាំងពីដើមដល់ចប់ ហើយហៅខ្ញុំទៅអង្អែលស្មាសរសើរ ព្រមទាំងប្រាប់ទៅម្ចាស់ក្បត្រីប្លួន ឲ្យលើកខ្ញុំធ្វើជាតួ

សំខាន់ឡើង ព្រោះបើតាមលោកមើលទៅឃើញថា ខ្ញុំអាចបំពេញមុខងារនេះបានប្រសើរណាស់។ ម្ចាស់ក្បាត្រើទទួលធ្វើតាមបញ្ជា ហើយបញ្ចេញឫកសួតជាមួយខ្ញុំឬែកសព្វមួយដង។ ប៉ុន្តែឫកពារសួតបូតរបៀបនេះ បែរជាធ្វើឲ្យខ្ញុំខ្លាចទៅវិញ ព្រោះតែកាលណាម្ចាស់ក្បាត្រើយ៍ សើចម្តងៗ ចេញធ្មេញស៊ីស្លាខ្មៅអ៊ូញ ធ្វើឲ្យខ្ញុំខ្លាចរត់គេចខ្លួនបាត់មួយរំពេច។

នៅក្នុងវាំង ម្ចាស់ក្បាត្រីមានឥទ្ធិពលគ្របសង្កត់លើហ្លួងបិតាសម្តើមណាស់។
គេខ្សឹបខ្សៀវគ្នាពីមាត់មួយទៅមាត់មួយថា តាមពួកអ្នកបំរើចាស់ៗធ្លាប់នៅវាំងខាងជើងនិយាយថា សម្តេចឧបរាជ បានលបលាក់ស្រឡាញ់គ្នាជាមួយកូនបង្កើតឯងផង។ គេនិយាយទៀតថា នេះជាក្រឃៅ អាក្រក់តពូជ នៃក្រកូលស្តេចសោយរាជ្យ គឺស្តេចស្រីក្មេងៗ ស្រឡាញ់សាហាយស្មន់ជាមួយ ឪពុកមាឯង, ឪពុកឯង ឬ ជីតាឯង ដូចមានរឿងម្ចាស់ក្បាត្រី ជិប ជាដើម ហើយរឿងវាំរអស់នេះ តែងលេចឮទៅដល់ចំណោមប្រជារាស្ត្រ ដែលកំពុងរស់នៅលំបាកអត់ឃ្លាន ដែលជាហេតុធ្វើឲ្យរាស្ត្រក្តៅក្រហាយក្រៃលែង។

នៅទន្ទឹមគ្នានឹងឥទ្ធិពលដ៏ខ្លាំងក្លា នៃម្ចាស់ក្បាត្រីរំមធីតានេះ លោកមហាមន្ត្រីទទួលបន្ទុកមើលការខុសត្រូវក្នុងវាំងក៏ប្រើអំណាចសង្កត់សង្កិនទៅលើហ្លួងខ្លាំងណាស់ដែរ ព្រោះគាត់ចេះនិយាយបារាំង និង មានការទាក់ទងយ៉ាងស្និទ្ធស្នាលជាមួយពួកអាណាព្យាបាលបារាំង។ គាត់ប្រសប់ប្រើឧបាយកេងយកប្រយោជន៍ពីហ្លួងណាស់ ហើយយកសុទ្ធតែគ្មីគ្មាគាត់ឲ្យទៅនៅជិតហ្លួង។ ហ្លួងមិនសូវយល់ពីគោលបំណង ពិតប្រាកដរបស់លោកមហាមន្ត្រីទេ ម្ល៉ោះហើយលោកចេះតែព្រួយបារម្ភជានិច្ច។ ក្នុងការនិយាយស្តី គាត់មានប្រៀបលើហ្លួងជានិច្ច អាចសុំឲ្យក្រុមគ្រួសារ ឬ បក្សពួកទៅធ្វើការកន្លែងណាក៏បាន។ កិច្ចការគ្រប់ដំពូកនៅក្នុងវាំង ស្ថិតក្នុងកណ្តាប់ដៃគាត់ទាំងអស់ ព្រោះគាត់ជាខ្មែរចេះបារាំង គាត់ចង់ធ្វើអ្វីបានតាមចិត្ត ពុំចាំបាច់ស្តាប់បង្គាប់បញ្ជានរណាទេ ហើយគេក៏ពុំអាចធ្វើការដោយគ្មានគាត់បានដែរ បើសង្ឃឹមទៅលើស្តេច គឺគ្មានសមត្ថភាពអ្វីបន្តិចបន្តួចទាល់តែសោះ។

ក្រោយគេបំផុត គឺនួណាម ដែលឆ្លៀតឱកាសប្រើអំណាចខាងផ្លូវចិត្ត ជិះជាន់លើហ្លួងខ្លាំងណាស់ដែរ គាត់រចនាផ្ទៃវាំងទៅតាមតែចិត្តនឹកឃើញ។ គាត់បានឡើងហាន:ជាម៉ម ហើយក្លាយឈ្មោះជា ម៉មនូ ដ៏ល្បីល្បាញ មានផ្ទះពីរជាន់សង់នៅចុងផ្លូវធំ ក្បែរប្រាសាទភិមានអាកាស។ ម៉មនូ ស្រឡាញ់រាប់អានខ្ញុំ ណាស់ ហៅខ្ញុំសុទ្ធតែកូន ព្រមទាំងឲ្យមាសពេជ្រខ្ញុំពាក់ស្រោចខ្លួន រហូតទាល់តែខ្ញុំភ្លេចម្ចាស់ក្បាត្រីរំមធីតា ឈឺងតែម្តង។

ច្រើនខែកន្លងទៅ...ការដែលគេលែងរីរវល់គិតពីរឿងវិន័យរបៀបរៀបរយ បានធ្វើឲ្យវាំងក្លាយទៅជាទីច្របូកច្របល់រកមើលមិនយល់។ និយាយពី “ម្ចាស់ផែនដី” វិញ គឺបាត់ ខ្លួនតែម្តង កម្រឃើញចេញមកក្រៅណាស់ មួយថ្ងៃៗ សម្ងំផ្តុំឬ សោយអាភៀន នៅតែក្នុងប្រាសាទ មេខលា ជួនកាលនៅរាជមន្ទីរ ជួនកាលនៅប្រាសាទបាញ់យ៉ុង ហើយស្រមោលហ្លួងដែលសុគតទៅនោះ តែងមកលងអារម្មណ៍ហ្លួងជានិច្ច។

អ្នករបាំណាទំនេរ ម្ចាស់ក្បាត្រីតែងហៅទៅឲ្យអង្គុយកំដរលោក សោយស្រា ឬអាភៀន យ៉ាងសប្បាយរីករាយ។ គេទើបនឹងបង្កើតស្រាថ្មីមួយមុខ ល្អជាងស្រាបារាំង ទិញនៅផ្ទះចិនទៅទៀត ។ គេចាក់ស្រាគ្រប់ពណ៌ ត្រប់ម៉ាក លាយគ្នាបន្តិចៗ និង ដាក់ទឹកកកមួយដុំ ហៅថា “ក្រឡៃ” ហើយផឹកដីបមួយភ្លើកម្នាក់ បញ្ជូនបន្តពីមួយទៅមួយ រហូតដល់ត្រប់គ្នាមួយដុំ។ អា “ក្រឡៃ” ហ្នឹង ខ្ញុំក្របតែមួយភ្លើក ក្តៅឆួលបំពង់កស្ទើរប្រកាច់ស្លាប់។

ពេលនោះ មានពួកថ្មីដែលភាគច្រើនសុទ្ធតែស្រីកូនអ្នកស្រែ នាំគ្នាមកនៅក្នុងវាំង ដើម្បីបំពេញកន្លែងទំនេររបស់ពួកដែលចាកចេញឈប់នៅវាំង។ ពួកអស់នេះ រូបអាក្រក់ ដៃជើងគ្រមឹងគ្រមាំង ពិបាកមើលណាស់ ហើយក្រីក្រគ្មានបានរៀនសូត្រផង ខ្លះក៏មកសុំនៅក្នុងវាំងដោយខ្លួនឯង ខ្លះក៏មានគ្រួសារជូនមក ដើម្បីឲ្យបាននៅបំរើអស់អ្នកអស់នាងមានអំណាចនៅក្នុងវាំង។ ពួកនេះ ដៃជើងរឹងធ្វើម្តេចអាចពត់ពេនរាំ ដូចយើងបាន? ម្ល៉ោះហើយ គ្មាមិនចង់រាំរែកទេ គ្រាន់តែសុំបំរើគេយកបាយបរិភោគប៉ុណ្ណោះ។ ខ្លះទៀត ទំនេរឥតការធ្វើ ដើររើរំពេញវាំង រង់ចាំទម្រាំថ្ងៃណាមួយម្ចាស់ក្បាត្រីនាំយកទៅឲ្យបម្រើហ្លួងនឹងគេ ក្រែងបានកម្រៃខ្លះ។

ពួកវាមកនៅក្រោយគេសម្បូរខ្មៅគ្រិចជាងគេ ប៉ុន្តែមានចិត្តលោភលន់ជាងគេ ខំទៅគាល់បំរើយកចិត្តម្ចាស់ក្បាត្រីខ្លាំងណាស់ ដើម្បីឲ្យបានគាប់ក្បែរ។

ម្ល៉ោះហើយ ពួកយើងក្មេងៗត្រូវបាត់បង់អស់រលីងនូវសេចក្តីសប្បាយរីករាយ ដែលយើងធ្លាប់ស្គាល់ ពីមុនមក។ រាល់ថ្ងៃក្រោយពេលឈប់ហាត់រាំ យើងដើរជំនុំគ្នាពីផ្ទះមួយទៅផ្ទះមួយនៅក្នុងថែវ ហើយ មួយថ្ងៃៗ យើងទៅមុជទឹកពីរ-បីដង ដើម្បីឆ្លៀតរកឱកាសឈ្លោះវាយតប់គ្នា។ អារឿងវាយតប់ ខ្ញុំស៊ីដាច់គេទាំងអស់ បណ្តាលឲ្យពួកវានាំរឿងទៅទូលម្ចាស់ក្បាត្រីជាញឹកញាប់ ហើយម្ចាស់ក្បាត្រីក៏តែងគំរាមរកវាយ និង ចាប់ខ្ញុំយកទៅដាក់គុកដែរ។

និយាយពីគុកនោះ ខ្ញុំគ្មានខ្លាចទេ ពីព្រោះខ្ញុំតែងគេចរកកន្លែងស្ងាត់ ទៅដេកជាមួយពួកស្រីមានទោសស្ទើរតែរាល់យប់ ទាល់តែសុំទៅហើយ។ បើរំពាក់ផ្តៅនោះ ទើបគួរឲ្យខ្លាចមែន ប៉ុន្តែខ្ញុំប្រសប់រកពាក្យ ដោះសាររួចខ្លួនជានិច្ច ហើយដើម្បីសងសឹកនឹងម្ចាស់ក្បាត្រី ខ្ញុំលបទៅបើកម៉ាស៊ីនទឹកបង្ហូរចោលរាប់ម៉ោង។

កាលណាយើងចង់សប្បាយភ្លើតភ្លើនមែនទែន យើងប្រមូលគ្នាទៅផ្ទះអាចម៍នៅបង្គន់ឯចុងវាំងខាងលិចឯណោះ។ កន្លែងនោះមានសល់ចន្លោះមួយសម្រាប់ចេញ-ចូល ទៅទ្វារខាងលិច ដែលយូៗទើបគេបើកម្តង ដើម្បីដឹកយកខ្មោច

ចេញទៅក្រៅវាំង។ មានជណ្តើរថ្មសម្រាប់ដើរឡើងទៅកាន់បង្គន់ដ៏ធំក្លិនស្អុយអាសោចម៍ ដែលសង់បន្តើតពីលើដីថ្ពក មួយ ពេញហៀរទៅដោយដង្កូរវិច ដូចជារបងសម្រាប់ការពារមិនឲ្យនរណាមក ត្រេងត្រាងក្បែរវាំងបាន។ យើងពុំ អាចមើលទៅក្រៅឃើញទេ ប៉ុន្តែមានពួកមីច្រឡឹមខ្លះ វាគាស់ក្បឿងដំបូលបង្គន់ ហើយបន្តោងឡើងតាមជញ្ជាំង អើតការហង់មើលទៅក្រៅ។

ពេលយប់ គ្មាននរណាហ៊ានដើរមកកន្លែងនេះដែលឮតែសួរហ៊ីងយ៉ង់ទ្រហឹង និង ងងឹតចាក់ភ្នែកមិនយល់ គួរឲ្យខ្លាច នោះទេ។ នរណាឈឺដុះយប់ព្រលប់ ទយត្រង់ណាក៏ទយទៅឲ្យតែប្រទះ។ ហេតុនេះហើយ បានជាយប់មួយ ខ្ញុំប្រហែសមិន បានមើល ជ្រុលជះទឹកមួយដុំលទៅលើម្ចាស់ក្បត្រី ដែលកំពុងអង្គុយច្រហោង ដោះទាល់នៅក្រោមផ្ទះឃុនថាន់។

ទីវាំង ខ័ណ្ឌដាច់ពីទេសភាពខាងក្រៅដីស្រពាប់ស្រពោន និង អាក្រក់មើលក្រៃលែង ដោយសារអន្លង់មួយ ដែលគេជីក នៅក្រោយវាំង ទិសខាងលិច។ នៅឯជ្រាំងម្ខាងនោះ មានផ្ទះដីតូចមួយ ដែលពួកកម្លោះតណ្ហាក្រាស់ តែងដើរមក លេងកំសាន្តពេលយប់ ទាំងភ័យខ្លាចភ្នែកនៅកញ្ចឹងក ដើម្បីស្រែក ឬ ហួចសុំញ៉ែពួកស្រីវាំង ត្រែងលោបានទទួល សំបុត្រស្នេហា ឬ កន្សែងបញ្ចាំចិត្តពីអ្នកក្តងវាំង ទុកជារបស់អនុស្សាវរីយ៍។ ប៉ុន្តែគួរឲ្យអាស្រូវណាស់ ពួកកម្លោះអស់ហ្នឹង អត់ដឹងថា គ្មានក្រមុំខ្វាកមកចាំស្នេហាជាមួយខ្លួន ហើយបែរជាមានក្មេងច្រឡឹមកំពុងតាមលួចមើលខ្លួនទេ។ កាលណាយើងមើលស្គាល់នរណាម្នាក់ យើងស្រែកហៅ ចំឈ្មោះវា ដេរបញ្ឆោ ព្រមទាំងរើសដុំថ្មគប់ចូលទីកខ្លាតភក់ ប្រឡាក់ពួកនោះស្រមក។ កាលណាស្ងាត់អស់ហើយ មុនត្រឡប់មកវិញ យើងមិនដែលខាននឹងអង្គុយច្រហោងក្តង បន្ទប់បង្គន់មួយម្នាក់ ដែលខ័ណ្ឌគ្នាដោយជញ្ជាំងក្តារ ហើយលបមើល តើអ្នកជិតខាងធ្វើអ្វីខ្លះទេ។

នេះជាល្បែងក្មេងព្រើលដំពូកអស់យើង។ ក្មេងស្រីសព្វថ្ងៃនេះ វាឥតចេះលេងផ្តេសផ្តាសដូចយើងទេ ព្រោះតែពេញ ដំទង់ភ្លាម វាយល់អស់អារឿងកិច្ចការប្តី-ប្រពន្ធ ហើយធ្វើឫកដូចជាមនុស្សក្រមុំអញ្ចឹង។

ពួកក្រុមវាំងចាស់ៗ គាត់មួម៉ៅនឹងអាកប្បកិរិយាច្រឡឹមខុសបទរបស់យើងខ្លាំងណាស់។ ប៉ុន្តែធ្វើម្តេច បើគាត់គ្មាន ពេលចាំត្រួតគ្រាយើងឲ្យបានដិតដល់ ព្រោះមួយថ្ងៃៗគាត់រវល់តែចាំឃ្លាំដំណើរចេញ-ចូលទៅ ក្នុងវាំងនៃ មនុស្សប្លែកៗ ដែលមានការមិនចេះអស់មិនចេះហើយជាមួយហ្លួង។ យើងស្អប់ពួកក្រុមវាំង ហ្នឹងណាស់ ព្រោះគាត់ចេះតែគំរាមគំ ហែងចង់យករឿងយើងទៅទូលម្ចាស់ក្បត្រីឲ្យវាយយើង។ កាលពីប៉ុន្មានឆ្នាំមុន ដោយសារតែរឿងច្រឡឹមរបៀបក្មេង នេះ ទើបស្រីរជាំម្នាក់ឈ្មោះ កែម នៅជំទង់នៅឡើយ ត្រូវរងគ្រោះរហូតជាគប់ជង់ជីវិត គឺវាទៅលួចបេះផ្កាកញ្ចាស់ក្បត្រី ឈ្មោះយ៉ែ ដំឆ្នាស់ឆ្នើម ហើយត្រូវគេចាប់បាន យកទៅវាយនឹងដំបងដែក ធ្វើទារុណកម្មវាទាល់តែស្លាប់។

ប៉ុន្តែយើងចេះប្រើល្បិច ពុំដាយនរណាចាប់បានឡើយ ជួនកាលយើងថែមទាំងរត់ជាន់ពួកក្រុមវាំង ដែលកំពុងដេក លក់ភ្លេចខ្លួននៅលើកាំជណ្តើរទីនាំងដ៏ស្ងាត់ជ្រងំនោះផង។ យើងលួច បេះស្វាយ បេះល្អត បេះផ្លា ឬ លួចដុំកែវ ដុំស្ពាន់ មូលដូចគ្រាប់ឃ្លី ដែលគេដាក់លំអលើចង្កៀងដ៏ល្អទិញមកពីអឺរ៉ុប។ ស៊ុន នឹង ខ្ចំ ពិសោធន៍មើលឃើញថា ដុំគ្រាប់ឃ្លី អស់នេះស្រណុកមួលដោះណាស់ ហើយយើងក៏លួចដោះយកមកប្រមៀលលេងតាមកាំជណ្តើរយ៉ាងសប្បាយ។ ប៉ុន្តែគេពុំ ដែលរកមុខអ្នកធ្វើអំពើខិលខូចនេះឃើញឡើយ។

យប់មួយនោះ វិះតែគេចាប់យើងបាន។ យើងកំពុងតែដើរលបៗឡើងទៅលើវានហាលទីនាំងតុសិត ប៉ុន្តែក្រុមវាំង ឃើញភ្លើងបារីរបស់យើង ក៏លបឡើងមកតាមក្រោយ ដោយកាន់ឈើច្រត់ដងប្រាក់មកជាមួយផង។ យើងងាក ក្រោយឃើញស្រមោលគាត់ ភ្ញាក់ព្រើតក៏គប់កន្ទុយបារីតម្រង់ក្បាលគាត់ ហើយរត់តម្រង់ជណ្តើរ ជាយចុះក្រោមទៅ សម្ងំពួនក្តងគុម្ពផ្កាបាត់ឈឹង។

ក្រោយបន្តិចមក ហ្លួងថ្លឹក់យាងមកទតការសមរជាំ ដែលមាន ម៉មនូវាំងងដែរ។ រោងរជាំពេញចង្អៀត ទៅដោយអ្នករជាំ និង ទស្សនិកជន ដែលភាគច្រើនសុទ្ធតែព្រះរាជវង្សានុវង្សនៅក្នុងវាំង។ ថ្ងៃនេះអ្នករជាំ គាប់ព្រះទ័យហ្លួង ចងផ្តាចម្បាទម្លាក់មកកៀនត្រចៀក ដៃពាក់កម្រងផ្កាម្លិះ តែងខ្លួនហ៊ីហា និង ខំរាំពត់ពេន ល្អលើសសព្វមួយដង។ ទាល់តែ ហ្លួងទ្រាំអត់មិនបាន ដើរកាត់ឆាកល្ខោនទៅអង្អែលថ្ពាល់ដំបូរងង នៃស្នំឯក។ មិនដឹងជាយ៉ាងម៉េច ស្រាប់តែម៉មនូ លូកដៃទាញកន្ត្រោក់សារុងសូត្ររបស់ហ្លួង ព្រមទាំងផ្ទុះសំណើចខ្លាំងៗដូចជាសប្បាយចិត្តណាស់។ សារុងរបូតហួសក្បាល ពោះ ប៉ុន្តែជាសំណាងល្អ ហ្លួងភ្ញាក់ព្រើតស្រវាទប់ទាន់ ហើយស្រែកដោយក្តីឈឺចាប់:

~ ម៉ែនូ, អូយ! ម៉ែនូ! អាណិតអញផង កុំទាញខ្លាំងដៃពោក!
ពេលនោះខ្ញុំឥតត្រូវចេញវាំងទេ ខ្ញុំនៅអង្គុយលាយឡំជាមួយគេឯង ដល់ឃើញរឿងវ៉ាវអញ្ចឹង ខ្ញុំទៅជាខ្លាសលាយភ័យ មិនហ៊ានមើល។ ពួកនាម៉ឺនអង្គុយនៅពីក្រោយខ្ញុំ ងាកមុខចេញក្រៅក្បាល ហើយនិយាយ ជំនុំគ្នាថា :

~ ម៉មនូ ដូចជាជ្រុលបន្តិចហើយ! ទោះបីគាត់ជាស្នំឯក ក៏គាត់ជាកូនរាស្ត្រសាមញ្ញ មិនគួរហ៊ានលេងសើចជាមួយហ្លួង ដល់ថ្នាក់ហ្នឹងសោះ!។

កាលពីដំនាន់ហ្លួងមុន ឲ្យតែនរណាហ៊ានធ្វើផ្តេសផ្តាសកណ្តាលចំណោមអញ្ចឹង ច្បាស់ជាត្រូវទណ្ឌកម្មទ្រមខ្លួនមិនខាន។ ហ្លួងថ្មីនេះ ក៏អៀនខ្មាសខ្លាំងណាស់ដែរ ប៉ុន្តែមិនហ៊ានធ្វើអ្វីគេ ក៏ចេះតែទ្រាំធ្វើមុខក្រាស់ទៅ។ សកម្មភាពផ្តេសផ្តាសរបស់ម៉មនូ កាន់តែធ្វើឲ្យហ្លួងនឿយណាយខ្លាំងឡើង រហូតដល់ក្រោយមកមិនយូរប៉ុន្មាន លោកក៏ឆ្អែតឆ្អន់នឹងគាត់មែនទែនតែម្តង។

លុះមកដល់ខែ អាសាធ នៃ ឆ្នាំនេះ ជារាំងត្រូវធ្វើបុណ្យជាតិគេនៅក្នុងសួនច្បារវត្តភ្នំ ហើយលោកទេសាភិបាល បានមកសុំហ្លួងឲ្យក្រុមល្ខោនទៅរាំក្នុងឱកាសនោះផង។

ពាក្យសុំរបស់ជារាំង ក៏ដូចជាពាក្យបង្គាប់ដែរ ម្ល៉ោះហើយហ្លួងត្រូវតែធ្វើតាមបង្គាប់គេទាំងទើសទាំងទាល់ ប៉ុន្តែមិនឲ្យយកអ្នករបាំល្អៗទៅរាំទេ យកតែពួកមិនដឹងខ្យល់អី ចែកលុយឲ្យពីរ-បី រៀលម្នាក់ ហើយឲ្យចេញទៅរាំទៅ។ ហ្លួងផ្ទាល់ព្រះអង្គ, ក្សត្រា, ក្សត្រី និង អស់អ្នក-អស់នាងទាំងអស់ បានទៅរួបរួម ក្នុងរាត្រីសមោសរនោះ ហើយខ្ញុំក៏តាមទៅនឹងគេដែរ ដើម្បីលួចមើលជារាំងឲ្យឃើញច្បាស់ម្តង ព្រោះខ្ញុំខានដើរទៅលេងឯសង្កាត់ជារាំង តាំងពីយូរណាស់មកហើយ។

ក្នុងរាត្រីដ៏ភ្លឺព្រោងព្រាតដោយពន្លឺភ្លើងចម្រុះពណ៌យ៉ាងនេះ ខ្ញុំមើលមកខ្លួនឯងឃើញដូចជាស្អាត ដូចជាល្អប្លែកសព្វមួយដង។ មនុស្សគ្រប់សញ្ជាតិយ៉ាងច្រើនកុះករ មកប្រមូលផ្តុំគ្នានៅពីមុខរោងរបាំ ដែលតុបតែង លំអរទៅដោយទង់ជាតិ និង ស្លឹកទន្សែ។ ក្បែររោងរបាំ មានសង់វេទិកាឈើមួយទៀត ដែលនៅលើនោះ ពួកស្រីរាំងអង្គុយបត់ជើងក្រៀបគ្រា ដោយម្នាក់ៗសុទ្ធតែមានក្មេងបំរើ កាន់ប្រអប់ស្លា និង កន្ទោរស្ពាន់ នៅពីក្រោយខ្នងផង។

លោកទេសាភិបាល អង្គុយលើកៅអីលាបទឹកមាសខ្ជីមកពីក្នុងរាំង ប៉ុន្តែគាត់អង្គុយទាបជាងហ្លួងបន្តិច។ ឫកពាគាត់ហ៊ីហាថ្លៃថ្នូរមែន ប៉ុន្តែបើមើលមកហ្លួងយើង ដែលពាក់អាវកត្រង់ឡេវមាស ស្លៀកសំពត់ចងក្បិនពណ៌បៃតងនោះវិញ ក៏មិនមែនអន់ណាស់ណាដែរ។

ជារាំងមួយហ្វូង អង្គុយខ្លះ, ឈរខ្លះ, ចាស់ក៏មាន, ក្មេងក៏មាន, ទាបក៏មាន, ខ្ពស់ក៏មាន, សក់វែងក៏មាន, ក្បាលទំពែកក៏មាន។ ពួកប្រុសៗមានឧធំរាងសង្ហា ហើយហាក់ដូចជាយកចិត្តទុកដាក់នឹងមើលរបាំខ្លាំងណាស់។ ចំណែកឯស្រីៗវិញ ពាក់មួកដូចទូលកញ្ជើ ក្រាន់តែកដៃជំជាងកជើងយើងទៅទៀត។ គេជជែកគ្នាអែ ឆ្កាដៃឆ្កាជើង គ្មានរវល់មើលរបាំរាំរែកអ្វីទេ។ ដល់ពេលគេលើកយកភេសជ្ជៈ និង ថាសនំមកជូន ពួកស្រីៗអស់ហ្នឹងផឹកស៊ីកណ្តាលចំណោមគ្មានខ្មាសអៀន ហើយបែបគ្មានបណ្តាក់ពោះផងមើលទៅ។

ពេលនោះ ស្រាប់តែកើតមានចលាចលនៅចំកណ្តាលវេទិកា ធ្វើឲ្យយើងស្រឡាំងកាំងគ្រប់គ្នា។ ស្រីម្នាក់ពាក់អាវបំពង់ខ្មៅវែងហៀរដល់កែងជើង មានឈ្មួលម្នាក់កាន់ស្បែកជើងឈើដើរតាមក្រោយ ដើរកន្លងក្បាល ទាំងស្តេច ទាំងរាស្ត្រ ជាន់ដៃជាន់ជើងនរណាក៏មិនរវល់ គិតតែវែកផ្លូវប្រជ្រៀតឲ្យបានទៅដល់ កៅអីជួរមុខ។ អស់ពីឆ្ងល់ យើងត្រឡប់ជាក្តៅក្រហាយ នាំគ្នាព្រួតបញ្ចោរមីស្រីឃួនផង្គើយ ព្រមទាំងចាប់ច្រានវាចេញផង។ ប៉ុន្តែវាបែរជានិយាយខ្ទើរបៃឡាំៗដេរតបមកយើងវិញ:

~ ពួកឯងរាល់គ្នាអាងអីក៏សង្ឃើមម្ល៉េះ? អាងអំណាចស្តេចហ្នឹងហ្ល៉ុ? ពួកឯងស្គាល់អញជានរណាទេ? អញជាប្រពន្ធលោកទេសាភិបាលណា! ឯងមិនដឹងថាប្តីអញជាម្ចាស់ស្រុកខ្មែរ ត្រួតគ្រាលើក្បាលស្តេចរបស់ឯងទេឬអី?

ស្តី! មីស្រីស្លៀកពាក់មើលតែអ្នកលក់ទឹកត្រីអញ្ចឹង ហ៊ានអួតខ្លួនថាជាប្រពន្ធទេសាភិបាលជារាំងផង។ ពួកយើងជជែកឈ្លោះគ្នាទ្រហឹងអឺងអាប់មិនដាច់មិនស្រេចសោះ។ លោកមហាមន្ត្រី រត់ក្រហេបក្រហបមកឃាត់ទាន់ពេលដែលស្រីមួយហ្វូងជំកំពុងស្ទះព្រៃ ប្រុងចូលមកជួយគ្នាវា។ គាត់ខំឃាត់ឲ្យឈប់ឈ្លោះគ្នា ប៉ុន្តែម្ចាស់ក្សត្រី ជីប នៅតែប្រឹងស្រែកជំទាល:

~ បើមីហ្នឹងវាថា វាជាប្រពន្ធជារាំង ម៉េចវាក៏មិនមកអង្គុយលើកៅអីមាសជិតប្តីវាទៅ?
ក្រោយបន្តិចមក របៀបរៀបរយក៏កើតមានឡើងវិញ ប៉ុន្តែរឿងរ៉ាវមិនទាន់ចប់ត្រឹមណេះទេ។

នៅពេលត្រឡប់មករាំងវិញ ពួកអស់អ្នក-អស់នាងនាំគ្នាដុតដាន់ឲ្យហ្លួងចាប់ស្រីជម្លើយនោះមកធ្វើទោស ព្រោះវានេះពីដើមគ្រាន់តែជាឈ្លបំរើនៅក្នុងរាំងប៉ុណ្ណោះ ប៉ុន្តែដំណើររឿងវាបែរជាមានសភាព ផ្ទុយទៅវិញគឺស្រីនោះចូលមកគាល់ហ្លួង ដោយម្តងនេះស្លៀកពាក់ហ៊ីហាអស្ចារ្យ ដើម្បីសុំឲ្យហ្លួងស្តីបន្ទោសពួកយើង ដែលហ៊ានជេរបញ្ឆោរវា។ ជាសំណាងល្អ ខ្ញុំរួចខ្លួន ព្រោះត្រូវបានគេហៅទៅទទួលទោសជាមួយអ្នកឯទៀតទេ បើសិនជាទៅប្រហែលជាខ្ញុំទទួលទោសធ្ងន់ជាងគេផងក៏មិនដឹង ព្រោះក្នុងពេលមានរឿងខ្ញុំជេរបញ្ឆោរខ្លាំងដែរណាស់។ ហ្លួងអស់សង្ឃឹមទន់ដៃទន់ជើងប្រគល់កិច្ចការទៅឲ្យលោកមហាមន្ត្រីចាត់ចែងជំនួស។ ដើម្បីបំពេញចិត្តស្រី គេចាប់ម្ចាស់ក្សត្រី ជិន្នារង្ស ដែលគ្មានដឹងរឿងអ្វីសោះ យកទៅដាក់គុកលេងទេ ព្រោះគ្នាជាចៅស្តេចអង្គឌួង សាច់ញាតិឆ្ងាយពីគេ ហើយជាពិសេសទៅទៀតគ្នាក៏ព្រា គ្មាននរណាជួយការពារផង។

ខ្ញុំអាយុបាន ១២ ឆ្នាំ ហើយ ប៉ុន្តែចរិតខ្ញុំឃើញហាក់ដូចជាគ្មានប្រែប្រួលប្លែកពីដើមសោះ។ អ្នកឯម ទទួលបន្ទុកខាងត្រួតត្រា ក្រុមចាំយាមបំរើហ្លួង និង បើកប្រាក់ខែឲ្យពួកអស់អ្នក-អស់នាង បានចុះឈ្មោះខ្ញុំទៅក្នុងបញ្ជីក្រុមយាមទីបួន ហើយខ្ញុំក៏ចូលទៅកាន់មុខការថ្មី ចាប់តាំងពីពេលនោះមក។

ពួកស្រីយាមបំរើហ្លួង មានចែកជាបួនក្រុម ដែលត្រូវចូលមកធ្វើការឲ្យបានទៀងទាត់បំផុត។ ពួកធំៗ ក្នុងក្រុមនិមួយៗ ត្រូវចូលទៅគាល់ផ្ទាល់ដល់ក្នុងបន្ទប់ដែលហ្លួងគង់តែម្តង សម្រាប់រៀបចំខ្សៀវអាភៀន បញ្ជូនពាក្យបញ្ជាផ្សេងៗ មកអ្នកបំរើ និង រៀបចំព្រះស្ងោយថ្វាយហ្លួងសោយលើតុតាមរបៀបអឺរ៉ុប ហើយខ្លួនឯង បរិភោគបាយអង្គុយបត់ជើងផ្ទាល់លើកន្ទេលព័ទ្ធជុំវិញតុ ដោយស្រែកច្រៀងបទមហោរីកំដរជាប់រហូតផង។ នរណាជាអ្នករបាំ ពុំបាន

ចោះបង់ការហាត់រាំប្រចាំថ្ងៃរបស់ខ្លួនចោលទេ ម្ល៉ោះហើយមួយថ្ងៃៗ គ្មានរវល់ជាប់រហូត រកពេលដើរកំសាន្តមិនបាន ឲ្យតែទំនេរ ក៏គាំងប្រៈដេកភ្លាម ព្រោះអស់កម្លាំង អត់ងងុយខ្លាំងពេក។ ក្នុងរាជ្យហ្លួងមុន តែនរណាបានមកបំរើហ្លួងហើយ ទុកជាមិនបាច់ទៅហាត់រាំ ក៏គេមិនថាអ្វីដែរ ខុសប្លែកពីឥឡូវឆ្ងាយណាស់។

ប៉ុន្តែ យើងជាពួកក្មេងតូចៗ គេឲ្យនៅខាងក្រៅត្រង់រានហាល ឬ ក្នុងបន្ទប់ណាមួយក្បែរបន្ទប់ហ្លួង សម្រាប់ចាំជួយធ្វើការពួកធំៗ និង អង្គុយទាញខ្សែបក់ផ្លិតព្យារនៅពិតាន ឲ្យរហើយក្នុងកន្លែងហ្លួងគង់។

មុខការទាញខ្សែបក់ផ្លិតតាមប្រហោងជញ្ជាំងអញ្ចឹង វាមិនគាប់ចិត្តខ្ញុំសោះ ទម្រាំតែជុតយាមម្តងៗ ខ្ញុំអជ្ជុកស្ទើររយៈដើមទ្រូង។ ថ្ងៃមួយខ្ញុំយកខ្សែមកចងបន្តឲ្យបានវែងមែនទែន ដើម្បីចេញទៅទិញនំនៅខាងក្រៅ ស្រាប់តែខ្សែនោះដាច់ប៉ឹត ខ្ញុំភ័យស្ទើរលោះព្រលឹង។ ប៉ុន្តែជាសំណាងល្អ ពេលនោះហ្លួងកំពុង ផ្ទំលក់ស្កប់ស្កល់ ពុំបានឃើញកន្ទុយខ្សែរបូតទៅដល់ជិតក្រែទេ។

ពេលមួយនោះ យើងកំពុងអង្គុយជុំគ្នាក្នុងបន្ទប់ទទួលភ្ញៀវ រង់ចាំហ្លួង និង ស្តាប់ព្រះទ័យទាំងឡាយសោយ និង បរិភោគបាយរួច នឹងអាលគេរៀបចំឲ្យយើងបរិភោគម្តង ស្រាប់តែឮសូរសម្លេងហ្លួងស្រែកខ្លាំងៗ ហៅពួកយើងក្មេងតូចៗឲ្យចូលទៅបរិភោគបាយជាមួយពួកគេឯងខាងក្នុង។

គ្រាន់តែឮអញ្ចឹងភ្លាម ពួកម៉ាកខ្ញុំស្ទុះរត់ប្រូចគេចបាត់អស់ ព្រោះពួកវាខ្លាចហ្លួងផង ខ្លាសគេផងមិនហ៊ានចូលទៅស៊ីបាយជិតគេ។ ខ្ញុំក៏រៀបរត់ទៅតាមគេដែរ ប៉ុន្តែហ្លួងចូលមកទាន់ឃើញខ្ញុំតែម្នាក់ឯង ក៏គំហកសួរថា:

~ ពួកហ្នឹងវាទៅណាអស់ទៅ? អញហៅវា វារត់ពួនអញ្ចឹងហ្ល៉ៃ! មីក្មេងច្រឡឹមអស់ហ្នឹង សមតែកាត់កចោល.... ហើយឯងម៉េចមិនរត់ទៅនឹងគេ? ឯងឈ្មោះអី?
~ ក្រាបទូល ខ្ញុំម្ចាស់ឈ្មោះ យ៉ែម (ខ្ញុំស្ទើរតបទាំងភ័យរញ្ជើរញ្ជ័រ) ។
~ យ៉ែម? មីណាក៏ឈ្មោះ យ៉ែម... យ៉ែម ដូចគ្នាទាំងអស់តែម្តង ។ ហ៎! ទៅស៊ីបាយទៅ ចាំអញរកឈ្មោះថ្មីដាក់ឲ្យ។

ខ្ញុំដើរចូលទៅក្នុង ហើយអង្គុយក្បែរ ពួកឃុន ពួកម៉ម ដែលតាមសម្លឹងមើលខ្ញុំដោយញញឹមខ្ជឹប។ ម៉មនូ ចៅហ្វាយខ្ញុំក៏នៅទីនោះដែរ គាត់អង្គុយក្បែរកៅអីហ្លួង។ គាត់និយាយឡើងរបៀបម្ចិកម្ច៉ក់:

~ ខ្ញុំម្ចាស់សប្បាយចិត្តណាស់ ដែលឃើញព្រះអង្គចង់ប្រទានឈ្មោះឲ្យក្មេងនេះ។ ខ្ញុំម្ចាស់ស្រឡាញ់វាណាស់ ព្រោះវាមានចរិតគួរឲ្យចូលចិត្ត។
~ ឈប់ ម៉ែនូ, ចាំអញរកឈ្មោះល្អដាក់ឲ្យវា។

ការបរិភោគបាយបានបន្តទៅទៀត ក្នុងបរិយាកាសសប្បាយរីករាយ។
ខ្ញុំសង្កេតឃើញពួកបោយប្រុស អាចចេញចូលក្នុងបន្ទប់បានដោយសេរី ដើម្បីលើកម្ហូបអាហារបំរើហ្លួង និង ប្រពន្ធហ្លួង ដែលជាការផ្តុយស្រឡះកាលពីរាជ្យមុន។ ពួកបោយនេះ ស្លៀកពាក់សង្ហាអស្ចារ្យ អ្នកខ្លះជាកូននាម៉ឺនធំដុនដាសុខចិត្តមកធ្វើបោយហ្លួង ព្រោះតែចង់នៅជិតអស់អ្នកអស់នាង និង ស្រីបាំ។

នៅពីមុខតុហ្លួង គេក្រាលកន្ទេលធំពីរលើកម្រាលព្រំ ហើយរៀបចំ ចានប្រាក់, ដបស្រាបារ៉ាង និង បង្អែមពោរពាសពីលើនោះ។ ពួកស្រីបំរើតម្រៀបគ្នាជាជួរ លើកថាសមាសដាក់ បាយអង្ករសក្បុស និង ម្ហូបអាហារផ្សេងៗ ពីតំណាក់ពិសេស មកហុចបន្តឲ្យបោយប្រុសយកមករៀបចំថ្វាយហ្លួងលើតុ និង រៀបចំដាក់ឲ្យយើងបរិភោគលើកន្ទេល ហើយថយទៅអង្គុយលុតជង្គង់ពីក្រោយខ្នងយើង ចាំបម្រើហុចនេះ ហុចនោះទៀត។

ខ្ញុំអង្គុយបត់ជើងផ្ទៀងខ្លួនបន្តិចច្រត់ទៅលើដៃឆ្វេងដូចពួកគេធំៗដែរ សល់ទំនេរតែដៃស្តាំមួយ សម្រាប់កាន់ស្លាបព្រា ឬ សម។ យើងអង្គុយចាំតែស៊ី មានឈ្លួលចាំបំរើ ដួសបាយ ហុចទឹក ក្រប់បែបយ៉ាងទាំងអស់។

ស្រីចាស់ទុំអង្គុយផ្អែកខ្នងទល់នឹងជញ្ជាំងជុំវិញបន្ទប់ ចាំយាមបំរើយើង។ ក្នុងបន្ទប់នេះមានមនុស្សអ៊ូអែរ និង អុជភ្លើងភ្លឺព្រោងព្រាតពេញមួយយប់ទល់ភ្លឺ។

ខ្ញុំសង្កេតឃើញក្នុងចំណោមពួកស្រីដែលអង្គុយបរិភោគបាយជុំវិញកន្ទេល មានពួកកូនអ្នកស្រែទើបមកនៅវាំងថ្មីៗ ហើយត្រូវហ្លួងហៅមកឲ្យស៊ីបាយជាមួយគេដែរ ដើម្បីលោកនិយាយបង្ហាប់បន្ថុះឲ្យអស់អ្នកអស់នាង និង អ្នកបំរើបានសើចលេងជាល្បែង។ ខ្ញុំយល់ឃើញថា ស្តេចផែនដីដល់ធ្វើអញ្ចឹងទៅវាដូចជា មិនសូវសមរម្យ ព្រោះវាដូចជាបង្អាប់ស្រីបំរើឲ្យថោកជាងបោយលាងបានទៅទៀត។ នៅក្នុងរាជ្យថ្មីនេះ អ្វីៗក៏ផ្លាស់ប្តូរទាំងអស់ គឺហ្លួងមិនគ្រាន់តែអនុញ្ញាតឲ្យបោយប្រុស ចូលមកក្នុងបន្ទប់ផ្ទាល់ប៉ុណ្ណោះទេ ថែមទាំងបង្គាប់ឲ្យពួកនោះ និយាយរឿងចំអេសចំអាសនៅនឹងមុខយើងស្រីៗ ដើម្បីសើចលេងទៀតផង។

ស្អែកឡើង ម៉មនូ ហៅខ្ញុំទៅលាបម្សៅ, លាបទឹកអប់ដើម្បីទៅគាល់ហ្លួងសុំឈ្មោះថ្មី។ ឃើញ ម៉មនូ នាំខ្ញុំមកហ្លួងញញឹមខ្ជឹបដើបអង្គុយលើក្រែ សំយុងដើងមកជិតយើង ដែលអង្គុយបត់ជើងផ្ទាល់លើកន្ទេល។ លោកដោក្បាលគិតយ៉ាងយូរ ហើយធ្វើមាត់ជីបអូចៗ សូត្រឈ្មោះដែលបានប្រទានឲ្យគ្រូចទៅហើយ៖ ស៊ីម៉ាឡា, ស៊ីម៉ារ៉េត, កេតស៊ីនី, សុផាស៊ី, សុមីរ៉ា

ន, ភិតសុមុន, សុផារ៉េត, រីឡេឡា, បុប្ផាភួង, សុម៉ារិន, ដួងបួង៉ា, សយផា, ណារ៉ាកាន, សុម៉ន់មិត្រ, សយសង្វាន, ម៉ាឡាស៊ី។ នៅទីបញ្ចប់ លោកមានបន្ទូលថា:

~ ឈ្មោះ សុម៉ារ៉េត វាមិនសមទេ, ស៊ីម៉ាឡា ក៍មិនសម... កាលពីដើមមានស្តេចភូមាមួយអង្គមានប្រពន្ធបី ប្រពន្ធទីមួយឈ្មោះ សារ៉ាម៉ានី, ទីពីរឈ្មោះ សុម៉ារ៉េត និង ទីបីឈ្មោះ ស៊ីម៉ាឡា។ ស្តេចស្រឡាញ់ នាង សារ៉ាម៉ានី ណាស់ ព្រោះនាងចេះថ្នាក់ថ្នម ហើយជាពិសេសទៅទៀត នាងមានកូនប្រុសមួយទុក សម្រាប់ស្នងរាជ្យ ដែលជាហេតុធ្វើឲ្យប្រពន្ធចុងទាំងពីរកើតក្តីច្រណែននិន្នា រកឧបាយសម្លាប់ប្រពន្ធដើមចោលទៅ។ ប៉ុន្តែបានគុណបុណ្យនៃអំពើល្អលោកជួយ នាងក៍បានរស់រានមានជីវិតឡើងវិញ ហើយរស់នៅយ៉ាងសុខសាន្តជាមួយស្វាមីរៀងរហូតមក។ អញឲ្យឈ្មោះឯងថា សារ៉ាម៉ានី, ឯងទៅប្រាប់ឯម ឲ្យគេចុះឈ្មោះហ្នឹងដាក់ក្តងសៀវភៅបញ្ជីទៅណា! ហើយនែ៎! អញផ្តាំផ្តាច់ បើអាណាហៅឈ្មោះឯងផ្សេងពីហ្នឹង កុំឆ្លើយឲ្យសោះ។

ម៉មនូ អង្គុយក្រោយខ្នងលួចខ្សឹបប្រាប់ខ្ញុំឲ្យថ្វាយបង្គំហួងបីដង ប៉ុន្តែខ្ញុំថ្វាយបានតែម្តង ក៍ស្រាប់រឹងគាំងឆ្កឹត រកធ្វើតទៅទៀតមិនកើត។ លោកមានបន្ទូលតទៅទៀត:

~ ឯងបានឈ្មោះល្អអញ្ចឹង ខំប់រើអញឲ្យល្អណា កុំធ្វើឆ្កួតដូចពួកមីឯទៀតនោះ អញស្អប់ណាស់។
ម៉មនូ ដឹកដៃខ្ញុំចេញទៅក្រៅវិញ ដែលនៅទីនោះមានពួកម៉ាកខ្ញុំកំពុងឈរង៉ងចាំកុះករ ដោយចិត្តច្រណែនឈ្នានីសថា ឈ្មោះខ្ញុំល្អជាងវា។ មីប៉ុន វាបានឈ្មោះថា កេតស៊ីនីរួចទៅហើយ ប៉ុន្តែដល់ឃើញឈ្មោះខ្ញុំល្អជាង វាក៍ប្រាប់អ្នកឯមថា ខ្ញុំព្រមដូរឈ្មោះជាមួយវា ឲ្យគាត់ចុះបញ្ជីថាឈ្មោះ សារ៉ាម៉ានី នេះជាឈ្មោះវាវិញ។ ខ្ញុំទៅទូលហួងពីរឿងនេះ ហើយហួងក៍ហៅ មីប៉ុន ទៅ ទៅស្តីឲ្យសន្ធឹកសន្ធាប់ ព្រមទាំងហាម មិនឲ្យនរណាដូរឈ្មោះខ្ញុំជាដាច់ខាត។

ចាប់តាំងពីថ្ងៃនោះមក ខ្ញុំត្រូវបានរួចខ្លួនពីមុខការទាញខ្សែបក់ផ្លិត ប៉ុន្តែដោយខ្ញុំពុំចេះរបៀបរៀបចំខ្សៀអាកៀន គេគ្រាន់តែឲ្យខ្ញុំចាំទទួលយកខ្សៀដែលគេ «ធ្វើ» រួចស្រេច ដើម្បីយកទៅថ្វាយហួងសោយតែប៉ុណ្ណោះ។ មុខការនេះស្រណុកពេកណាស់ គ្រាន់តែប្រយ័ត្នប្រយែងបន្តិច ក៍គ្រប់គ្រាន់ណាស់ទៅហើយ ស្អានចាំបាច់រោយខ្នងរោយចង្កេះទេ។ ហួងផ្តំសណ្តែកលើគ្រែដ៏តូចហើយទាប ប្រកបទៅដោយពូកទន់ល្មើយ មានកម្រាលកម្ចី ដែលគេផ្លាស់ប្តូរពណ៌រៀងរាល់ថ្ងៃ ម្តងបែរទៅខាងណោះ ម្តងបែរទៅខាងណោះ ដើម្បី ទទួលខ្សៀអាកៀនពីស្រីពីរ ឬ បួននាក់ អង្គុយអមសង្វាងគ្រែជាអ្នកចាំហុចថ្វាយយកទៅបឺតបង្ហួយ។

ហួងមិនសូវនិយាយស្តីអ្វីទេ ម្តងបែរទៅឆ្វេង ម្តងបែរទៅស្តាំ ដើម្បីហុចខ្សៀដែលសោយរួចហើយ ឬ ទទួលយកខ្សៀថ្មីមកទៀត..... យូរៗម្តង លោកសួរយើងពីចំនួនខ្សៀដែលលោកបានសោយរួចហើយ។ ខ្ញុំមិនដែលចាំថា ហួងសោយប៉ុន្មានខ្សៀទេ ម្ល៉ោះហើយគេក៍យកពែងមាសមកដាក់ពីមុខយើង កាលណាហួងសោយមួយខ្សៀ យើងត្រូវទម្លាក់គ្រាប់ក្រហមមួយទៅក្នុងពែងនោះ។ ទោះបីគេធ្វើយ៉ាងហ្នឹង ក៍យើងនៅតែភ្លេចភ្លាំងជាញឹកញយ ដែលជាហេតុញ៉ាំងឲ្យហួងតវ៉ាថា លោកបានសោយ ច្រើនលើសចំនួន ដែលយើងរាប់ឆ្ងាយណាស់។

ខ្ញុំចាំច្បាស់ថាក្នុងមួយថ្ងៃ យ៉ាងហោចណាស់ក៍ហួងសោយអស់ជាងមួយរយខ្សៀដែរ។ កាលណាហួង សោយស្រវឹងហើយ លោកមិនរវល់រឿងយើងរាប់ខុសឬត្រូវទេ ប៉ុន្តែលោកជេរបញ្ឆោរយើងជាញឹកញាប់ ព្រោះយើងចេះតែលួចបារីលោកចែកគ្នាជក់ និង ឆ្លៀតពេលលោកផ្តំលក់ ជជែកគ្នាខ្សឹបខ្សៀវ ឬ ចាក់ក្រឡេកប្រឡែងគ្នា។

កាលណាហួងសោយអាកៀនអស់កម្លាំង ហើយសម្ងំផ្តំ ម៉មនូ ក៍ឡើងទៅសម្រាន្តលើគ្រែជិតលោក ឱបរឹតគ្នាទៅវិញទៅមក ស្អានគិតខ្មាសអៀនពួកយើងដែលនៅអង្គុយក្រៀបគ្រានេះសោះ។ ពេលនោះយើងនាំគ្នាថយទៅកាន់បន្ទប់មួយស្ថិតនៅជាប់គ្នានឹងបន្ទប់ហួង ហើយវែកមុងប្រះដេកទៅលើពួកនាប ដែលគេរៀបចំទុករួចស្រេចសម្រាប់ឲ្យយើងសំរាក។ យើងប្រះដេកកាលណា ក៍លក់ភ្លាមមួយរំពេច ពីព្រោះយើងពុំដែលគិតខ្វាយខ្វល់ព្រួយបារម្ភពីរឿងអត់ស៊ីមានស៊ីនៅថ្ងៃស្អែកឡើយ។

យប់ខ្លះខ្ញុំភ្ញាក់ដឹងខ្លួនយប់កណ្តាលអាត្រាត្រ ស្រាប់តែឃើញហួងស្លៀកសារុងលែងខ្លួនទទេ ចេញក្បាលពោះទ្រយុកដើរពាសពេញបន្ទប់តែម្នាក់ឯង គតមានដាស់នរណាសោះ។ ជួនកាលលោក ដើរមកជិតមុង ឈរមើលពួកយើងដេកយ៉ាងយូរ ហើយទាញដើងមុងរៀបដាក់ឲ្យស្រួលឡើងវិញ ដើម្បីកុំឲ្យមូសចូលខាំយើង។

កាលណាលោកដើរតម្រង់មកកន្លែងខ្ញុំដេក ខ្ញុំសម្ងំបិទភ្នែកធ្វើហាក់ដូចជាដេកលក់ រង់ចាំទាល់តែលោកចេញទៅផុត ទើបដើបលួចមើលតទៅទៀត។ ហួងដើរយឺតៗកាត់បន្ទប់នានា ចេញទៅឈរលើរានហាល ស្រូបយកជាតុអាកាសត្រជាក់ នៃរាត្រីកាលដែលមានសម្លេង ចង្រិត និង រៃ បន្លឺតតាំងរយៈជាគ្រឿងកំដរសភាពស្ងប់ស្ងាត់។ ហួងរាប់ជំហានដើរទៅដើរមកជារបៀបហាត់ប្រាណ ដោយមិនបាច់ចេញទៅក្រៅវាំង ពីព្រោះគេកម្រនឹងអនុញ្ញាតឲ្យលោកចេញពីវាំងណាស់ ហួងរស់នៅសព្វថ្ងៃ ប្រៀបបាននឹងមនុស្សជាប់គុក យ៉ាងនោះដែរ ។ លោកអត់ចេះខ្លាចខ្មោចទេ ហើយឈរភ្លឺកស្តេចខ្លួន ហាក់ដូចជាគិតទៅវែងឆ្ងាយ។

ហួងចូលចិត្តមើលយើងដេកណាស់ ប្រហែលពីព្រោះទស្សនិយភាព នៃ យុវវ័យតតាំងទុក្ខព្រួយបែបនេះ អាចធ្វើឲ្យលោកទន់ចិត្តអាណិតស្រឡាញ់យើងក៍មិនដឹង ឬមួយក៍លោកមើលប្រយ័ត្នក្រែងនរណាមួយដេក បម្រះបូកសំពត់ ខ្លាចក្រែងអ្នកបំរើប្រុសវាដើរកាត់តាមនេះ មើលឃើញក្តិតក្តាំងក៍មិនដឹង។ ម្តងនោះ ខ្ញុំឃើញហួងយកជើងឆ្អឹះដាស់ស្រីៗ

ដែលដេកថ្ងាចង្រ្គោងយះជើងឥតអាសូរ ហើយសំពត់របូតមកគ្របក្បាលឯណោះវិញ។ លោកស្តីឲ្យពួកនោះសន្ធឹកសន្ធាប់ណាស់ ព្រមទាំងប្រាប់យើងទាំងអស់គ្នាថា ក្រោយៗបើឃើញនរណាដេកប្រហែសអញ្ចឹង ឲ្យកឈើគូសអុជមមិះក្តិតម្តង ទើបវារង។ របៀបប្រដៅបែបនេះ អាចទម្លាប់ឲ្យយើងចេះរស់នៅក្នុងជំនុំចំណោម ក៏ដូចជាទីស្ងាត់កំបាំងពីភ្នែកអ្នកដទៃដែរ គឺយើងចេះដេកសមរម្យ មិនកន្ទិងកន្ទាំងផ្តេសផ្តាស។

ដល់ពេលថ្ងៃសីលម្តងៗ ហ្លួងស្លៀកពាក់ស តមមិនសោយបាយល្ងាច អត់រហូតដល់ព្រឹកស្អែក មួយទៀត។ ដោយអជ្ឈូកមិនដឹងធ្វើអ្វី លោកសោយអាភៀនបង្ហួយជាប់រហូត ភ្នែកសម្លឹងមើលទ្រនិចនាឡិកាជ៉ោល ដោយក្តីអន្ទះអន្ទែងហើយសួរច្រដែលៗតែពីរឿងគេបាញ់កាំភ្លើងព្រឹកព្រហាមហើយឬនៅ? គួរឲ្យធុញទ្រាន់ពេកណាស់!។

ត្រាន់តែមាន់រងាវមិនទាន់ លោកស្រែកដាស់គេដាស់ឯង នរណាមិនភ្ញាក់ក៏ស្រែកដេរឡើឡាទាល់តែភ្ញាក់។ កាលណារឿងរ៉ាវដ៏អភ័ព្វបែបនេះ ត្រូវធ្លាក់មកចំលើវេនខ្ញុំ ខ្ញុំត្រូវដើបសើងមម៉ើងភ្នែកមមីរ ទៅលាបម្សៅ, លាបទឹកអប់ ហើយចូលទៅអង្គុយគាល់ជាមួយមិត្តភក្តិឯទៀត។ មួយប៉ប្រិចភ្នែកសោះ ម្ហូបអាហារក៏រៀបចំរួចស្រេច ហ្លួងចាប់សោយដូចឃ្លានដាច់ដាបណាស់ ហើយចេះតែបង្ខំយើងឲ្យធ្វើដូចលោក ប៉ុន្តែយើងធ្វើតាមមិនកើតសោះ ព្រោះវាងងុយដេកជាងឃ្លាន ម្ល៉ោះហើយអ្នកខ្លះដេកលក់អង្គុយក៏មាន។

ប៉ុន្តែក្រោយពេលបរិភោគហើយ ហ្លួងតែងចែកបារីស៊ីហ្គារជំស្ទើរបៀមមិនជាប់ ឲ្យយើងជក់លេងកំសាន្ត និង រង្វាន់ផ្សេងៗទៀត ដែលជាហេតុធ្វើឲ្យយើងសប្បាយរីករាយ រហូតទាល់តែភ្លេចងងុយដេកអស់រលីង។

នេះជាជីវភាពរបស់ហ្លួង ដែលមានដំណើរប្រព្រឹត្តទៅចាប់តាំងពីពេលថ្ងៃលិចទៅទល់នឹងពេលថ្ងៃរះ។ នៅខាងក្រៅវាំងឯណោះ ស្លូរកាំភ្លើងម៉ោងប្រាំភ្លឺបន្លឺឡើង បណ្តាលឲ្យហ្លួងភ្ញែកដែលកំពុងដេកនៅតាមដើមឈើនានា ក្នុងសង្កាត់កំពង់ផែ ភ្ញាក់ផ្អើលខ្ទៀវខ្ទា ដើម្បីស្វែងរកចំណីអាហារក្នុងថ្ងៃថ្មីមួយទៀត។ កាលណាថ្ងៃក្តៅ ហ្លួងផ្តំសោយអាភៀនតែអជ្ឈូកមួយថ្ងៃវាល់ល្ងាច។ ជាពិសេសក្នុងមួយថ្ងៃ ហ្លួងមុជទឹក ពីរ- បីដង ដោយមានអ្នកបំរើប្រុសជាអ្នករៀបចំថ្នាយហើយលោកលាបទឹកអប់ជារាំង ដែលទិញមកទុកទាំងទូៗ ឡើងក្រអូបឈ្ងុយឈ្ងប់។ ខ្ញុំក៏ឧស្សាហ៍លួចលាបទឹកអប់ហ្នឹងជាញឹកញយដែរ។

មានតែទេសាភិបាលជារាំងទេ ដែលអាចមករំខានការសំរាកពេលថ្ងៃរបស់ហ្លួងមួយដងមួយយាមបាន។ កាលណាគាត់ត្រូវការមកជួបហ្លួងម្តងៗ គេសុទ្ធតែប្រាប់ពួកយើងឲ្យដឹងមុន ហើយនរណាចេះមើលម៉ោង ត្រូវទទួលបញ្ជាថាំដាស់ហ្លួងនៅវេលាម៉ោងបួន ដើម្បីលោកមានពេលមុជទឹក, ស្លៀកពាក់ខោអាវ និង ដកមេអាភៀន ពីរ-បីឌៀសិន។

ការប្រែប្រួលទម្លាប់ប្រចាំថ្ងៃបែបនេះ តែងធ្វើឲ្យយើងច្រឡំម៉ោងពេលជាញឹកញយ ម្ល៉ោះហើយហ្លួងភ្ញាក់ឡើងហួសម៉ោង ក្រទីក្រទាជេរបញ្ចោរបាច់តណាបាំតណាបណ្តើរ ហៅយើងឲ្យទៅជួយស៊កស្រោមជើង, ចងខ្សែស្បែកជើងបណ្តើរ។ រវល់តែឆ្គេមឆ្គួម ក្រុមភ្លេងម៉ានីល (៧) នៅក្នុងសួនច្បារ ចាប់ប្រគុំឡើងជាសញ្ញាឲ្យដឹងថា លោកទេសាភិបាលមកដល់ស្រេចទៅហើយ។ លោកមហាមន្ត្រីចេញមកទទួលភ្ញៀវជាន់ខាងក្រោម ប៉ុន្តែពួកបារាំងដូចជាធុញទ្រាន់ខ្លាំងណាស់ក្រពាត់ដៃដើរចុះដើរឡើងធ្វើមុខក្រញូវ។

នៅជាន់ខាងលើឯណោះ ហ្លួងស្លៀកពាក់ ហើយនៅឲ្យគេយកទឹកអប់មកប្រោះលើខោអាវទៀត។
ឆ្លៀតឱកាសនោះ យើងបានលួចបាញ់ទឹកអប់លាបខ្លួនឯងផងដែរ។ បន្ទាប់មកហ្លួងអង្គុយចុះ ឲ្យយើងយកផ្លិតមកបក់ក្បាល ដើម្បីឲ្យរាប់សួតសក់ ហើយមុននឹងចុះទៅជួបភ្ញៀវ ដែលគេកំពុងតែអង្គុយចាំនោះ លោកឆ្លៀតបឺតអាភៀន ពីរ-បី ហឺតសិន។

នៅទីបំផុតហ្លួងចុះទៅដល់ គោរពគ្នាទៅវិញទៅមកហើយចាប់ចរចាគ្នាដោយមាន លោកមហាមន្ត្រីធ្វើជាអ្នកបកប្រែ។ យើងនាំគ្នាមកពួនពីក្រោយរនាំង ដែលគេដាក់បាំងទ្វារខាងក្រោយ ដើម្បីលួចមើលឆាកសន្ទនានេះតាំងពីដើមដល់ចប់។ ក្រោយពេលភ្ញៀវជារាំងចេញអស់ទៅ តែងមាននាម៉ឺនចូលមកគាល់បន្តបន្ទាប់គ្នា ហើយនៅពេលត្រឡប់មកបន្ទប់វិញ លោកមានទឹកមុខស្រពោនព្រួយជារម្ភអស់មួយយប់ ជួនកាលមានទាំងហៅម្ចាស់ក្បាត្រីកូននោះមកជជែកគ្នាយ៉ាងសម្ងាត់ទៀតផង។

ពេលធម្មតា មានតែប្រជារាស្ត្រមកពីចុងកាត់មាត់ញក ដើម្បីមកសុំទានព្រះរាជទ្រព្យ ឬ មកសុំមើលព្រះភ័ក្ត្រហ្លួងឲ្យបានច្បាស់ម្តងតែប៉ុណ្ណោះ។ ហ្លួងចេញមកឲ្យអ្នកទាំងនោះថ្វាយបង្គំ ហើយប្រទានរង្វាន់បន្តិចបន្តួចឲ្យត្រឡប់ទៅវិញ។ យើងទទួលភារៈកាន់សោទូ ដាក់លុយ និង គ្រឿងអាលង្ការ មួយវេនម្នាក់ ដែលជាភារៈធ្ងន់ធ្ងរគួរឲ្យខ្ពុំភ័យព្រួយលើសអ្វីទាំងអស់ ពីព្រោះហ្លួងឧស្សាហ៍ ដាក់លុយលើតុ, ដាក់ជារឹតួងជើងពាន ឬ ដាក់ទឹកអប់កន្លែងណាមួយ ហើយធ្វើជាភ្លេចចោល ដើម្បីចាប់ផ្តាក់យើងថាលួចរបស់លោកជាញឹកញយ។

(៧) ក្រុមភ្លេងម៉ានីលនេះ គឺជាក្រុមភ្លេងបែបអឺរ៉ុប ដែលមានមកដល់ប្រទេសយើងមុនគេបង្អស់ សម្រាប់ប្រគុំក្នុងពិធីផ្សេងៗ របស់ហ្លួង។ ហេតុដែលនាំឲ្យគេហៅថា ក្រុមភ្លេងម៉ានីល ពីព្រោះសមាជិកក្រុមនេះ សុទ្ធតែជាជនជាតិ ហ្វីលីពីន មកពីក្រុងម៉ានីល។

មុខការខ្ញុំកាន់តែយ៉ាប់ខ្លាំងឡើងៗ ហើយជាពិសេសទៅទៀត ខ្ញុំត្រូវទៅហាត់រាំរាល់ថ្ងៃឥតដែលខកខាន ពីព្រោះអ្នកគ្រូបង្ហាត់ណែនាំដោយ ឲ្យតែខកខានហាត់ ច្បាស់ជាធ្លាក់ខ្លួនឈឺ ចុកពោះដែលមិនទន់ភ្លក់ភ្លាមមួយរំពេច។ រាល់ព្រឹកអ្នកគ្រូច្រៀបជាច់ដៃជើង សម្រួលសាច់ដុំឲ្យខ្ញុំ ដែលជាហេតុធ្វើឲ្យរាងខ្ញុំរឹតតែខ្ទង់ឡើងហើយខ្ញុំក៏មិនសូវឈឺថ្ពាត់ក្តួងការចាំយាមបម្រើហ្លួងនៅវេនទីបួននេះ។ ខ្ញុំបានឡើងឋានៈជាអ្នកគាល់បម្រើ ផ្ទាល់ និង កាន់សោទូព្រះរាជទ្រព្យតែម្តង។ វេននីមួយៗ មានរយៈពេលដប់ពីរម៉ោងជាប់គ្នារហូត ដល់មានក្រុមថ្មីក្តួងចំណោមក្រុមបីផ្សេងទៀតចូលមកទទួលវេន គឺថាក្តួងរយៈពេលពីរយប់ពីរថ្ងៃ, សែសិបប្រាំបីម៉ោង យើងត្រូវចូលវេនដប់ពីរម៉ោង។ ប៉ុន្តែការដែលគួរឲ្យអផ្សុកបំផុត គឺក្តួងមួយអាទិត្យម្តង ខ្ញុំត្រូវដល់វេនបម្រើ ហ្លួងសោយអាភៀន ពេញម្តែបួនម៉ោង។ ខ្ញុំស្រែកសាច់ចុះស្គមស្ងួតណាស់ ដោយសារមិនសូវបានដេកសម្រាកឲ្យពេញភ្នែក ម្ដីងហើយកាលណាគេហៅខ្ញុំទៅ ច្រៀងមហោរី ឬ សក្រវាទីជាមួយអស់អ្នកអស់នាង ដែលគេជ្រើសរើសចម្រាញ់សុទ្ធតែជើងល្អឲ្យចូលក្តួងក្រុមតន្ត្រីនោះ ខ្ញុំក៏មិនដែលប្រកែកម្តងណាឡើយ។

ប៉ុន្តែ ទោះបីខ្ញុំខិតខំធ្វើការនឿយហត់យ៉ាងនេះក្តី ក៏ហ្លួងមិនដែលមើលឃើញ សោតឯម្ចាស់ក្បត្រី ក៏មិនដែលទូលហ្លួងថាម៉េចដែរ ព្រោះតែខ្ញុំមិនចេះអារបៀបលុតក្រាបយកគាប់នៅនឹងមុខដូចគេ។

ចំណែកឯមិត្តភក្តិខ្ញុំវិញ ខ្ញុំសង្កេតឃើញថា គេមានតែជួយជាន់ពន្លិចថែម ដើម្បីយកគាប់គួរសម្រាប់តែខ្លួនគេ។ ឆ្ងាញ់ណាស់ទៅទៀត ថ្ងៃមួយហ្លួងចោទប្រកាន់ថា ខ្ញុំលួចលុយពីររៀល ដែលលោកបានដាក់ក្តួងថាសមាស ទោះបីខ្ញុំប្រកែកមិនដឹងយ៉ាងណា ក៏លោកមិនព្រមស្តាប់។ លុះដល់ខ្ញុំទៅខ្ចីលុយម៉ែបានពីររៀល មកសង លោកទទួលយកភ្លាមថែមទាំងនិយាយថា:

~ ហេងមែន! ចំលើពេលអញកំពុងខ្វះលុយផង! តែប៉ុណ្ណោះម៉េចក៏គ្រាន់នឹងថាយបណ្តើរៗ ទម្រាំដល់ ដាច់ខែដែរ។

ហើយលោកប្រទានលុយឲ្យបោយទៅទិញទឹកកកមកភ្លាមមួយរំពេច។ រំលងមកបានប៉ុន្មានថ្ងៃលោក ហ៊ាននិយាយដោយឥតអៀនខ្មាសថា លុយពីររៀលនេះគ្មាននរណាលួចទេ គឺលោកយកខ្លួនឯង ប៉ុន្តែលោកចង់បំភ័យយើង ដើម្បីទក់មើលទឹកមុខ តើនរណាខ្លះវាខូច ទម្លាប់មានដៃមានជើង។ លុយពីររៀលនេះ ហ្លួងឥតសងខ្ញុំរហូត។ ប៉ុន្តែក្រោយមកមិនយូរប៉ុន្មាន ម៉ែខ្ញុំបានចូលមកសុំគាល់ហ្លួង ដើម្បីសុំព្រះរាជទ្រព្យ ខ្លះយកទៅជួសជុលផ្ទះ ព្រោះសសរពុកអស់ទៅហើយ ហើយជញ្ជាំង ដំបូល ក៏រហែកធ្លុះធ្លាយខ្លាំងណាស់ដែរ។ ក្រោយពីបានស្គាល់ថាជាម្តាយខ្ញុំ ហ្លួងក៏ប្រទានលុយសែសិបរៀលឲ្យម៉ែដោយផ្ទាល់ដៃ។

ឃើញហ្លួងដូចជាសប្បុរសយ៉ាងនេះ ខ្ញុំក៏ប្រថុយទូលសុំច្បាប់ទៅលេងផ្ទះបងប្អូនឯស្រែបានពីរ-បី ថ្ងៃ។ មិនយូរប៉ុន្មានសំបុត្រឡាយធ្លាក់មកមាន ទូក, ដំរី, រទេះ ខ្ញុំជ្រើសរើសយកមួយណាសម្រាប់ធ្វើដំណើរក៏បាន ព្រមទាំងមានក្រុមរាំងជូនដំណើរផង។ ខ្ញុំជ្រើសរើសយកដំរី ហើយនៅវេលាព្រលឹមស្រាងៗ នៃខែបុស្ស ខ្ញុំចេញដំណើរទៅជាមួយពុក និង ម៉ែ ដោយមានក្រុមរាំងចាស់សួតបួតម្នាក់ជូនទៅ។យើងធ្វើដំណើរតាមបណ្តោយស្ទឹងព្រែកស្នោតពេញមួយថ្ងៃ ស្ពោះទៅកំពង់កន្ទួត។

សប្បាយអ្វីម្ល៉េះទេ! ខ្ញុំជ្រងន្ត្រូងឧប្បាកនៅពេលបានចេញមកដកដង្ហើមស្រូបយកខ្យល់អាកាស នៃសេរីភាពនៅខាងក្រៅ។ ពុកសម្លឹងមើលមកខ្ញុំដោយក្រសែភ្នែកស្រទន់ គាត់ហ៊ឺហាក្តួងចិត្តខ្លាំងណាស់ ដែល មានកូនស្រីជាអ្នកបំរើហ្លួងជាអ្នករាល់គ្នាហ្លួង។ យើងអង្គុយលើកន្ទេលដែលក្រាលលើកូបដំរី ឃ្លេងឃ្លោងយោលខ្លួនប្រៀបបាននឹងជិះទូកដោយសារចលនាបោះជំហានទៅមុខមួយៗ នៃពាហនៈជាដំនិះ។ ដុំវិញខ្លួនឃើញតែវាលស្រែតាប់គ្នាឆ្ងាយដាច់កន្ទុយភ្នែក ខ្លះក៏ច្រូតហើយ ខ្លះមិនទាន់ច្រូតនៅឡើយ... ដើមស្នោតដុះ ឯណោះមួយដុំ ឯណោះមួយដុំ ឃើញតែដើមត្រង់ឆ្លីតនឹង ស្លឹកមួយកញ្ចាំនៅពីលើ ហើយនៅឆ្ងាយជាប់នឹងជើងមេឃ ស្រមោលដូរភ្នំខៀវស្រងាត់ជាប់គ្នារដឹក។

យើងមាន ខ្ទប់បាយ និង ម្ហូបគោក ព្រមទាំងបង្អែមផ្លែឈើមកផង ហើយយើងនាំគ្នាបរិភោគយ៉ាងឆ្ងាញ់ក្រៃលែងក្រោមដំនោររហើយ នៃហេមន្តរដូវ។

នៅពេលទៅដល់កំពង់កន្ទួត ផ្តើលតាំងពី មេស្រុក, បាលដ្ឋ, សុភា, រហូតដល់អ្នកស្រុកអ្នកភូមិមកចោមរោមកុះករទទួលខ្ញុំ ហើយសុំឲ្យខ្ញុំរាំឲ្យគេមើលម្តងផង។ អ្នកស្រែខ្មៅក្រញោះ ហៅខ្ញុំសុទ្ធតែម្ចាស់ក្បត្រី ឃើញគ្រឿងអលង្ការដែល ម៉ែមនូ ឲ្យខ្ញុំខ្ចីពាក់មក គេជញ្ជក់មាត់សរសើរគ្រប់គ្នា។ ម្ហាយមីងខ្ញុំឈ្មោះ ម៉ុម ហៅយើងឲ្យទៅសំណាក់នៅផ្ទះគាត់ ដែលសង់នៅនឹងមាត់ស្ទឹង ប៉ុន្តែហ្លួងអ្នកស្រុកដែលទើបនឹងបានដឹងថា មានពួកលោកឃុនមកក្តួងស្រុកខ្លួនអញ្ចឹង ចេះតែលើកគ្នាមកមើលមិនចេះអស់មិនចេះហើយសោះ។

ឆ្នាំរោង ជិតនឹងផុតទៅហើយ គឺហ្លួងថ្មីឡើងគ្រប់គ្រងនគរបានពីរឆ្នាំហើយ។ តាមការគន់គូររបស់តាហោរា និង ជាគូពិធីបុណ្យអភិសេកហ្លួងឡើងសោយរាជ្យ នឹងត្រូវរៀបចំធ្វើនៅ ដើមឆ្នាំមមីខាងមុខនេះ។

ជីវភាពរស់នៅក្តួងរាំងកាន់តែប្រែជាយ៉ាប់ឃឺនឡើងជាងពេលណាទាំងអស់។ ខ្ញុំត្រូវបំពេញមុខការជា ធម្មតាផង និង ត្រូវទៅហាត់រាំរៀងរាល់ថ្ងៃមិនដែលខកខានផង ដើម្បីចេញរាំក្តួងឱកាសបុណ្យដ៏មហោឡារិក នៅពេលខាងមុខនេះ។ យើងទាំងអស់គ្នា កើតមានការព្រួយបារម្ភខ្លាំងណាស់ ពីព្រោះយើងដឹងថា ទេសាភិបាលបារាំងនឹងឡើងមកពីក្រុង

ព្រៃនគរ ដើម្បីមកបំពាក់មកុដរាជ្យជានិមិត្តរូប នៃអំណាចថ្មាយហ្លួង ហើយបើតាមពាក្យចចាមអារាម ដែលគេនិយាយពីមាត់មួយទៅមាត់មួយថា ហ្លួងនឹងត្រូវចេញដំណើរទៅស្រុកបារាំង ឯនាយសមុទ្រឯណោះផង។

ក្នុងរោងជាង និង ថែរនៅទីធ្លាខាងក្រៅ ពួកជាងធ្វើការញាប់ដៃញាប់ជើង សង់ជារោងឈើតាំងលំអដោយក្រដាសលាបពណ៌ ព័ទ្ធជុំវិញទេវាវិនិច្ឆ័យ និង សង់ជាភ្នំកៃលាសក្លែងក្លាយមួយ ដែលហ្លួងត្រូវឡើងឈរលើកំពូលភ្នំនោះ ដើម្បីទទួលទឹកមន្តពីបាគូបុរោហិត។ រាំងទាំងមូលអ៊ូអរទាំងយប់ទាំងថ្ងៃ គឺនាម៉ឺនចេញចូលជំនុំគ្នាមិនដាច់មិនស្រេចសោះ ពីរឿងកាត់ខោអាវស្លៀកឲ្យបានហ្វីហាក្នុងពេលបុណ្យ។ លោកមហាទេព និង លោកមហាមន្ត្រីត្រួតគ្រាមើលជាងធ្វើការទាំងខាងក្នុងទាំងខាងក្រៅទេវាវិនិច្ឆ័យ ក្នុងទេវាទក្សិណ មហាមន្ទីរកន្លែងទទួលព្រះរាជវង្សានុវង្ស និង កន្លែងទទួលអស់អ្នកអស់នាងក្នុងវាំង ឲ្យស្អិតស្អែងភក្តីភាពចំពោះព្រះមហាក្សត្រ... ។

ពិធីបុណ្យអភិសេក រៀបចំធ្វើឡើងពេញ ជ្រាំមួយយប់ ជ្រាំមួយថ្ងៃ ហើយក្នុងរយៈពេលនេះ មានភ្ញៀវ ជារាំង ស្តេច និង ខ្ញុំរាជការ ចេញចូលក្នុងទេវាវិនិច្ឆ័យ ថ្វាយបង្គំច្រើនកុះករ។

ព្រះសង្ឃគ្រប់ចីវរលឿង និមន្តមកសូត្រធម៌គ្រប់ទាំងជ្រាំមួយថ្ងៃ ហើយពួកជាគូបួងសក់ ពាក់អាវផាយជាំក់ឱនមាសដៃកាន់រូបសំណាក ព្រះវិស្ណុ ព្រះសិវៈ ព្រះខានរាជ្យ និង ត្រា ជាសញ្ញានៃអំណាចគ្រប់បែបយ៉ាង ដែលគេប្រគល់មកឲ្យខ្លួនថែរក្សានោះ ក៏រវល់ខ្វែងដៃខ្វែងជើងខ្លាំងណាស់ដែរ។

ហ្លួងដូចជារីកមុខរីកមាត់សប្បាយចិត្តរកអ្វីមកប្រៀបឲ្យស្មើពុំបាន។ លោកភ្លេចអស់តំនិតផ្តេសផ្តាស កាលពីមុនគេបង្គាប់ថាឲ្យលុតក្រាបយ៉ាងម៉េចតាមទំនៀមទម្លាប់ ក៏ចេះតែធ្វើតាមគេទាំងអស់។ លោកស្លៀកពាក់ស្អាតអស្ចារ្យ ដូរពណ៌ស្វាយ លឿង ស ឬ ខ្មៅ ទៅតាមថ្ងៃ ព្រមទាំងទ្រង់គ្រឿងអលង្ការដ៏មានតម្លៃកាត់ថ្លៃមិនបាន។

ប្រជារាស្ត្រនៅក្នុងរាជធានីខ្លះ មកពីខេត្តក្រៅខ្លះ ឈរប្រជ្រៀតគ្នាណែនណាន់តាន់តាប់ ដើម្បីមើលពិធីនេះ។ មិនដឹងជាយល់ឃើញយ៉ាងម៉េច បានជាគេយកពួកល្ងោនមកឲ្យរាំក្នុងទេវាវិនិច្ឆ័យ ដែលពោរពេញទៅដោយនាម៉ឺនគ្រប់ជាន់ថ្នាក់យ៉ាងនេះទៅវិញ។ ខ្ញុំដូចជាចាំថា ក្នុងរាជ្យមុនគេអត់ដែលមានធ្វើអញ្ចឹងទេ ឬមួយគេធ្វើតាមទំនៀមទម្លាប់បុរាណតាំងពីយូរណាស់ហើយក៏មិនដឹង។ នៅខាងក្រៅក្នុងទីធ្លាក្រាលអិដ្ឋនោះ មានសង់រោងសក្ការៈបួន ដាក់ត្រង់ទិសទាំងបួន ហើយមានអ្នករបាំបួននាក់ឈរយាមប្រចាំការ រង់ចាំតែភ្លេងឲ្យសញ្ញាឡើង នឹងអាលធ្វើពិធីបូជាជានិមិត្តរូប។

ក្រុមខ្ញុំមានគ្នាដប់ជ្រាំមួយនាក់ ជាក្រុមសំខាន់ជាងគេ ត្រូវរាំនៅក្នុងទេវាតែម្តង។ ការដែលគេប្រគល់កិត្តិយសយ៉ាងនេះមកឲ្យខ្ញុំ ធ្វើឲ្យខ្ញុំឡើងជំនោរបន្តិចដែរ ប៉ុន្តែបើនិយាយពិតទៅ ខ្ញុំដូចជាខ្មាសខ្លាំងណាស់ ដែលឲ្យមករាំមុខព្រះសង្ឃអញ្ចឹង ពីព្រោះវិន័យសង្ឃហាមផ្តាច់មិនឲ្យមើលរបាំរ៉ាវែកអ្វីទេ។ ប៉ុន្តែធ្វើម៉េច បើកាលៈទេសៈវាតម្រូវអញ្ចឹងទៅហើយ។ យើងមានគ្នា ១៦ នាក់ តម្រៀបជាពីរជួរ, ជួរខាងឆ្វេងជ្រាំបីនាក់ ដើរតួប្រុស, ជួរខាងស្តាំជ្រាំបីនាក់ ដើរតួស្រី។ យើងដើរចូលមកក្នុងឆាក ដែលនៅទីនោះ គេមានតម្រៀបជើងពានដប់ជ្រាំមួយជាពីរជួរទុកប្លុចស្រេច ហើយយើងអង្គុយចុះពីមុខជើងពានមួយម្នាក់រៀងៗខ្លួន។ ភ្លេងចាប់ប្រគុំបទបើកឆាក យើងម្នាក់ៗលូកដៃចាប់ជើងពានរៀងៗខ្លួន ដែលមានដំកល់គ្រឿងបូជាផ្សេងៗដូចជា សាច់ជ្រូក, មាន់ស្ងោរ, ផ្លែឈើ និង ចំណីច្រើនមុខទៀត ហើយយើងដើបឈរឡើងធ្វើកាយវិការបូជាទៅ ក្រប់ទិសទាំងបួន។ រួចាំនេះចប់ទៅ យើងដាក់ជើងពានចុះទៅវិញ ហើយភ្លេងឆាបញ្ចោះក៏ចាប់ប្រគុំឡើង ដោយមានភ្លេងរវៃ បន្ទរតាមក្រោយយ៉ាងញ័រទន្ទ្រើក ជាសញ្ញាប្រាប់ថាដល់ពេលចូលទៅក្នុងឆាកវិញហើយ។ ពេលនោះ ពួកតួប្រុសយកដៃកៀកចង្កេះពួកតួស្រី ហើយបណ្តើរគ្នាមួយគូម្តងៗ ចូលបង្ហួសទៅដល់ក្នុងទីនាំងទក្សិណ។

ពិធីនេះមានធ្វើដដែលៗជ្រាំមួយថ្ងៃជាប់គ្នានៅក្នុងទេវាវិនិច្ឆ័យ ហើយក្រោយពេលចប់រួចាំបួងសួង ខ្ញុំត្រូវចេញទៅរាំរឿងបុរាណឲ្យប្រជារាស្ត្រមើលលេងកំសាន្ត រហូតទល់ភ្លឺទៀតផង។

ទោះបីនឿយហត់យ៉ាងណាក្តី គឺខ្ញុំពុំដែលទម្រន់ភ្នែកដេរដល់ម្តងណាឡើយ ពីព្រោះខ្ញុំដឹងខ្លួនថាបន្តិចទៀតខ្ញុំគង់នឹងបានឡើងធ្វើជាតួឯកមិនខាន ហើយការដែលខ្ញុំអាចបំពេញក្តីប្រាថ្នារបស់ខ្លួនឯងបានយ៉ាងនេះ វាអាចធ្វើឲ្យខ្ញុំភ្លេចការនឿយហត់អស់រលីង ប្រសើរជាងរង្វាន់ដែលហ្លួងផ្តាប់ប្រទានឲ្យនោះទៅទៀត។

ផ្ទុយទៅវិញ មានមិត្តភក្តិតិចណាស់ ដែលមានយោបល់ស្របនឹងខ្ញុំ។ ហ្លួងតែរវល់យកចិត្តទុកដាក់ មើលរបាំរ៉ាវែកទេ លោកជាប់ចិត្តតែនឹងគ្រឿងតុបតែងលំអខ្លួន នៃប្រពន្ធជាទីគាប់ចិត្តទាំងពីរគឺ ម៉មនូ និង ម៉មប្រឹម រហូតដល់យល់ថា ស្នានរបស់អ្វីប្រសើរ និង មានប្រយោជន៍ជាងស្ត្រីទាំងពីរនាក់នេះទេ។ សិល្បៈពិតប្រាកដ ដែលមានលាក់បង្គប់នូវតម្លៃអាថ៌កំបាំងក្នុងចលនាពាក់ពោនទន់ភ្លន់នៃពួកអ្នករបាំ ដែលអាច ញ៉ាំងហ្វូងទស្សនិកជនឲ្យសើច ឲ្យយំ ឲ្យរភើបញាប់ញ័រ ទៅតាមជម្រៅធាតុពិត នៃចលនារបស់ខ្លួននោះ វាពុំអាចធ្វើឲ្យហ្លួងគាប់ចិត្តផងទេ។ ហេតុនេះ ទើបបានជាសព្វថ្ងៃ គេកាត់ដកស្រង់សាច់រឿងពីនេះបន្តិច ពីនោះបន្តិច យកមកបញ្ចូលគ្នាគ្រាន់តែដើម្បីរាំបង្គ្រប់កិច្ចប៉ុណ្ណោះ គេលែងរាំរឿងនីមួយៗហូរហែតាំងពីដើមដល់ចប់ដូចពីមុនទៀតហើយ សូម្បីតែពួកគ្រូកំលែងត្រួតគ្រាមើលឲ្យយើងស្លៀកពាក់ត្រឹមត្រូវ មុនពេលចេញរាំម្តងៗដែរ។

រឿងរ៉ាវដែលអាក្រក់ហួសពីអាក្រក់ទៅទៀតនោះ គឺសព្វថ្ងៃនេះគេពុំអាចរកពួកល្មោនណាម្នាក់ ដែលចេះរាំពិតប្រាកដបានទេ។ ចំណែកឯហ្លួងវិញ កុំសង្ឃឹមថាលោកហ៊ានចំណាយព្រះរាជទ្រព្យដើម្បីរៀបចំក្រុមល្មោនជាថ្មីឡើងវិញឲ្យសោះពីព្រោះ លោកមហាមន្ត្រី ទ្រង់សូរីវង្ស និង កូនចៅឯទៀតដែលជាអ្នកត្រូវបានទទួលកេរ្តិ៍ពីហ្លួង គេយើញហ្លួងចាស់ជរាជិតចូលទីរង្គត់យ៉ាងនេះ គេមិនព្រមឲ្យលោកយកព្រះរាជទ្រព្យទៅចំណាយឥតប្រយោជន៍ទេ ប៉ុន្តែគេឲ្យលោកយកទៅទិញ ផ្ទះសម្បែង ឬ មាសពេជ្រវិញ សម្រាប់កាលណាហ្លួងសុគតទៅគេស្រណុកវាយចំណែកចែកគ្នា។

ចំពោះយើងជាអស់អ្នក-អស់នាងក្នុងវាំង ពេលមានរៀបចំធ្វើបុណ្យដែលគេទាំងអស់គ្នាត្រូវសប្បាយរីករាយយ៉ាងនេះម្តងៗ ផ្តួយទៅវិញវាជាពេលដែលយើងត្រូវធ្វើការនឿយហត់ក្រៃលែង ម្ល៉ោះហើយយើងបន់មួយថ្ងៃដប់ដង ឲ្យតែបុណ្យចង្រៃនោះឆាប់ចប់ស្រឡះទៅ។

យើងត្រូវរាំជ្រាំមួយថ្ងៃជ្រាំមួយយប់ នៅលើឆាកខាងក្រៅកណ្តាលហ្លួងប្រជារាស្ត្រ ដែលឈរមើលប្រជ្រៀតគ្នាកកកុញជុំក្លិនស្អុយញើសជះមួយភាយៗមកដល់យើងស្ទើរទ្រាំពុំបាន ទោះបីយើងខំបាញ់ទឹកអប់លាបខ្លួនឲ្យក្រអូបយ៉ាងណាក៏ដោយ។

មកដល់យប់ទីជ្រាំ ខ្ញុំអស់កម្លាំងទប់ខ្លួនពុំជាប់ ទ្រាំខាំមាត់រាំរឿង ឯណារបុស្សា តទៅទៀតស្ទើរមិនរួច.... នៅពេលដែលស្គរទួងសញ្ញារំរោងនោះ ពិតជាមាន់រងាវ មេឃក្រហមឯកើតស្រេចទៅហើយ។ ខ្ញុំដើរទ្រេតទ្រោតចូលទៅក្នុងវាំងវិញតាមទ្វារព្រលប់ ទាំងក្របកភ្នែកទន់បើកពុំរួច។ ទៅដល់ដំណាក់ម្ចាស់ក្សត្រី ខ្ញុំដេកលក់ឈរបណ្តោយឲ្យគេដោះសម្លៀកបំពាក់ដែលរឹតរួតដងខ្លួនខ្ញុំ មួលខ្ចៅដោះកងដៃកងជើងតាមចិត្ត។ គ្រាន់តែដោះសម្លៀកបំពាក់ហើយភ្លាម ខ្ញុំមិនទាំងរវល់លប់មុខ លាងម្សៅយីហ៊ុនផង ខ្ញុំឡើងទៅដល់បន្ទប់ដេកនៅឯជាន់ទីមួយ នៃអគីតដំណាក់ ឃុនថាន់ហើយប្រះដេកទៅលើគ្រែលក់ភ្លាមមួយរំពេច។

ខ្ញុំភ្ញាក់ពីដេកយឺតហួសពេលខុសធម្មតា ឃើញក្បួនដង្ហែហ្លួងដុំវិញរាជធានីនោះ ប្រុងប្រៀបចេញពីវាំងទៅហើយ។ ស្រីៗណាចង់ទៅតាមក្បួនដង្ហែ គេឲ្យជិះលើរទេះ ប៉ុន្តែខ្ញុំហាក់ដូចជាគ្មានចិត្តគិតចង់ទៅជាមួយគេបន្តិចបន្តួចសោះ ទើបខ្ញុំដើរទៅមុជទឹកសំអាតខ្លួនយឺតៗ គ្មានប្រញាប់រួសរាន់អ្វីឡើយ។ ថ្ងៃនេះ ជាថ្ងៃបញ្ចប់បុណ្យ លែងមានរាំរែកទៀតហើយ អ្នកឯទៀតក៏ចេញទៅក្រៅវាំងទាំងអស់គ្នាដែរ ដូច្នេះខ្ញុំនៅស្ងាត់ម្នាក់ឯង អាចឡើងតាមជណ្តើរទៅដល់កំពូលប្រាសាទបាញ់យុំង ដើម្បីគយគន់មើលទិដ្ឋភាពក្រុងភ្នំពេញ ពីលើទីខ្ពស់មកយ៉ាងសប្បាយរីករាយ។

ទីធ្លាកិត្តិយសលាតសន្ធឹងនៅពីក្រោមខ្ញុំ ពេញចង្អៀតទៅដោយហ្វូងទស្សនិកជនយួន ចិន ជាវាំង និង ស្ត្រីខ្មែរ ដែលគេអាចសម្គាល់យ៉ាងច្បាស់បានដោយសារក្រមាពណ៌ឆើតទទូរលើក្បាល។ នៅក្នុងថែវដុំវិញវាំង នាម៉ឺនធំៗក្នុងរាជធានី និង មកពីគ្រប់ខេត្តឌ័ណ្ឌ បានរៀបចំតុសម្រាប់មណ្ឌលរបស់ខ្លួនម្នាក់ៗ ដោយមាននាំយករបស់មានតម្លៃផ្សេងៗ មកតាំងលំអក្នុងឱកាសបុណ្យអភិសេកហ្លួងនេះផង។

ក្បួនដង្ហែដ៏វែងចេញជុតក្លោងទ្វារ ហើយបត់ទៅខាងក្បួង តាមផ្លូវជាប់នឹងរបងវាំង។ នៅឯម្ខាងកំផែងសីមា ខ្ញុំមើលឃើញស្វែកថ្នំក្រលាបពណ៌មាស និង ក្រែស្តែងដែលមានហ្លួងពាក់មកុដ និង ក្រឿងអលង្ការមានតម្លៃចាំងផ្លេកៗ អង្គុយឆ្លុបពីលើនោះ។ ក្នុងសួនច្បារមាត់ច្រាំងកំពង់ផែ មនុស្សមិនសូវកកកុញពេកទេ ព្រោះគេរវល់តែរត់មកប្រជ្រៀតមើលក្បួនដង្ហែស្តេចសោយរាជ្យនៅមុខវាំងឯណេះ។

ខ្ញុំចុះពីលើដំបូលប្រាសាទបាញ់យុំង មកអង្គុយក្នុងដំណាក់ម្ចាស់ក្សត្រី ដើម្បីរង់ចាំទម្រាំក្បួនដង្ហែត្រឡប់មកដល់វាំងវិញ។ អស់រយៈពេលជាច្រើនម៉ោងក្រោយមក ទើបហ្លួងត្រឡប់ចូលមកវាំងវិញតាមទ្វារខាងជើង ដោយជិះលើដំរី និងដោះមកុដចេញ ពាក់អ្នកមាលាជំនួសវិញ។ លោកយាងចូលរហូតដល់ទេវាវិនិច្ឆ័យ មានទាំងក្បួនហែហមជូនជាប់រហូតមក។

តទ្បាយសម្តេចឧបរាជ បានទទួលអភិសេកជាស្តេចសោយរាជ្យពេញលក្ខណៈហើយ ប៉ុន្តែការផ្លាស់ប្តូរនេះ វាពុំបានធ្វើឲ្យយើងខ្វល់ខ្វាយទេ ពីព្រោះខ្ញុំសង្កេតឃើញថាមុនពេលអភិសេក ឬ ក្រោយពេលអភិសេក ហ្លួងនៅតែហ្លួងដដែល គ្មានឃើញប្លែកអ្វីសោះ។ ហើយគ្រាន់តែពិធីអភិសេកចប់សព្វគ្រប់កាលណា ជីវភាពនៅក្នុងវាំងក៏ចាប់ប្រព្រឹត្តទៅជាធម្មតាដូចកាលមុនដែរ តតឃើញប្រែប្រួលបន្តិចបន្តួចសោះទេ។ ប៉ុន្តែមិនទាន់បានប៉ុន្មានផង ស្រាប់តែដំណឹងថា ហ្លួងត្រូវយាងទៅស្រុកបារាំង ដែលកាលពីមុនស្ថានទណារវល់យកចិត្តទុកដាក់គិតគូរសោះនោះ លេចឡើងជាថ្មីម្តងទៀត បណ្តាលឲ្យយើងភ័ន្តភាំងស្រឡាំងកាំងគ្រប់គ្នា។

យើងពុំយល់ថា ហ្លួងយាងទៅស្រុកបារាំងដើម្បីប្រយោជន៍អ្វីទេ ប្រហែលជាបារាំងចង់នាំហ្លួងយើង ទៅឃុំឃាំងទុកឯស្រុកគេ ដើម្បីគេស្រួលរំលោភយកទឹកដីយើងក៏មិនដឹង? ប្រសិនបើអញ្ចឹងមែន យើងមិនគួរឆ្ពួតទៅតាមហ្លួង ឲ្យជាប់គុកវេទនានៅស្រុកគេ ឆ្ងាយពីម៉ែ-ឪ ពីស្រុកទេសទេ។ ពាក្យចចាមអារាម ចេះតែមានលេចឮពីមាត់មួយទៅមាត់មួយ មានអ្នកក្រៅវាំងជួយថែមថយបន្តិចបន្តួចទៀត ហើយនរណាក៏យ៉ាងគេ ក៏ចេះតែស្រមៃឃើញអារឿងភ័យ នាំយកមកនិយាយបន្លាចឲ្យជ្រួលច្របល់អស់មួយផ្នែវាំង។ គេនិយាយថា បារាំងអត់ឲ្យស៊ីបាយទេ គេបង្ខំឲ្យយើងស៊ីនំប៉័ងដូចគេអញ្ចឹង យើងត្រូវជិះកប៉ាល់កាត់សមុទ្រធំ មើលកោះមើលត្រើយមិនឃើញ ហើយយើងគង់នឹងកើតជម្ងឺពុលរលក ក្អួតចង្អោរស្ទើរដាប់ស្ទើររស់មិនខាន។ នៅលើកប៉ាល់ បារាំងហាមផ្តាច់មិនឲ្យមានមនុស្សឈឺទេ មើលតែនរណា

បែបមិនសូវស្រួល គេចាប់បោះទៅក្នុងសមុទ្រឲ្យស្លាម ក្រពើស៊ីក្លាមមួយរំពេច។ ឮពាក្យសំដីអស់នេះ ខ្ញុំខ្លាចព្រឺសម្បុរគិង្គក់ !។

ម្ចាស់ក្បត្រី រ៉មធីតា ម៉មនូ និង ម៉មប្រឹម ត្រូវទទួលភារៈជ្រើសរើសអ្នករជាំសម្រាប់ដង្ហែហួងទៅស្រុកបារាំង។ ពួកយើងច្រើនគ្នាណាស់បានប្រកែកដាច់អហង្ការពុំព្រមទៅ រហូតដល់អ្នកខ្លះទៀតសុខចិត្ត យកដំនូនបន្តិចបន្តួចមកសូកម៉មនូ និង ម៉មប្រឹម ដើម្បីឲ្យគាត់ដាក់ឈ្មោះខ្លួនថាមានជម្ងឺ ពុំអាចដង្ហែហួងទៅបានទៀតផង។ ពួកអ្នករជាំដើងឆើត និង អស់អ្នកអស់នាងស្អាតៗ សុទ្ធតែប្រកែកពុំព្រមទៅ ផ្តួយទៅវិញ ពួកស្រីចាស់ៗ អ្នកបំរើដ៏មានរូបរាងអាក្រក់ក្តារខ្មាសអៀននោះ បែរជាលើកទ័ពមកសុំចុះឈ្មោះឲ្យបានទៅជាមួយក្មួនខ្លួន។

អ្នកខ្លះ ដែលកាលពីដើមមិនដែលទាំងហ៊ានមកឡេមឡឺមក្បែរទ្វារវាំងផង ឥឡូវស្រាប់តែបានមកហែហមម្ចាស់ក្បត្រីទៅស្រុកបារាំងយ៉ាងក្រអឺត។ ទ្រាំមិនបានហួងលានមាត់ថា :

~ ទេ! ទេ ! កុំឲ្យមីនេះទៅហ្ន៎! រូបរាងអាក្រក់ម្ល៉ឺងៗឲ្យវាដង្ហែអញទៅ អញខ្មាសបារាំងងាប់ហើយ !។

ប៉ុន្តែស្មានមិនស្តាប់សំដីហ្នឹងទេ អ្នកមកចុះឈ្មោះចេះតែមានជាបន្តបន្ទាប់គ្នា រហូតដល់ពេលចេញដំណើរ ហើយនៅពេលកប៉ាល់ចេញដំណើរទៅនោះ ស្រាប់តែឃើញមានអ្នកខ្លះឡើងមកសម្ងំពួនតាំងពីយូរហើយផង។

ចំពោះខ្លួនខ្ញុំ ខ្ញុំដឹងច្បាស់ថាមិនអាចគេចផុតទេ ពីព្រោះខ្ញុំស្មានជន្ទល់ការពារខ្លួនឲ្យបានមាំមួននឹងគេ។ ម្ល៉ោះហើយគេចុចឈ្មោះខ្ញុំ និង ពួកម៉ាកពីរ-បីនាក់ទៀត ឲ្យទៅរាំនៅស្រុកបារាំង មុននរណាទាំងអស់។ ទោះបីម៉ែយំស្រែកមិនព្រមឲ្យខ្ញុំយកឆ្អឹងទៅចោលនៅស្រុកគេយ៉ាងណា ក៏ខ្ញុំនៅតែធ្វើសឿង មិនខ្ជឹឲ្យចាញ់ចិត្តនរណាដែរ គឺខ្ញុំពុំព្រមប្រកែក ពុំព្រមអង្វរម្ចាស់ក្បត្រីអ្វីទាំងអស់។

ប៉ុន្មានអាទិត្យមុនពេលចេញដំណើរ ខ្ញុំត្រូវខំហាត់រាំទាំងព្រឹកទាំងល្ងាច ទុកសម្រាប់រាំនៅស្រុកបារាំង។ គេរៀបចំវាយឡាំងដាក់សម្លៀកបំពាក់ និង គ្រឿងតុបតែងខ្លួនសម្រាប់ឲ្យយើងស្លៀកពាក់រាំនៅស្រុកបារាំង។ ចំណែកខាងម្ចាស់ក្បត្រីវិញ រវល់តែភ័យព្រួយរឿងអត់ស៊ីតាមផ្លូវ និង នៅស្រុកគេ ខំរេចអង្ករ ត្រីដៀត ព្រមទាំងប្រហុកជាច្រើនពាងយកទៅដាក់លើកប៉ាល់ ទុកសម្រាប់បង្ការពេលអាសន្នអន់ក្រ ប៉ុន្តែក្រោយពេលចេញដំណើរទៅបានប៉ុន្មានថ្ងៃ ប្រហុកនោះវាឲ្យក្លិនខ្លាំងពេក ទ្រាំមិនបាន លោកមហាមន្ត្រីក៏បង្គាប់ឲ្យគេលើកទម្លាក់ចោលក្នុងសមុទ្របាត់ទៅ។

ចិន ជាងដេរស្បែកជើងនាំយកស្បែកជើងម៉ូតរបៀបអឺរ៉ុបទាំងកន្ត្រកៗមកប្រគល់ឲ្យយើង ប៉ុន្តែស្បែកជើងហ្នឹង ដេរខ្ជីខ្ជាពេកណាស់ មិនគួរជាទីពេញចិត្តសោះ។

បើយើងស្លៀកពាក់ និង ពាក់ស្បែកជើង ហើយឆ្លុះកញ្ចក់មើលឃើញរូបខ្លួនឯងបែបគួរឲ្យចង់សើចពេកណាស់។ លើសពីអីវ៉ាន់ដែលអ្នករាជការរាំងគេរៀបចំដាក់ក្នុងឡាំងវាយបិទជិតនោះ យើងម្នាក់ៗសុទ្ធតែមានហិបដាក់របស់របរផ្ទាល់ខ្លួន ជញ្ជួនយកមកគរទុករាយប៉ាយពេញក្នុងរាំង។

ព្រឹកមួយនោះ បារាំងរាងសង្ហា បី-បួននាក់ ចូលរហូតមកដល់កន្លែងសមរជាំនៅខាងក្នុង ហើយអង្គុយមើលពួកល្ខោនដែលត្រូវដង្ហែហួងទៅស្រុកបារាំង កំពុងហាត់រៀនយ៉ាងយកចិត្តទុកដាក់។ ស្រីបារាំងម្នាក់ ដែលចូលមកជាមួយពួកប្រុសៗនោះ សម្លឹងមើលខ្ញុំដោយញញឹមខ្ជឹប ពុំដឹងជាគាត់ញញឹមពេញចិត្ត ឬ ញញឹមពេបជ្រាយទេ។ ម្ចាស់ក្បត្រីនិយាយលេងរាក់ទាក់ជាមួយភ្ញៀវទាំងនេះ ដោយមានអ្នកបកប្រែម្នាក់ជាជំនួយ ហើយខ្ញុំសង្កេតឃើញលោកអួតសរសើរប្រាប់បារាំងតែពីរឿង មីសួន កូនចៅលោក អត់មាននិយាយពីរឿងអ្វីផ្សេងទៀតសោះ ចាប់តាំងពីពេលនោះមកមីសួន វាបានចិត្តឡើងចាងរហូត និង រឹតតែខំផ្គាប់ផ្គុនចៅហ្វាយវាលើសដើម។ មីសួននេះ ពីដើមវាធ្លាប់តែដើរយួរស្បែកជើងតាមខ្ញុំប៉ុណ្ណោះ ឥឡូវវាហ៊ានបំបាក់មុខខ្ញុំនៅកណ្តាលដំនុំចំណោមភ្ញៀវឲ្យចុកឈាមណាស់។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ពួកបារាំងពុំមែនភ្លើ រហូតដល់បណ្តោយឲ្យម្ចាស់ក្បត្រី បោកក្បាលគេលេងទទេបានដែរគឺគេនាំគ្នាគយគន់ មើលខ្ញុំយ៉ាងយកចិត្តទុកដាក់ជាទីបំផុត។

ក្នុងសភាពប្រួលច្របល់មុនពេលចេញដំណើរ អស់អ្នកអស់នាងជាច្រើន រត់ខ្វែងដៃខ្វែងជើង រកខ្ចីលួយគេសម្រាប់ចំណាយទិញរបស់កំប៉ិកកំប៉ុកប្រើប្រាស់ផ្ទាល់ខ្លួន។ ពួកចាស់ៗនៅក្នុងរាំងជាសាច់ញាតិនឹងម្ចាស់ក្បត្រី សុខចិត្តឲ្យប្រាក់ពួកនោះខ្ចី ហើយទទួលកាត់ប្រាក់ខែសងវិញ ដោយយកការអារកគ្នាក្រៃលែង។ បើកុំតែខ្ញុំចេះមានគំនិតសុំហួងបានមួយរយរៀល កុំអីខ្ញុំក៏មិនអាចជៀសមិនជំពាក់គេវ័ណ្ឌកបានដែរ។

ព្រឹកពេលចេញដំណើរមកដល់ហើយ! យប់នោះ នៅក្នុងរាំងស្ងាននរណាម្នាក់ដេកលក់ទេ។ យើងជិះរទេះចេញពីរាំងហួរទឹកភ្នែករហាម ខំដកការហង់សម្លឹងរកមើលឪពុក-ម្តាយ សម្លឹងសួនច្បារដែលប្រែជាស្ងាត់ជ្រងំ មើលពួកអ្នករាជការនិង ក្រុមរាំងដែលឈរតម្រៀបគ្នាជារបងអមសង្ហាងផ្លូវ មើលដើមគគីរធំៗ ដែលទម្លាក់មែកសំយាកទៅលើដំបូលរាំង ដោយក្តីស្តាយស្រណោះរកហាមាត់និយាយមិនរួច។ ក្បួនដំណើរលឿនទៅមុខតាមចង្វាក់ជើងសេះ តម្រង់ទៅទិសខាងជើង គឺតម្រង់ទៅសង្កាត់បារាំង ដែលជាកន្លែងកប៉ាល់បោះយុថ្ការង់ចាំយើង។

មនុស្សម្នាមួយហ្វូងធំ ក៏បាននាំគ្នាមកមើលយើងចេញដំណើរនេះដែរ។ បារាំងចោមរោមនិយាយលេងជាមួយហ្គួងនៅលើកប៉ាល់ ហើយម្នាក់នោះមាឌធំដូចយក្ស ភ្នែកខៀវដូចត្រីស្ងោរ ទុកពុកមាត់ស្រមាមត្រូវដង្ហែហ្គួងរហូតដល់ស្រុកបារាំង។ ដោយសារវាអ៊ូអែរខ្លាំងពេក យើងក៏នាំគ្នាសម្លឹងទៅជុំវិញកប៉ាល់ សម្លឹងមើលមកមនុស្សដែលឈរកកកុញនៅលើច្រាំង ក្នុងទ្រូងចង្អៀតចង្អល់រកនិយាយអ្វីមិនចេញ ហូរតែទឹកភ្នែករហាម។

នៅទីបំផុតកកប៉ាល់ក៏លូនចេញពីច្រាំង ចូលទៅដល់កណ្តាលទន្លេ ហ្វូងពួកបារាំងដែលប្រជុំគ្នានៅលើច្រាំងក៏បំបែកអស់រលីង។ ទោះបីកប៉ាល់បើកហួសឆ្ងាយមកហើយក្តី ក៏ខ្ញុំនៅតែចង់ណាំបានកំពូលវាំង កំពូលវត្ត និង ផ្ទះឪពុក-ម្តាយដែលខ្ញុំខំផ្តិតឲ្យជាប់ក្នុងអារម្មណ៍កុំឲ្យភ្លេច រួចបន្តិចក្រោយមកផ្សែងអ័ព្ទនៃទន្លេដែលហូរនាំយើងទៅកាន់សមុទ្រនេះ បាំងមិនឲ្យយើងមើលឃើញអ្វីទាំងអស់។

ចង្អៀតចង្អល់អ្វីម្ល៉េះទេនៅលើកប៉ាល់នេះ ដែលមានមនុស្សជិះដល់ទៅជាងមួយរយនាក់ ព្រមទាំងតវ៉ាន់ដទៃទៀតជាច្រើន! ហ្គួងលែងរវល់គិតគូរពីរឿងពួកយើងទៀតហើយ។ លោកផ្តំក្នុងបន្ទប់ សោយអាហារទ្វើព្រងើយ ជាមួយស្រីពីរនាក់ នៃក្រុមភ្លេងមហោរី។ យើងអង្គុយលើហិបរៀងខ្លួន ជង្រែកគ្នាអែប្រមែ ដើម្បីគ្រាន់នឹងលើកទឹកចិត្តគ្នាទៅវិញទៅមកកុំឲ្យភ័យព្រួយខ្លាំងពេក។ ក្នុងចំណោមអ្នកដំណើរជិះលើកប៉ាល់ដែលត្រូវដង្ហែហ្គួងទៅស្រុកបារាំងនោះ តិចគ្នាណាស់ដែលមានការចាប់បាច់ត្រូវទៅខានមិនបាន ភាគច្រើនសុទ្ធតែមនុស្សអត់ប្រយោជន៍ មិនដឹងជាគេសណ្តោងយោងយកទៅធ្វើអ្វីទេ។

នៅលើកប៉ាល់ មានកូនប្រុសហ្គួងជាច្រើននាក់គឺ អ្នកអង្គម្ចាស់តសូរវង្ស អ្នកអង្គម្ចាស់ សូរីវង្ស ជាទីគាប់ចិត្តហ្គួងជាងគេ និង ប្អូនប្រុសមួយទៀតឈ្មោះ ចិន្តានុវង្ស ដែលគិតតែនិយាយពីរឿងទៅ “លេង” ស្រីបារាំងឲ្យចាស់ដៃម្តងដូចជាស្តេចបងនោះដែរ។ ព្រះសង្ឃប៉ុន្មានអង្គ ដែលសុំដោយសារតាមកប៉ាល់ទៅសិក្សាឯប្រទេសសេរីលង្កា លោកគង់បត់ជើងដាច់ឡែកឆ្ងាយពីពួកយើង ហើយនៅក្បែរនោះពួកក្រុមវាំង និង ពួករាជការវាំងអង្គុយស៊ីស្លាយ៉ាងស្ងៀមស្ងាត់ ភ្នែកសម្លឹងមើលទៅច្រាំងចំការស្រុកលើកដែក និង ស្រុកល្វាឯមដែលរសាត់ហួសទៅជាបន្តបន្ទាប់គ្នា។

ម៉ែអូន ធ្វើឫកបែបម៉ឺងម៉ាត់និយាយថា គាត់នឹងសរសេរកត់ទុកក្នុងសៀវភៅនូវរឿងហេតុទាំងអស់ក្នុងពេលធ្វើដំណើរនេះ ប៉ុន្តែយើងរវល់តែព្រួយបារម្ភគ្រប់គ្នា គ្មាននរណាគិតគូរស្តាប់គាត់ឡើយ សូម្បីតែបាយទឹក ក៏មិននឹកឃ្លានផង។ ម្ល៉ោះហើយ យើងពឹតតែជក់បារីកែអង្ករបង្ហុយផ្សែងទ្រលោមទៅលើចាស់ៗ ដែលអង្គុយធ្វើមាត់ច្រហ។ បន្ទប់មានតិចពេក ពុំអាចឲ្យយើងដេកគ្រប់គ្នាបានឡើយ ម្ល៉ោះហើយយើងត្រូវនាំគ្នាដេកកណ្តាលវាលនោះទៅ ប៉ុន្តែជាសំណាងល្អម្យ៉ាងដែរ យប់នោះគ្មានមូសមួយគ្រាប់សោះ។

បន្ទាប់ពីធ្វើដំណើររបៀបនេះអស់មួយថ្ងៃមួយយប់ ស្លែកព្រឹកឡើងយើងក៏បានចូលមកដល់ទន្លេ ចង្អៀតពេញពាសទៅដោយកប៉ាល់ខ្ពស់ត្រដែតដូចភ្នំ។ មើលទៅច្រាំងឃើញអ៊ូអែរ ខ្ញុំដឹងថាយើងមកដល់ក្រុងធំមួយហើយ លុះខ្ញុំសួរគេទៅទើបដឹងថា នេះជាក្រុងព្រៃនគរដែលអ្នកខ្លះគេហៅថា សៃហ្គង ។ បើតាមមើលទៅ ក្រុងព្រៃនគរហ្នឹងមិនសូវហ៊ឺហាជាងភ្នំពេញប៉ុន្មានទេ។ កប៉ាល់យើងចូលទៅអែបជិតកប៉ាល់មួយទៀតធំអស្ចារ្យ ហើយយើងនាំគ្នារើតវ៉ាន់ទៅដាក់លើកប៉ាល់ធំនោះវិញ។

យើងនាំគ្នាជញ្ជូនអីវ៉ាន់ផ្ទាល់ខ្លួនទៅដាក់ក្នុងបន្ទប់តូចចង្អៀតនៅខាងក្រោយកប៉ាល់ ហើយក្នុងបន្ទប់នីមួយៗយើងត្រូវនៅដល់ទៅប្រាំ ឬប្រាំមួយនាក់ឯណោះ។ ខ្លះប្រតែងប្រគោងឡើងទៅដេកលើត្រែ ដែលគេព្យួរជាប់នឹងជញ្ជាំង ខ្ពស់សឹងតែអើតកមើលមិនដល់ ខ្លះទៀតក្រាលកំណាត់លើឡាំង ឬ ផ្ទាល់នឹងក្តារ ដេកគរជើងលើគ្នា។ ក្នុងបន្ទប់ហ្នឹងគ្មានខ្យល់អាកាសល្អគ្រប់គ្រាន់សម្រាប់ដកដង្ហើមសោះ ជាពិសេសទៅទៀត វ៉ាថែមទាំងធំក្លិនអាក្រក់ចង់ក្អួត។ យើងស្រូតរូតនាំគ្នាចេញមកកន្លែងវាល ដែលនៅទីនេះមានអ្នកជំនួញបារាំងលក់គ្រឿងសំអាង និងស្បែកជើងកែងចោទល្អគួរចាប់ចិត្ត។ ហ្គួងទិញស្បែកជើងនេះ ចែកឲ្យយើងមួយគូៗម្នាក់គ្រប់គ្នា ដល់បានថ្មី យើងដោះស្បែកជើងចាស់ដែលចិនភ្នំពេញដេរយកមកឲ្យទុកមួយកន្លែង ឬក៏ឲ្យទៅយាយចាស់ៗ ដែលខំយកទៅញាត់ទុកក្នុងបង្ហិចគាត់យ៉ាងប្រយ័ត្នប្រយែងក្រៃលែង។

ពីលើកប៉ាល់មកយើងមើលឃើញបារាំង និង យួនឈរប្រជុំគ្នាកុះករលើច្រាំង ដើម្បីមើលស្តេចខ្មែរយាងទៅស្រុកបារាំង។

ខ្ញុំចង្អើតជើងមើលតាមបង្អួច ឃើញវាលស្រែលិចទឹកជាប់គ្នារហូតដល់ជើងភ្នំនៅទិសខាងជើង ស្រដៀងគ្នានឹងវាលស្រែកំពង់លែង ដែលខ្ញុំធ្លាប់បានឃើញកាលពីក្មេងក្នុងពេលពុកដឹកយកអីវ៉ាន់ទៅលក់តាមទន្លេសាបនោះដែរ។ រវល់តែជ្រួលច្របល់រឿងរៀបចំអីវ៉ាន់ ខ្ញុំភ្លេចគិតឈឹង មិនដឹងជាកប៉ាល់ចេញដំណើរពីថ្ងៃម៉ាន ស្រាប់តែមួយភ្លែតក្រោយមក ខ្ញុំមើលទៅក្រោយលែងឃើញអ្វីទាំងអស់ ក្រៅពីរលកទឹកបៃតងពុះស្ពុល និង ផ្ទៃទឹកដ៏ល្អល្អេរ។

ទស្សនីយភាពដ៏ធំល្ហឹងល្ហើយ សម្លឹងមិនយល់កោះត្រើយដែលពីដើមមកយើងធ្លាប់តែឮគេនិយាយក្នុងរឿងព្រេងបុរាណនោះ ឥឡូវយើងបានឃើញច្បាស់នឹងភ្នែកមិនអាចទប់ចិត្តមិនឲ្យរភើបញាប់ញ័របានឡើយ។ យើងឃ្លាតឆ្ងាយពីស្រុកភូមិណាស់ហើយ បណ្តាលឲ្យចិត្តយើងក្រៀមក្រំស្រពោនទឹកថាយើងនឹងត្រូវបារាំងនាំយកទៅនិរទេសចោលនៅស្រុកគេជាមួយហ្គួងជាពិតប្រាកដណាស់។

ផ្តួយទៅវិញ កាលណាយើងបែរភ្នែកមកមើលកន្លែងដេកដ៏ចង្អៀតចង្អល់ ទំហំនាវាដ៏ធំសម្បើមដែលអាចឲ្យយើងដើរលេងទៅមក នឹងដូចឈរលើដី យើងដូចជាមានការកក់ក្តៅច្រើន។

នៅប៉ែកខាងក្រោយកប៉ាល់ មានកំណាត់ជាំងកុំឲ្យត្រូវកំដៅថ្ងៃពួកយើងចង់លេងសើចយ៉ាងម៉េចបានតាមចិត្ត ស្ថានទរណាត្រួតត្រាទេ។ បន្ទប់យើងនៅខាងក្រោមជាប់ៗគ្នា ហើយក្រខ្វក់ដូចធុងសំរាម ពីព្រោះយើងនៅច្រើនគ្នា ពេក ចេះតែចោលនេះចោលនោះផ្តេសផ្តាស គូលីកប៉ាល់បោសជ្រះសំអាតពុំឈ្នះ។ ហ្លួងនៅក្តងបន្ទប់ខាងលើឯណោះ ក្បែរអស់លោកនាម៉ឺនវាំង និង បារាំងមេធំលើកប៉ាល់នេះដោយមានតែប្រពន្ធគាប់ចិត្តប៉ុន្មាននាក់ប៉ុណ្ណោះ នៅចាំគាល់បំរើផ្ទាល់។ យើងជក់បារីជជែកគ្នា លេងបៀ ឬ រាំច្រៀងលេងតាមចិត្ត ហ្លួងមិនដែលរវល់មកមើលសុខទុក្ខពួកយើងដល់ម្តងណាឡើយ។

ម្ចាស់ក្បត្រី ភ័យណាស់ខ្លាចតែយើងដេកស៊ីទំនេរពេកទៅ វានាំឲ្យជាត់ដុសក្បាលពោះអស់រាងរៅ ម្ល៉ោះហើយលោកឧស្សាហ៍បង្គាប់ឲ្យយើងសមរជាំជាញឹកញាប់ ដែលជាហេតុនាំឲ្យពួកបារាំងដែលជិះលើកប៉ាល់ជាមួយគ្នា មកឈរមើលយើងក្រៀបក្រាយ៉ាងសប្បាយរីករាយ។

តើដំណើរនេះត្រូវស៊ីពេលអស់ប៉ុន្មាន? ខ្ញុំអត់ដឹងអីទាំងអស់... ប្រហែលជាមួយខែ ឬ ពីរខែក៏មិនដឹង ? ប៉ុន្តែខ្ញុំជឿជាក់ថា ដំណើរនេះត្រូវប្រើពេលយូរណាស់ ម្ល៉ោះហើយខ្ញុំមិនខ្ជិរល់ រាប់ថ្ងៃរាប់ខែធ្វើអ្វីទៀតទេ។ រាល់ថ្ងៃឃើញតែរឹតែសមុទ្រឥតកោះត្រើយដដែលៗយ៉ាងនេះ ខ្ញុំរង្គេងលែងស្គាល់ទិសតំបន់អ្វីទាំងអស់។ នៅខាងក្រោយឆ្ងាយឯណោះ សត្វស្លាបសហើរតាមរលកកប៉ាល់ ហើយកាលណាមានរលកធំៗសាត់មកដល់ វាទំបណ្តែតខ្លួនលើរលក ប្រៀបបាននឹងកុកឬខ្មែកដែលឈរលើពំនូកឧស្សាច់ដុះកណ្តាលទន្លេក្តងស្រុកយើងយ៉ាងនោះដែរ។

ក្តងចំណោមអ្នកធ្វើការលើកប៉ាល់មានយួនពីរ-បីនាក់ ក្រៅពីនេះសុទ្ធតែបារាំងទាំងអស់ ដែលធ្វើជាគូលីដុះលាងសំអាតទឹកមាត់ស្លាលើក្តារកប៉ាល់រៀងរាល់ព្រឹក។ នៅចុងខាងក្រោយកប៉ាល់ មានបន្ទប់តូចមួយ ធំក្លិនអាសោចអស្ចារ្យ ជាកន្លែងដេករបស់តាកញ្ជាសម្លាក់ ដែលជាអ្នកលកនំ ម្សៅ និង សាប៊ូក្រអូប ប៉ុន្តែរូបរាងគាត់អាក្រក់គគ្រិចស្មោកគ្រោកណាស់ ថែមទាំងថ្លង់ទៀតផង ហាមាត់និយាយម្តងៗ ស្តួយមួយយោជន៍។

កាលណាគាត់ដេកលក់ យើងនាំគ្នាយកជើងជាក់ទ្វារក្តាំងៗ ដើម្បីរំខានកុំឲ្យគាត់ដេកពួនបាន ហើយបើឃើញថាគាត់អត់នៅនឹងកន្លែង យើងលួចយកអីវ៉ាន់កំប៉ិកកំប៉ុករបស់គាត់ទៅបោះចោលលេងជាល្បែង។ ម៉ែថែម អ្នកពូកែលេងសើចច្រើនជាងគេ ខុស្សាហ៍ស្រែកដាក់ត្រចៀកតាដំឡង់ជ្រាំពីរសន្ថានោះថា: “អូ! ស្តួយមាត់តាប៉ិឯណាស់!”, តាហ្គីងសើចញញឹមញញែម ប្រហែលជាគាត់ស្មានថាម៉ែថែម និយាយពាក្យ ស្នេហាជាមួយគាត់ហើយមើលទៅ។

បោយបារាំង ដែលចូលមកបោសជ្រះសំអាតបន្ទប់ និង យកកន្ទោរទឹកមាត់ទៅចាក់រាល់ថ្ងៃនោះ វាទុកពុកមាត់រ៉ុយៗ និង សិតសក់ស្អាតជានិច្ច, វានៅក្មេងរាងសង្ហា ថែមទាំងខំបំរើយកចិត្តយើងខ្លាំងណាស់។ យើងហៅវាថា “អាបារាំងក្បាលពុក” ហើយវានិយាយរដាក់រដុបថាតាមយើង គួរឲ្យចង់សើចក្រៃលែង។ ម្តងនោះ សារិន ពួកម៉ាកខ្ញុំ ឲ្យចិញ្ចៀនវាខ្ចីពាក់លេង ស្រាប់ដល់ពេលដោះមកវិញ វាចង្អៀតជាប់ម្រាមដៃ ទាល់តែដាក់ប្រេងទាញចង់ងាប់ទំរាំរបូត។ ថ្ងៃមួយពួកធំៗប្រជុំគ្នាក្តងបន្ទប់ លេងបៀ ខ្លះអង្គុយលើកន្លែងដេក ខ្លះអង្គុយលើហិប លែងខ្លួនទទេទាំងអស់គ្នា ដណ្តប់តែស្បៃស្តើងមួយប៉ុណ្ណោះ ស្រាប់តែទ្វាររបើកឡើង លេចបោយបារាំងដៃកាន់អំបោសប្រុងដើរចូលមក។ ដល់ឃើញស្រីៗអង្គុយជុំជុំគ្នារបូតសំពត់អាវអញ្ចឹង វាទៅជាស្រឡាំងកាំងធ្វើភ្នែកស្លឹចំហមាត់ធ្លង។

- កូនមីចោរ! (ម៉ែថែមស្រែកបញ្ឆោរវាដោយយកដៃទាំងពីរខ្ទប់ភ្នោះ) ឯងមិនចេះសុជីវធម៌បារាំងទេហ្ន៎ ? មុននឹងចូលឯងម៉េចមិនចេះគោះទ្វារ?
- យីស! (ម៉ែអូន បន្ទរតាមក្រោយ) អាហ្គីងវាឆ្លួតទេ បានជាចូលមកស្ថានធ្វើសញ្ញាឲ្យអាណាដឹងសោះអញ្ចឹង។

ខ្ញុំដេកទ្រាលលើក្រែពីលើក្បាលពួកគេអ្នកលេងបៀ, ខ្ញុំមិនរវល់ខឹងអីទេ ពីព្រោះក្តងវ័យដប់បីឆ្នាំនេះ ខ្ញុំពុំទាន់ចេះអៀនខ្មាសប៉ុន្មានឡើយ។

ពេលយប់ យើងត្រូវប្រយ័ត្នការពារខ្លួនទល់នឹងកូនស្តេចក្មេងៗ ដែលតែងដើរក្រឡឹងជិតកន្លែងយើង ដើម្បីសម្លឹងមើលឲ្យតែឃើញមីណាមួយបេបឲ្យដៃបន្តិច ក៏តាំងចូលដេកជាមួយមីនោះភ្លាម។ យប់មួយនោះ គេឃើញទាន់ម្ចាស់សុផល្លិកា កំពុងប្រគាក់ប្រគងគ្នាជាមួយមីស៊ុន ហើយត្រូវម៉ែអូន ស្រែកឡឡាបណ្តេញចេញទៅវិញទាំងកណ្តាលយប់។

ទីបំផុត យើងក៏បានមកដល់កោះសេរីលង្កា ដែលចាស់ៗធ្លាប់និយាយប្រាប់ថានេះជានគរក្រុងរាពណ៍ ដែលវាធ្លាប់យកនាងសិតាមកលាក់ទុកនៅទីនេះ។ កោះនេះមានភ្នំខ្ពស់ប្រកបទៅដោយទេសភាពស្រស់ឆើតឆាយដូចដែលយើងធ្លាប់ស្រមៃឃើញតាមពាក្យនិទាននៃ រឿងរាមកេរ្តិ៍ យ៉ាងនោះដែរ។

ព្រះសង្ឃនិមន្តចុះត្រង់កំពង់ផែក្រុង កូឡុមបូ។ ហ្លួងនាំយើងឡើងគោកជិះរទេះភ្លើង ដើម្បីទៅមើលព្រះវិហារដែលគេតម្កល់ទុកធ្មេញព្រះពុទ្ធ ហៅថាព្រះចង្កូមកែវ។ ក្រោយពេលត្រឡប់មកពីដើរកំសាន្តយ៉ាងរីករាយនោះវិញ កប៉ាល់យើងក៏បន្តដំណើរឆ្ពោះទៅមុខទៀត ដែលគ្មានឃើញកោះក្រើយដាច់សង្វែង មិនគួរឲ្យសង្ឃឹមថានឹងបានទៅដល់។

រាល់ថ្ងៃយើងនាំគ្នាស៊ីតែត្រីដៀក ត្រីឆ្អើរដែលយើងនាំយកមកជាមួយប៉ុណ្ណោះ ពីព្រោះយើងមិនចូលចិត្តម្ហូបបារាំងសោះ ប៉ុន្តែបើនិយាយឲ្យចំគឺយើងខ្មាសគេមិនហ៊ានទៅរៀបឬកតាមរបៀបបារាំង អង្គុយស៊ីបាយលើតុក្តៅបន្ទប់បាយដ៏ធំទូលាយ កណ្តាលដំនុំចំណោមនេះឯង យើងចេះតែនាំគ្នាគេចឲ្យគេលើកបាយយកមកឲ្យដល់បន្ទប់ដេកតែម្តង។ ខ្ញុំចាំថានៅពេលមកដល់ប្រទេសសូម៉ាលី ដែលកប៉ាល់ត្រូវចូលចតដើម្បីដាក់ឆ្ងាបន្តែមនោះ មានមនុស្សខ្មៅឃ្លឹក ខ្មៅជាងខ្មែរទៅទៀត ហែលទឹកក្រឡឹងជុំវិញកប៉ាល់ ដើម្បីចាំមុជដណ្តើមយកប្រាក់កាក់ដែលយើងទម្លាក់ទៅឲ្យវា។ ហ្លួងបង្គាប់ម្ចាស់ក្សត្រី ឲ្យកលុយទៅទម្លាក់ទឹកឲ្យពួកនោះប្រញាយគ្នាមុជទឹកដណ្តើមដើម្បីបានសើចលេងសប្បាយ។

បន្ទាប់មកទៀតបានប៉ុន្មានថ្ងៃ ខ្យល់ត្រជាក់ចាប់ផ្តើមបក់មកជាលើកដំបូងបំផុត។ នរណាម្នាក់បាននិយាយប្រាប់យើងថា ពីយប់មិញនេះកប៉ាល់យើងបានឆ្លងផុតព្រែកជីកធំ (៨) ចូលមកដល់សមុទ្រទ្វីបអឺរ៉ុបហើយ។ ខ្ញុំស្តាយណាស់ដោយមិនបានឃើញព្រែកជីកនោះ ប៉ុន្តែបើតាមស្តាប់គេនិយាយវាមិនមែនចម្លែក ឬ ធំជាងព្រែកពាមជ្ពង (៩) ប៉ុន្មានទេ វាប្លែកតែត្រង់ព្រែកនេះ ជីកកាត់វាលខ្សាច់ប៉ុណ្ណោះ។

យើងរងាខ្លាំងណាស់....ផ្ទៃសមុទ្រប្រែជាមានរលកធំៗ ហើយសត្វស្លាបសម្បុរស នៅតែហើរតាមក្រោយកប៉ាល់យើងពីចម្ងាយជានិច្ច។ តើសត្វនេះវាហើរតាមយើងតាំងពីព្រៃនគរមកឬ? ខ្ញុំមិនជឿថាអញ្ចឹងទេ ពីព្រោះវាអាចហើរយ៉ាងច្រើនណាស់បានពីរ-បីថ្ងៃ ក៏អស់កម្លាំងទៅហើយ ដូច្នេះអានេះវាជាសត្វផ្សេងទៀតទេ។

ពេលនោះ ថៅបកឈ្មោះព្រុំ ចង្អុលប្រាប់ឲ្យយើងមើលស្រមោលអ្វីមួយនៅឆ្ងាយស្តុងៗឯណោះ ហើយគាត់និយាយថានេះជាភ្នំភ្លើង, ស្រុកណាដែលមានភ្នំព្រួសភ្លើងអញ្ចឹង ជាតុអាកាសត្រជាក់អាក្រក់ណាស់។ ខ្ញុំមិនដែលស្គាល់ភ្នំភ្លើងយ៉ាងម៉េចទេ ម្ល៉ោះហើយគេនិយាយថាម៉េចក៏ចេះតែជឿទៅ។

នៅទីបំផុតសម្រែកថា: "ស្រុកបារាំង, ស្រុកម៉ារីសី" រសាត់មកប៉ះនឹងត្រចៀកយើង ជាសញ្ញាប្រាប់ឲ្យដឹងថាដំណើរយើងចប់ហើយ។ ទុក្ខវេទនារបស់យើងក៏នឹងត្រូវបញ្ចប់ក្តងពេលជាមួយគ្នានេះដែរ។ ខ្ញុំមើលទៅខាងដីគោក ឃើញភ្នំស្រុកបារាំងសស្គុស ឃើញផ្ទះពណ៌ប្រផេះ មានផ្សែងហុយចេញតាមដំបូល ឃើញដងក្តោងកប៉ាល់ច្រូងច្រាង ឃើញថ្មគេចាក់លយចូលជ្រៅមកក្តងសមុទ្រ ហើយនៅពីក្រោយនោះ កប៉ាល់ចតតម្រៀបគ្នា មានខ្លះធំជាងកប៉ាល់ដែលខ្ញុំជិះនេះទៅទៀត។ បន្ទាប់មក នៅលើដីទួលមួយនោះ មានរូបចម្លាក់លាបទឹកមាសធំអស្ចារ្យ។ ទស្សនីយភាពនេះប្រៀបបានទៅនឹងនគរយក្ស ដែលយើងធ្លាប់ ស្រមៃឃើញក្តងរឿងព្រេងនិទាន ហើយដែលយើងពុំធ្លាប់សង្ឃឹមថានឹងបានស្គាល់សោះ។ ពាក្យដែលចាស់ៗនិយាយទាំងប៉ុន្មាន គឺជាពាក្យភូតភរទាំងស្រុង ពីព្រោះសមុទ្រទោះបីធំយ៉ាងណាក៏មនុស្សនៅតែអាចឆ្លងកាត់បាន ហើយនៅឆ្ងាយពីប្រទេសយើង មានទ្វីបមួយទៀតដែលលាតសន្ធឹងធំល្វឹងល្វើយក្រោមផ្ទៃមេឃដ៏ត្រជាក់។

ក្រាន់តែកប៉ាល់អែបចូលតម្រង់ផែ ទាំងគេទាំងយើងរវល់តែដាកមករៀបចំអីវ៉ាន់ ម្ល៉ោះហើយគ្មាននរណាបានគយគន់មើលទិដ្ឋភាពមាត់ច្រាំងនៅពេលកប៉ាល់ចូលចតទេ។ ពួកយើងស្លៀកពាក់សំពត់អាវក្រាស់ ពាក់ស្រោមដៃនិងមានជាហ៊ីរ៉ុកទៀតផង ប៉ុន្តែខ្ញុំដូចជារកនឹកហ៊ីហាមិនឃើញសោះ ពីព្រោះសម្លឹងមើលមកគ្នាឯង ឃើញសុទ្ធតែខ្មៅក្រញ្ជេះ។

ប្រសិនបើហ្លួងនាំយកមកជាមួយតែពួកក្មេងស្អាតៗ ម្ល៉ោះយើងមិនសូវខ្លាចគេពេបជ្រាយប៉ុន្មានទេ ប៉ុន្តែអ្នកដង្ហែមក សុទ្ធតែចាស់ទ្រុឌទ្រោមក្រហម ស៊ីស្លាក្រហមប្រកាកពេញមាត់ ជាហេតុធ្វើឲ្យយើងខ្មាសគេ ងើបមុខមិនរួច ហើយប្រហែលជាបារាំងគេស្មានថា ស្តើខ្មែរសុទ្ធតែគ្រិចទាំងអស់អញ្ចឹងផងក៏មិនដឹង។

ហ្លួងយាងចុះទៅកណ្តាលចំណោមបារាំងមួយហ្វូងធំ ដោយមាននាម៉ឺនវាំងហែហមពីក្រោយជាប់ រួចហើយយាងទៅជាត់ជាមួយពួកទាហានបារាំងដែលស្លៀកពាក់ហ៊ីហាជិះសេះ ទុកយើងចោលលើកប៉ាល់ជាមួយម្ចាស់ក្សត្រី បណ្តោយឲ្យពួកគូលីកប៉ាល់មករើជញ្ជូនអីវ៉ាន់យើងតាមចិត្ត។

យើងដូចជាមិនសូវទុកចិត្តសោះ! មេឃស្រទុំជាប់ ហើយខ្យល់ត្រជាក់បក់បោកមកឥតឈប់ឈរ បណ្តាលឲ្យយើងរងាចង់រឹងផ្តាម... លុះដល់ពេលល្ងាចគេមកហៅឲ្យយើងចុះពីកប៉ាល់ទៅ។ ពួកក្រុមវាំង និង ស្មៀនហ្លួងស្លៀកពាក់ខោអាវក្រាស់ ពាក់មួកហ្វឺត្រ មើលទៅវាគ្មានឃើញហ៊ីហាត្រង់ណាឡើយ ប៉ុន្តែពួកយើងក៏មិនមែនហ៊ីហាជាងពួកគាត់ប៉ុន្មានដែរ, យើងប្រជ្រៀតដណ្តើមគ្នាដើរកណ្តាលពពាក់ពពូនដូចហ្វូងគោ តម្រង់ទៅរកផ្ទះសេះធំៗដែលចតចាំយើង។ ម្ចាស់ក្សត្រីបង្គាប់ឲ្យគេ លើកកៅអីផ្តៅ ជារអង្គរ ត្រីដៀត និង អីវ៉ាន់ទាំងអស់ដាក់លើដំបូលរទេះ រួចទើបយើងឡើងជិះចេញទៅ ប៉ុន្តែផ្លូវសុទ្ធតែក្រាលថ្មរដិបរដុប រលាក់ស្ទើរក្រឡកផ្តើមប្រមាត់។

(៨) ព្រែកជីក សុយអេស៍។
(៩) ព្រែកពាមជ្ពង ពីដើមស្ថិតនៅមុខចំណតអយស្តុយយានក្រុងភ្នំពេញ ប៉ុន្តែសព្វថ្ងៃនេះ គេចាក់ដីលុបបំពេញបាត់ទៅហើយ។

ជារាំងឈរប្រជុំគ្នាដង្ហែតាមមាត់ផ្លូវ និយាយឡូឡាហៅចំឈ្មោះហួងយើងតែម្តង ហើយមានអ្នកខ្លះថែមទាំងបោះជារឿយើងជក់ទៀតផង។ នៅស្រុកនេះស្រណុកមើលងឹងអ្នកមាន អ្នកក្រណាស់ គឺអ្នកមាន គេពាក់អាវកខុបចង្កេះវាត់ អ្នកក្រអត់មានសម្លៀកបំពាក់អញ្ចឹងទេ ប៉ុន្តែទាំងអ្នកមានទាំងអ្នកក្រ សុទ្ធតែពាក់មួក ពាក់ស្បែកជើងឡូបដូចគ្នាទាំងអស់។ យើងមើលមកខ្លួនឯងឃើញដូចជាតូចហេងហាង គ្មានបង្គោលទីពឹងមាំមួន បណ្តោយវាសនាឲ្យសាត់អណ្តែតទៅតាមជើងសេះ ដែលកំពុងបោះជំហានទៅមុខ ពុំដឹងជាចង់នាំយើងទៅកាន់ទីណាឡើយ។

ការដែលហួងបោះបង់យើងចោលយ៉ាងនេះ ធ្វើឲ្យយើងនឹកមួម៉ៅខ្លាំងណាស់។ ចំណែកឯម្ចាស់ក្បត្រីវិញ លោកវីតតែព្រួយបារម្ភនឹងរឿងយើងជាងខ្លួនយើងទៅទៀត ហើយលោកមិនសប្បាយចិត្តសោះ ចំពោះការដែលជារាំងមិនសូវរាក់ទាក់ទទួលបណ្តោយឲ្យយើងជិះរទេះជាមួយអ៊ីវ៉ាន់អញ្ចឹង។

ពេលមកឃើញបន្ទប់ដែលគេឲ្យយើងដេកនោះ យើងវីតតែហួសចិត្តណាស់ទៅទៀតពីព្រោះគេមិនឲ្យ យើងនៅជិតហួងទេ ហើយមិនដឹងជាបានទាហានខ្មែរពីណា យកមកដាក់ឲ្យចាំយាមឃ្លាំមើលយើងដូចមនុស្សជាប់គុក។

ក្នុងបន្ទប់នេះខ្វះសព្វខ្វះគ្រប់... ម្ចាស់ក្បត្រីបានផ្តុំក្នុងបន្ទប់មួយមានក្រែក្រាំ ចំណែកពួកល្មោនវិញ នាំគ្នាក្រាលពួកដេកលើកំរាលក្តារស្រល ដែលមានបិទក្រដាសកាសែតពាសពីលើ។ កាលណាពួកស្តេច ឬ នាម៉ឺនចូលមកឃើញកន្លែងយើងដេក គេញ៉ាក់មុខញាក់មាត់ជាហេតុបណ្តាលឲ្យយើងខ្មាសគេដើបមុខមិនរួចសើចមិនសម។

យើងមិនដែលឃើញបានបាយប្រាក់របស់ជារាំងដែលគេតែងអួតប្រាប់យើងនោះទេ រាល់ថ្ងៃគេដាក់តែបានដីទិញពីចិនលក់អេតចាយនៅព្រៃនគរឯណោះឲ្យយើងស៊ី។ ចំណែកឃ្លួនអ្នកដាំបាយនោះវិញ វាធ្វើម្ហូបឲ្យយើងស៊ីខ្ជីខ្ជាជាងម្ហូបអ្នកទោសនៅស្រុកខ្មែរទៅទៀត ហើយយើងមិនអាចរកទិញអ្វីស៊ីបន្តែមបានឡើយ។ ម្ចាស់ក្បត្រីច្រឡំរលីរលើង មិនព្រមចាំសោះពីរបៀបចាយកាក់មាស កាក់ប្រាក់ របស់ជារាំង។ និយាយពីក្រុមរាំងដែលម្ចាស់ក្បត្រីប្រើឲ្យទៅផ្សារនោះវិញ ស្រាប់តែត្រឡប់មកវិញដៃទទេភ័យញ័រខ្លួនទទ្រើក ពីព្រោះលុយឲ្យទៅប៉ុន្មានត្រូវចោរឆក់យកអស់រលីង។ ឮអញ្ចឹងយើងភ័យចង់ក្រុនទាំងអស់គ្នា រអ៊ូរទាំខឹងនឹងខ្លួនឯង មិនគួរឆ្លួតមកស្រុកគេឲ្យវេទនាខ្លួនសោះ។ ចាប់តាំងពីនោះមក យើងលែងហ៊ានចេញទៅទីផ្លាខាងក្រៅ ស្មោះតែម្តង ណាមួយខ្លាចចោរ ណាមួយខ្មាសមនុស្សម្នាដែលមកប្រជុំគ្នាអឺអើតការហង់មើលយើង ហាក់ដូចជាយើងនេះជាមនុស្សចម្លែកខ្លាំងណាស់។

យើងមិនដឹងជាបង្គន់នៅកន្លែងណាទេ ឬមួយប្រហែលជាផ្ទះនេះអត់មានធ្វើបង្គន់ក៏មិនដឹង ម្ល៉ោះហើយមីខ្លះវាជុះអាចម៍ ដាក់ចានដែកសម្រាប់ដាក់ទឹកមុជ ដាក់ចានសម្ហ ហើយសើចហ៊ោសប្បាយដោយបាន សងសឹកឲ្យជារាំងយកអាចម៍វាទៅចាក់ចោល។

ពេលស៊ីបាយយើងបិទទ្វារបិទបង្អួចខ្លាចគេឃើញ ពេលយប់យើងដេកឱបដៃរងាស្ទើរីរឹងពោះលើពូករនាប ដែលស្តាយយកមកជាប់ជាមួយតាំងពីស្រុកខ្មែរ។

ប៉ុន្តែ ស្រុកនេះសម្បូរណ៌រុយអ៊ីម្ល៉េះទេ! រុយហើរអ៊ូដូចឃ្មុំ រោមមនុស្ស រោមបាយសម្ហ ដូចរោមអាចម៍ ហើយបើតាមមើលទៅរុយនេះវាបែបចង់សម្បូរណ៌ជាងមូសនៅស្រុកខ្មែរផង។

ថ្ងៃមួយម្ចាស់ក្បត្រីបានប្រាប់ថីបកឈ្មោះព្រំ ឲ្យយកទឹកផឹកមកថ្វាយលោក ដោយជារាំងនៅចាំបម្រើយើង វាបែរជាយកកំប៉ុងដូចចានទឹកត្រីយួនមកថ្វាយទៅវិញ។ ម្ចាស់ក្បត្រីប្រកែកពុំព្រមសោយទឹកនោះ ហើយប្រើស្រីម្នាក់ឲ្យទៅយកផ្តិលមាសផ្តិលប្រាក់ មកថ្វាយរួចលោកប្រាប់ថីបកឲ្យពន្យល់ជារាំងថា លោកផ្តាប់សោយទឹកសុទ្ធតែក្នុងផ្តិលប្រាក់ ផ្តិលមាស គេមិនដែលប្រើកំប៉ុងអញ្ចឹងជាមួយស្តេចទេ។

ជាសំណាងដែរ ការស្នាក់នៅរបស់យើងក្នុងផ្ទះដ៏អភ័ព្វនេះ មានរយៈពេលតែពីរ-បីថ្ងៃប៉ុណ្ណោះ។ ម្ចាស់ក្បត្រីបានទៅអង្វរករលោកមេទ័ពទាហានជើងទឹកជារាំង ទាល់តែគាត់រកផ្ទះមួយដ៏សមគួរ មានសួនច្បារ មានដើមឈើឲ្យយើងបាននៅស្រួលជាងមុន។ ទោះជាយ៉ាងណាក៏យើងមិនសូវបានដើរទៅមើលស្រុកភូមិគេដែរ ពីព្រោះឲ្យតែឃើញមុខយើងនៅកន្លែងណា ពួកជារាំងចោមរោមមើលអ្វីមួយរំពេច ហាក់ដូចជាយើងនេះជាមនុស្សចម្លែកខុសពីពួកគេអញ្ចឹង។

នៅពេលដែលយើងត្រូវចេញវាំ តូក់ខ្លះសម្លៀកបំពាក់ក៏មិនដឹងជាគេយកទៅទុកនៅឯណា ហើយជាពិសេសទៅទៀតរោងល្មោននោះនៅឆ្ងាយរាប់គីឡូពីកន្លែងដេក គឺគេរៀបចំធ្វើនៅក្នុងវិមានមួយធ្វើពីថ្ម ប្រកបទៅដោយសួនច្បារស្រស់ប្រពាង។

ក្នុងទីនេះ ជារាំងរៀបចំធ្វើបុណ្យតាំងតូរបស់គេ ដោយមានតាំងឲ្យមើលនូវរបស់ចម្លែកៗជាច្រើន នាំយកមកពីគ្រប់ប្រទេស។ របស់ចម្លែកទាំងនោះ យើងគ្រាន់តែក្រឡេកឃើញប៉ុណ្ណោះ ឥតបានមើលឲ្យសព្វគ្រប់តាមចិត្តចង់ទេ។ ប៉ុន្មានថ្ងៃក្រោយមក ហួងលះបង់យើងចោលមែនទែន ដោយលោកយាងទៅទីក្រុងប៉ារីសបាត់ នាំយកទៅជាមួយតែក្រុមភ្លេងមហោរីជាងដប់នាក់ប៉ុណ្ណោះ ដែលសុទ្ធសឹងជាមនុស្សកំជិល ស្ទាបបានការអ្វីក្រៅពីរៀបចំខ្សៀអាកៀន និងដេញវាយរនាត តាំងពីព្រលឹមទល់ព្រលប់។ យើងដទៃទៀតជាអ្នករបាំនឿយមួយចប់ វេទនាមួយចប់ បែរជាហួងត្រូវបោះបង់ចោលដូចជាខ្លាំកពួះគេដាច់ថ្លៃទៅវិញ។ យើងមិនដឹងជាគិតខុស នាំគ្នាហែហមស្តេចឆ្លងកាត់សមុទ្រធំធេង

មកដល់ស្រុកគេអញ្ចឹងសោះ ពីព្រោះទោះបីយើងនឿយហត់យ៉ាងណា ខិតខំធ្វើការអស់ពីកម្លាំងចិត្តយ៉ាងណា ក៏ហួងនៅតែមើលមិនឃើញហើយទំនងដូចជាធុញទ្រាន់នឹងពួកយើងទៀតផង។ ម្ចាស់ក្សត្រី ពីមុនមកធ្លាប់គិតខុសធ្លាប់មានគំនិតអាក្រក់ក៏ពិតមែន ប៉ុន្តែក្នុងកាល:ទេស:នេះ លោកប្រែជាស្រឡាញ់យើងលើសពេលណាទាំងអស់។ លោកបានប្រថុយផ្តាំផ្ញើទៅទូលហួងបិតា ឲ្យលោកបានយល់ពីទុក្ខវេទនារបស់ពួកយើង ដែលត្រូវលោកបោះបង់ចោលនេះដែរ ប៉ុន្តែហួងគ្រាន់តែផ្តាំតាមគេមកវិញថា ឲ្យម្ចាស់ក្សត្រីនាំយើងទៅបើកប្រាក់ខែ ពេលដាច់ខែនៅឯក្រុងប៉ារីស៍តែប៉ុណ្ណោះ។

រង់ចាំទម្រាំតែដល់ដាច់ខែ យើងខ្វះសព្វខ្វះគ្រប់ ម្ល៉ោះហើយម្ចាស់ក្សត្រី លោកពិបាកចិត្តគិតតែសោយស្រាដូចគេផឹកទឹក ហើយនិយាយពីរឿងស្រានោះវិញ ជារាំងជញ្ជួនយកមកផ្តល់ឲ្យមិនដែលឲ្យ ខ្វះខាតទេ។ បើតាមស្តាន នៅស្រុកត្រជាក់ ប្រហែលជាគេត្រូវការធីកស្រាច្រើន ដើម្បីកំដៅពោះអញ្ចឹងហើយមើលទៅ។ ជាតុអាកាសត្រជាក់ធ្វើទុក្ខយើងខ្លាំងណាស់ ហើយក្តីព្រួយជារម្ភាតែងតាមញាំញីយើងជាប់ជានិច្ច ប៉ុន្តែយូរៗទៅ យើងដូចជាធ្លាប់នឹងជីវភាពរបៀបនេះបន្តិចដែរ។ យើងឧស្សាហ៍ចេញទៅអង្គុយលេងក្តងសួនច្បារ អង្គុយលេងលើកាំជណ្តើរថ្មដុំរិញអាងទឹក ឬ អង្គុយលេងលើវាលស្មៅជារឿយៗ ហើយមានពួកជារាំងក្មេងៗ មកស៊ីញ៉ែដេរដើងសុំថតរូបយើងទុកជាអនុស្សាវរីយ៍។

ប៉ុន្តែសាសន៍ស្តីគេហ្នឹងដូចជាចម្លែកណាស់ ស្លៀកពាក់មិនសូវបានត្រឹមត្រូវសោះ គឺគេមិនរវល់បិទបាំងគ្រឿងអៀនខ្មាសដូចយើងឡើយ។ មានរឿងផ្សេងទៀតដែលប្លែករកគិតមិនយល់ទាល់តែសោះ ដូចជាពេលយប់មានរយៈពេលខ្លីណាស់ ក្រោយពេលបាយល្ងាចហើយយើងទើបនឹងដក់ជារឹអស់ពីរ-បីដើម ស្រាប់តែថ្ងៃចាប់រះឯកើតទៀតទៅហើយ រួចព្រះអាទិត្យតែរះហើយ ហាក់ដូចជាពុំព្រមចង់លិចទៅវិញសោះ។

យើងដាច់សោហ៊ុយទាំងអស់គ្នា សូម្បីតែម្ចាស់ក្សត្រីក៏ដូចជាអផ្សុកគប់ប្រមល់ខ្លាំងណាស់ដែរ។ ពួកក្រុមរាំងដ៏អភ័ព្វពីដើមគាត់ធ្លាប់ធ្វើជាអ្នកចាំយាមឃ្លាំមើលយើង តឡើរត្រូវធ្លាក់ខ្លួនមកជាអ្នកបំរើយើង យ៉ាងស្មោះត្រង់បំផុត។

កាលណាត្រឡប់មកពីផ្សារម្តងៗ ក្រុមរាំងអស់ហ្នឹងតែងទិញបានរបស់ចម្លែកៗមកផ្ញើយើង ដូចជារូបឆ្កែម៉ាស៊ីនចេះលោត កាលណាគេមួលខ្មៅ ជាល់កៅស៊ូ នំ ផ្លែឈើ កំណាត់ស្បៃ។ របស់ទាំងនេះ ថ្លៃកប់ពពក ប៉ុន្តែយើងចេះតែខំទិញដាក់ពេញហិបគ្រប់គ្នា ដើម្បីបានយកទៅបង្ហាញឪពុក-ម្តាយឲ្យបានស្គាល់របស់ចម្លែកនៅស្រុកគេ។

ល្ងាចមួយនោះ យើងត្រូវចេញដំណើរឆ្ពោះទៅកាន់ក្រុងប៉ារីស៍ទាំងអស់គ្នាដោយជិះលើរទេះភ្លើងបើកតាមផ្លូវដែកដូចកាលនៅស្រុកសេរិលង្កាដែរ។ បន្ទប់ធ្វើដំណើរក្នុងរទេះនេះទូលាយស្រួល មានកៅអីក្រាលពូកសម្រាប់អង្គុយ មានចង្កៀងឆេះឯងអុជបំភ្លឺ មានបង្គន់សព្វគ្រប់ទាំងអស់។ បានធ្វើដំណើរស្រួលអញ្ចឹង យើងដូចជាទុកចិត្តហើយជូរច្រូងខ្សាក ប្រៀបបានមនុស្សទើបនឹងរួចពីគុក។ យើងអើតតាមបង្អួច គយគន់មើលដើមឈើ និង ផ្ទះក្នុងផ្ទៃអន្ធការនៃរាត្រីកាល ដែលរសាត់ថយក្រោយរហ័សស្មើរមើលមិនទាន់។

រំពេចនោះ ស្រាប់តែយើងមើលទៅក្រៅលែងឃើញអ្វីទាំងអស់ គឺរទេះភ្លើងបើកចូលទៅក្នុងរូងដែល ជីកទម្លាយដើងភ្នំពីម្ខាងទៅម្ខាង ដោយបញ្ចេញសូរសំឡេងខ្ទរខ្ទារ ហាក់ដូចជាដីភ្នំរលំសង្កត់មកលើយើង។

ស្អែកព្រឹកឡើង រទេះភ្លើងនៅតែបើកទៅមុខដដែល ឆ្លងកាត់វាលស្រែពណ៌បៃតងស្រស់ ព្រៃស្បាត និង ឆ្លងស្ពានច្រើនរាប់មិនអស់។ ស្រុកស្រែស្រុកចំការនៅស្រុកបារាំង វាខុសគ្នាស្រឡះពីស្រុកយើង គឺគេដាំដំណាំតតឲ្យសល់ដីទំនេរមួយដុំណាឡើយ។

ទីបញ្ចប់ នៅពេលយើងមកដល់កន្លែងមួយ ដែលផ្ទៃមេឃប្រែជាខ្មៅអាប់ជាងនៅឯ ស្រុកម៉ាស៊ីទៅទៀតនោះ មាននរណាម្នាក់ប្រាប់ថា យើងជិតមកដល់ក្រុងប៉ារីស៍ហើយ។ គឺក្រុង ប៉ារីស៍នេះហើយដែលគេតែងសរសើរក្រាប់មាត់ថា ជាទីសប្បាយលើសកន្លែងណាទាំងអស់ មើលពីចម្ងាយឃើញក្រុងនេះលាតសន្ធឹងលើដីវាលរាបស្មើ ប្រកបទៅដោយផ្សែងខ្មៅគ្របដណ្តប់ពីលើ និង មានផ្ទះថ្ពក់ស្ង សងឯណោះមួយដុំ ឯណោះមួយដុំ។ សូម្បីជញ្ជាំងផ្ទះ រានហាល ដី ពពក ក៏មានផ្សែងខ្មៅស្ថិតនៅប្រឡាក់លាយឡំដែរ។

រទេះភ្លើងនីមួយៗ សណ្តោងរឺម៉ករាប់រយ បើកជៀសគ្នាខ្វាត់ខ្វែងលើផ្លូវដែក, ខ្លាំភ័យស្មើរលោះព្រលឹងនឹកអស់គុណម៉ែគុណឪ ព្រោះថាបើមានតែរទេះភ្លើងណាមួយបើកច្រឡំផ្លូវ ច្បាស់ជាបុកគ្នាក្រឡាប់ស្លាប់អស់អ្នកជិះមិនខាន។ ហើយនៅឆ្ងាយឯណោះ យើងមើលឃើញប្រាសាទដែកមួយ ដែលមាចុងកំពូលលូតខ្ពស់ហួសកំពូលកណ្តាលនៃប្រាសាទអង្គរវត្តរបស់ខ្មែរទៅទៀត។

នៅពេលមកដល់ក្រុងប៉ារីស៍ ខ្ញុំហាក់ដូចជារិលមុខភ្លេចស្តាំងអ្វីទាំងអស់ ឃើញតែហ្វូងមនុស្សច្រើនកុះករ សម្លេងអ៊ូអរ និង ភ្លឺនអាក្រក់ជះមកស្ទើរទ្រាំមិនបាន។ ផ្លូវថ្នល់ធំទូលាយហើយស្អាតជាងនៅម៉ាស៊ីមែន ប៉ុន្តែធំភ្លឺនផ្សែងប្រេងសាំង និង មានមនុស្សរាប់ម៉ឺននាក់ប្រជ្រៀតគ្នាឆ្លងកាត់ថ្នល់ទៅមក គួរឲ្យចង់ទស្សនា។

ជាសំណាងល្អណាស់ដែលនៅទីបញ្ចប់យើងបាន មកជួបមិត្តភក្តិ មកជួបហួងវិញ។ ហួងគង់នៅក្នុងដំណាក់មួយធំប៉ុនគ្នានឹងប្រាសាទបាញ់យ៉ុងនៅភ្នំពេញដែរ ស្ថិតនៅជាប់ផ្លូវធំ មានដាំដើមឈើលើចិញ្ចើមថ្នល់អមសង្ខាង ព្រមទាំងមានឡានបើកបន្តកន្ទុយគ្នាទៅមកឥតដាច់។

យើងស្នាក់នៅក្រុងប៉ារីស៍បានតិចថ្ងៃណាស់ ហើយយើងត្រូវរាំតែពីរដងប៉ុណ្ណោះ។ ទីមួយរាំនៅផ្ទះលោកប្រធានាធិបតីបារាំង និង ទីពីររាំនៅក្នុងសួនច្បារ ដែលមើលទៅល្អដូចស្ថានសួគ៌យ៉ាងនោះដែរ។ ហ្លួងបង្គាប់ឲ្យគេនាំយើងដើរលេងទៅមើលសៀកដែលមានមនុស្សប្រុសស្រីស្លៀកពាក់ស្អាតៗ ហើយនាំគ្នាផែឡើងជិះសេះ ដែលកំពុងដាយពេញល្បឿន មានមនុស្សឡើងជិះត្រួតលើគ្នាលើកជើងឡើងលើ មានមនុស្សវាយប្រដាល់គ្នា....។

ម្ចាស់ក្សត្រី ក៏បាននាំយើងទៅមើលប្រាសាទដែកដ៏ធំគួរឲ្យខ្លាច រហូតដល់មានពួកយើងខ្លះខ្លាច មិនហ៊ានឡើងមើលសុខចិត្តអង្គុយចាំគេនៅខាងក្រោមរងាឱបដៃកំប្រោន។ ខ្ញុំប្រថុយឡើងទៅលើជាមួយម្ចាស់ក្សត្រី និង ពួកម៉ាក ពីរ-បីនាក់ រហូតដល់ជាន់ទីមួយ។ គេឲ្យយើងចូលទៅក្នុងរទេះមួយបិទជិត ស្រដៀងគ្នានឹងរទេះដែលដឹកយើងពីម៉ាស៊ីមកប៉ារីស៍ដែរ ហើយគេរុតសណ្តោងឡើងទៅពុំចាំបាច់ឲ្យយើងដើរឡើងតាមជណ្តើរនាំហត់ទេ។ នៅលើជាន់ទីមួយនេះមានលក់នំ លក់ស្រា មើលទៅក្រោមឃើញក្រុងបារីស៍លាតសន្ធឹងធំល្វឹងល្វើយ ក្របកទៅដោយកំពូលប្រាសាទ និង សសរថ្លែងច្រាង ហើយទន្លេមួយហូរកាត់ទីក្រុង មានស្ពានច្រើនរាប់មិនអស់សម្រាប់ឆ្លងពីច្រាំងម្ខាងទៅច្រាំងម្ខាង។ ប៉ុន្តែខ្ញុំមិនអាចមើល ទៅឆ្ងាយឃើញដល់ជើងមេឃទេ ពីព្រោះផ្សែងដែលហុយចេញមកពីគ្រប់ដំបូលផ្ទះនោះ វាធ្វើឲ្យផ្ទៃមេឃទាំងមូលប្រែជាងងឹតដាស ។

ភ្នានរណាម្នាក់ហ៊ានឡើងខ្ពស់ជាងនេះទៀតទេ។ នៅពេលចុះមកវិញ គេសម្រួតរទេះលឿនស្តេវ ហាក់ដូចជាយើងរបូតធ្លាក់មកឥតមានអ្វីទ្រពីក្រោមជើងដូច្នោះដែរ ដែលជាហេតុនាំឲ្យយើងវិលមុខរកកល ក្អួតចង្អោរ។

ក្នុងថ្ងៃធ្វើបុណ្យជាតិបារាំង គេយករទេះមកដឹកហ្លួង និង ពួកយើងជាបរិវារទាំងអស់គ្នា ហើយបរចេញទៅតាមផ្លូវដ៏ធំទូលាយ និង ស្អាតក្រៃលែង។ បារាំងមានឌធំៗ ស្លៀកពាក់ខោអាវក្រហម ពាក់មួកជិះសេះ អមសង្ខាងក្បួនរទេះយើងជាបរហូត។ គេយាមការពារប្រយ័ត្នប្រយែងម្លឹងៗ ប្រហែលជាគេចាំហ្លួងទៅដាក់គុក ឬ នាំទៅសម្លាប់ចោលក៏មិនដឹង។ យើងឧស្សាហ៍លួចចោលកន្ទុយភ្នែកមើលទៅពួកជិះសេះទាំងសង្ខាងហ្នឹងជាញឹកញាប់ មើលយូរទៅរឹតតែខ្លាចខ្លាំងឡើង ខ្លាចរហូតទាល់តែមិនហ៊ានស្លប់! បារាំងរាប់លាននាក់ ឈរនៅសង្ខាងផ្លូវ ស្រែកហ៊ោកញ្ជ្រៀវរកស្តាប់មិនយល់ នៅពេលឃើញក្បួនរទេះយើងមកដល់ ដែលជាហេតុធ្វើឲ្យយើងភ័យញ័រទន្ទ្រើក។

ក្បួនរទេះមកឈប់ក្នុងទីវាលមួយដែលគេមានសង់វេទិកាធំៗ អាចដាក់ទស្សនិកជនបានរាប់ពាន់នាក់។ ហ្លួងចុះទៅឈរក្បែរប្រធានាធិបតីបារាំង ប៉ុន្តែខ្ញុំសម្លឹងពីចម្ងាយរកចំណាំមុខគាត់ហ្នឹងមិនបានសោះ។ ទាហានតម្រៀបជួរដើរស្រុះដើងគ្នាលើវាលស្មៅ បន្ទាប់មកមានអ្នកជិះសេះកាន់ដាវនៅដៃ ធ្វើដំណើរកាត់មុខហ្លួងរាស្ត្រប្រជា ដែលស្រែកអបអរសាទរឡើងទ្រហឹងអឺងអាប់រកស្តាប់ទិសតំបន់អ្វីមិនយល់ បើកុំតែមានបាដែកបាំងជាប់ កុំអីពួករាស្ត្រមុខតែផ្លាយមកជាន់ទាហានដែលកំពុងដើរនេះមិនខាន។ ទស្សនីយភាពនេះ មានសភាពសម្បើមគួរកោតស្ងប់ស្ងែងក្រៃលែង។

ល្ងាចនោះ បារាំងអុជកាំជ្រួចនៅកណ្តាលទន្លេដែលហូរកាត់ក្រុងប៉ារីស៍ ភ្លឺរន្ទាលព្រោងព្រាត ក្អេងប្រុសស្រីស្រែកច្រៀងសប្បាយ ហ៊ោកញ្ជ្រៀវបន្ទរតាមបទភ្លេង ព្រមទាំងបង្ហោះបេងហ៉ោងចម្រុះពណ៌ ឲ្យហើរពេញផ្ទៃមេឃ។

ហ្លួងរវល់តែសប្បាយរីកល្ហែមនឹងការដែលបារាំងលើកកិត្តិយស សប្បាយទាល់តែភ្លេចគិតដល់ពួកយើង។ ពួកស្រីក្រមភ្លែងមហោរី ដែលបានដង្ហែហ្លួងមកក្រុងបារីស៍មុនយើង គេនិយាយរឿងចម្លែកៗ ស្ទើរជឿពុំបានប្រាប់យើង ប៉ុន្តែសុទ្ធសឹងជារឿងពិតទាំងអស់។ សូម្បីហ្លួង និង អ្នកអង្គម្ចាស់សូរីវង្ស ជាកូនប្រុសបណ្តូលចិត្តរបស់ហ្លួងនោះ ក៏បាននិយាយប្រាប់យើងដោយឥតលាក់លៀម ពីស្រីបារាំងដែលលោកបាន “ជួប” ហើយលោកបញ្ជាក់ថា ស្រីបារាំងគេចេះ “ម៉េតូត” ច្រើនបែបណាស់ មិនមែនល្ងង់ដប់គត់ដូចខ្មែរទេ។

គេដណ្តើមគ្នាមើលរូបថតដែលអ្នកអង្គម្ចាស់ សូរីវង្ស ទិញមកឃើញរូបបារាំងប្រុសបារាំងស្រីស្រាតនន្លះកកទាំងអស់គ្នា ហើយប្រើរបៀបចំគិតចំតូងផ្លែកៗអស្ចារ្យ សូម្បីស្រីសំផឹងនៅស្រុកយើង ក៏គ្មានមីណានឹកឃើញធ្វើដូចអញ្ចឹងដែរ។ ពួកយើងទើបនឹងមកដល់ក្រុងប៉ារីស៍ក្រោយគេ ហើយបានឃើញរូបថតនេះជាលើកដំបូងបំផុត ខ្លះមិនហ៊ានមើលយកដៃខ្ទប់ភ្នែក ខ្លះក្អួតចង្អោរនៅពេលបានឃើញឆាកដំសែនអាសអាភាសនេះ។

ខ្ញុំចេះតែនឹកបារម្ភក្នុងចិត្តថា បើយើងនៅក្នុងស្រុកបារាំងតែពីរ-បីអាទិត្យទៀត ថ្ងៃណាមួយហ្លួងគង់នឹងបង្គាប់ឲ្យយើងចំគិតចំតូងដូចក្នុងរូបថតថ្វាយលោកមិនខាន។ ពួកយើងចង់តែចាកចេញពីដីស្រុកបារាំង ឲ្យបានឆាប់បំផុត ហើយរហូតមកដល់សព្វថ្ងៃនេះក្តី នៅក្នុងវាំងចតុមុខក៏ពួកស្រីៗដែលធ្លាប់បានដង្ហែហ្លួងទៅស្រុកបារាំង នៅតែស្តាយថា មិនគួរនាំគ្នាទៅស្រុកអាសអាភាសអញ្ចឹងសោះ។ តាមស្តាប់ដីម្នាក់ៗ ទាំងនាម៉ឺនរាជការ ពួកល្ខោននរណាក៏សុទ្ធតែឆ្អែតនឹងស្រុកបារាំងដែរ។

មានតែហ្លួងមួយអង្គឯងទេ បែបដូចជាខុសគេ កាលណាលោកយាងចេញកំសាន្តទៅណាម្តងៗ លោកបាចទានលុយទៅលើផ្លូវឲ្យបារាំងដណ្តើមគ្នារើសដូចឆ្កែ ឲ្យទានរបៀបនេះ បើនៅស្រុកខ្មែរវិញ សូម្បីអតិឃ្លានយ៉ាងណាក៏គេមិនខ្ចីរើសយកដែរ ហើយពួកបារាំងនេះមិនមែនរើសតែលុយទេ សូម្បីកន្ទុយបារីដែលយើងជក់ជិតអស់ ក្រវាត់ចោលទៅក្នុងសួនច្បារនោះ ក៏គេរើសយកទៅជក់ នៅស្រុកខ្មែរមិនដែលមាននរណាធ្វើឫកថោកដល់ថ្នាក់ហ្នឹងឡើយ។

ពេលយប់ កូនស្តេចក្មេងៗពីរនាក់ បានទៅមើលឃើញគេធ្វើស្រា, ស្ករស និង ន៉ំប៉ាង ក្នុងរូងក្រោមដី ក្រខ្វក់រកអ្វីមកប្រៀបឲ្យស្មើពុំបាន។ ចាប់តាំងពីពេលនោះមក ម្ចាស់ទាំងពីរអង្គ ដើរប្រាប់គេប្រាប់ឯងថា លោកសោយតែបាយទេ ឈប់លូកបះពាល់ម្ហូបបារាំងទៀតហើយ ពីព្រោះវាគ្រិចគួរឲ្យខ្ពើមជាងប្រហុកទៅទៀត។

បើនិយាយឲ្យខ្លី តាមអ្វីៗដែលយើងបានឃើញ បានដឹង បានឮ យើងអាចសន្និដ្ឋានបានថារបៀបរបប នៅស្រុកបារាំង វាខុសគ្នាស្រឡះពីស្រុកយើង ឥតឃើញមានសាសនា សេចក្តីថ្លៃថ្នូរ សីលធម៌ ឥតមានធ្វើបុណ្យប្រាថ្នាស្វែងរកសុខក្នុងបរលោកដូចយើងទេ។ បារាំងជាយក្ស ជាមនុស្សខ្លាំងពូកែ តែល្ងង់ គិតតែនាំគ្នាធ្វើការនឿយហត់ គិតតែបង្កើតរបស់ប្លែកៗ ប៉ុន្តែមិនអាចរកផ្លូវទៅនិព្វានឃើញឡើយ។

មនុស្សម្នាត្រូវធ្វើការទាំងយប់ទាំងថ្ងៃ ឥតមានពេលឈប់សំរាក មើលទៅគួរឲ្យវេទនាក្អែកក្រៃលែង ហើយយើងជាប្រជាពលរដ្ឋខ្មែរ ក៏គង់នឹងត្រូវទទួលរងវាសនាកម្មដូចគ្នានេះដែរ ពីព្រោះយើងកាន់តែធ្លាក់ខ្លួនជាខ្ចុំបារាំងបន្តិចម្តងៗហើយ!។

ការចាប់បង្ខំខ្មែរ ឲ្យធ្វើការដូចទាសករ ការតម្លើងថ្លៃពន្ធអាករ ការតម្លើងថ្លៃទំនិញ ពួកបរទេសលើកគ្នាមកនៅក្នុងក្រុងកាន់តែច្រើនឡើងៗ... ទាំងអស់នេះឬ ជាសុភមង្គលដែលបារាំងនាំយកមកឲ្យខ្មែរជាថ្នូរនឹង ការដែលគេដកហូតយកឯករាជ្យរបស់យើងនោះ?...

យើងបែកចេញពីហ្លួង និង ក្រុងប៉ារីស៍ដោយក្តីសប្បាយរីករាយក្រៃលែង ដើម្បីត្រឡប់មកកាន់ក្រុងម៉ាវ៉ាសី ដ៏ស្ងាត់ជ្រងំវិញ ដែលយើងអាចធ្វើដំណើរទៅណាមកណាបានតាមចិត្ត ពុំចាំបាច់មានទាហានជិះសេះអមសង្ខាង ដូចមនុស្សទោសទេ។

ក្នុងពេលធ្វើដំណើរពីប៉ារីស៍ មកម៉ាវ៉ាសី ម្ចាស់ចិន្តាវង្ស ក៏ធ្វើដំណើរមកជាមួយយើងដែរ ស្រាប់តែវង្វេងបាត់ម្តាយលើរទេះភ្លើង ក៏តាំងស្រែកទួញដូចកូនក្មេង ដើរកកេរកពេញរទេះភ្លើង ប៉ុន្តែនៅពេលចូលមកដល់ក្នុងបន្ទប់យើង ម្ចាស់ខូចនេះបែរជានិយាយរឿងផ្តេសផ្តាស កាលពីពេលម្ចាស់ស៊ូរីវង្ស ជាបងនោះនាំទៅ ផ្ទះសំណឹងបារាំងទៅវិញ ហើយយើងក៏ចាប់ប្រាន់ចេញទៅវិញភ្លាម ព្រោះយើងមិនចង់ស្តាប់រឿងអាសអាភាសនេះ។

មកដល់ម៉ាវ៉ាសី បារាំងលើកគ្នាភ្ជួរកទឹកភ្នែកមកសុំថតរូបយើងច្រើនណាស់ ហើយពួកនេះមកមិនសូវរើសពេលវេលាផង ជូនកាលមកចំលើពេលបាយ យើងក៏ត្រូវឈប់ស៊ីបាយសិនដើម្បីទៅឈរឲ្យគេថត។ ព្រឹកនៃការធ្វើដំណើរវិលត្រឡប់មកកាន់ស្រុកខ្មែរវិញមកដល់ហើយ! យើងរៀបចំឡើងលើកប៉ាល់ ជាមួយម្ចាស់ក្បាត្រី ហើយទាល់តែថ្ងៃជិតត្រង់ទើបឃើញហ្លួងយាងមកដល់។ បន្តិចក្រោយមកកប៉ាល់ ក៏ចាកចេញពីច្រាំង ដឹកនាំយើងមកកាន់មាតុប្រទេសដែលយើងតែងនឹកគិតឥតភ្លេច។

កូនស្តេចជាច្រើនឥតត្រឡប់មកវិញទេ គឺគេនៅរៀនក្នុងស្រុកបារាំង។ ពួកអស់ហ្នឹងរៀនស្អី? រៀនចម្លងយកទំនៀមទម្លាប់អាសអាភាសមកផ្សាយក្នុងស្រុកខ្មែរឬ?... ប៉ុន្តែផ្តុយទៅវិញ នៅលើកប៉ាល់មានមនុស្សថ្មីខ្លះ ដែលយើងពុំដែលឃើញសោះកាលពីពេលទៅ គឺពួកជាងដែលគេដឹកយកមកពីស្រុកខ្មែរតាំងពីយូរណាស់មកហើយ ដើម្បីសង់វិមានថ្មនៅម៉ាវ៉ាសី ជាកន្លែងយើងឆ្លាប់ទៅរាំនោះ។

ពួកអ្នកធ្វើការលើកប៉ាល់ ពុំមែនជាមនុស្សដដែលដែរ គឺប្រាកដជាកប៉ាល់ផ្សេងមួយទៀតហើយ ទោះបីរូបរាងកប៉ាល់នេះដូចគ្នាបេះបិតនឹងកប៉ាល់ដែលយើងជិះមកក៏ដោយ។

ព្រឹត្តិការណ៍សំខាន់ជាងគេក្នុងពេលធ្វើដំណើរ គឺរឿងដែលគេឃើញ ម៉ាមន្ទ កំពុងសាហាយជាមួយលោកមហាមន្ត្រី នៅក្នុងបន្ទប់ទឹក។ រឿងនេះគេខំខ្ទប់លាក់លៀមខ្លាំងណាស់ គ្រាន់តែខ្សឹបខ្សៀវរអេចរអូចពីមាត់មួយទៅមាត់មួយប៉ុណ្ណោះ។ ហ្លួងក៏បានដឹងរឿងអពមង្គលនេះដែរ ប៉ុន្តែមិនហ៊ានមាត់កថាដូចម្តេច ពីព្រោះសព្វថ្ងៃនេះ លោកមហាមន្ត្រីកំពុងមានអំណាចខ្លាំងណាស់។ ប៉ុន្តែទោះជាយ៉ាងណាក៏លោកកាន់តែជិនឆ្អន់នឹង ម៉ាមន្ទ ខ្លាំងឡើងៗ។

ចាប់តាំងពីថ្ងៃនោះមក មីរ៉ែន និង មីស៊ុន ពួកម៉ាកខ្ចុំតាំងពីក្មេងៗមក គេប្រសប់អែបអបយកគាប់គួរ ក៏បានឡើងហាន:ជាអ្នកគាប់ចិត្តហ្លួង បានត្រួតត្រាមើលក្រុមអ្នកគាល់បម្រើផ្ទាល់ព្រះអង្គ ព្រមទាំងបានទទួលរង្វាន់ជាកិត្តិយសនិង គ្រឿងអាលង្ការច្រើនណាស់។ មីរ៉ែន ខ្មៅក្រចេះបានប្រែឈ្មោះជា វណ្ណរតន៍ ហើយបានត្រូវគេទាំងអស់គ្នាគោរពអ្នកសរសើរ សុទ្ធតែវាហ្នឹងជាស្រីគ្រប់លក្ខណ៍ ហើយម្ចាស់ខ្លួនវានោះទៀត ដល់បានឡើងបុណ្យអញ្ចឹង វាស្តេចអស់ជាតិកំណើតវាជាដង្កូវ ស្តេចអស់ពួកម៉ាកដែលកាលពីដើម ធ្លាប់ស៊ីបាយមួយចានពីរនាក់ ជក់ជារឹមួយដើមពីរនាក់។

ប្រហែលជាទេវតារក្សាសមុទ្រ ចង់ផ្តន្ទាទោសចំពោះពួកអ្នកដំណើរដ៏មានគំនិតខូចរៀបរេ ហ៊ានសាហាយស្មន់គ្នាលើកន្លែងដែលគេថែរក្សាហើយមើលទៅ! ខ្យល់ខ្លាំងបក់មកពីទិសនិរតី លាន់ឮសន្ធឹកដូចព្យុះសង្ឃរា បង្កើតជារលកធំៗជាងផ្ទះ បក់បោកមកលើកប៉ាល់ បណ្តាលឲ្យឃ្លេងឃ្លោងរកកលនឹងលិច។ ទឹកកញ្ជ្រោលបោកឡើងលិចដល់ក្តារកប៉ាល់ ហើយហៀរចូលតាមបង្ហួចបិទមិនជិត លិចទាំងបន្ទប់ដែលយើងដេកនោះផង។ យើងទាំងអស់គ្នាកើតជម្ងឺពុលរលកក្អួតដាក់លើឡាំងឈើ លើពូកប្រឡាក់អស់ស្អាតសល់។ នរណាដែលពីមុនមកធ្លាប់អួតថាខ្លួនក្រានបើនោះ ក៏លែងអួតក្អេងក្អាង ត្រឡប់ជារត់រកធូបមកអុជសុំបួងសង្រួង នឹកអស់គុណម៉ែ-គុណឪ ហើយអ្នកខ្លះទៀត យំស្រែកទ្រហឹងអឺង

អាប់។ និយាយពីហួងវិញ ធ្លាក់ខ្លួនឈឺពុលរលកប៉ុណ្ណឹងហើយ នៅឆ្ងៀតដេរបញ្ឆោរបារាំង ស្តីឲ្យអ្នកត្រួតត្រាធំជាងគេលើកប៉ាល់ថា នាំលោកចេញឆ្ងាយពីច្រាំងមកដល់កណ្តាលសមុទ្រទាល់តែរង្វេងផ្លូវរកទិសគំបន់មិនឃើញ។ លោកនឹកអស់គុណជីដូនជីតា ព្រមទាំងសារភាពទទួលកំហុសទាំងអស់ដែលលោកបានប្រព្រឹត្ត សុំឲ្យតែរួចរស់ជីវិតមួយគ្រានេះ។

ក្នុងពេលនោះ គ្មាននរណាម្នាក់ហ៊ានសង្ឃឹមថានឹងគេចផុតពីកណ្តាប់ដៃសមុទ្រទេ។ យើងម្នាក់ៗ នឹកឃើញអស់រឿងសត្វសមុទ្រ ក្រពើឆ្លាម ហើយគំនិតយើងរសាត់ទៅដល់មាត់ច្រាំងដ៏រីករាយ ក្រោមរស្មីព្រះអាទិត្យនៃមាតុភូមិរបស់យើង ដែលពេលនេះប្រហែលជាឪពុក-ម្តាយយើង កំពុងអង្គុយលើរានហាលផ្ទះ នឹកព្រួយបារម្ភពីវាសនាយើង ភ្នែកមើលទៅជើងមេឃដ៏ឆ្ងាយឥតព្រំដែន... ។

នៅទីបញ្ចប់ មហាសមុទ្រក៏រងាប់ភ្លើងកំហឹងខ្លួនទៅវិញ... យើងត្រឡប់មកដល់ប្រទេសសេរីលង្កាដោយសុវត្ថិភាព។ ក្រោយពេលឃ្លាតទៅអស់ពេលបីខែដំបូរប្រៀបបានបីឆ្នាំ យើងបានវិលមកឃើញច្រាំងកូសាំងស៊ីន ក្រុងព្រៃនគរទន្លេធំ និង ដីចំការស្រុកលើកដែកវិញ ដោយក្តីសប្បាយរីករាយរកអ្វីមកប្រៀបឲ្យស្មើពុំបាន។ ទឹកដែលហូរនាំដីល្បាប់មក ជន់ឡើងលិចដល់ច្រាំង ទំនងដូចជាចង់លិចដល់សួនច្បារ កំពង់ផែផង។ កប៉ាល់ចូលមកចតចំមុខរាំងតែម្តង ... ទូកជ្រើនរាប់មិនអស់ មកចោមរោមជុំវិញកប៉ាល់..... ខ្ញុំឃើញពុក និង ម៉ែ ឈឺស្រកសាច់ស្គមជាងមុនឆ្ងាយណាស់ ព្រោះគាត់ព្រួយចិត្តខ្លាំងពេក ស្មានថាខ្ញុំស្លាប់មិនបានមកជួបគាត់វិញទេ។ គេងឆ្ងៃពួកយើងចុះពីកប៉ាល់ ដើរតាមផ្លូវរហូតដល់មាត់ទ្វារកំផែងសីមា។

ពេលបានមកឃើញផ្ទះឪពុកម្តាយខ្ញុំដ៏តូចច្រឡឹងក្រោមរស្មីព្រះអាទិត្យនេះវិញ ការគានតឹងក្នុងចិត្តទាំងប៉ុន្មានក៏រលាយបាត់អស់ដោយឯកឯង។

អស់អ្នក-អស់នាង ដែលមិនបានទៅស្រុកបារាំងនឹងគេ ដណ្តើមគ្នាស្តាប់យើងនិយាយប្រាប់ឡើងចំហមាត់ ហើយប្រញាប់គ្នាដណ្តើមយកអស់របស់របរដែលយើងទិញបានមកទាំងប៉ុន្មាន ឥតមានសល់អ្វីបន្តិចបន្តួចឡើយ ក្រៅតែពីអនុស្សាវរីយ៍ដ៏ល្វីងជូរចត់ ដែលយើងខំបំភ្លេចចោលឲ្យបានឆាប់ជាទីបំផុត។

ឥឡូវនេះ ខ្ញុំមានការពិសោធន៍គ្រប់គ្រាន់ ខ្ញុំអាចនឹងយ៉ាងច្បាស់ដោយខ្លួនឯងថាចាប់តាំងពីពេល នេះតទៅ ក្តីសង្ឃឹមថានឹងបានក្លាយទៅអ្នកជាំមានកេរ្តិ៍ឈ្មោះល្បីក្នុងថ្ងៃណាមួយខាងមុខនោះរលាយសាបសូន្យអស់ហើយ។ ក្នុងរយៈពេលពីរឆ្នាំចុងក្រោយនៃការរស់នៅក្នុងវាំង ខ្ញុំជួបប្រទះតែនឹងរឿងរ៉ាវគួរអស់សង្ឃឹម គួរឆ្អែតចិត្តផ្តួនៗគ្នា។

ខ្ញុំអាយុបានដប់បីឆ្នាំហើយ គឺខ្ញុំនេះពេញវ័យលួមគេចាត់ទុកថា ជាស្ត្រីម្នាក់ហើយ។ ភ្លៅខ្ញុំប្រែជាមានសាច់ណែនមូលក្តី ហើយខ្ញុំភ័យណាស់ខំរត់ទៅលបសួរម៉ែនៅពេលឃើញមានដុះរោមត្រឡាចត្រង់ចន្លោះគល់ភ្លៅទាំងពីរ។ ត្រគាកខ្ញុំរឹក ហើយដោះខ្ញុំក៏ចាប់ផ្តើមដុះធំប្រហែលប៉ុនមេដៃប៉ុណ្ណោះ ប៉ុន្តែឈឺពាល់មិនបាន។

ខ្ញុំមិនដែលហ៊ាននិយាយរឿងអស់នេះប្រាប់ពួកម៉ាកទេ ព្រោះពួកមីអស់ហ្នឹងវាសុទ្ធតែស្រួតគ្រប់ការមុនខ្ញុំទៅទៀត។ ប៉ុន្តែពួកវានៅតែប្រឡែងដេញគ្នាពេញសួនច្បារ ស្រែកហ៊ោកញ្ជ្រៀវ ឬ ស៊ីន់កាន់សំញែងដូចកូនក្មេង ឥតឃើញវាផ្លាស់ប្តូរចរិតត្រង់ណាបន្តិចបន្តួចសោះ។ ចំណែកខ្ញុំវិញ ខ្ញុំលែងហ៊ានទៅដួតទឹកម៉ាស៊ីននៅកណ្តាលវាលដូចមុនទៀតហើយ ដោយខ្លាចប្រសៗដូចជាបោយ ឬ អ្នកធ្វើបាយហួង អ្នកភ្លេង បងប្អូន ឬ ឪពុកម្តាយពួកល្ងោន ឬ កូនស្តេចតូចៗ ក្បាលខូច គេដើរទៅមកឃើញ។

សេចក្តីអៀនខ្មាសវាគម្រុឲ្យខ្ញុំលះបង់សេរីភាពខ្លះចោលចេញ គឺខ្ញុំត្រូវប្រយ័ត្នប្រយែងដូចទឹកតែក្នុងបន្ទប់ស្រួលបួល។ ស្រីៗខ្លះបានចូលដល់ក្នុងបន្ទប់ទឹកក៏តាំងលែងខ្លួនទទេ ស្លៀកតែសារុងចងក្បិន កប់ក្រលៀនដូចប្រុស។ ទោះបីខ្ញុំមានការអៀនខ្មាសខ្លះយ៉ាងនេះក៏ដោយ ក៏ខ្ញុំនៅតែភ្លីភ្លើមិនសូវដឹងអី នៅតែមានចរិតក្មេងនៅឡើយ។ ពេលទំនេរក្រោយពេលហាត់រាំ នៃថ្ងៃណាដែលខ្ញុំពុំត្រូវរេនចូលគាល់បំរើហួង ខ្ញុំចំណាយពេលសម្រាប់ដេរអាវ ឬ ជ្រលក់សំពត់មិនឲ្យទំនេរឥតប្រយោជន៍។

ខ្ញុំយកចិត្តទុកដាក់ថែទាំរបស់ប្រើប្រាស់ខ្លាំងណាស់ ហើយមីពួកម៉ាកអស់ហ្នឹង បើខ្ចីសំពត់អាវខ្ញុំយកទៅស្លៀកម្តងៗ វាស្លៀកពង្រីចពង្រិលទាល់តែ ប្រឡាក់គក្រិច ឬ រហែកឆ្នុះឆ្លាយទើបវាយកមកសងវិញ ម្ល៉ោះហើយខ្ញុំខ្ជិលយកវិញ សុខចិត្តឲ្យវារហូតតែម្តង។

ឥឡូវខ្ញុំមានបន្ទប់ផ្ទាល់ខ្លួនតូចមួយ សម្រាប់ដេកម្នាក់ឯងដាច់ឡែកពីគេនៅក្នុងរោងដែលពីដើម ឃុនថាន់ គាត់សងឲ្យក្រុនល្ងោនគាត់នៅ។ ផ្ទះនេះធ្វើពីឈើ មានពីរជាន់ សង់ខ្ពស់ពីដីបន្តិច ពិបាកក្រៃលែងក្នុងការលូនចូលចោសសំរាមដែលគរស្ទួយរលួយនៅក្រោមផ្ទះ តាំងពីច្រើនឆ្នាំណាស់មកហើយ។ ជណ្តើរនាំឡើងទៅកាន់ជាន់ទីមួយ ដែលជាកន្លែងដេករបស់ពួកល្ងោន វាយខ័ណ្ឌជាបន្ទប់ដាច់ៗពីគ្នា។ នៅជាន់ខាងក្រោមក៏ដូចជាជាន់ខាងលើដែរ ពិតានឈើពុកអស់ កាលណាភ្លៀងម្តងៗ លិចដូចដេកកណ្តាលវាលអញ្ចឹង។ ពីកន្លែងដេកទៅ ខ្ញុំអាចមើលឃើញសួនច្បារ ផ្លូវក្រាលថ្ម ដើមឈើធំៗ និង កំពូលប្រាសាទលាបទឹកមាសលឿងឆ្អិនឆ្អៅ ហើយនៅខាងត្បូងឯណោះ ដងទង់ នៃ វត្តព្រះកែវ លូតខ្ពស់ដាច់គេ។

គ្រឿងប្រើប្រាស់ទាំងអស់ សុទ្ធតែជារបស់ផ្ទាល់ខ្លួនខ្ញុំ ដែលពុកទិញយកមកឲ្យ គឺគ្រែឈើមួយ មានមុង ពូកក្រាល កម្រាលខ្មៅ កន្ទេល ខ្នើយ ហិបពីរសម្រាប់ដាក់សំពត់អាវ និង ប្រាក់កាស និង ទូកញ្ចក់តូចមួយ ដែលនៅក្នុងនោះ ខ្ញុំតម្រៀបដាក់ ដបទឹកអប់ កំប៉ុងម្សៅ និង រម៉ៀត សម្រាប់លាបសំអិតសំអាងកាយរាល់ថ្ងៃ។ លើសពីនេះទៅទៀត ខ្ញុំមានរ៉ៀប ជរ អំបោះហុង ម្ជុល កន្ត្រៃ សំពត់ ជាហ៊ុ សារុង បត់តម្រៀបគរលើគ្នា ព្រមទាំងមានដាក់ផ្តាចម្បា ផ្តាចេកទុំ ផ្តារចេកនៅជាមួយនោះ សម្រាប់អប់សំពត់អាវឲ្យក្រអូប។

ខ្ញុំឧស្សាហ៍មានទទួលភ្ញៀវពីក្រៅ គេមកលេងជាញឹកញយ ប៉ុន្តែខ្ញុំមានកន្លោងស្កាន់មួយសម្រាប់ការពារកុំឲ្យភ្ញៀវស្តោះទឹកមាត់ស្លាដាក់លើក្តារ។ ពួកភ្ញៀវស្រីអស់ហ្នឹងថាមកលេង ប៉ុន្តែតាមពិតគេតម្រង់មករកសុំសំពត់អាវ ឬ លុយកាក់ទៅវិញទេ ហើយខ្ញុំក៏កម្រប្រកែកថាមិនឲ្យណាស់ ពីព្រោះថ្ងៃណាមួយខ្ញុំនឹងត្រូវ ពឹងពាក់អ្នកអស់នោះវិញមិនខាន។ ជួនកាលទៀត ភ្ញៀវអស់ហ្នឹងមានរឿងផ្សេងៗ គឺគេលាក់ សាប៊ូក្រអូប ទឹកអប់ស្រុកបារាំង ម្សៅកញ្ចប់ ឬ នំចំណី ដែលសុទ្ធជារបស់មានតម្លៃយកមកឲ្យខ្ញុំ ហើយសារភាពប្រាប់ថានេះជាបញ្ជើ របស់អ្នកនេះ របស់អ្នកនោះ ដែលធ្លាប់ឃើញខ្ញុំរាំ ហើយចាប់ចិត្តស្រឡាញ់ខ្ញុំ។ គេសុំឲ្យផ្ញើកន្សែងមួយទៅឲ្យគេវិញ ទោះជាកន្សែងនោះចាស់រហែកយ៉ាងណាក៏ដោយ ឲ្យតែមានជាប់ក្លិនខ្លួនខ្ញុំ! ខ្ញុំធ្វើឫកជាខឹងនឹងពួកមេអណ្តើកនេះ ដោយនិយាយកំភ្លើញថានឹងទៅទូលហ្លួងឲ្យចាប់យកទៅវាយធ្វើបាប យកទៅដាក់គុកអស់អាយុមិនខាន ប៉ុន្តែទោះជាយ៉ាងណាខ្ញុំក៏នៅតែទទួលយករបស់ដំនូនដែរ ដើម្បីយកទៅ ចែកពួកម៉ាកស៊ីសើចលេងសប្បាយ ដោយមានផ្តាំផ្ញើពាក្យដេរបញ្ជារឲ្យទៅពួកកម្លោះស្នេហារលុងខួរនោះផង។

ខ្ញុំខំរៀបចំបន្ទប់ឲ្យបានស្អាតជាងបន្ទប់ពួកម៉ាកឯទៀត។ មានតែកាហ៊ុន ប្អូនស្រីដ៏ជូនមួយខ្ញុំទេ ដែលមកនៅជាមួយខ្ញុំរាល់ថ្ងៃ ជាអ្នកបំរើ ជាពួកម៉ាក ជាអ្នកមើលខុសត្រូវលើទ្រព្យសម្បត្តិខ្ញុំ និងជាអ្នកនាំដំណឹង ពីខ្ញុំទៅផ្ទះ និង ពីផ្ទះមកខ្ញុំ។

រាល់ថ្ងៃ វាពិបាកបំផុតត្រង់អារឿងបោសសំរាម និង រៀបចំអីវ៉ាន់ដែលពួកភ្ញៀវចូលមកអើរុះតាមចិត្ត។ ពួកម៉ាកខ្លះនៅក្នុងថែវនោះ ពិបាកពេកវានាំគ្នាម្តង បួន-ប្រាំនាក់ មកដេកពេញកន្លែងខ្ញុំ ថែមទាំងលេងបៀ ដក់បារីគ្រប់ឲ្យគ្រឿងធ្មញទ្រាន់ក្រៃលែង។ ដើម្បីបណ្តេញវាចេញទៅវិញ ទាល់តែប្រើកម្លាំងជាយ ឬ ធ្វើចរិតឲ្យកាចយោរយៅបន្តិច ប៉ុន្តែខ្ញុំពុំបានទឹកស្មានថា ការដែលខ្ញុំធ្វើដូច្នេះវាអាចជាហេតុនាំឲ្យគេយកទៅទូលហ្លួង ទូលម្ចាស់ក្សត្រី ថាខ្ញុំកាចស្ទាស ដើម្បីដណ្តើមយកសេចក្តីគាប់គួរសម្រាប់ខ្លួនគេវិញសោះ។

ពេលព្រលប់ មានចង្កៀងឆេះឯងព្យួរនៅនឹងពិតានបំភ្លឺពេញបន្ទប់ ហើយមានចង្កៀងមួយទៀតដាក់នៅក្រោមបង្អួចបន្ទប់ខ្ញុំ សម្រាប់បំភ្លឺសួនច្បាររហូតទល់ព្រឹក។ រាល់ព្រឹកខ្ញុំ និង កាហ៊ុន កាន់អំបោសស្រកីដូងមួយម្នាក់ដើម្បីបោសជ្រាសបន្ទប់សព្វអស់កន្លែកកន្លៀត បន្ទាប់មកខ្ញុំដូតទឹកសំអាតខ្លួន ហើយបើចំលើពេលត្រូវវេនចូលបំរើម្ហូងខ្ញុំត្រូវដូតទឹកយូរជាងសព្វមួយដង។

កាលណា កាហ៊ុន វាទៅយកបាយពីផ្ទះមកទទួលទាន ម៉ែឧស្សាហ៍តាមមកជាមួយវាដើម្បីមកលេងនឹងខ្ញុំ។ ចំណែកពូកវិញ យូៗទើបបានមកលេងម្តង ប៉ុន្តែមកម្តងណាក៏ដូចម្តងណា ពុំដែលបានលុយមួយសេនពីខ្ញុំយកទៅផ្ទះទេ មានតែខ្ញុំខ្ទេចកកាយយកអស់ពីហោជ៉ៅគាត់ ហើយបើមានបារីប៉ុន្មាន គាត់បារឲ្យខ្ញុំទាំងអស់ សុខចិត្តអត់ខ្លួនឯង។

ក្នុងបួនថ្ងៃ ខ្ញុំទំនេរបានបីថ្ងៃ...ក្នុងពេលទំនេរនេះ ខ្ញុំមិនសូវរវល់រឿងសំអាតខ្លួនប៉ុន្មានទេ ហើយខ្ញុំចុះទៅទិញនំដែលគេដាក់លក់នៅក្នុងសួនច្បារ បន្ទាប់មកយើងប្រជុំគ្នាដើរលេងទាំងក្រុមៗ ដោយមានម៉មសំអយ, សំអាង, ថែម, ស៊ុន, សូឡាយ អ្នកក្លាហានជាងគេជាមេអ្នកដឹកនាំ។ យើងលួចអស់មាន់ទា ផ្លែពុទ្រា ផ្លែល្អក ដែលស្តេចចាស់ៗ និងអស់អ្នកអស់នាង ថែទាំស្រោចទឹកយ៉ាងដិតដួងបំផុត។ កាលណាយើងលួចឆ្អែតឆ្អន់ហើយ យើងនាំគ្នាទៅអង្គុយជជែកលេងនៅកន្លែងកៀនងងឹត ។ ពួកធំៗបង្អាប់គ្នា ទៅវិញទៅមកថាមានទាក់ទងជាមួយស្មៀនធ្វើការ នៅប៊ុយរ៉ូរ៉េស៊ីដង់បារាំង ឬ នៅប៊ុយរ៉ូក្អាឡ ពីព្រោះកាលពីពេលចេញរាំលើកមុន គេសង្កេតឃើញអ្នកនេះលួចឲ្យកន្ទុយភ្នែកអ្នកនោះច្បាស់ណាស់។ អ្នកខ្លះទៀត និយាយសារភាពប្រាប់គ្នាពីការមិនពេញចិត្ត ចំពោះជីវភាពក្នុងវាំង ចំពោះការដែលហ្លួងមិនសូវរវីរវល់គិតគូរដល់ខ្លួន ព្រមទាំងអួតសរសើរពីការសប្បាយរីករាយនៃជីវភាពដែលពោរពេញទៅដោយសេរីភាពនៅខាងក្រៅវាំង ដែលប្រុសអាចតាមមើលស្រីបានដោយឥតភ័យខ្លាចជាប់គុក ដែលស្រីអាចតែងខ្លួនស្អាតបាតដោយមិនចាំបាច់លាក់លៀមពីភ្នែកពួកក្រុមវាំង។ គេជជែកគ្នាអែបមែរហូតដល់យាមទីពីរ ទើបនាំគ្នាទៅដេករៀងៗខ្លួន។ ខ្ញុំងងុយដេកធ្ងន់ក្បាល ប្រះដេកភ្លាមក៏លក់ភ្លាម តតមានគិតខ្វាយខ្វល់ដល់ពាក្យសំដីដែលពួកធំៗគេនិយាយគ្នានោះទេ ខ្ញុំស៊ីមួយថ្ងៃសម្រាប់រស់មួយថ្ងៃ តតមានភ័យព្រួយពីថ្ងៃស្អែក រស់ប្រៀបបាននឹងសត្វយ៉ាងនោះដែរ។

វិន័យ និង របៀបរៀបរយនៅក្នុងវាំង ត្រូវគេបោះបង់ចោលទាំងស្រុង។ វាំងសព្វថ្ងៃ ក៏មិនដូចវាំងកាលពីដើមដែរ ពីព្រោះអ្នកធំចេះតែមានគំនិតបង្កើតរឿងមិនល្អប្លែកៗគ្នាមិនចេះអស់ ម្ល៉ោះហើយអ្នកតូចតាចចាំតែយកម្រាប់តាម នរណាមិនចូលចិត្តយកតម្រាប់តាមគេទេ ក៏ត្រូវតែចាកចេញពីវាំងទៅនៅក្រៅវិញ។ មិនបានប៉ុន្មានឆ្នាំផង អស់អ្នកអស់នាង អ្នកភ្លេង អ្នករបាំ ក្រូរបាំ រហូតដល់អ្នកបំរើ សុទ្ធតែផ្លាស់ថ្មីទាំងអស់។

កាលពីដើម មានក្រុមល្ខោនបី តឡរនៅសល់តែមួយគត់ ក្រោមកិច្ចដឹកនាំនៃម្ចាស់ក្សត្រី ដែលសំអាងយកអំណាចខ្លួនជាកូនស្រីច្បងនៃស្តេចសោយរាជ្យមកធ្វើជាធំលើសគេទាំងអស់។ មុខងាររបស់លោកមានត្រឹមតែជ្រើសរើសស្រី

ក្មេងៗកូនអ្នកស្រែរំយីរំយារ មកបំពេញកន្លែងខ្វះចន្លោះតែប៉ុណ្ណោះ។ រឿងអស់នេះ ហ្លួងមើលមិនឃើញទេ ពីព្រោះទាំងយប់ទាំងថ្ងៃ លោកសម្ងំនៅតែក្នុងប្រាសាទជាញឹយ៉ុង។ សូម្បី ទិដ្ឋភាពនៅជុំវិញដំណាក់ហ្លួងក៏ប្លែកពីដើមដែរ អ្នកលក់នំចំណី អ្នកសុំទាន ចូលមកដល់ជិតដំណាក់ហ្លួង បង្កើតជាភាពក្រខ្វក់គ្រប់ទីកន្លែង។

ពួកមីដែលថា មកសុំនៅក្នុងវាំងនៅពេលក្រោយៗនេះទាំងប៉ុន្មាន វាគ្រាន់តែរៀនលាបម្សៅយីហ៊ុន រៀនពាក់ដៃពាក់ជើង ដើម្បីធ្វើជាលេសប៉ុណ្ណោះ តាមពិតវាមកលួចសំពត់អាវ មាសពេជ្ររបស់គេឯងរាល់គ្នា យកទៅកប់លាក់ទុកក្នុងកន្លែងណាមួយ រង់ចាំតែយប់ណាមានឱកាសល្អ វានឹងទៅកកាយយករបស់ទាំងនោះ ហើយលួចរត់ចេញពីវាំងទៅបាត់តែម្តង។ រាល់យប់តែងតែមានមីណាមួយលួចរត់ មិនសូវលោះខានឡើយ។

ពួកអ្នកធ្វើព្រះស្ងោយហ្លួង និង ពួកកូនចៅឧស្សាហ៍និយាយប្រាប់ខ្ញុំថា កាលគាត់ចេញទៅផ្សារ គាត់បានឃើញមីនេះមីនោះ ដែលធ្លាប់មកនៅវាំងបានប៉ុន្មានថ្ងៃ ហើយលួចរត់ចេញទៅវិញ ធ្វើឫកដូចជាសំធឹង ដើរទាក់ទងជាមួយចិនជាមួយបារាំង អួតសុទ្ធតែខ្លួនវាហ្នឹងជាពួកល្ងោនហ្លួង។

ជំនាន់នោះ មានតែពួកយើងមិនដល់ដប់នាក់ផង ដែលជាអ្នករបាំយកចិត្តទុកដាក់ក្នុងការងារគឺ លួនមិតសំអាង ម៉ាប៉ាន់ យ៉ាន វ៉ន ហើយនិងខ្ញុំ។ ពួកយើងសុខចិត្តនៅហាត់រៀនជាមួយគ្រូចាស់ៗ ជាជាងឆ្លៀតពេលទំនេរដើរអង្គុយលេងតតប្រយោជន៍ឯដំណាក់ហ្លួង។ ប៉ុន្តែក្នុងចំណោមអ្នកប៉ុន្មាននាក់នេះ មានតែយ៉ាន និង ខ្ញុំទេ ដែលហាក់ដូចជាលេចមុខខ្ពស់ជាងគេ។ ទោះបីពាក្យទំនាយរបស់អ្នកអង្គម្ចាស់ ដួងមធុរា ដែលលោកទាយទុកថា យើងពីរនាក់នឹងក្លាយទៅជាតារានៃក្រុមល្ងោនហ្លួងនោះ ពុំអាចសំរេចទៅបាន ដោយហេតុកាល:ទេស:ថ្មីវាប្រែប្រួលប្លែកពីដើមយ៉ាងណាក៏ដោយ ក៏ទឹកមុខញញឹមរបស់អ្នកគ្រូសម្តែងសេចក្តីពេញចិត្តចំពោះយើង វាជាកម្លាំងលើកទឹកចិត្តម្យ៉ាងដែរ ពេលណាយើងត្រូវចេញរាំលើឆាកម្តងៗ។

យ៉ាន និង ខ្ញុំ ត្រូវចេញរាំមុខអ្នករបាំទាំងពីរដួរជានិច្ច។ យើងមានសៀកកន្សែងសូត្រពណ៌ក្រហម ឬ សនៅខ្សែក្រវាត់រៀងខ្លួន ហើយកាលណាយើងចូលមកជិតគ្នា យើងលួចកេះ លួចក្តិចគ្នាទៅវិញទៅមកយ៉ាងពេញចិត្ត។ យើងពីរនាក់ជាគូរបាំឆើត អាចពាក់ពេទន់ភ្លន់ទៅតាមចង្វាក់ភ្លេងត្រូវតែខ្មោះ ប៉ុន្តែតមានឧណារវល់យកចិត្តទុកដាក់នឹងយើងប៉ុន្មានឡើយ ព្រោះសព្វថ្ងៃនេះគេរើសយកធ្វើជាតួឯក តែឧណាដែលជាទីពេញចិត្តរបស់ហ្លួង ឬរបស់ម្ចាស់ក្សត្រីប៉ុណ្ណោះ ទោះបីអ្នកនោះក្មានលក្ខណ:ជាអ្នករបាំក៏ដោយ។

ពួកអ្នកស្រួយល់ច្បាស់ណាស់ថា តួ យ៉ាន និង ខ្ញុំ ពុំអាចយកនរណាផ្សេងទៀតមកផ្លាស់ដំនួសបានទេ ប៉ុន្តែគាត់ក៏មិនដឹងធ្វើម៉េចដែរ សុខចិត្តតែនៅស្ងៀមទៅ ពីព្រោះសព្វថ្ងៃ មិសួនវាគាប់ជាងគេ វាត្រូវតែបានឡើងធ្វើតួឯកអញ្ចឹង។ ពេលចេញរាំម្តងៗ វាពាក់មាសពេជ្រស្រោចខ្លួន ពីព្រោះវាពូកែបញ្ឆោរចៅហ្វាយនាយ យកគាប់គួរកនរណាប្រៀបឲ្យស្មើពុំបាន ប៉ុន្តែតាមពិត វាគ្រាន់តែជាអ្នករបាំរាយរងប៉ុណ្ណោះ។

ហេតុនេះហើយ ទើបបានជាសព្វថ្ងៃគេត្រូវបង្ខំចិត្តជ្រើសរើសយកពួកអ្នកមិនចេះអីសោះ មកដាក់បំពេញកន្លែងហាត់រាំ និង រត់ទៅពឹងអ្នករបាំដើងចាស់ដូចយ៉ាង ម៉មនូ ម៉មប្រឹម ម៉មសំអយ ជាដើមដែលគេបំភ្លេចចោលទៅហើយនោះ ឲ្យត្រឡប់មកជួយបង្ហាត់ក្មេងសារក្រោយផង។

ខ្ញុំនេះលួងពេកណាស់ ពុំអាចកាត់យល់បានពីអំពើអយុត្តិធម៌ផ្សេងៗ ដែលគេធ្វើមកលើខ្ញុំបានទេ។ ខ្ញុំចេះតែគិតថាបើខ្ញុំខិតខំធ្វើការបានល្អ គង់នឹងមានគេមើលឃើញ ហើយគេនឹងលើកខ្ញុំឲ្យធ្វើជាតួឯកមិនខាន។ ពេលចេញរាំម្តងៗ ខ្ញុំមួម៉ៅណាស់ គេឲ្យខ្ញុំធ្វើតែតួរាយរង អត់បានស្លៀកពាក់សំពត់អារល្អនឹងគេ បានពាក់តែមកុដជ្រលក់ទឹកមាសតែប៉ុណ្ណោះ។ ជួនកាលខ្ញុំឈឺចិត្តទ្រាំមិនបានទាល់តែស្រក់ទឹកភ្នែកនៅពេលឃើញគេប្តូរមិនឲ្យខ្ញុំរាំតួដែលខ្ញុំហាត់រាប់ខែមកហើយ។ ការខំប្រឹងប្រែងរបស់ខ្ញុំ ពុំបានធ្វើឲ្យម្ចាស់ក្សត្រីពេញចិត្តទេ ប៉ុន្តែលោកហាក់ដូចជាជិនឆ្អន់នឹងខ្ញុំកាន់តែខ្លាំងឡើងៗជាលំដាប់។

សូម្បីពួកមីកូនចៅម្ចាស់ក្សត្រី ក៏បញ្ចេញឫកពេបជ្រាយដាក់ខ្ញុំខ្លាំងណាស់ដែរ ដែលជាហេតុធ្វើឲ្យខ្ញុំយល់បានខ្លះថាគនីតក្រងភ្លឹងសួតស្លាប់របៀបខ្ញុំនេះ ពុំមែនជាទីពេញចិត្តនៃម្ចាស់ក្សត្រីឡើយ ពីព្រោះលោកបានសាកល្បងទាញខ្ញុំឲ្យទៅរស់នៅក្នុងចំណោមកូនចៅលោកច្រើនដងណាស់ហើយ ពុំដែលបានសំរេចសោះ។

យ៉ាន ក៏មិនមែនសប្បាយចិត្តជាងខ្ញុំប៉ុន្មានដែរ ប៉ុន្តែធ្វើម៉េចគ្នាជាកូនកំព្រាគ្មានទីពឹង ចេះតែទ្រាំទៅ ឲ្យតែមានបាយស៊ី មានដំបូលជ្រក ប៉ុណ្ណឹងវាគ្រប់គ្រាន់ណាស់ហើយ វាមិនចង់យកគាប់គួរ ជាមួយម្ចាស់ក្សត្រី ជាមួយហ្លួងអ្វីទាំងអស់។

តឡូវ ខ្ញុំក៏ខ្លាចហ្លួងណាស់ដែរ បើកុំតែអញ្ចឹងខ្ញុំមិនបាច់ទៅហាត់រាំ នាំតែនឿយហត់អត់ប្រយោជន៍ទេ ចាំមើលតែស្អែកឡើងដល់ពេលចេញរាំ យប់នេះទៅនាយអោយជាមួយហ្លួងមួយសន្តុះ ច្បាស់ជាបានធ្វើតួឯកមិនខាន។

ហេតុដែលនាំឲ្យខ្ញុំខ្លាចហ្លួង គឺថ្ងៃមួយជាជនខ្ញុំគាល់បំរើហ្លួង ខ្ញុំអង្គុយជជែកគ្នាលេងជាមួយពួកម៉ាកពីរ-បីនាក់ នៅលើក្បាលជណ្តើរប្រាសាទជាញ៉ុង រង់ចាំទម្រាំហ្លួងភ្ញាក់ពីផ្ទំវិញ។ ពេលនោះហ្លួងឲ្យគេហៅមីស៊ុន និងមីវ៉ែន ចូលទៅក្នុងបន្ទប់ផ្ទាល់ព្រះអង្គ ហើយបិទទ្វារចាក់សោជាប់។ ប្រហែលមួយម៉ោងក្រោយមក ទើបឃើញវាទាំងពីរនាក់ចេញមកវិញ

ធ្វើឫកបែបអៀនប្រៀន ភ្នែកក្រហម សំពត់ខ្មៅកខ្មុកខ្មេចខ្មីអស់ ហើយវារត់ទៅសម្លុំនៅក្នុងបន្ទប់ដេកបាត់។ ពួកជំទាវតេនាំគ្នាសើចគិល ដែលជាហេតុអាចឲ្យខ្ញុំ កាត់យល់រឿងហេតុសព្វគ្រប់ទាំងអស់បានដោយងាយ។ បន្ទាប់ពីមានរឿងនេះបន្តិចមក ដល់វេនហ្លួងហៅនាងម៉ាឡា ដែលទើបនឹងគ្រប់ការថ្មីៗឲ្យចូលក្នុងបន្ទប់ម្តង ហើយមួយសន្ទុះក្រោយមកស្រាប់តែឮហ្លួង ស្រែកឡឡាដេញវាថាឲ្យទៅលាងក្តិតសិន ហើយត្រឡប់ចូលមកវិញ។ ខ្ញុំពុំដែលគិតថារឿងវ៉ាវបែបនេះ នឹងកើតមានចំពោះខ្លួនឡើយ ព្រោះខ្ញុំធ្លាប់តែស្រឡាញ់ហ្លួងទុកដូចជាជីតាខ្ញុំយ៉ាងនោះដែរ ម្ល៉ោះហើយខ្ញុំភ្ញាក់ផ្អើលខ្លាំងណាស់ នៅពេលឮពួកជំទាវគេនិយាយបំភ័យថាខ្ញុំឆ្កួត ថាកាលណាគេចូលមកបម្រើហ្លួង គេត្រូវតែស្រឡាញ់ហ្លួងដូចស្រឡាញ់ប្តីអញ្ចឹង។

បន្ទាប់ពីកើតឧប្បត្តិហេតុនេះមក ថ្ងៃមួយមីពួកម៉ាកម្នាក់ក្បាលខូច វាធ្វើជានិយាយលេងស្រែកខ្លាំងៗ ពីរឿងខ្ញុំខ្លាចហ្លួង ទាល់តែឮដល់លោក, លោកខំសាកសួរគេឯងរកដើមហេតុ ដែលនាំឲ្យខ្ញុំខ្លាចលោកយ៉ាងនេះ ហើយលោកដូចជាចង់លេងសើចនឹងសភាពល្ងង់ខ្លៅរបស់ខ្ញុំខ្លាំងណាស់។ រាល់ថ្ងៃខ្ញុំខំធ្វើការប្រយ័ត្នប្រយែងក្រៃលែង ដើម្បីជៀសវាងកុំឲ្យហ្លួងស្តីបន្ទោស ប៉ុន្តែខ្ញុំពុំបានគិតឃើញថាលោករឹតតែស្អប់ខ្ញុំលើសដើម ដោយហេតុលោកពុំអាចសំរេចបំណង ដែលក្របួចមាត់ប៉ងប្រាថ្នារូបខ្ញុំតាំងពីយូរហើយនោះទេ។ ជួនកាលលោកគំរាមកំហែងគិតធ្វើបាបខ្ញុំ ជួនកាលលោកបណ្តុះបង្អាប់ដោយប្រើពាក្យមានន័យជ្រៅ គិតទៅឈឺក្បាលទម្រាំយល់។ ថ្ងៃមួយខ្ញុំកាន់ខ្សៀអាភៀនយកទៅថ្វាយលោកដែលកំពុងផ្តំលើត្រែ ដោយមានអាកប្បកិរិយាភ្លឺក ហាក់ដូចជាកំពុងគិតទៅរឿងអ្វីមួយផ្សេងទៀត លោកសំលាន់មាត់ថា:

- ស្តាយណាស់រី មនុស្សមិនគួរស្អាតហើយភ្លើដល់ម្ល៉ឺងសោះ! សារ៉ាម៉ានី ដូចគោអញ្ចឹង ប្រហែលជាវាមានសាហាយនៅឯណា ចង់រត់ចោលអញហើយមើលទៅ.....!។

ខ្ញុំធ្វើជាមិនឮ ព្រោះខ្ញុំមិនយល់ថា ហ្លួងចង់និយាយពីអ្វីទេ។ នេះជាសំណាងរបស់ខ្ញុំហើយ ដែលទេវតាលោកជួយបិទបាំងមិនឲ្យខ្ញុំយល់អ្វីទាំងអស់ បើកុំតែអញ្ចឹង ម្ល៉ោះសមខ្ញុំនឹងត្រូវធ្លាក់ខ្លួនទៅក្នុងចំណោមប្រពន្ធដ៏ច្រើនរាប់មិនអស់របស់ហ្លួងមិនខាន។

ពេលវេលាចេះតែធ្វើដំណើរទៅមុខជាល់ដាប់...
ថ្ងៃមួយ ពេលដល់ម៉ោងហ្លួងដើរបាត់ផ្តំ មីងទ្រែតអ្នកលក់មាសពេជ្រ មកសុំចូលគាល់ដើម្បីថ្វាយហ្លួងទតគ្រឿងអលង្ការខ្លះ ក្រែងលោកត្រូវការទិញ។ ហ្លួងអនុញ្ញាតឲ្យគាត់ចូលមក គាត់ក៏អង្គុយរៀបឫកស្រួលបួរចួចហើយដាក់ប្រអប់ដែកនៅលើកម្រាលព្រំ ហើយលូករាយកកញ្ចប់តូចៗច្រើនណាស់ចេញពីក្តាងស្ពោងដែលព្យួរនឹងខ្សែក្រវាត់ទម្លាក់ទៅក្រោមក្បាលពោះគាត់។ ហ្លួងក្រពាត់ដៃ ដើរទៅដើរមកនិយាយថា:

- មីងទ្រែត ឯងចំជាមនុស្សមានទ្រព្យសម្បត្តិច្រើនមែន សូម្បីអាកន្លែងហ្នឹងក៏មានមាសពេជ្រដែរ, នែ! បើមនុស្សធម្មតា លូកទៅកន្លែងហ្នឹង ច្បាស់ជាបានមមិះជាប់ដៃស្រមាមមិនខាន។

មីងទ្រែត ញញឹមមិនរវល់ឆ្លើយតបថាម៉េច គិតតែតម្រៀបកងដៃដាំពេជ្រ ចិញ្ចៀនត្បូង ក្រវិល ទំហ៊ូដាំពេជ្រ ថ្វាយហ្លួងទត។

ពេលនេះជាពេលដើមខែ មីងទ្រែត គាត់ប្រសប់រើសពេលវេលាល្អណាស់ គឺគាត់មកចំលើពេលដែល ហ្លួងកំពុងសម្បូរណ៌លុយ។ ថ្ងៃនេះជាវេនខ្ញុំកាន់សោ ហ្លួងក៏ប្រើឲ្យខ្ញុំទៅយកកាបូបដាក់ក្រដាសប្រាក់ពេញហៀរមកថ្វាយ។ ខ្ញុំធ្វើតាមបញ្ជាយ៉ាងប្រយ័ត្នប្រយែងក្រៃលែង ដោយភ័យខ្លាចក្រែងត្រូវហ្លួងដេរបញ្ឆោរដូចមីពួកម៉ាកខ្ញុំកាលពីវេនទីបីនោះទៀត ពីព្រោះមីនោះគេឲ្យយាមមើលទូ វាមើលតែទូទទេ បណ្តោយឲ្យម៉មប្រឹម លួចយកលុយទៅសងបំណុលគាត់ឯផ្សារអស់រលីង តែមួយរៀលក៏ភ្នាននៅសល់ផង ។ ហ្លួង រាប់លុយទិញគ្រឿងអលង្ការ ចេញលុយដល់ដៃឲ្យខ្លះ ខ្លះប៉ុន្មានដំពាក់សិន។ មីងទ្រែត ថ្វាយបង្គំលា ហើយដើរដិនៗចេញទៅវិញ ដាក់ស្មោងលុយលាក់ក្នុងអាវជិតល្អណាស់។

ខ្ញុំអង្គុយបត់ជើងក្បែរហ្លួង រង់ចាំក្រែងលោកមានប្រើធ្វើអ្វីផ្សេងទៀត។ អស់អ្នក-អស់នាងជាច្រើន ខំនាំគ្នាតែងខ្លួនលាបទឹកអប់ ប្រេង ម្សៅ ក្រអូបឈួយឈប់ ដើម្បីចូលមកគាល់ហ្លួង សង្ឃឹមក្រែងបានអ្វីបន្តិចបន្តួចនឹងគេ។ ហ្លួងសម្លឹងមើលខ្ញុំតប់ប្រិចភ្នែក ហើយហុចក្រវិលមួយគូមកឲ្យខ្ញុំ ប៉ុន្តែនៅពេលដែលខ្ញុំលូកដៃទទួលទាំងចិត្តសប្បាយរីករាយចំពោះរង្វាន់ដ៏ល្អនេះ ស្រាប់តែលោកដកដៃចេញវិញ ព្រមទាំងនិយាយបញ្ជីចិត្តថា :

~ ទេ! ឯងនេះខ្ចិលណាស់ កុំអាលយកអី ចាំថ្ងៃក្រោយទៅចាំយក ហើយលោកប្រទានក្រវិលនោះទៅឲ្យ មីប៉ុនដែលវាផ្លៀតចោលកន្ទុយភ្នែករបៀបចង់អកមើលមកខ្ញុំទៀតផង។ ខ្ញុំឈឺចិត្តស្រក់ទឹកភ្នែកជ្រោក រត់ត្រឡប់មកកាន់បន្ទប់ដេកវិញ ស្រាប់តែប្រទះឃើញម៉ែដែលមកលេងនឹងម៉មនូ។ ចាប់តាំងពីពេលត្រឡប់មកពីស្រុកបារាំងវិញ ហ្លួងមិនសូវរវីរវល់នឹកនាដល់ ម៉មនូ ដូចពីដើមទេ ប៉ុន្តែទោះជាយ៉ាងណាក៏ម៉មនូ សន្យាថានឹងជូនខ្ញុំទៅសុំគ្រឿងអលង្ការពីហ្លួងឲ្យបាន ព្រោះគាត់មិនស្គេចខ្ញុំដែលជាកូនចៅចាស់ ធ្លាប់បម្រើគាត់តាំងពីដើមមកនោះទេ។

ព្រឹកមួយ ត្រូវរេនគាល់បំរើហ្លួង ខ្ញុំអស់កម្លាំងពេកក៏ប្រះដេកទៅលើពូកក្នុងបន្ទប់ដែលហ្លួងទើបនឹងដើរចេញទៅក្រោយពីផ្តំសោយអាភៀនអស់ពេលដ៏យូរ។ ពេលនោះស្រាប់តែ ម៉មនូ ចូលទៅដល់និយាយថា:

~ ក្រាបទូល! ខ្ញុំម្ចាស់អាណិត សារ៉ាម៉ានី ណាស់ ព្រោះគ្មានមាសពេជ្រពាក់នឹងគេសោះ។ វានេះជា ក្តួយរបស់ខ្មោចលោក អគ្គមហាសេនា ជាកូនគេអ្នកត្រឹមត្រូវ ហើយធ្វើការម៉ឺងម៉ាត់ល្អណាស់។
~ ស្អី! ធ្វើការម៉ឺងម៉ាត់? (ហ្លួងសឹកសំដីមកឲ្យវិញភ្លាម) មើលវា! គេធ្វើការគ្រប់គ្នា វាទៅសម្លុំដេក បើម្ហឹងៗឲ្យអញស្រឡាញ់វាយ៉ាងម៉េចនឹងកើត។

លោកអត់និយាយថាម៉េចតទៅទៀតទេ..... ម៉មនូ ដើរចេញទៅវិញដោយឆ្លៀតលូកក្តិចដាស់ខ្ញុំឲ្យភ្ញាក់ផង ប៉ុន្តែខ្ញុំមានដេកលក់ឯណា នរណានិយាយថាអីក៏ខ្ញុំស្តាប់ឮទាំងអស់។

ខែបន្ទាប់មក ដល់ពេលចែកគ្រឿងអលង្ការជាថ្មីម្តងទៀត ខ្ញុំនឹកទៅដូចជាតូចចិត្តខ្លាំងពេក មិនខ្ចីចង់បានអ្វីទាំងអស់ ទើបមិនរវល់ទៅមើលហ្លួងចែកនឹងគេ។ ហ្លួងកាន់ក្រវិលពីរគូ មួយគូតូចលោកប្រទានឲ្យមីយ៉ាន ហើយប្រើគេឲ្យមកហៅខ្ញុំទៅយកអាមួយគូធំ ប៉ុន្តែមីយ៉ាន វាមានគំនិតខូចទទួលហ្លួងថា ត្រចៀកវាធំជាង ត្រចៀកខ្ញុំ បើវាបានពាក់ក្រវិលធំទើបសមជាង ហើយលោកក៏ប្រទានអាធំនោះឲ្យវាទៅ។

ខ្ញុំបានអាតូចតតពេញចិត្តសោះ ហើយហ្លួងក៏ដឹងថាខ្ញុំមិនពេញចិត្តដែរ ទើបលោកបង្គំឲ្យខ្ញុំពាក់នៅនឹងមុខលោកតែម្តង ក្រវិលនេះខ្ញុំពាក់ជាប់នឹងត្រចៀករហូតដល់សព្វថ្ងៃ តតដែលដោះដូរទៅណាឡើយ។ ដល់ពេលចែកចិញ្ចៀន លោកស្តីឲ្យតិតសាមែច្រើនណាស់ ព្រោះក្រចកវាមិនស្អាត។ ដល់វេនខ្ញុំ លោកប្រទានចិញ្ចៀនបីវង់ ព្រមទាំងសរសើរថាខ្ញុំចេះថែដៃជើងបានស្អាតទៀតផង។

អ្នកដែលគាប់ចិត្តហ្លួង ពុំមែនសុទ្ធតែបានទទួលរង្វាន់ច្រើនជាងគេនោះទេ គឺជេរបញ្ឆោរក៏ញយជាងគេ រំពាត់ក៏ត្រូវញឹកជាងគេ។

អ្នកដែលបានឡើងជាស្នំគាប់ចិត្តក្រោយពេលដែលម៉មនូ អស់បុណ្យទៅនោះគឺ វ៉ន, ស៊ុន និង ស្អាត ប៉ុន្តែតាមចិត្តហ្លួង ស្រឡាញ់ម្ចាស់ក្សត្រីជីប ជាចៅស្រីរបស់លោកលើសនរណាទាំងអស់។ នេះហើយ អំពើឆ្កួតលីលារបស់ស្តេច សមតាមពាក្យដែលប្រជារាស្ត្រតែងនិយាយថា “ស្តេច ក៏ដូចជាឆ្កែដែរ សូម្បី បងប្អូនកូនចៅឯង ក៏ចេះយកគ្នាជាប្តីប្រពន្ធទៅកើត” ។ ស្នំឯកទាំងនេះគ្មានអំណាចអ្វីជាធំដុំទេ ហ្លួងតែងនិយាយថា :

- អញមិនមែនភ្លើទេ, ពួកមីអស់ហ្នឹងវាគ្មានស្រឡាញ់អញសោះ, វាស្រឡាញ់តែលុយអញប៉ុណ្ណោះ។ ដូច្នេះ នរណាក៏យល់ដែរថា គណ្ឌរបស់ហ្លួង គ្រាន់តែជាអំពើខូចខិលមួយភ្លែតៗ ម្តងគាប់នឹងអ្នកនេះ ម្តងគាប់នឹងអ្នកនោះ រកប្រាកដប្រជាលើនរណាមួយពុំបានឡើយ។

ចំណែកខ្ញុំ ខ្ញុំមិនដែលត្រូវរំពាត់ទេ ប៉ុន្តែម្តងនោះខ្ញុំភ័យញ័រទន្ទ្រើក ស្មានថាមិនអាចគេចរួចពីរំពាត់ផ្តៅហ្លួងឡើយ។ តើខ្ញុំមានធ្វើអ្វីខុស? យ៉ាន រត់មកដាស់ខ្ញុំទាំងកណ្តាលយប់ ពេលដែលខ្ញុំទើបនឹងប្រុះដេកលក់លើក្រែក្តងបន្តប់ ម៉ែអួន ហើយទោះបីខ្ញុំដងឪកសួរវាយ៉ាងណា ក៏វាអត់ដឹងអីសោះ។ ខ្ញុំរកគិតមិនយល់សោះ តើមានរឿងអ្វី បានជាហ្លួងខឹងដល់ម្ល៉េះ? លោកប្រើឲ្យខ្ញុំយកកន្ទេលថ្មីបួនទៅជូន ម៉មនូ ម៉មប្រឹម ម៉មសំអយ និង ម្ចាស់ជីប ប៉ុន្តែខ្ញុំឃើញលោកកំពុងសោយព្រះស្ងោយ ក៏ឆ្លៀតចូលលេងផ្ទះម៉ែអួន មួយភ្លែតសឹន គិតថាចាំបន្តិចទៀតសឹមយកទៅជូនគេក៏បានដែរ ហើយដោយអស់កម្លាំងពេក ខ្ញុំក៏ដេកលក់មួយស្រឡេតទៅ។ តើកំហុសនេះល្មមត្រូវរំពាត់ដែរឬអ្វី?

មីពួកម៉ាកខ្ញុំអង្គុយក្រៀបក្រា វាសប្បាយចិត្តណាស់នឹងឃើញហ្លួងវាយខ្ញុំ វាបូញមាត់ចង្អៀលបង្ហាញរំពាត់ ដែលហ្លួងផ្អែកទុកនៅកៀនជញ្ជាំង។

ហ្លួងស្លៀកសារុងទទឹកដោកចេញមកស្រែកសួរគេថា តើខ្ញុំមកដល់ហើយឬនៅ? គ្រាន់តែក្រឡេកឃើញខ្ញុំភ្លាម លោកដេរបញ្ឆោរកបអាកាស ប៉ុន្តែលុះមកឃើញខ្ញុំក្រាបញាក់ទន្ទ្រើកក្បែរជើង លោកដូចជាអាណិតរកលើកដៃវាយមិនរួច ហើយនិយាយថា:

~ ឯងនេះបានចំជាលង់រកលេខដាក់ភ្នាន! បើគេអ្នកមានប្រាជ្ញាតែបន្តិចបន្តួច គេឃើញអញខឹងអញ្ចឹង មិនបានអីក៏គេចេះសុំទោសដែរ...។

ទោះបីចូលចិត្តក្តី មិនចូលចិត្តក្តី ក៏ខ្ញុំត្រូវតែធ្វើការបំរើហ្លួងឲ្យបានដិតដល់ជាទីបំផុត។ ហ្លួងខ្លួនឯងបាននិយាយប្រាប់ខ្ញុំថា:

~ អាល្មោនហ្នឹងវាបានការអី? វាមានប្រយោជន៍ដល់ ឪ-ម៉ែអញ, ដល់ខ្លួនអញ ត្រង់ណាខ្លះ? បើឯងខានទៅហាត់រាំច្រើនណាស់ម្ចាស់ឯងគេរកឯងបន្តិចបន្តួចប៉ុណ្ណឹង ប៉ុន្តែបើអញរកហៅប្រើមិនឃើញ អាហ្នឹងច្បាស់ជារំពាត់ស៊ីខ្នងហើយ។

ដើម្បីផ្គាប់ចិត្តចៅហ្វាយម្តងពីរនាក់អញ្ចឹង ខ្ញុំត្រូវធ្វើការនឿយហត់ទ្វេមួយជាពីរ ជាបី ក្នុងរយៈដប់បួនឆ្នាំ ដែលគេត្រូវការសម្រាកច្រើន ដេកច្រើនជាទីបំផុត ម្ល៉ោះហើយខ្ញុំឧស្សាហ៍ផ្លាក់ខ្លួនឈឺជាញឹកញយ។ យប់ខ្លះដែលពុំត្រូវវេនខ្ញុំយាមសោះ ពេលពាក់កណ្តាលអាធ្រាត្រកំពុងតែដេកស្ងាញ់ ស្រាប់តែមានគេមកដាស់ឲ្យទៅអង្គុយកំដរហ្លួងសោយស៊ុប ខ្ញុំ

ត្រូវដាស់កាហ៊ុន ឲ្យវាជួយស្មៀកពាក់ ជួយសំអិតសំអាងខ្លួន ហើយទៅអង្គុយកំដរហ្លួងក្នុងបន្ទប់ទទួលភ្ញៀវ នៃប្រាសាទបាញ់យុំង អង្គុយជុំវិញកន្ទេលដូចគេឯងទាំងអស់គ្នា ហើយស៊ីធ្វើឫកដូចជាឆ្ងាញ់ ដូចជាសប្បាយណាស់ ប៉ុន្តែតាមពិតខ្ញុំដេកលក់ក្តាងទៅហើយ។

តាំងពីពេលទើបនឹងឡើងសោយរាជ្យភ្លាមមកម្ល៉េះ ចិត្តគំនិតហ្លួងប្រែជាស្រពាប់ស្រពោនខ្លាំងណាស់។ ខ្ញុំឮគេនិយាយថា លោកកើតមានវិប្បដិសារីចំពោះរឿងអ្វីមួយដែលតាម លងបន្លាចអារម្មណ៍លោកទាំងយប់ ទាំងថ្ងៃ ទោះបីលោកខំសោយអាភៀនយ៉ាងណា ក៏ពុំអាចរំលាយអារម្មណ៍ររើរាយផ្តេសផ្តាសអស់នេះបានដែរ។ សូម្បីម្ចាស់ក្បាត្រីយើង ជាកូនស្រីច្បង និង ម្ចាស់សូរីវង្ស កូនប្រុសសម្លាញ់ចិត្ត ក៏ពុំអាចលួងលោមលោកឈ្នះដែរ។ ជួនកាល លោកយាងទៅសំរាកឯទីនាំងដែ ឬ ឯរោងបញ្ជា ឬជួនកាលទៀតលោកលួចចេញទៅដើរកំសាន្តក្នុងសួនច្បារឯកំពង់ដែ ក្រុមរាំងពីរបីនាក់ទៅចាប់ប្រអូសប្រទាញមកវិញមិនចង់ឈ្នះ។

លោកមិនមែនជាស្តេចសោយរាជ្យទេ ប៉ុន្តែជាអ្នកទោសដែលគេយាមល្បាតជាប់ទាំងយប់ ទាំងថ្ងៃយ៉ាងប្រយ័ត្នប្រយែងក្រៃលែង។ ក្តងរាំងមិនដឹងជាមានគិញបារាំងប៉ុន្មាននាក់ទេ ពួកអស់នោះយកលេសថាមកមើលត្រួតត្រាកិច្ចការក្នុងរាំង ប៉ុន្តែតាមពិតគឺគេមកឃ្លាំមើលហ្លួងនេះឯង។

លោកមហាមន្ត្រីប្រសប់លើកជើងបារាំងណាស់ ដើម្បីការពារអំណាចគាត់ ហើយគាត់មកល្បួងលួងលោមទាល់តែហ្លួងសុខចិត្ត លះបង់ឯករាជ្យ លះបង់ប្រទេសទាំងមូលឲ្យទៅជនបរទេស ដើម្បីជាផ្តួរយករាជ្យបល្ល័ង្កមកអង្គុយសោយរាជ្យត្រួតត្រាលើតែផ្ទៃរាំងមួយក្រវិចតូចប៉ុណ្ណោះ។

ទុក្ខក្រៀមក្រំគ្របដណ្តប់លើផ្ទៃរាំងទាំងមូល ដែលប្រែជាគ្មានរបៀបរៀបរយ រកកលតែនឹងធ្លាក់ទៅជាចំណីនៃពួកមនុស្សមានគំនិតពុតត្បុតអាក្រក់។ ចាប់តាំងពីពេលហ្លួង សុវណ្ណកោដ្ឋ ចូលទីវង្គតទៅ ពួកយើងរឹតតែហេងហាងរកទីពឹងឲ្យមាំមួនពុំបាន។ ហ្លួងថ្មីជាមនុស្សគ្មានអំណាច ជាអ្នកទោសគ្មានការទាក់ទងជាមួយរាស្ត្រ គ្មានអំណាចគ្រប់គ្រងលើប្រទេស បណ្តោយឲ្យជនបរទេសធ្វើអ្វីបានតាមចិត្ត។ រាំង គឺជាគុកនៅកណ្តាលទីក្រុង ជាលំនៅនៃមនុស្សខ្វាក់ ដែលឥតមើលឃើញដល់ទុក្ខវេទនានៃរាស្ត្រប្រជា ដែលត្រូវគេជិះជាន់។ ហ្លួងខ្លួនឯងក៏ដឹងច្បាស់ថា លោកមានអំណាចធ្វើអ្វីបានតាមចិត្ត តែនៅក្នុងរាំងនេះទេ។

ម្ល៉ោះហើយហ្លួងមិនដឹងធ្វើអ្វី មួយថ្ងៃៗគិតតែពីផ្ទំ សោយអាភៀន សោយក្រយ៉ា ជជែកលេង ហើយ ផ្ទំទៀត...។
យើងអាចសុំគ្រឿងឈើ ឬ ជាងពីក្តងរាំង ឲ្យទៅជួសជុលផ្ទះឪពុក-ម្តាយយើងដោយគ្មានភ័យព្រួយ ខ្លាចហ្លួងបដិសេធឡើយ។ ប៉ុន្តែហ្លួងទទួលតាមពាក្យសុំហើយ ច្រើនតែថាឲ្យយើងចាំខែក្រោយ ដោយលោកសារភាពប្រាប់តាមត្រង់ថាខែនេះលោកអត់មានលុយទេ ពីព្រោះមួយខែៗ លោកត្រូវចំណាយច្រើនណាស់ដើម្បីរៀបចំទទួលភ្ញៀវជារាំង ដើម្បីជូនវត្ថុអនុស្សាវរីយ៍ដ៏មានតម្លៃចំពោះគេ...។

កាលណាអជ្ញរកគ្មានជែកមិនបាន លោកនិយាយប្រាប់យើង ពីរឿងកាលលោកនៅក្មេងទៅរៀនឯក្រុងបាងកក ពីរឿងដែលលោកទើបនឹងចេះលេងស្រីជាលើកដំបូង ដោយឆ្លៀតអួតថាពេលកំពុងពេញកម្លាំង មួយយប់លោកអាចលេងស្រីដប់នាក់ក៏បានដែរ។ ដោយឃើញពួកយើងភ័យធ្វើមុខស្លើ លោកសើចសប្បាយខ្លាំងណាស់។

ល្ងាចមួយនោះ ហ្លួងដើរចេញពីគុសោយក្រយា ដើរក្រឡឹងព័ទ្ធជុំវិញអស់អ្នកអស់នាងដែលកំពុងអង្គុយដំកង់បរិភោគបាយនៅលើកន្ទេល ហើយចែកបារីស៊ីហ្គារ៍ឲ្យយើងមួយម្នាក់ៗ ព្រមទាំងនិយាយដោយរីករាយមកកាន់យើងថា:

~រី! ពួកក្មេងៗ អញតវ៉ាយកខេត្តបាត់ដំបង និង ខេត្តអង្គរ (១០) ពីសៀមបានមកវិញហើយ អញនាំឯង ទាំងអស់គ្នាទៅវាំងថ្វាយទេវតារក្សាទឹកដីនៃខេត្តទាំងពីរនោះម្តង...។

ការធ្វើដំណើរលើកនេះពុំបានធ្វើឲ្យយើងភ្ញាក់ផ្អើលដូចកាលមុនចេញដំណើរទៅស្រុកបារាំងទេ។ អ្នកដែលធ្លាប់បានធ្វើដំណើរយ៉ាងកំសត់កម្រ ឆ្លងកាត់សមុទ្រធំមិនយល់កោះត្រើយម្តងរួចហើយនោះ វាហាក់ដូចជាថ្មីកមិនខ្លាចសព្វបើគ្រាន់តែជិះកប៉ាល់ឆ្លងទន្លេមួយប៉ុណ្ណោះទេ ប៉ុន្តែអ្នកឯទៀតដែលស្គាយមិនបានទៅស្គាល់ស្រុកបារាំង ម្តងណោះក៏ប្រថុយដើរមើលឲ្យស្គាល់ស្រុកទេសនឹងគេដែរ។

ការរៀបចំសម្រាប់ធ្វើដំណើរ ត្រូវចំណាយពេលអស់ជាច្រើនសប្តាហ៍ សោកឯការសមរជាំ ក៏មានដំណើរប្រព្រឹត្តទៅយ៉ាងសកម្មឡើងវិញដែរ។ យើងម្នាក់ៗ រៀបចំអីវ៉ាន់ប្រើប្រាស់ផ្ទាល់ខ្លួនយ៉ាងធ្ងិតធ្ងង់ក្រៃលែង។ ជាងចិនដេរស្បែកជើងម៉ូតបារាំងមកឲ្យយើងទាំងកន្ត្រក។ ហើយហ្លួងបង្ខំឲ្យយើងពាក់ស្បែកជើង ពាក់ចិញ្ចៀន ធ្វើខ្លួនឲ្យស្អាតដើម្បីទៅបង្ហួតអ្នកស្រុកបាត់ដំបង។ យើងដឹងថា តែងខ្លួនតាមបញ្ជាហ្លួង វាគ្មានស្អាតត្រង់ណាសោះទេ ឬ វានាំឲ្យគេពេបជ្រាយវិញផងក៏មិនដឹង។

(១០) ខេត្តសៀមរាប ។

ពេលរៀបចេញដំណើរទៅណាម្តងៗ វាជួនចំលើតែពេលអត់លុយ យាយម៉ែន ត្រូវជាសាច់ញាតិនឹងម្ចាស់ក្បត្តើ គាត់សម្បុរណ៍លុយណាស់ នរណាចង់ចងការប៉ុន្មានក៏បាន ប៉ុន្តែទាស់ត្រង់គាត់យកការថ្លៃពេក។ ខ្ញុំខ្ចីគាត់ហាសិបរៀលដល់សងវិញ គាត់កាត់យកប្រាក់ខែខ្ញុំអស់ទាំងដប់រៀល ទាល់តែគ្រប់ប្រាំបីខែ ទើបរួចជំពាក់។ ពុក និង ម៉ែ ជួលទូកមួយជិះតាមទៅជាមួយគេឯងដែរ ហើយគេមាននាំយកពួកបំរើ ប្រុសស្រី ទាហានរក្សាព្រះអង្គ បង្ការក្រែងមានចោរឌួញតាមផ្លូវ ក្រុមភ្លេងពិណពាទ្យ និង ភ្លេងបារាំង ព្រមទាំងមួបមុំគ្រប់មុខ មានតាំងពីទឹកម៉ាស៊ីនជាច្រើនពាងទៅជាមួយផង។

ថ្ងៃមួយ នៃរដូវរស្យា ហួង និង បរិពារទាំងអស់ មានចំនួនច្រើនរយនាក់ ចាកចេញពីវាំង ចុះសំបាន ចុះទូកដែលចង់សណ្តោងទៅនឹងកប៉ាល់ធំមួយ ហើយធ្វើដំណើរចេញទៅ។ ស្តេច និង នាម៉ឺនធំៗ សុទ្ធតែមានទូកជិះផ្ទាល់ខ្លួន។ ចំណែកអ្នកណាដែលចង់តាមទៅលេងនឹងគេក្រៅផ្លូវការ ក៏ជួលទូកជិះទៅជាមួយគេដែរ។ អ្នកបំរើ, ទាហាន និង អ្នកភ្លេងជិះប្រជ្រៀតគ្នាលើដំបូលកប៉ាល់ មានដាក់ចង្ក្រានឆ្នាំងគ្រប់គ្រាន់ទាំងអស់។

ក្បួនទូកចេញពីកំពង់ផែ ក្រោមសូរស័ព្ទហ៊ោកញ្ជ្រៀវគឹកកងនៃហ្វូងប្រជារាស្ត្រ ដែលឈរប្រជ្រៀតគ្នាកកកុញពេញមាត់ទន្លេ ហើយធ្វើដំណើរលឿនស្តេវឆ្ពោះទៅទន្លេសាប ដោយមានខ្សែទឹកជួយរុញច្រានផង។ ពេលនោះ ព្រលប់ងងឹតខ្លាំងណាស់ទៅហើយ មើលទៅក្រោយខ្នងឃើញពន្លឺភ្លើងព្រិចៗរាប់ពាន់ នៃព្រះរាជធានី ចាំងឆ្លុះកណ្តាលផ្ទៃអន្លង្គការ។

ខ្ញុំជិះលើទីនាំងសក្តិក្រសេម ចាំគាល់បំរើហ្លួងជាមួយអស់អ្នក-អស់នាងជាងសែសិបនាក់ ស្រីបំរើម្នាក់ និង ក្រុមរាំងម្នាក់ដែលប្រសប់អស្ចារ្យខាងជួសជុលខ្នោកងដៃ កងជើងរបស់ពួកល្ខោន។ ដើម្បីឲ្យបានការហ៊ានទៅជាមួយ ខ្ញុំយកវាទៅលាក់ជាមួយអ្នកបំរើ។ ពីក្រោយនិង ពីចំហៀងសង្ហាងយើង ឃើញសុទ្ធតែទូកតូច-ធំពាសពេញទន្លេ ហើយបន្តកន្តុយទៅវែងឆ្ងាយស្ទើរងុតកន្តុយភ្នែក។ ទូកតម្រៀបជិតៗគ្នាល្អណាស់ គេអាចដើរឆ្លងពីមួយទៅមួយបានយ៉ាងស្រួល។

នៅលើទីនាំងសក្តិក្រសេម ហ្លួងកំពុងសម្លុំផ្តុំក្តងបន្ទប់ធំជាងគេ។ អស់អ្នក-អស់នាង ដេកប្រគាក់ប្រគងលើគ្នាក្តងមុងធំៗដែលចងលាតសន្ធឹងនៅកណ្តាលកប៉ាល់ ខ្លះដេកលក់ ខ្លះនៅនិយាយដដែកគ្នាខ្សឹបខ្សាវនៅឡើយ។ ខ្ញុំអង្គុយក្រៅមុងសម្លឹងមើលទៅច្រាំង ឃើញខ្មៅទទុងក្រោមផ្ទៃមេឃស្រឡះល្អរល្អើ មានពពកឯណោះមួយដុំ ឯណោះមួយដុំ... យូរៗម្តង ស៊ីរ៉ែនកប៉ាល់បន្លឺឡើងជាសញ្ញាប្រាប់ឲ្យទូកដែលកំពុងធ្វើដំណើរឆ្លងកាត់ទន្លេ ចៀសចេញពីផ្លូវយើង។

យើងឆ្លងហួស អន្លង់រាជ ដែលជាកន្លែងលាក់ខ្លួនពួនអាត្មា នៃត្រីធំៗប៉ុនខ្លួនមនុស្ស សម្តែងមាន់រងាររសាត់តាមរលកទឹកពីខាងលិចភ្នំឧដុង្គ មកប៉ះនឹងត្រចៀកយើងឮល្វើយៗត្រូវ ស្រដេះស្រដោចក្នុងចិត្តក្រៃលែង។

ជាតុអាកាសត្រជាក់ខ្លាំងណាស់! មូសហើរប្រណាំងនឹងទូកតាមខាំយើងជាប់រហូត មានតែផ្សែងជារំទេដែលអាចបណ្តេញវាបាន។ ខ្ញុំវែកមុងចូលទៅប្រៃដេកដើម្បីយកកម្លាំងទុកសំរាប់ចូលវេនគាល់បំរើហ្លួងនៅពេលព្រឹកស្អែក។ ក្រោមពន្លឺចង្កៀងប្រទីប ខ្ញុំឃើញពួកស្រីៗដេកអូសរណែលប្រជ្រៀតគ្នា។ លួនកេះក្បួយដៃខ្ញុំ ហើយខ្សឹបប្រាប់ឲ្យខ្ញុំមើលទៅកៀនក្បែរបន្ទប់ហ្លួងតង់។ ខ្ញុំពិនិត្យមើលយូរណាស់ នៅតែមិនស្គាល់ថាជានរណា ឃើញតែស្រីពីរនាក់ របូតអាវ របូតសារុង ចេញអស់ពីខ្លួនស្រាតនន្ទល កំពុងឱបរឹតគ្នា អង្អែលដោះ អង្អែលក្តិតគ្នា។

~ លួន! លួន! (ខ្ញុំនិយាយតិចៗ) ពួកវាធ្វើអីហ្នឹង?
~ កុំមាត់! ទុកឲ្យគេធ្វើអីក៍ធ្វើទៅ (លួន ឆ្លើយតបមកវិញ) សារ៉ាម៉ានឹងង មើលមិនស្គាល់ទេហ្អែ? មីយ៉ាន ហើយនិង បងវា កំពុងលេងគ្នាណា!... ។

ស្អែកឡើងយើងមកដល់កំពង់ឆ្នាំង។ ខ្ញុំខានមកឃើញស្រុកនេះជ្រាំ ឬ ជ្រាំមួយឆ្នាំហើយ ប៉ុន្តែហាក់ដូចជាគ្មានឃើញប្លែកត្រង់ណាសោះ ចម្លែកតែត្រង់មានដោតទង់ជ័យនៅតាមមាត់ផែ មាននាម៉ឺន រាជការ និង មនុស្សច្រើនកុះករមកឈរង់ចាំទទួលហ្លួងប៉ុណ្ណោះ។ ក្រុមភ្លេងអ្នកស្រុកកំពង់ឆ្នាំង ចាប់ប្រគុំសំដែងពាស្ងាតមន៍ថ្វាយហ្លួង ហើយក្រុមភ្លេងវាំងក៍ប្រគុំឆ្លើយតបវិញយ៉ាងសប្បាយរីករាយ។ នៅលើផែ មានបារាំងរាងក្មេងម្នាក់ ឈរនិយាយស្តាដៃស្តាជើងជាមួយបើបករបស់ហ្លួង។ ពួកយើងដណ្តើមគ្នាមើលបារាំងនោះចំហមាត់ ពីព្រោះមានអ្នកខ្លះនិយាយថា ដូចជាធ្លាប់ឃើញគាត់នេះម្តងនៅឯ ស្រុកម៉ារ៍សី ប៉ុន្តែ ខ្ញុំយល់ច្បាស់ថា នេះគ្រាន់តែជាឫកមាយាធ្វើឲ្យគេកោតថា វាធ្លាប់បានទៅស្គាល់ស្រុកបារាំងតែប៉ុណ្ណោះ។ ពួកវាស្លៀកពាក់អញ្ចឹង ដើម្បីបង្ហូតអ្នកស្រុកឲ្យគេកោតវា ប៉ុន្តែខ្ញុំយល់ថាសម្លៀកបំពាក់នេះពុំមែនជាការសមរម្យទាល់តែសោះ ហើយវាថែមទាំងអាចធ្វើឲ្យគេមានគំនិតយល់ឃើញមិនល្អ ចំពោះស្រីក្តងវាំងទៀតផង។

ហួសពីកំពង់ឆ្នាំងទៅ កប៉ាល់អត់មានតាមសណ្តោងទៀតទេ គឺយើងត្រូវបន្តដំណើរដោយចែវនឹងដៃម្តង។ នៅត្រង់កន្លែងចូលទៅកាន់បឹងធំ មានភ្នំអមសង្ហាង ហើយភ្នំដែលនៅខាងកើតនោះឈ្មោះថា ភ្នំនាងកង្រី។

ក្រាន់តែទៅដល់ជើងព្រៃស្លាម ក្បួនទូកបំបែកគ្នាចេញអស់។ ពួកម៉ាឡាយូមាឌមាំ ជួតក្បាលក្រហម ឈរពីមុខពីក្រោយទូក ចែវស្រុះគ្នាដោយស្រែកច្រៀងបន្ទរចង្វាក់ជាភាសាសាសន៍គេថា "ហៃអើម៉ារីរ៉ា" ញ៉ាំងទូករាប់រយឲ្យលឿនទៅមុខ តាមចន្លោះដើមឈើលិចដល់មែកដោយសារទឹកជំនន់ នៃទន្លេសាប។

យើងធ្វើដំណើរតាមទិសខាងជើង វែកឆ្ងាយកាត់ព្រៃលិចទឹកនៃខេត្តស្នោង ជីក្រែង និង សៀមរាប.... ដំណើរនេះប្រព្រឹត្តទៅអស់រយៈពេលជាច្រើនថ្ងៃ ហើយពីមួយថ្ងៃទៅមួយថ្ងៃ យើងកាន់តែរំភើលចូលជ្រៅឡើងៗ ទៅក្តងបរិវេណនៃទន្លេសាប។

ហ្លួងគិតតែសោយអាភៀន ចាក់ម៉ាស៊ីនច្រៀងស្តាប់ លើចលេងជាមួយស្រីអ្នកគាល់បំរើ។ ជួនកាល លោកចេញមកក្រៅបន្ទប់ ស្លៀកសារុងសំយេះហួសនិត ពួកម៉ាឡាយូអ្នកចែវទូក ឱនមុខ ឬ ងាកមុខចេញ មិនហ៊ានមើលដោយក្តីអៀនខ្មាស។ ប៉ុន្តែដល់ឃើញគេអៀនខ្មាសមិនហ៊ានមើលអាកប្បកិរិយាអាវ៉ាឡកររបស់ខ្លួនយ៉ាងនេះ ហ្លួងបែរជាសើចសប្បាយទៅវិញ។

ខ្យល់បក់មកមួយរឹប បណ្តាលឲ្យក្បូនទូកឃ្លេងឃ្លោង ញ័ងអ្នកដំណើរឲ្យភ័យរញ៉ូរញ៉ារ ប្រញាប់ស្រូតរូតដំណើរឲ្យឆាប់បានដល់ដើមឈើណាមួយ គ្រាន់នឹងទីពឹងជាបណ្តោះអាសន្នសិន។ អស់អ្នក អស់នាង យំសស្រាក រត់ទៅឱបជើងហ្លួងឲ្យជួយ ប៉ុន្តែឲ្យលោកធ្វើម៉េច បើលោកកំពុងតែភ័យភ្នែកនៅកញ្ចឹងកដែរ។ មីស្អាត វាក្អួតចាក់ទឹងហ៊ុងហោង អ្នកខ្លះទៀតធ្លាក់ខ្លួនឈឺដោយផឹកទឹកមិនស្អាត ពីព្រោះទូកអ្នកចុងភៅ ធ្វើដំណើរមិនដែលទាន់គេទេ។

មកដល់កន្លែង មានដើមឈើច្រើនគួរសម ហ្លួងបែបដូចជាអន់ភ័យបន្តិច ក៏តាំងស្រែកដេរបញ្ជាអ្នកធ្វើបាយ ដែលចង់បង្អក់កូនចៅលោកឲ្យដាច់ពោះស្លាប់។ នៅទីបញ្ចប់ យើងបានមកឃើញដីគោកមួយកន្លែង គេក៏ផ្អុំត្រៃហៅប្រមូលទូកទាំងអស់ឲ្យមកជួតជុំសំរាកនៅកន្លែងនេះសិន។ ត្រង់កន្លែងឆ្នេរខ្សាច់ដែលយើងចុះចតនេះ យើងអាចមើលទៅគ្រប់ទិស គ្មានទើសទាក់អ្វីទាំងអស់។ នៅខាងក្បាលហួសឆ្ងាយពីបឹងទន្លេសាបទៅទៀត ខ្ញុំឃើញភ្នំពោធិ៍សាត់ និង ភ្នំក្រវាញ ហើយមាននរណាម្នាក់ ឡើងលើដំបូលទូកមើលទៅខាងជើងឯណោះ ឃើញរហូតដល់ទៅភ្នំគូលែន។

មិនបានប៉ុន្មានម៉ោងផង ទីដែលធ្លាប់តែស្ងាត់ជ្រងំគ្មានមនុស្សរស់នៅសោះ បានក្លាយទៅជាបូរីហ្លួង អ៊ូអរសប្បាយក្រៃលែង។ អ្នកចុងភៅ និង ចោយធ្វើការញាប់ដៃជើង រហូតដល់ហ្លួង និង អស់អ្នក-អស់នាងបានសោយ និង បរិភោគ យ៉ាងឆាប់ទាន់ចិត្ត។ ក្រោយពេលបាយ ហ្លួងចែកលុយឲ្យយើងប្រាំរៀលម្នាក់ ដើម្បីលេងបៀថ្វាយលោកទតឲ្យសប្បាយភ្នែកម្តង។ ខ្ញុំមិនចេះលេងបៀនឹងគេ គិតថាទុកលុយនេះសម្រាប់ទិញនំបរិភោគនៅពេលធ្វើដំណើរទៅដល់ផែខាងមុខ ប៉ុន្តែហ្លួងមិនព្រមឲ្យខ្ញុំទុកលុយទេ លោកកំញើញថា បើខ្ញុំមិនលេងបៀ លោកយកលុយវិញឥឡូវហ្នឹង។ ជាសំណាងល្អ កំពុងតែនិយាយ ស្រាប់តែទូកម្ចាស់ក្បូត្រីមកដល់ ហើយហ្លួងរវល់តែបែរទៅគិតរឿងថ្មី ភ្លេចរឿងខ្ញុំសូន្យឈឹង។

ចាប់តាំងពីពេលទើបនឹងចេញពីភ្នំពេញមក ម្ចាស់ក្បូត្រីបានខិតខំខ្លាំងណាស់ ដើម្បីឲ្យមីសួន ជាកូនសម្លាញ់ចិត្តរបស់លោក បានជិះលើទីតាំងជាមួយហ្លួង ដើម្បីប្រដែងយកឈ្នះខ្ញុំ ប៉ុន្តែមិនបានសំរេច ទើបតែពេលនេះ ដែលទូកទាំងពីរចូលមកកៀកគ្នា ម្ចាស់ក្បូត្រីក៏ថ្វាយបង្គំហ្លួង ហើយនិយាយថា:

- ក្រាបទូល, ខ្ញុំម្ចាស់យល់សប្តិឃើញខ្មោចម្តាយខ្ញុំម្ចាស់មកប្រាប់ថា គាត់មកចាប់ជាតិជា នាងសួន ហើយសុំឲ្យព្រះករុណាជួយមើលខុសត្រូវឲ្យបានស្រួលបួលផង។

នេះជាពាក្យប្រឌិតយ៉ាងស្ទាត់ជំនាញ ដើម្បីឲ្យមីសួន បានចូលមកគាល់បំរើហ្លួង នឹងអាលឆាប់បាន គាប់គួរ ហើយវាក៏ជាកត្តាមួយបង្ហាញឲ្យឃើញនូវលក្ខណៈទន់ខ្សោយនៃចរិតរបស់ហ្លួង ដែលបណ្តោយខ្លួន ឲ្យគេប្រើល្បិចបោកបញ្ឆោតបានយ៉ាងងាយ។

- ហា! ហា! (ហ្លួងសើចសប្បាយ) វ៉ម, កូនឯងយល់សប្តិឃើញអញ៊ីងហ្ន៎? អញក៏ធ្លាប់យល់សប្តិ ឃើញដូចគ្នាបេះបិទអញ៊ីងម្តងដែរ។ ឯណា នាងសួន, ឲ្យវាឡើងមកលើទូកអញមក, វាជំលួមប្រើប្រាស់បានហើយមែនទេ?

ប៉ុន្តែដោយហេតុថ្ងៃនោះ ទឹនាំងហ្លួងចង្អៀតខ្លាំងពេក លោកក៏បញ្ជូនមីសួន ឲ្យត្រឡប់ទៅជិះទូកជាមួយម្ចាស់ក្បូត្រីវិញ ដែលជាហេតុធ្វើឲ្យម្ចាស់ក្បូត្រីក្តៅក្រហាយក្រៃលែង ប៉ុន្តែលោកពុំមែនអស់សង្ឃឹមត្រឹមនេះទេ។ ពេលនេះជាឱកាសល្អ គួរណាស់តែខ្ញុំឆ្លៀតយកគាប់នឹងហ្លួងឲ្យបានមុនមីសួន ប៉ុន្តែខ្ញុំឥតនឹកឃើញធ្វើអញ៊ីងសោះ ពីព្រោះតែកាលណានឹកដល់រឿង មីសុន មីរ៉ន និង ស៊ីម៉ាឡា ខ្ញុំចេះតែភ័យខ្លាចហួង ស្ទើរមិនហ៊ានដើរជិតផង។

នៅលើទូកមួយផ្សេងទៀត គេនាំគ្នាសើចលេងសប្បាយនឹងឆាកស្នេហារវាង ម្ចាស់ដួងមធុរា និង ម្ចាស់ក្បូត្រីសិរីវង្ស។ ម្ចាស់ដួងមធុរា អង្គុយលើទូកស្រែកហៅម្ចាស់ក្បូត្រីសិរីវង្ស ដែលកំពុងអង្គុយលើដីខ្សាច់មាត់ទន្លេ សុទ្ធតែប្រើពាក្យអូនបង ដើម្បីឲ្យឡើងមកផ្អុំជាមួយលោកលើទូក។ ម្ចាស់ក្បូត្រីខ្មាសគេក៏ស្រែកយំ ហើយអ្នកឈរមើលទាំងអស់គ្នាសើចគិលឡើង ដើម្បីលើកជើងម្ចាស់មធុរា ព្រោះនរណាក៏ដឹងដែរពីការទាក់ទងរវាងអ្នកទាំងពីរ។ បន្តិចក្រោយមក ម្ចាស់ក្បូត្រីសិរីវង្ស ក៏សុខចិត្តឡើងទៅតាមកូសង្សារ ហើយបណ្តើរគ្នាចូលទៅក្តងបន្ទប់លើកជាំល់សម្ងំឈឹង...។

រាជការស្រុកបានទទួលដំណឹងថា ហ្លួងយាងមកដល់មណ្ឌលខ្លួន ក៏នាំយកម្ហូបអាហារជាច្រើនមកថ្វាយសម្រាប់ទុកធ្វើជាស្បៀងបន្តទៀត។ ហ្លួងចែកសាច់ជ្រូកឲ្យពួកម៉ាឡាយូអ្នកចែវទូកគ្រប់គ្នា ប៉ុន្តែទោះបីអស់កម្លាំងឃ្លានយ៉ាងណាក៏គ្នាមិនហ៊ានបរិភោគដែរ ពីព្រោះសាសនាអ៊ីស្លាមហាមផ្តាច់មិនឲ្យបរិភោគសាច់ជ្រូកទេ...។

ស្អែកឡើងវេលារសៀល ក្បួនពួកយើងមកដល់បឹងកន្ទាយកុំ និង ចំការតាយ៉ែម ស្ថិតនៅត្រង់ផ្លូវបំបែកទៅកាន់សៀមរាប។ នៅកណ្តាលទីព្រៃលិចទឹក មានភ្នំថ្មមួយដុះលេចឡើងខ្ពស់ជុតពីទឹកប្រៀបបាននឹងកោះ ប្រកបទៅដោយដើមឈើដុះ ឯណោះមួយដុំ ឯណោះមួយដុំ។ ក្បួនទូកបន្តធ្វើដំណើរតាមជើងព្រៃ ផ្អើលអស់សត្វបក្សាបក្សី, ហ្លួង ដើរចេញពីបន្ទប់ ហើយនិយាយថា:

- នោះ ពួកកែវកីគេមកទទួលយើងហើយ!។

ពួកកែវកី គឺជាក្មេងស្រីកូនអ្នកស្រុកសៀមរាបជ្រើនរយនាក់ជិះលើទូកងវែងៗ ហើយថែរប្រណាំងគ្នា លឿនស្មើតម្រង់មកចំយើង។ លុះចូលមកដល់ជិតគ្នាមែនទែន ខ្ញុំអាចមើលឃើញពួកនោះ មានរង្វង់មុខមូល ជាត់ម្សៅសក្បស ចងផ្កាព្យារតែងកោងនៅនឹងត្រចៀក ហើយស្រែកច្រៀងបន្តរទំនុកខ្នុរបំពងព្រៃ។ អស់អ្នក-អស់នាង នៅលើទូកម្ចាស់ក្បូត្រីអគ្គនារី ស្រែកច្រៀងតទៅវិញយ៉ាងសប្បាយរីករាយ។ បន្ទាប់មក សម្តេងចម្រៀងបទសក្រវាទីលាន់ឮឡើងពីគ្រប់ទូក ហើយក្បួនទូកកំកាន់តែរសាត់ចូលទៅជិតច្រាំងណាស់ហើយដែរ...។ ពេលនោះយប់ងងឹតបន្តិចទៅហើយ ក្រុមភ្លេងពិណពាទ្យនៅនឹងជើងភ្នំក្រោម ចាប់ប្រគុំទទួលដំណើរហ្លួង យ៉ាងស្រងេះស្រងោច។

ខ្ញុំដល់វេនចូលគាប់បំរើហ្លួងជាមួយអស់អ្នក-អស់នាង នៃវេនទីបួន។ យប់នោះ ខ្ញុំថ្វាយខ្សៀអាកៀន ឲ្យហ្លួងសោយអស់ប្រហែលសាមសិបខ្សៀ ហើយដៃគូខ្ញុំនៅខាងម្ខាងទៀតនោះ ក៏បានថ្វាយសាមសិបខ្សៀដែរ...។ ហ្លួងសម្លឹងផ្តំលក់យើងក៏ថយចូលមកដេកក្នុងមុងធំ ត្រចៀកប្រុងស្តាប់ជានិច្ច ក្រែងលោកត្រូវការប្រើប្រាស់អ្វីទៀត។ ស្អែកឡើងហ្លួងសម្រេចថា ចាំត្រឡប់មកពីបាត់ដំបងវិញ សឹមឆៀងចូលទៅអង្គរ ហើយយើងក៏ចាកចេញពីដីច្រាំងសៀមរាប ទាំងស្តាយស្រណោះ ដើម្បីបន្តដំណើរដ៏គួរឲ្យធ្លុញទ្រាន់នេះទៅមុខទៀត។ អ្នកខ្លះបានឡើងទៅដល់កំពូលភ្នំក្រោម គេនិយាយប្រាប់ថាពីលើកំពូលភ្នំ គេអាចមើលឃើញផ្ទៃទន្លេសាបទាំងមូល ហើយនៅខាងជើងឯណោះ គេមើលឃើញកំពូលប្រាំនៃប្រាសាទអង្គរវត្ត លូតខ្ពស់ហួសព្រៃព្រឹក្សា... ។

ស្ទឹងសង្កែ ជាដៃទន្លេធំមួយ ហូរកាត់ភូមិស្រុកមានមនុស្សរអ៊ូអរ ជួនកាលយើងប្រទះឃើញមាន វត្តអារាមនៅជាប់នឹងមាត់ស្ទឹងទៀតផង។ នៅក្រុងបាត់ដំបង ផ្ទះលោកផ្សាកាថាថន អតីតចៅហ្វាយខេត្តសៀម ល្អលើសគេទាំងអស់ ប៉ុន្តែសព្វថ្ងៃនេះលោក កាថាថន ត្រឡប់ទៅនៅឯស្រុកសៀមវិញបាត់ទៅហើយ។

ពេលក្បួនទូកធ្វើដំណើរចូលមកដល់ទីក្រុង គេមានបាញ់កាំភ្លើងទទួលអបអរសាទរនាម៉ឺនបារាំង និង សៀម ព្រមទាំងទាហាន និង ប្រជាពលរដ្ឋ ជ្រើនកុះករមកឈរឆ្ងាំសំដែងការរកិច្ចចំពោះហ្លួង...។

គេរៀបចំធ្វើបុណ្យលេងសប្បាយជ្រើនថ្ងៃណាស់។ ខ្ញុំត្រូវរាំជូនទស្សនិកជនមើលកំសាន្តពីរថ្ងៃជាប់គ្នា ហើយបន្ទាប់មកត្រូវទៅរាំបួងសួងវត្តសក្តិសិទ្ធិ នៅឯប្រាសាទបាក់បែកណាមួយនោះ ដែលគេនិយាយថាប្រែកបទៅដោយគ្រោះថ្នាក់សម្បើមណាស់។ ណាមួយខ្លាច ណាមួយអស់កម្លាំង ខ្ញុំក៏ប្រកែកមិនព្រមទៅរាំនៅទីនោះ ប៉ុន្តែមីពួកម៉ាកខ្ញុំដែលទៅរាំទាំងប៉ុន្មាន វាត្រឡប់មកវិញសុខសប្បាយទាំងអស់គ្នា។

យើងដើរមើលសព្វកន្លែកកន្លៀតក្នុងខេត្តបាត់ដំបង មើលតាំងពីផ្ទះលោកចៅហ្វាយខេត្តសៀម ដែលគេកំពុងសង់និង វត្តដំរីស មើលអ្វីៗទាំងអស់ដែលយើងចង់ឃើញ។ ស្រីស្រុកបាត់ដំបង ភាគច្រើនស្អាតៗណាស់ ស្អាតជាងអ្នកភ្នំពេញទៅទៀត។ លើសពីរបស់របរដែលអ្នកស្រុកនាំយកមកថ្វាយហ្លួង គេមានថ្វាយស្រីក្រមុំបីនាក់ឈ្មោះ រួយ, ទួន និង ព្រិល សម្រាប់ធ្វើជាស្នំ ដែលហ្លួងទទួលឲ្យជិះលើទូកជាមួយអ្នកម្នាងម្លិះ។ ពួកវាមិនអាក្រក់ ប៉ុន្តែក៏មិនស្អាតណាស់ណាដែរ ហើយវានិយាយខ្មែរដឹង ស្តាប់ភ្លេងឲ្យចង់លើច។ ពុកទិញបាន ទឹកដោះគោកំប៉ុង នំប៉័ង និង ត្រីខប្រអប់ ពីផ្ទះចិនឯផ្សារយកមកផ្ញើខ្ញុំ ប៉ុន្តែមីពួកម៉ាក អត់ឃ្លានដាច់ដាបអស់ហ្មឹង វាដណ្តើមស៊ីអស់ ខ្ញុំគ្មានបានលេបមួយម៉ាត់ទេ។

ក្រោយពេលដែលធ្វើបុណ្យនៅនឹងខេត្ត បាត់ដំបង ចប់សព្វគ្រប់ហើយ យើងក៏ធ្វើដំណើរត្រឡប់មកសៀមរាបវិញ វាងតាមចុងខាងលិចបឹងធំ ហើយបត់ក្បាលតំរង់ទៅរកប្រាសាទអង្គរវត្ត។

ខ្ញុំមិនដែលឃើញស្រុកណាល្អដូចស្រុកនេះទេ! ទឹកស្ទឹងថ្លាឆ្វង់ហូរចាក់ពីភ្នំគូលែនមក ទោះបីក្តងរដូវរស្សាមានភ្លៀងធ្លាក់ច្រើនយ៉ាងណា ក៏ទឹកឡើងមិនហួសច្រាំងដែលមានស្មៅលាស់ខៀវខ្ចីក្រោមម្លប់ដ៏សែនសុខុមនែ ដើមស្នោត ដើមដូង និង ដើមស្លា។

នៅលើច្រាំង រទេះគោបរទៅមុខលាន់ឆៅតង់ត... តាមបណ្តោយដងស្ទឹងដ៏មានមនុស្សរស់នៅកុះករ ដូចនៅ ជាត់ដំបងដែរ។ អ្នកស្រុកស្លៀកពាក់ស្អាតបាត នាំគ្នាលុតជង្គង់ថ្វាយបង្គំទីនាំងហ្លួង ខ្លះរត់ដើម្បីទៅឲ្យបានដល់ភូមិដែលស្ថិតនៅពាក់កណ្តាលផ្លូវទៅអង្គរនោះមុនយើង។

ដល់កន្លែងរាក់មែនទែនពុំអាចចែវកើត គេក៏ចាប់អ្នកស្រុកឲ្យចុះទៅក្នុងទឹកត្រឹមដើមទ្រូងដើម្បីអូសទូក ឡើងទៅលើបញ្ញើសខ្សែទឹកហូរ។ យើងប្រញាប់ប្រញាល់រៀបចំស្លៀកពាក់ ស្ទានថាជិតដល់ហើយ ប៉ុន្តែតាមពិត យើងត្រូវធ្វើដំណើរយឺតៗបែបនេះអស់រយៈពេលជាច្រើនម៉ោង។ មិនដឹងជាចង្រៃអី ខ្ញុំស្រាប់តែឈឺនោម រាន់ចង់លេចស្ទើរទ្រាំទប់មិនជាប់។ កន្លែងបង្គន់នោះ គឺជាធុងឈើមួយមានចោះប្រហោង ដាក់ចងជាប់នឹងចង្កេះទូក លយចេញទៅលើទឹ

ក។ តាមប្រហោងបង្គន់ គេអាចមើលឃើញក្បាលអ្នកអូសទូក ថ្ងាស់ក្រឡែត ហើយបើខ្ញុំចូលទៅបត់ជើងក្នុងហ្នឹង គេងើយមើលពីក្រោមមក ក៏ឃើញថ្ងាស់ក្រឡែតដូចគ្នា។ ខ្ញុំខំទ្រាំអត់ចង់ខ្សល់ចាប់ នៅតែរកមធ្យោបាយដោះស្រាយមិនរួច។ ម៉ែអូន ម៉ឺងម៉ាត់ណាស់ មើលឃើញទឹកមុខខ្ញុំបែបមិនស្រួល គាត់យល់ការទាំងអស់ ក៏ផ្តល់យោបល់ដ៏ល្អមួយនៅខាងក្រោយទូក គេមានរៀបចំកន្លែងមុជទឹក ខ្ញុំផ្លាស់សារុងចាស់ ស្រោចទឹកលើខ្លួនធ្វើដូចជាងូតទឹក បន្លំនោមបានយ៉ាងស្រួល ក្មានននរណាចាប់ភ្លឺកសង្ស័យទេ។

ប៉ុន្តែ ម៉ែអូនខ្លួនឯង កំពុងកើតទុក្ខធ្ងន់ជាងខ្ញុំទៅទៀត គឺគាត់ឈឺដុះអាចម៍។ គាត់ឆ្ពេស្លាច្រាសច្រាល ដូចមាន់រកពង រកកន្លែងដោះទាល់មិនបានសោះ។ គាត់ចូលទៅក្នុងបន្ទប់ហួងបាត់មួយសន្ទុះ ទើបឃើញចេញមកវិញ មានកាន់ទាំងប្រអប់ក្រដាសទទេមួយដែលគេចំណាំដាក់បារីស៊ីហ្គារ មកជាមួយផង។ គាត់ ខ្សឹបប្រាប់ខ្ញុំថា:

~ កុំទៅឆ្ពេត ពួកឯទៀតគេនោមពាសណាពាសណើដូចតែគ្នាហ្នឹង!

គាត់ចូលទៅក្នុងបង្គន់ បើកចំហរប្រអប់ដាក់លើប្រហោងបង្គន់ ដើម្បីដោះទាល់បានយ៉ាងស្រួល។ រួចហើយគាត់បិទប្រអប់វិញយ៉ាងស្អាត ទើបបោះចោលតាមប្រហោងទៅក្នុងទឹក ប្រអប់នោះអណ្តែតស្ទឹង បញ្ជិតស្មាពួកអ្នករុញទូក ប៉ុន្តែគេចាប់មិនបាន វាចេះតែរសាត់ចេញទៅដល់ក្បែរទូកមួយទៀត។ ម៉ែអូនកាន់ដីលទឹកឈរជិតខ្ញុំ មុខញញឹមពាក្រាយតាមមើលប្រអប់។ បន្តិចក្រោយមក ពួករុញទូកខាងក្រោយចាប់ បានស្គាន់ថាប្រអប់បារីល្អ បើកមើលយ៉ាងរហ័ស ដល់ឃើញសុទ្ធតែអាចម៍ ក៏ធ្វើមុខជូរហួញ ក្រវាត់ចោលព្រួស។ ម៉ែអូន និង ខ្ញុំនាំគ្នាសើចស្ទើរដួលពោះ...។

បន្តិចក្រោយមក ស្ទឹងប្រែជារួមតូចទៅៗ... នៅពីមុខអតីតវេសនដ្ឋាន នៃលោកចៅហ្វាយខេត្តសៀម មន្ត្រីបារាំង, សៀម និង ខ្មែរនាំគ្នាមកឈរង់ចាំទទួលហួងយ៉ាងច្រើនកុះករ។

គេសង់រោងរបាក្បែរផ្ទះថ្មមួយ ដែលមានដាក់កាំភ្លើងធំយាមប្រចាំការនៅជុំវិញ ប៉ុន្តែមុននឹងរាំឲ្យអ្នកស្រុកសៀមរាបមើលលេងកំសាន្ត ហួងបានបញ្ជាឲ្យយើងទៅរាំបួងសួងថ្វាយវត្តសក្តិសិទ្ធិឯអង្គរវត្តជាមុនសិន។

យើងនាំគ្នាចេញដំណើរទៅកាន់ប្រាសាទបាក់បែកនោះតាំងពីព្រលឹមស្រាងៗ.....ពួកក្មេងតូចៗភ័យខ្លាចគេមិនឲ្យទៅមើលអង្គរវត្ត វាខំយំស្រែកតាមអង្វរម្ចាស់ក្បាត្រីខ្លាំងណាស់ ទម្រាំលោកព្រមយកវាទៅជាមួយ។

រទេះគោ រទេះក្របី តម្រៀបបន្តកន្ទុយគ្នា វែងអន្លាយតាមបណ្តោយដងស្ទឹង លើផ្លូវដ៏មានដើមឈើដុះអមសង្ខាងចោលជាម្លប់ត្រជាក់ស្រួលក្រៃលែង។ អ្នកស្រុកម្ចាស់រទេះចិត្តបានណាស់ គាត់សុខចិត្តដើរជើងទទេអូសគោពីមុខដើម្បីទុកកន្លែងទូលាយឲ្យយើងបានអង្គុយស្រួល។ ប៉ុន្តែទោះជាយ៉ាងណា ក៏វានៅតែចង្អៀតដដែលពីព្រោះក្នុងមួយរទេះ យើងត្រូវជិះប្រជ្រៀតគ្នាដល់ទៅបី ឬ បួននាក់ឯណោះ។ អ្នកចែម ជើងកំប្លែងយកជន្លួញចាក់ក្តិតគោបណ្តាលឲ្យវាផ្ទើលស្ទុះរត់ត្រណាត់ត្រណែង ខ្ញុំអង្គុយពីក្រោយខ្នងគាត់ជាមួយអ្នករបាំម្នាក់ទៀត រលាក់ក្រឡកស្ទើរបែកផ្តើមប្រមាត់។ ហួងមិនទាន់ចេញដំណើរមកទេ លោកចាំយាងមកតាមក្រោយជាមួយពួកនាម៉ឺនសព្វមុខមន្ត្រី។ ចំណែកខោអាវសម្រាប់ស្លៀកពាក់វានោះវិញ គេដឹកផ្សែង យើងពាក់ជាប់នឹងខ្លួនតែគ្រឿងអលង្ការបន្តិចបន្តួចប៉ុណ្ណោះ។

ក្បួនរទេះធ្វើដំណើរទៅមុខយឺតៗ ស្ងួរភ្លៅរទេះសង្កៀតគ្នាលាន់ដែត... ដែត..... ហ៊ឹងត្រចៀក ហើយកង់រទេះនោះទៀតសោតម្ខាងទៅឆ្វេង ម្ខាងទៅស្តាំ យោលប្រៀបបាននឹងជិះទូកយ៉ាងនោះដែរ។ មួយសន្ទុះក្រោយមក ផ្លូវបែកចេញពីមាត់ស្ទឹង មើលលេងឃើញច្បារដំណាំ និង ផ្ទះសម្បែងអ្នកស្រុកអ្វីទាំងអស់ ឃើញតែព្រៃស្រោងស្រឹងស្ងាត់ជ្រងំ ហាក់ដូចជាពុំដែលមានមនុស្សដើរទៅមកកាត់តាមនេះឡើយ។

បន្ទាប់មក ផ្លូវរទេះត្រូវឆ្លងកាត់ក្រហុកដីជាច្រើនកន្លែង ហើយរំពេចនោះយើងស្រែកភ្ជាត់មាត់ស្រុះគ្នា ទាំងអស់:

- ឃី, មើលន់! មើលឯនោះន់!

ព្រមទាំងលើកដៃចង្អុលទៅទិសខាងកើត ដែលបង្ហាញទិដ្ឋភាពដ៏ល្អក្រៃកាលក្រោមផ្ទៃមេឃក្រហមព្រឿងៗនាពេលព្រឹកព្រហាម។ នៅចំងាយប្រហែលម្ភៃជំហានពីផ្លូវ យើងឃើញដុំថ្មពណ៌ខ្មៅប្រផេះ ព័ទ្ធព័ន្ធទៅដោយវល្លិ និង ស្លែ ដាក់តម្រៀបគ្នានៅសង្ខាងផ្លូវ កន្លែងខ្លះបាក់បែកជ្ពាក់ទៅក្នុងអន្លង់ទឹកដ៏ជ្រៅ ដែលគេដឹកពីក្រោម។ អន្លង់នេះគ្រាន់តែទទឹងប្រវែងសីងប៉ុនទន្លេ ប្រកបទៅដោយទឹកនឹងថ្ពល់មានផ្កាឈូក និង វារីជាតិដទៃទៀត ដុះដេរដាសពីលើ បង្កើតបានជាកម្រាលធម្មជាតិមួយបែបដ៏ប្រណិតក្រៃលែង។

នៅជ្រាំងខាងម្ខាងឯណោះ រីតតែល្អជាងនេះទៅទៀត កំពែងថ្មលាតសន្ធឹងកាត់ព្រៃ សសរ និង ក្តោងទ្វារធំៗ មានសន្ទបក់ពូលថ្មពីលើ ចាំងឆ្លុះច្បាស់ក្រឡែតពីលើផ្ទៃទឹក ប៉ុន្តែកំពូលថ្មទាំងនេះបាក់បែកស្ទើរតែទាំងអស់ទៅហើយ ឃើញតែដុំថ្មរបូតធ្លាក់មកនៅរាយពាសពេញដី។ បន្ទាប់ពីកំផែងនេះទៅឆ្ងាយជ្រៅខាងក្នុង មានកំណ្ចថ្មមួយប្រកបដោយកំពូលជ្រាំបន្តបពីលើ កំពូលបួននៅគ្រប់ជ្រុងទាំងបួន និង កំពូលកណ្តាលខ្ពស់ជាងគេ លេចត្រដែតហួសអស់ព្រៃព្រឹក្សាហើយនៅគង់វង់ទាំងអស់ គ្មានឃើញបាក់បែកត្រង់ណាទេ។

ស្ទួរទេះស្ងាត់ទៅវិញម្តងមួយៗជាបន្តបន្ទាប់គ្នា... ក្បួនរទេះឈប់តកន្លែយគ្នារែងអន្លាយតាមបណ្តោយ មាត់ប្រឡាយទឹកព័ទ្ធជុំវិញអង្គរ ដែលមានស្ពានថ្មធំទូលាយនៅចំកណ្តាលសម្រាប់ឆ្លងពីម្ខាងទៅម្ខាង។ រូបសិង្ហពីរបាក់បែកស្ទើរតែមើលមិនចង់ស្គាល់ទៅហើយ នៅឈរយាមល្បាតនឹងផ្តល់ត្រជាដួរចូល។ យើងឆ្លងផុតមកដល់ក្លោងទ្វារ ដែលតាមស្ពានមើលទៅ កន្លែងនេះពីដើមជាកន្លែងទាហានឈរយាមប្រកបទៅដោយជញ្ជាំង សសរ និង បង្អួចមានក្បាច់ចម្លាក់ឆ្លាក់ដោយដៃវិចិត្រការដ៏ប៉ិនប្រសប់គ្មានពីរក្នុងលោក។ រូបទេពអប្សរ និង អ្នករបាំពាក់មកុដដ៏នាន់បុរាណញញឹមពាក្រាយហាក់សម្តែងពរស្វាគមន៍ចំពោះយើង។ បន្ទាប់ពីក្លោងទ្វារនេះ មានផ្លូវក្រាលថ្មមួយទៀតលាតសន្ធឹងរែងរហូតដល់កាំជណ្តើរអង្គរវត្ត។ រូបនាគរែងដែលគេឆ្លាក់ធ្វើជាបង្កាន់ដៃនោះនៅតង់រង់នៅឡើយ ប៉ុន្តែទ្រេតទ្រោតរកកលនឹងបាក់ធ្លាក់ទៅលើវាលស្មៅនៅខាងក្រោម។ ផ្ទៃប្រាសាទទាំងមូល មានសភាពស្ងប់ស្ងាត់គួរឲ្យខ្លាច ទោះបីពួកយើងនាំគ្នានិយាយឡឡាយ៉ាងណា ក៏ពុំអាចបង្កើតជាភាពអ៊ូអរបានដែរ នៅតែស្ងាត់ ស្ងាត់គួរឲ្យស្រងេះស្រងោចក្នុងចិត្ត។

យើងដើរមកដល់ជណ្តើរថ្មបួនកាំ ដែលនៅក្បែរនោះមានវត្តមួយសម្ងំពួនយ៉ាងសុខសាន្តកណ្តាលសភាពស្ងប់ស្ងាត់ក្រោមម្លប់រុក្ខជាតិធំៗស្លឹកត្រសុំត្រសាយ។ អ្នកភ្ជុំពេញ និង អ្នកជាត់ដំបង ជាច្រើននាក់បានមកដល់ទីនេះមុនយើងទៅទៀត ហើយគេដើរទៅដើរមកអ៊ូអរពាសពេញ។ ពួកក្រុមវាំងប្រយ័ត្នប្រយែងខ្លាំងណាស់ គាត់តាមឃ្លាំយើងជាប់ក្រាប់ជំហាន ដើម្បីការពារកុំឲ្យស្មៀនក្មេងៗដែលធ្វើដំណើរមកជាមួយ នាំយីនសព្វមុខមន្ត្រីនោះ តាមឆាវៅយើងបាន។ ពួកក្មេងកម្លោះអស់ហ្នឹង ពុំមែនប្រាថ្នាមកមើលអង្គរវត្តប៉ុន្នានទេ ប៉ុន្តែតាមពិតគឺគេមកតាមមើលយើងនេះតែម្តង។ នៅពេលដែលយើងនាំគ្នាដើរចូលទៅកន្លែងឆងដត ខ្ញុំសម្គាល់ឃើញអស់អ្នកអស់នាងជាច្រើន បានខំចោលឫក ចោលពារដើម្បីឲ្យគេយកតាមខ្លួន ដែលជាហេតុអាចឲ្យខ្ញុំកាត់យល់បានថា ពួកទាំងនេះសុទ្ធតែធ្លាប់ទាក់ទងគ្នាតាំងពីយូរណាស់មកហើយ ហើយគេប្រហែលជាមានសន្យាថានឹងរៀបការជាមួយគ្នាក្នុងពេលណាមួយទៀតផង។ អារបៀបឲ្យកន្តុយភ្នែក ឬ ញញឹមស្តីអញ្ចឹង ខ្ញុំមិនរវល់យកចិត្តទុកដាក់មើលទេ ពីព្រោះក្បាច់ចម្លាក់អង្គរវត្តល្អពេកណាស់ មើលហើយជក់ភ្នែកចង់តែមើលទៀត! សម្តេងមនុស្សជជែកគ្នាចេកចាចលាន់ឮមកពីគ្រប់ទីកន្លែង ហើយនៅតាមច្រក ងងឹតនោះ ជុំគ្និនស្ពយអាចម៍ប្រចៀវគួរឲ្យចង់ក្អួត ។

ជណ្តើរមានគ្រប់កន្លែង ងាកទៅខាងណាក៏ឃើញ មិនដឹងជាឡើងទៅដល់កន្លែងណាខ្លះទេ មកដល់ ក្លោងទ្វារទីមួយៗតែមិនបានប្រយ័ត្នមើលក្រោម ច្បាស់ជាជំពប់ដើងដួលជ្កាប់មុខមិនខាន។ នៅតាមជញ្ជាំងរែង មានឆ្លាក់រូបល្អណាស់ រូបទេពអប្សរដែលឆ្លាក់ជាប់នៅនឹងជញ្ជាំង សុទ្ធតែមានដោះរលោងស្រិល ពីព្រោះនរណាដើរមកឃើញក៏អង្អែលគ្រប់ៗគ្នា។

មានកន្លែងមួយនោះ ឲ្យតែគក់ទ្រូង លាន់ឮសូរខ្ទ័រឆ្លើយតបមកវិញ។ ហេតុតែចង់ស្តាប់សម្លេងខ្ទ័រនេះ ខ្ញុំគក់ទ្រូងខ្លួនឯងទាល់តែចុក។

ក្រោយដែលដើរលេងនៅកន្លែងឆងងឹតអស់ហើយ យើងក៏ដើរចេញមកដល់ទីធ្លាមួយភ្លឺច្បាស់ក្រឡែត ដែលមានដុំថ្មធ្លាក់មករាយប៉ាយពាសពេញ។ កន្លែងនេះតតមានដុះដើមឈើធំៗដូចនៅកន្លែងដទៃទៀតទេ ហើយនៅពីមុខយើងក៏ពូលទាំងប្រាំលូតខ្ពស់ត្រដុបត្រដើមតួរឲ្យខ្លាច បន្តបពីលើពំនូកថ្មធំសម្បើមប៉ុនភ្នំ។ ជណ្តើរសម្រាប់ឡើងទៅកាន់កំពូលនោះមានច្រើនណាស់ ជណ្តើរសម្រាប់ស្រីផ្សេង សម្រាប់ប្រុសផ្សេង មិនច្រឡូកច្រឡំគ្នាទេ។ ម្ចាស់ក្បត្រី អស់កម្លាំងពេកឡើងទៅទៀតមិនរួច សុខចិត្តអង្គុយចាំនៅខាងក្រោម ពួកយើងដោះស្បែកជើងនាំគ្នាឡើងយឺតៗយ៉ាងប្រុងប្រយ័ត្នក្រែលែង មិនហានដាកក្រោយមើលមកក្រោម ពីព្រោះជណ្តើរនោះចោតសន្ធឹម ប្រកបទៅដោយកាំនីមួយៗតូចជាន់មិនពេញជើង។ បានឡើងទៅដល់លើ យើងអាចមើលឃើញទិដ្ឋភាពផ្ទៃអង្គរវត្តទាំងមូលដែលល្អប្រៀបបានទៅនឹងប្រាសាទទិព្វដុះចេញកណ្តាលទ្រូងព្រៃស្រោងស្រឹង ស្ទើរតែពុំអាចជឿថាជាស្នាដៃមនុស្ស។ ខ្ញុំឮគេប្រាប់ថា នៅជិតៗនេះមានអង្គរធំ, ប្រាសាទលលៃ, ប្រាសាទតាព្រហ្ម និង ប្រាសាទផ្សេងៗទៀតជាច្រើន ដែលខ្ញុំភ្លេចឈ្មោះអស់ទៅហើយ ប៉ុន្តែខ្ញុំរកមើលមិនឃើញមួយសោះ ព្រោះព្រៃដុះគ្របពីលើជិតអស់ទៅហើយ... ឃើញតែព្រៃខៀវស្រងាត់លាតសន្ធឹងរែង រហូតទៅដល់ទន្លេសាប។

ដោយសារខ្ញុំចេញមុខការពារកាហ៊ុន វាបានតាមមកជាមួយគេជាប់រហូត វារត់ឡើងជណ្តើរលឿន ដូចកណ្តុរ។ យើងដើរមើលខាងឆ្វេងបន្តិច ខាងស្តាំបន្តិច រួចនាំគ្នាអុជធូបបូជារូបសំណាកធ្លាក់ជាប់នឹងទ្វារមួយនោះ របៀបគជាជញ្ជាំងអញ្ចឹង។

ថ្ងៃខ្ពស់ណាស់ហើយ... យើងកូរពោះឃ្លានបាយ ហើយក៏អស់កម្លាំងបន្តិចដែរ ជាពិសេសគឺខ្ញុំនេះឯង ដែលអស់កម្លាំងខ្លាំងជាងគេ ពីព្រោះខ្ញុំមិនរវល់កាចរាងឲ្យគួសង្សារមើលដូចពួកគេឯទៀតទេ។ ខ្ញុំហាក់ដូច ជាឈឺចុកចាប់ពេញខ្លួនទ្រាំមិនបានក៏ចូលទៅសម្ងំដេកក្នុងរោងស្តីកដែលគេសង់ទុកសម្រាប់ឲ្យពួកបរិការហ្លួងចូលឈប់សម្រាកកំដៅថ្ងៃ។ ការនឿយហត់ក្នុងពេលធ្វើដំណើរ ចាប់ផ្តើមធ្វើទុក្ខខ្ញុំខ្លាំងឡើងៗជាលំដាប់ រហូតដល់ពេលថ្ងៃត្រង់ខ្ញុំធ្លាក់ដាបមែនទែន ប៉ុន្តែខ្ញុំទ្រាំថ្វាយវត្តសក្តិសិទ្ធិ និង ទេវតារក្សាទឹកដី ជាមួយគេឯងទាល់តែចប់ចុងចប់ដើម។

ខ្ញុំធ្មេចភ្នែកមមើមមាយឃើញតែរឿងផ្តេសផ្តាសគួរឲ្យខ្លាច ហើយមួយសន្ទុះក្រោយមកខ្ញុំក៏សន្លប់លែងដឹងខ្លួនសោះតែម្តង... ពេលត្រឡប់មកវិញ គេម្នាក់ៗសង្ខាតយោងអាស្មាតែរាល់ខ្លួន គ្មាននរណាគិតគូរនឹកនាដល់ខ្ញុំដែលដេកលក់ស្លុកស្តឹងតែម្នាក់ឯងនៅលើកន្ទេលក្នុងរោងនោះទេ។ ថ្ងៃនោះបើកុំតែបានពួកម៉ែ ទៅតាមជាមួយ ម្លេះសមគេភ្លេចទុកខ្ញុំចោលកណ្តាលព្រៃមិនខាន។ មកដល់សៀមរាបវិញ ខ្ញុំដេកស្តឹកនៅលើទីនាំងសក្តិក្រសេម រង់ចាំទម្រាំអ្នក

ឯទៀតត្រឡប់មកពីរាំបួងសួងឯអង្គរជំរិញ នឹងអាលនាំគ្នាត្រឡប់មកភ្នំពេញ។ ខ្ញុំដឹងថា នេះជាជម្ងឺពេលឡើងខួន ប៉ុន្តែជម្ងឺនេះវាធ្វើទុក្ខខ្លាំងរហូតដល់រើរាយរង្វេងស្មារតីពុំដឹងជាអស់រយៈពេលយូរប៉ុណ្ណា ស្រាប់តែមាននរណា អង្អែនដាស់ខ្ញុំសដ្ឋឹងមើលទៅដូចជាមុខ យ៉ាន ពូកម៉ាកខ្ញុំ។ វាខ្សឹបប្រាប់ថាពេលដេកមមើមមាយ ខ្ញុំវាសដៃទៅប៉ះក្បាល ម៉មនូ ដែលជាហេតុបណ្តាលឲ្យគាត់ខឹងច្រឡោត ហើយខ្ញុំហាក់ដូចជាស្រមៃឮ ម៉មនូ និយាយល្ងើយៗកំពុងទួលពិតហួងថា៖ ខ្ញុំព្រហើនណាស់ គ្រាន់តែបានចូលរេនគាប់បំរើហួងប៉ុណ្ណឹង ស្រាប់តែឡើងចាងហ៊ានវាយក្បាលគាត់ដែលមានហាន: ជាម៉ម ព្រមទាំងសុំឲ្យហួងវាយប្រដៅខ្ញុំម្តង កុំឲ្យព្រហើនដាក់គាត់ខ្លាំងពេក។ ខ្ញុំឮសម្តេងហួងឆ្លើយតបមកវិញថា:
ម៉ែន្ត អើយ កុំធ្វើបាបវាអី! មិនឃើញជាវាកំពុងឈឺមមើមមាយមិនដឹងខួនទេហ្ន៎? ក្មេងអាយុប៉ុណ្ណឹង វាតែងឈឺអញ្ចឹងហើយ ឈប់រអ៊ូរទាំទៅ ទុកពេលឲ្យអញដេកពួនខ្លះផង។

ប៉ុន្តែ ម៉មនូ គាត់មិនដាយឈប់រអ៊ូភ្លាមទេ ពីព្រោះគាត់ចងចិត្តស្អប់ពួកយើងក្មេងៗ ដោយសារសព្វថ្ងៃ ហួងសព្វព្រះទ័យនឹងពួកយើងជាងគាត់។

បន្ទាប់ពីពេលកើតឧប្បត្តិហេតុនេះមក ខ្ញុំហាក់ដូចជាបានស្រួលខួនបន្តិចឡើងវិញ.... ខ្ញុំមើលតាមបង្អួចឃើញទីនាំងលឿនលយទៅមុខតាមចង្វាក់ច្រវា កាត់តំបន់ព្រៃលិចទឹកក្តងស្រុកកំពង់លែង... យើងជិតទៅដល់កំពង់ឆ្នាំងហើយ មកដល់កំពង់ឆ្នាំង ម៉ែអូន ធ្វើជានិយាយទួលហួងថា ខ្ញុំឈឺធ្វើការមិនកើតអញ្ចឹង ឲ្យជិះលើទីនាំងសក្តិក្រសេមនាំតែធ្ងន់ទូកតតប្រយោជន៍ ដោយសារមធ្យោបាយដ៏ប៉ិនប្រសប់នេះ ខ្ញុំក៏បានចុះទៅជិតទូកជាមួយពុកម៉ែ ដើម្បីឲ្យគាត់បានមើលថែទាំខ្ញុំដោយផ្ទាល់។ កប៉ាល់ម៉ាស៊ីនសណ្តោងទូក ទាំងអស់ត្រឡប់មកដល់ភ្នំពេញក្តងរយៈពេលប៉ុន្មានម៉ោងប៉ុណ្ណោះ ហើយហួងបានអនុញ្ញាតឲ្យម៉ែយកខ្ញុំទៅមើលនៅផ្ទះ ចាំកាលណាជាស្រួលបួលសឹមត្រឡប់មកធ្វើការវិញ។

ខ្ញុំសប្បាយចិត្តក្រៃលែង ដោយបានរំលឹកស្គាល់ជីវភាពគ្រួសារដែលខ្ញុំបំភ្លេចចោលតាំងពីច្រើនឆ្នាំណាស់ហើយ។ ផ្ទះខ្ញុំផ្លាស់ប្តូរប្លែកពីមុនទាំងអស់។ កាលឆ្នាំទៅ មានភ្លើងឆេះផ្ទះ រាលដាលពេញម្តុំ ខាងជើងកំពង់ផែ បណ្តាលឲ្យពុក-ម៉ែគាត់ប្រញាប់ជញ្ជូនអីវ៉ាន់ និងរុះរើផ្ទះខ្ចេចខ្ចីអស់ ប៉ុន្តែភ្លើងនោះ មិនបានឆេះមកដល់ផ្ទះយើងទេ ណាមួយរៀងរាល់ឆ្នាំដីច្រាំងទន្លេចេះតែបាក់ទាំងផ្ទាំងៗធ្លាក់ចុះទៅក្នុងទន្លេ ពុកក៏លើកផ្ទះមកសង់នៅខាងលើឯណេះវិញ ដើម្បីឲ្យបានឆ្ងាយពីមាត់ទន្លេបន្តិច។

ប្រាក់ខែពុកគិចពេក ពុំអាចឲ្យគាត់រកប្រាក់គ្រប់គ្រាន់លួមសង់ផ្ទះមួយជំទូលាយ សមតាមចិត្តប្រាថ្នា ម្ល៉ោះហើយផ្ទះថ្មីនេះធ្វើពីស្លឹកដងែល មានពីរបន្ទប់ និង តសំយាកចេញជាផ្ទះបាយ ព្រមទាំងមានរានហាលនៅពីមុខ ដែលពុកដាំផ្ទាដាក់តាំងជាល់អផង។ នៅក្រោមផ្ទះមានដាក់របស់ប្រើប្រាស់ផ្សេងៗ ដូចជាពាងទឹក ក្បាល់បុកស្រូវ ចង្អេរ កញ្ជើ និង ឧសជាដើម ។ ពុក កាប់គាស់ដីរៀបចំធ្វើជាសួនច្បារតូចមួយ ខ័ណ្ឌដាច់ពីផ្ទះអ្នកជិតខាងដោយសារបងឬស្សីដែលនៅទីនោះមានដាំដើមចេក ដើមល្ហុង ប្រកបទៅដោយផ្លែរយើងរយោងផ្លែមត្រជាក់។ ពុកគិតថា បើយ៉ាងហោចណាស់ក៏ពីរឆ្នាំទៀតដែរ ទម្រាំរាជការដេញឲ្យរុះរើផ្ទះនេះ ហើយក្នងរយៈពេលនេះ គាត់នឹងខំសន្សំលុយទុកសម្រាប់ដើរកទិញដីនៅកន្លែងថ្មីទៀត។ ខ្ញុំអាណិតពុកណាស់!... ខួនគាត់ចាស់សក់ស្កូរសព្រោង ដុះពុកមាត់ស្រមួម កំមិនរវល់គិតគូរ គិតយ៉ាងណាឲ្យតែកូនស្រីតែមួយបានសប្បាយ បានស្រួល ពីព្រោះតទៅថ្ងៃមុខគាត់សង្ឃឹមថានឹងបាន ខ្ពស់មុខ ខ្ពស់មាត់ ស៊ីពោះលោះកម្លាំងដោយសារកូនស្រីដែលជាអ្នករាំល្ខោនហួងនេះហើយ។ គាត់ស្រមៃឃើញថា ការដែលគាត់សុខចិត្តលះបង់កូនសម្លាញ់ចិត្តថ្វាយទៅហួងយូរឬឆាប់ គាត់គង់នឹងបានទទួលការគាប់ក្បារពីហួងវិញ មិនខាន។ កាលណាខ្ញុំភ្ញញែរថ្លែងពីសេចក្តីអស់សង្ឃឹមក្នុងការរស់នៅក្នងវាំង គាត់តែងលួងលោមថា ឲ្យខ្ញុំទ្រាំនៅបន្តិចទៀតចុះ យ៉ាងហោចណាស់បើមុននឹងចេញមក ក៏ចាំគាត់រកផ្ទះថ្មីបាននៅស្រួលបួលជាមុនសិនដែរ។

គាត់បានទិញ ក្តារខៀនខ្មៅមួយ និង ដីសមួយប្រអប់សម្រាប់បង្រៀនឲ្យខ្ញុំចេះសរសេរ ចេះអាន អក្សរខ្មែរ ពេលណាគាត់ទំនេរ។ ប៉ុន្តែខ្ញុំខ្ជិលរលួយ មិនចង់រៀនសូត្រសោះ ដែលជាហេតុធ្វើឲ្យពុកអស់សង្ឃឹមលែងស្តី។

គាត់គិតតែម្យ៉ាង គឺធ្វើយ៉ាងណាដើម្បីរៀបចំអនាគតខ្ញុំឲ្យបានភ្លឺស្វាងដូចគេឯង ហើយទោះបីគាត់មិនសូវនិយាយស្តី មិនសូវចេះថ្នាក់ថ្នម ក៏ខ្ញុំនៅតែអាចគាត់ស្ទាយល់ដល់ជម្រៅចិត្តគាត់ថា គាត់ស្រឡាញ់ខ្ញុំ គិតខ្វាយខ្វល់រឿងខ្ញុំជាងខួនគាត់ទៅទៀត។ ពេលឃើញពុកសន្សំបានប្រាក់បន្តិចបន្តួចសល់ពីប្រាក់ខែ នឹង ប្រាក់រកបានក្រៅដោយសារគាត់ជួយសរសេរពាក្យបណ្តឹងឲ្យគេ ហើយទិញរបស់កំប៉ិកកំប៉ុកមកទុកឲ្យខ្ញុំប្រើប្រាស់ ម៉ែនិយាយចំអន់ឲ្យខ្ញុំថា ៖

- ពុកឯង គិតរៀបចំឲ្យឯងមានប្តីហើយ!

ផ្ទះខ្ញុំស្អាត ហើយសប្បាយរីករាយជានិច្ច... ក្តងទូកញាក់តូចៗមានដាក់ថ្លង្កា ដបទឹកអប់ និង កំប៉ុងម្សៅ ជាពិសេសទោះបីខ្វះខាតលុយយ៉ាងណា ក៏គាត់មិនព្រមលក់បញ្ចាំខ្សែក្រវាត់ប្រាក់របស់ខ្ញុំដែរ សុខចិត្តតែទុកដាក់តាំងសំញែងក្តងទូ។

កាលណាអ្នករែកទឹកក្រយកទឹកមកចាក់ឲ្យ គាត់មិនហៅមនុស្សប្លែកឲ្យរែកទឹកចូលរហេតរហូតក្តងផ្ទះទេ សុខចិត្តដោះអាវលែងខួនទទេ លីដងរែកទៅត្រងទឹកម៉ាស៊ីនរែកយកមកផ្ទះ មិនរវល់ខ្លាចនរណាគេសើចយំអ្វីទាំងអស់ ធ្វើម៉េចឲ្យតែមានទឹកសម្រាប់ខ្ញុំងូតសំអាតខួន។

- ពុកប៉ា (ខ្ញុំឃាត់គាត់) ពុកធ្វើអញ្ចឹង ខ្ញុំខ្មាសគេណាស់។

ប៉ុន្តែគាត់មិនស្តាប់ខ្ញុំទេ ហើយកាលណាម៉ែមិននៅផ្ទះ គាត់ថែមទាំងរៀបចំដាំបាយធ្វើម្ហូបម្នាដោយខ្លួនឯងទៀតផង។ គាត់នៅតែសង្ឃឹមជានិច្ចថា ថ្ងៃណាមួយខ្ញុំជួយទូលសុំហ្លួងឲ្យគាត់បានឡើងបុណ្យសក្តិ ឬ បើយ៉ាងហោចណាស់ក៏សុំព្រះរាជទ្រព្យខ្លះ យកមកសងផ្ទះឈើប្រក់ក្បឿងឲ្យបានសមរម្យដែរ ពីព្រោះអ្នកជាំដទៃទៀត គេធ្លាប់សុំបានច្រើនគ្នាហើយ។ ប៉ុន្តែគាត់មិនហ៊ាននិយាយប្រាប់ខ្ញុំសោះ ហើយខ្លួនគាត់ទៀតក៏ចេះតែគេចវេះមិនដែលចូលទៅគាល់ឲ្យស្គាល់មុខនឹងគេសោះ។

ថ្ងៃមួយគាត់ទិញផ្លែឈើមួយថាស ថាឲ្យខ្ញុំយកទៅថ្វាយហ្លួង ប៉ុន្តែខ្ញុំលួចស៊ីអស់រលីង មិនបានយកទៅថ្វាយហ្លួងឡើយ។ ក្រោយមកយូរណាស់ ទើបគាត់ដាច់ចិត្តហ៊ានសួរខ្ញុំ ពីរឿងគាត់ពឹងឲ្យទៅសុំហ្លួងនោះតើវាបានការយ៉ាងម៉េចទៅហើយ? ខ្ញុំនឹកស្តាយក្រោយ និង ខ្មាសខ្លួនឯងយ៉ាងខ្លាំង ដែលពុំបានសងគុណឪពុកម្តាយឲ្យសមតាមទំហំទឹកចិត្តដែលគាត់ខំស្រឡាញ់ថ្នាក់ថ្នមខ្ញុំ។

យើងក្រពិតមែន ប៉ុន្តែយើងមិនដែលខ្វះខាតទេ។ ពុកត្រូវខំធ្វើការរកប្រាក់ឲ្យបានច្រើនលើសពេលមុន ព្រោះសព្វថ្ងៃនេះខ្ញុំធ្លាក់មកលើបន្ទុកគាត់ទាំងស្រុង ប្រាក់ខែវ៉ាងមួយខែដប់រៀលរបស់ខ្ញុំនោះ ត្រូវគាត់សងលុយជំពាក់កាលខ្ញុំគេទៅបាត់ដំបង សៀមរាបអស់ទៅហើយ។ ហេតុនេះក្រួសារយើងចាយត្បិតក្បៀតជាទីបំផុត ដើម្បីជៀសវាងកុំឲ្យជំពាក់គេ។

ពុក និង ម៉ែ មួយថ្ងៃៗធ្វើការឥតទំនេរដៃ មួយផ្ទះនៅសល់ទំនេរតែខ្ញុំ ដែលឥតធ្វើការអ្វីទាំងអស់ក្រៅតែពីតែងខ្លួនសំអិតសំអាងកាយ។ ម៉ែ និង កាហ៊ីនទៅផ្សារដាំបាយ សួស្តក ចោកគក់សំពត់អាវខ្ញុំគ្រប់បែបយ៉ាង។ សុខភាពខ្ញុំបានស្រួលឡើងវិញជាល់ដាប់ ប៉ុន្តែឪពុកបែរជាធ្លាក់ខ្លួនឈឺម្តងក្តៅ ម្តងរងា គួរឲ្យព្រួយបារម្ភក្រៃលែង។ តាំងពីត្រឡប់មកពីអង្គរវិញ មួយយប់ៗគាត់ក្អកទល់ភ្លឺ ជួនកាលមានធ្លាក់ឈាមទាំងដុំមកផង ពេលក្អកម្តងៗទ្រូងគាត់ក្តៅដូចភ្លើង។ គាត់រេក្រសែភ្នែកពោរពេញទៅដោយក្តីស្នេហា និង ក្តីព្រួយបារម្ភសម្លឹងមើលខ្ញុំ សម្លឹងមើលផ្ទះ សម្លឹងមើលម៉ែ ដែលគិតតែអង្គុយយំ ឥតធ្វើអ្វីកើតទាំងអស់។ គាត់ហៅខ្ញុំចូលទៅជិត ហើយទូន្មានថា៖

- កូនឯងនៅក្តងវ៉ាងរហូតទៅណា ពីព្រោះបើចេញមកនៅក្រៅ កូនឯងគ្មានបង្គោលទីពឹងម៉ាំមួនទេ។
យើងពុំបានចាប់ភ្លឺកគិតថា គាត់ឈឺខ្លាំងទាល់តែសោះ ហើយខ្លួនគាត់ប្រហែលជាខំលាក់មិនឲ្យយើងដឹង ខ្លាចយើងព្រួយចិត្តហើយមើលទៅ។

ក្រាន់តែមានកម្លាំងបន្តិចឡើងវិញភ្លាម ខ្ញុំមានសេរីភាពពេញបរិប្ណ៌ អាចលេងសើច ឬ ធ្វើអ្វីបានតាមចិត្ត ព្រោះនៅផ្ទះគ្មានក្រមវ៉ាងចាំតាមយាមគ្រប់ជំហានដូចនៅវ៉ាង។ ចាប់តាំងពីពេលធំពេញរូបពេញរាងមក ខ្ញុំសង្កេតឃើញពុកគាត់ប្រឹតប្រៀនរឿងខ្ញុំខ្លាំងណាស់។ ថ្ងៃមួយគាត់ឃើញទាន់ខ្ញុំកំពុងងូតទឹកនៅមាត់ទន្លេ ឥតចេះអៀនខ្មាសដល់កេងឯងដែលមុជអ៊ូអរនៅជិតនេះសោះ គាត់ក៏ដេញឲ្យខ្ញុំក្រឡប់មកផ្ទះវិញ ព្រមទាំងស្តីបន្ទោសខ្ញុំយ៉ាងច្រើន ប៉ុន្តែគាត់ស្តីមួយម៉ាត់ ខ្ញុំស្តើយទៅវិញដប់ម៉ាត់ មិនព្រមចាញ់គាត់ទេ។ ឃើញថាប្រដៅខ្ញុំមិនបាន គាត់ក៏ទៅប្រាប់ម៉ែថា ខ្ញុំនេះឆ្នាស់រកនរណាប្រៀបឲ្យស្មើពុំបាន ហើយចាប់តាំងពីពេលនោះមក គាត់រឹតតែឃ្លាំមើលខ្ញុំ ប្រយ័ត្បប្រយែងជាងពេលមុនទៅទៀត។ ខ្ញុំក្លាយខ្លួនទៅជាមនុស្សទោសជាប់ឃុំឃាំង ពុំអាចដើរចេញទៅណាមកណាតែម្នាក់ឯងបានឡើយ ហើយខ្ញុំត្រូវតែយល់ថា ការប្រុងប្រយ័ត្នរបស់ពុកជាការត្រឹមត្រូវ ពីព្រោះនៅក្តងទីក្រុងមានមនុស្សប្រុសខូចខិលច្រើនណាស់ ស្រីអាយុដំណាលខ្ញុំ ត្រូវចេះការពារខ្លួនឲ្យមុឺងម៉ាត់ ដើម្បីកុំឲ្យធ្លាក់ខ្លួនទៅក្តងអន្ទាក់ពួករ៉ា។ លើសពីនេះទៅទៀត ខ្ញុំមិនត្រូវភ្លេចថា ខ្លួននេះជាអ្នកបំរើហ្លួង លោកឧស្សាហ៍ប្រើក្រុមវ៉ាងឲ្យមកតាមស៊ើបសួរដំណឹងពីខ្ញុំជារឿយៗ ឲ្យតែហ៊ានភ្លោះភ្លើយបន្តិចលេចឮទៅដល់វ៉ាង ច្បាស់ជាត្រូវទណ្ឌកម្មធ្ងន់ខ្លួនមិនខាន នេះមិននិយាយពីរឿងគេបណ្តេញឈប់ឲ្យនៅវ៉ាងផង។

មានកើតឧប្បត្តិហេតុមួយ ដែលជាសញ្ញាព្រមានថាឲ្យខ្ញុំត្រូវតែប្រយ័ត្នខ្លួនចាប់តាំងពីពេលនេះតទៅ ហើយពុក-ម៉ែក៏រឹតតែតឹងតែងខ្លាំងឡើងទៀតដែរ។ ថ្ងៃមួយខ្ញុំអង្គុយជក់ជាវ៉ៃ ជជែកគ្នាជាមួយកាហ៊ីន លើរានហាល ភ្នែកសម្លឹងមើលមនុស្សម្នាដែលដើរមកតាមផ្លូវមុខផ្ទះ ស្រាប់លេចឃើញជារ៉ាងម្នាក់ មុខក្រហមងាំង សក់ក្បាលបះកង្ហើង ពុកមាត់ស្រមុម ស្លៀកពាក់ស ពាក់មួកស ដែលជាការចម្លែកពេកណាស់ ពីព្រោះក្តងភូមិខ្មែរមិនសូវមានជារ៉ាងចេញចូលញឹកញាប់ទេ។ ក្រឡេកមកឃើញខ្ញុំ ស្រាប់តែវាបត់ក្បាលដើរចូលរុំយ តម្រង់មកចំផ្ទះខ្ញុំតែម្តង ខ្ញុំភ័យស្ទើរលោះព្រលឹង រត់ចូលទៅក្តងផ្ទះស្រែកឆោឡោ:

- ពុក! ម៉ែ! ជារ៉ាងចូលផ្ទះយើងហើយ ធ្វើម៉េចទៅ?
ពុកស្រវាទាញបានរនុកទ្វារ ម៉ែទាញបានជន្លង់បង្ហួច យកមកលាក់ក្រោយខ្នង ចេញទៅឈរពាំងមាត់ទ្វារ។
- លោករកអី? (ពុកសួរទៅជារ៉ាងដែលទើបនឹងឡើងផុតកាំជណ្តើរ ដើរទ្រេតទ្រោតចូលមក)។ ជារ៉ាងនេះធំក្លិនស្អុយស្រាហួង វាសើចខ្ចើរ ព្រមទាំងនិយាយក្រលស្ទើរស្តាប់មិនចង់បាន:
- ខ្ញុំរកប្រពន្ធខ្ញុំ វានៅទីហ្នឹងទេ?
- អត់មានប្រពន្ធលោកនៅទីនេះទេ, លោកអញ្ជើញទៅរកកន្លែងណាផ្សេងទៀតទៅ!
ខ្ញុំ និង ហ៊ុន ពួនពីក្រោយជញ្ជាំង លួចមើលតាមប្រហោងជញ្ជាំងភ័យញ័រទន្ទ្រើក ដោយឃើញពុកខ្ពស់មិនដល់ស្មាជារ៉ាងផង។ ប៉ុន្តែសំណាងល្អ អាជារ៉ាងហ្នឹងវាស្រវឹងស្រាខ្លាំងណាស់ វាព្រមចុះដើរចេញទៅវិញតាមសម្រួល ដោយលូកដៃ

ស្តាំមកចាប់ដៃពុកជាសញ្ញាលាគ្នាផង។ រឿងនេះវាធ្វើឲ្យផ្អើលអស់មួយភូមិ គេនាំគ្នាមកសាកសួរពុក-ម៉ែ ហើយយកទៅនិយាយសើចលេងពេញម្តុំកំពង់ផែអស់ពីរ-បីថ្ងៃ។

ផ្ទះខ្ញុំឧស្សាហ៍មានភ្ញៀវឡើងចុះណាស់ ហើយក្នុងចំណោមភ្ញៀវទាំងអស់ ខ្ញុំសង្កេតឃើញថាមានប្រុសកម្លោះពីរនាក់ដែលខ្ញុំធ្លាប់ស្គាល់តាំងពីយូរមកហើយ ដោយធ្លាប់ឮគេនិយាយនៅក្នុងវាំង និង ធ្លាប់ឃើញក្នុងពិធីបុណ្យផ្សេងៗ មួយឈ្មោះ នុន មួយទៀតឈ្មោះ ឱរ ជាអ្នកឡើងចុះញឹកញាប់ជាងគេ។ ជួនកាលវាមកលេងខុសពេលគ្នា ជួនកាលមកជួបគ្នាតែម្តង ដែលជាការគួរឲ្យជុញទ្រាន់ពេកណាស់ ព្រោះម្នាក់ៗ សុទ្ធតែប្រដែងគ្នាទិញនេះទិញនោះយកមកជូនម៉ែដើម្បីផ្គាប់ផ្គុន, ខ្ញុំក៏មិនមែនខ្វាក់មិនយល់ពីគោលបំណងរបស់វានោះទេ។ ម៉ែក៏មិនលាក់រឿងនេះនឹងខ្ញុំដែរ គាត់ប្រាប់ខ្ញុំថាឈ្មោះ នុន និង ឱរ ជាកូប្រដែងចង់ស៊ីដណ្តឹងខ្ញុំ ប៉ុន្តែខ្ញុំមិនដឹងជាសំរេចចិត្តស្រឡាញ់មួយណា គឺខ្ញុំស្អប់វាទាំងពីរនាក់តែម្តង គ្រាន់តែមិនចេញស្តីឲ្យនរណាដឹង។

ឪពុករបស់នុន ជានាម៉ឺនធំ ស្លាប់តាំងពីយូរណាស់ហើយ ក្នុងពេលថ្មាំងជាមួយសៀម។ សព្វថ្ងៃ នុន រស់នៅជាមួយម្តាយមេម៉ាយ និង បងប្អូនស្រីច្រើននាក់ទៀត, គ្រួសារគេជាពូជព្រាហ្មណ៍បារគូសុទ្ធ។ នុន សម្បុរខ្មៅស្រអែម មាឌធំ រាងសង្ហា ចេះគួរសម មិនប្រកាន់ខ្លួន ទោះបីម្តាយទំរើសកូនប្រុសតែមួយ ទិញនាឡិកា, ខ្សែដៃមាស, កង់យ៉ាងទាន់សម័យ បំពេញចិត្តមិនឲ្យទាស់យ៉ាងណាក៏ដោយ។ ផ្ទះម្តាយនុន ស្ថិតនៅខាងត្បូងវត្តបទុម ពីក្រោយស្រះស្រង់, ជំទូលាយល្អណាស់។

ឱរ ជាកូនចៅក្រមធំ អាយុស្រាលគ្នានឹងនុនដែរ ប៉ុន្តែវាជាកូនចៅចិន ហើយជាមនុស្សខ្ជីខ្ជា មិនសូវគិតគូរពីរឿងអីទេ។

នុន និង ឱរ ធ្លាប់ស្គាល់គ្នាតាំងពីក្មេង ដោយធ្លាប់រៀននៅក្នុងសាលាបារាំងជាមួយគ្នា ឈប់រៀនក៏ដំណាលគ្នា ហើយដល់ពេលបួស ក៏បួសក្នុងវត្តជាមួយគ្នាទៀត។ លុះសឹកមកវិញ ទំនេរមិនទាន់ចូលធ្វើការ គេក៏រឹតតែរាប់អានគ្នាលើសដើម ដើរទៅណាក៏ពីរនាក់ កម្រឃើញដើរបែកគ្នាណាស់។ គេមិនសូវមានតម្រិះ ជ្រៅជ្រះក៏ពិតមែន ប៉ុន្តែគេអាងសម្បត្តិម៉ែឪ មិនសូវភ័យព្រួយរឿងរកស៊ីធ្វើការដូចយើងជាកូនអ្នកក្រឡើយ។ ខ្ញុំដឹងថាពីមុន នុន ធ្លាប់មានទាក់ទងនឹងពួកល្ខោនម្នាក់ ប៉ុន្តែក្រោយមកបែកបាក់គ្នាទៅវិញ ដោយសារមើនោះលួចសាហាយគ្នាជាមួយស្នៀនលោកកុង្សីនៅលើកប៉ាល់ដែលដឹកយើងត្រឡប់មកពីស្រុកបារាំងវិញ។ នេះជារឿងចាស់មួយ, ហើយក្រោយមកខ្ញុំសង្កេតឃើញថាកាលណាអស់អ្នក-អស់នាង ក្នុងវាំងចេញទៅវត្តព្រះកែវម្តងៗ នុន តែងដើរក្រឡឹងធ្វើឫកជាមិនយកចិត្តទុកដាក់មើលអាកប្បកិរិយាមាយាទ្វិកម្ល៉ក់របស់នរណាទេ តាមសម្លឹងមើលតែខ្ញុំម្នាក់ប៉ុណ្ណោះ។

ចំណែក ឱរវិញ ក៏មានទាក់ទងស្នេហានៅក្នុងវាំងជាមួយមីមួយនោះឈ្មោះ ពុន ប៉ុន្តែជាអភ័ព្វយាយចាស់មេអណ្តើកបែរជាច្រឡំទៅទាក់ទងនឹងម្នាក់ផ្សេងទៀតឈ្មោះ ពុន ដូចគ្នាដែរ។ ក្រោយមកមីពុន ទាំងពីរនាក់ វាឈ្លោះដេរបញ្ឆោរគ្នាផ្អើលណាណី ពីព្រោះវាសុទ្ធតែមិនដែលស្គាល់មុខម្ចាស់សំបុត្រផ្ញើមកដូចគ្នា។ ចាប់តាំងពីពេលច្រឡំមួយបែកការខ្ចាស់គេម្តងមក ឱរ លែងហ៊ានរវីរវល់រឿងនេះសោះតែម្តង។

ខ្ញុំចេះតែឆ្ងល់ ហេតុដូចម្តេចបានជាខ្ញុំទាក់ទងស្គាល់ប្រុសកម្លោះពីរនាក់នេះ? ខ្ញុំគិតយូរណាស់ទម្រាំរកនឹកឃើញ។ នុន ប្រហែលជាចាប់ស្រឡាញ់ខ្ញុំបន្ទាប់ពីពេលបានជួបគ្នាដោយចៃដន្យនៅក្នុងទីធ្លាវត្តព្រះកែវ ក្នុងថ្ងៃសីលដែលខ្ញុំដង្ហែម្ចាស់ក្សត្រីយកចង្ហាន់ទៅប្រគេនព្រះសង្ឃជាមួយអស់អ្នក-អស់នាង ដទៃទៀត នោះហើយមើលទៅ។

កាលនោះ នៅក្នុងវាំងមានស្រីកូនស្តេចម្នាក់កំព្រា មិនដឹងជាកូនចៅស្តេចណាទេ ឈ្មោះ ចិន្តាវង្ស មានបន្ទប់ដេកនៅក្បែរខ្ញុំ ម្ចាស់នេះនៅជាមួយមីងចាស់ម្នាក់ឈ្មោះយាយអ៊ូ ដែលស្រឡាញ់រាប់អានខ្ញុំណាស់ ហើយថែមទាំងស្គាល់គ្រួសារនុន ច្បាស់លាស់ទៀតផង។ គាត់ត្រូវគេជួលឲ្យលុយយ៉ាងច្រើន ដើម្បីធ្វើមេអណ្តើក រហូតដល់ហ៊ានលួចដាហ៊ីចាក់ជរាពណ៌ក្រហមរបស់ខ្ញុំយកទៅឲ្យនុន ទាល់តែខ្ញុំគំរាមកំហែងខ្លាំងមែនទែន ទើបគាត់យកមកសងវិញ។ ឃើញថាទាក់ទងជាមួយខ្ញុំមិនបាន គាត់ក៏បែរទៅទាក់ទងជាមួយពុក-ម៉ែម្តង ហើយម៉ែនោះចេះតែនៅស្ងៀមរហូត។ ថ្ងៃមួយគាត់កំពុងមកលេងជាមួយខ្ញុំនៅឯវាំង ស្រាប់តែមានគេមកតាមថា ពុកឲ្យហៅត្រឡប់ទៅផ្ទះវិញជាប្រញាប់។ ទៅដល់ផ្ទះគាត់ភ្ញាក់ព្រើត ដោយឃើញមនុស្សមួយហ្វូងធំកាន់ថាសដាក់នំចំណី មានម្តាយនុន ជាអ្នកនាំមុខចូលមកចែចូវស្តីដណ្តឹងខ្ញុំ។

ដោយខ្លាចអំណាចគេជាអ្នកមាន ពុកមិនហ៊ានឆ្លើយថាយ៉ាងម៉េចឲ្យច្បាស់លាស់ គាត់យកអំណាចហ្លួងមកដឹកមុខថា មានតែហ្លួងទេដែលអាចសំរេចរឿងប្តីសី នៃពុកល្ខោនរបស់លោកបាន។ ពុកមិនបានបដិសេធដាច់ស្រេចអញ្ចឹងទើបបានជានុន នៅតែទៅមកឡើងចុះផ្ទះខ្ញុំជាញឹកញាប់ ហើយខំយកចិត្តពុក- ម៉ែលើសដើម។

ថ្ងៃមួយ នុន នាំ ឱរមកលេងផ្ទះខ្ញុំ ដើម្បីបង្ហាញឲ្យម៉ែបានស្គាល់ពួកម៉ាកសម្លាញ់ចិត្តរបស់គេ ហើយចាប់តាំងពីពេលនោះមក ឱរ ក៏ឧស្សាហ៍មកលេងតែម្នាក់ឯងជាញឹកញាប់ ដោយសំអាងថាជាពួកម៉ាកជិតជិតនឹងនុន ប៉ុន្តែតាមពិតអាគាត់ហ្មឺងចង់ដើរខ្សែលើពួកម៉ាកតែម្តង។ ឪពុករបស់ឱរ បានជួបជាមួយពុក ស្នើចង់ភ្ជាប់សាច់ឈាមរវាងគ្រួសារយើងទាំងពីរផង ប៉ុន្តែពុកក៏មិនបានឆ្លើយឲ្យជាក់លាក់ថាយ៉ាងម៉េចដែរ។
ថ្ងៃមួយ ឃាយអ៊ូមកសុំផ្ទះសំណាក់ពីរ-បីអាទិត្យ ដើម្បីដោយបញ្ហះបញ្ហូលពុក-ម៉ែ ឲ្យជាក់ចិត្តទៅលើនុន ពីព្រោះគ្រួសារនេះបានចំណាយលុយជួយគាត់អស់ច្រើនណាស់ ដើម្បីសំរេចការឲ្យគេ។ ម៉ែគាត់ល្ងង់ហើយចិត្តល្អពេក បណ្តោយឲ្យគេ

បង្វិលទៅឆ្វេង ទៅស្តាំបានតាមចិត្ត ទាល់តែពុកបន្ទោសថាគាត់ភ្លើ មិនចេះខ្លាចអ្នកជិតខាងគេពេបជ្រាយថា ឯងដីកញ្ជីបក្សីឈ្លោលសោះតែម្តង ប្រយ័ត្នតែរឿងនេះលេចឮទៅដល់ ហួងច្បាស់ជាកើតរឿងរ៉ាវធំមិនខាន។

បើនិយាយដោយពិត ឱរវាមានលក្ខណៈគួរឲ្យខ្ពំមិនចូលចិត្តច្រើនជាង នុន គឺវាចេះធឹកស្រា, ចិត្តកាចឆេវឆាវ ហើយស្អប់បំផុតត្រង់វាមានគំនិតខូងស៊ីលើពួកម៉ាកឯង។ ថ្ងៃមួយខ្ញុំជួបវាដោយចៃដន្យ ឃើញកំពុងអង្គុយជជែកអែប្រមែជាមួយមិត្តភក្តិពុកជាច្រើនទៀត ខ្ញុំក៏ភ្នាំដៀលថាឲ្យវាច្រើនណាស់ ប៉ុន្តែវានៅតែធ្វើមុខឆ្កែ មិនព្រមដឹងខ្លួនសោះ។

ពុក និង ម៉ែ បានជំនុំគ្នាស្រេចបាច់រួចហើយថា ទោះជាយ៉ាងណាក៏គាត់មិនព្រមលើកខ្ញុំឲ្យទៅឱរដែរ ប៉ុន្តែគាត់មិនហ៊ានប្រាប់វាឲ្យដឹងខ្លួនឡើយ ព្រោះថាគូប្រជែងមានដល់ទៅពីរនាក់ បើមួយដឹងខ្លួនថាគេមិនចូលចិត្តនឹងខ្លួនហើយវាអាចមានការគុំគួនធ្វើទុក្ខបុកម្នេញក្រួសារយើងទៅថ្ងៃក្រោយ។ ខ្ញុំសម្គាល់ឃើញថាពុកពេញចិត្តនឹងនុនមែន ប៉ុន្តែគាត់ចេះលាក់ទុក ពុំដាយបញ្ចេញឲ្យម្ចាស់ខ្លួនវាដឹងទេ ដើម្បីកុំឲ្យវាបានចិត្ត។

រឿងណាដែលមានជាប់ទាក់ទងមកក្នុងរឿងនេះ ម៉ែនិយាយប្រាប់ខ្ញុំទាំងអស់គ្មានលាក់ប៉ុនសរសៃសក់ឡើយ ហើយសំដីព្រោកប្រាជ្ញរបស់យាយអូ អាចឲ្យខ្ញុំដឹងអស់សព្វកន្លៀតកន្លៀត ព្រមទាំងអាចឲ្យខ្ញុំរិះរកមធ្យោបាយសម្រាប់ការពារខ្លួនជាមុនបានផង។ យាយអ៊ូបន្ទោសខ្ញុំថា មិនគួរធ្វើឲ្យប្រុសៗឯទុក្ខវេទនា ចំបែងចិត្តអញ្ចឹងសោះ ខ្លាចតទៅថ្ងៃមុខគេតាមញាបានដើម្បីសងសឹកនឹងខ្ញុំវិញ ប៉ុន្តែខ្ញុំបានសឹកសៀតសំដីឲ្យគាត់វិញធ្ងន់ៗ ទាល់តែគាត់សើចលែងសម។

ថ្ងៃមួយម៉ែចេញទៅផ្សារសួន តាំងពីព្រលឹមស្រាងៗ ពាក់អាវរហែក ស្លៀកសំពត់ចាស់ព្រមទាំងមានកណ្តៀតកញ្ជែងមួយយ៉ាងខ្ជីខ្ជាប់ផុត ដោយអាងថាជិតផ្ទះរាប់ត្រឡប់មកវិញ។ ទៅដល់កណ្តាលផ្លូវក្បែរដើមពោធិ៍ ស្រាប់តែជួបវាក់គ្នានឹងពួកកម្លោះមួយហ្វូងជិះកង់មក, គេនាំគ្នាចុះពីលើកង់ ដោះមួកហើយ លើកដៃសំពះ:

- មីងអញ្ជើញទៅណាហ្នឹង? (នុន, ឱរ និង មិត្តភក្តិគេទាំងអស់ ឧទានព្រមគ្នា) ។

ម៉ែអៀនខ្លួនរៀបឫកមិនត្រូវនៅចំមុខសេចក្តីគួរសមនៃពួកកូនអ្នកមានទាំងនេះ ណាមួយគាត់ស្លៀកពាក់មិនសូវសមរម្យផង ដែលជាហេតុធ្វើឲ្យអ្នកដើរទៅតាមផ្លូវគេបែរមើលគ្រប់គ្នា។ ដើម្បីគេចចេញពីពួកនេះ ម៉ែប្រាប់ថាឲ្យពួកវាមកផ្ទះមុនចុះ ហើយគាត់បង្ហួសមកផ្សារតែម្នាក់ឯង។ ម៉ែខំរើរើនៅផ្សារយូរណាស់ ដើម្បីឲ្យនុន, ឱរ វាត្រឡប់ចេញពីផ្ទះយើងទៅវិញ ប៉ុន្តែគាត់គន់គូរខុស មកដល់មាត់ទ្វាររបង ស្រាប់តែឃើញកង់ផ្អែកក្រៀបក្រានៅមាត់ជណ្តើរ និងសរសរផ្ទះ គាត់ហួសចិត្តមិនចេញស្តី សសៀរដើរលបៗមិនឲ្យគេឃើញ យកកញ្ជែងត្រីទៅទុកនៅឯចង្រ្កានបាយ។ ខ្ញុំពួននៅក្នុងបន្ទប់ខាងក្រោយជាមួយហ៊ុន លបមើលតាមប្រហោង ឃើញម៉ែលើកដៃលើកជើងឲ្យសញ្ញាទៅពុក ដែលកំពុងអង្គុយកណ្តាលហ្វូង ពួកក្មេងកម្លោះ។ គាត់និយាយកំបុតៗ បញ្ចេញទឹកមុខមិនសប្បាយចិត្ត ដើម្បីបង្ហាញឲ្យភ្ញៀវជម្លើយឃើញ ថាគាត់ធុញទ្រាន់ណាស់។ ពុកមើលឃើញទាំងអស់នូវកាយវិការ ម៉ែដែលមានន័យថាឲ្យបណ្តេញភ្ញៀវចេញទៅដើម្បីឲ្យគាត់មានពេលរៀបចំផ្ទះសម្បែង ដាំបាយទឹកផង ព្រោះថ្ងៃកាន់តែខ្ពស់ណាស់ទៅហើយ ប៉ុន្តែមើលទំនងហាក់ដូចជាគ្មាននរណាមួយប្រុងដើរសោះ។ ទ្រាំមិនបាន ពុកក៏សុំទោសភ្ញៀវថា គាត់រវល់ជួសជុលសរសរផ្ទះបន្តិចហើយដើរបង្ហើងទាញយកពូថៅដើរទៅក្រោមផ្ទះបាត់ គាត់សំពងសសរក្តាំងៗ រញ្ជួយញ័រតួផ្ទះ ធ្លាក់កំទេចស្លឹកព្រោងព្រាតមកលើក្បាលកម្លោះមុខក្រាស់។ ទាល់តែធ្វើអញ្ចឹងទើបពួកវាសំពះលាចេញទៅ។ មានអាខ្លះលួចសើចសប្បាយទៀតផង។

ខ្ញុំចេញពីកន្លែងពួនមកវិញ ដេរប្រទេចពួកនោះច្រើនណាស់ ហើយម៉ែក៏ប្រញាប់ប្រញាល់លាងអង្ករដាក់ដាំបាយដែរ។ ពុកកាន់ពូថៅដើរឡើងមកលើផ្ទះវិញ និយាយរអ៊ូថា:

~ ពួកអាច្រឡឹមអស់ហ្នឹង វាចង់បង្កត់បាយកូនស្រីអញដល់ថ្ងៃត្រង់ម្តង!។

ចាប់តាំងពីថ្ងៃនោះមក មិនសូវឃើញ នុន មកលេងញឹកញាប់ដូចមុនទេ។ យាយអ៊ូនិយាយប្រាប់ម៉ែថា គាត់តែងសង្កេតឃើញ ម្ចាស់កណ្តៀន មកផ្តុំខ្លួយក្បែរផ្ទះរាល់យប់ គឺប្រាកដជាមកឱកខ្ញុំហើយ ហើយគាត់ធ្វើឫកជាស្អប់ម្ចាស់ហ្នឹងខ្លាំងណាស់។

ចំណែកអាឆ្កែ ឱរវិញមុខក្រាស់រកស្អាន គេធ្វើប៉ុណ្ណឹងហើយនៅមិនដឹងខ្លួនទៀត វានៅតែមកគួរសមជាមួយម៉ែជានិច្ច ព្រោះវាដឹងថាម៉ែស្លូត។ វាបញ្ចេះបញ្ចូលពាក្យលំម៉ែថា:

- មីងកុំទុកចិត្តអានុនពេក ព្រោះវាជាមនុស្សមានពុតត្បិតអាក្រក់ ហើយវាមិនមែនស្រឡាញ់មីងដោយស្មោះទេ។

ក្រោយមកខ្ញុំបានដឹងថា នុន មានប្រពន្ធមួយឈ្មោះ ខ្វែន ដែលវាផ្តាប់យកមកនៅលើផ្ទះជាមួយគ្នាអស់រយៈពេលជាច្រើនថ្ងៃ។ ចាប់តាំងពីពេលនោះមក ពុកសម្រេចថានឹងមិនលើកខ្ញុំឲ្យទៅ នុន ឬ ឱរ អ្វីទាំងអស់ ព្រោះពីរនាក់នេះវាគ្មាននរណាគ្រាន់បើជាងនរណាទេ។ ខ្ញុំបណ្តេញយាយអ៊ូឲ្យចុះចេញពីផ្ទះ ហើយថែមទាំងពោលពាក្យបញ្ជឲ្យគាត់ទៅនៅជាមួយអាឆ្កែខ្មៅនុន នោះចុះ។

ក្រោយបន្តិចមកលេចឃើញ នុន មកដើរក្រឡឹងផ្ទះខ្ញុំរាល់យប់ ប៉ុន្តែយប់មួយនោះងងឹតចាក់ភ្នែកមិនយល់ ស្រាប់តែមានមនុស្សមិនស្គាល់មុខមួយក្រុមព្រួតគ្នាវាយវាបែកក្បាល ហើយរត់គេចខ្លួនបាត់ទៅ។ ខ្ញុំយល់ច្បាស់ណាស់ ប្រាកដជាអាឱរតែម្តង ដែលជួលអ្នកលេងឲ្យមកវាយពួកម៉ាកឯង ប៉ុន្តែអានេះប្រសប់ ធ្វើដូចជាមិនដឹងអ្វីទាំងអស់។

រឿងរ៉ាវរាជ្ជន់ដល់ប៉ុណ្ណោះហើយ ពុកព្រួយបារម្ភណាស់ខ្លាចក្រែងតែគេសងសឹកមកលើខ្លួនខ្ញុំទៀត។ ស្ទើរតែរាល់យប់ មនុស្សប្រុសទាំងហ្វូងៗ មកប្រជុំគ្នាអ៊ូអ៊ែរក្បែរផ្ទះខ្ញុំ ទាល់តែពុកកាន់ពូថៅចូរទៅសម្អាត ទើបវាប់បែកគ្នាដើរចេញ។ ម្តងនោះ វាលបគប់ដុំថ្មមកលើដំបូលផ្ទះយើងទៀតផង។ រាល់យប់ ពុកមិនដែល ហ៊ានសម្រាន្តទេ។ គាត់អង្គុយយាមទើសភ្លឺ ហើយគាត់ឲ្យខ្ញុំឡើងដេកលើក្តារឆៀក្រាស់ ដោយខ្លាចក្រែងមានគេលបចាក់ពីក្រោមមកតាមប្រហោងក្តារ។

នុន ចង់សម្លាប់ ឱរឲ្យបានដើម្បីសងសឹក ប៉ុន្តែចិត្តវាមិនសូវសឿងដូចមាត់សោះ។ ជាសំណាងល្អ ស្ថានការណ៍ដ៏ធ្ងន់ធ្ងរនេះបានប្រែជាធូរស្រាលឡើងវិញ ដោយលោកអ៊ុម ជាមេទាហាន ត្រូវហ្លួងគ្រាស់បង្គាប់ឲ្យទៅការពារសន្តិសុខឯខេត្តបាត់ដំបង ដែលទើបនឹងយកបានពីសៀមមកវិញ ហើយគាត់ក៏យកនុន និង ឱរ ទាំងពីរនាក់ឲ្យទៅជាមួយសម្រាប់ធ្វើជាស្មៀន។

មុនពេលចេញដំណើរទៅ នុនបានមកជំរាបលាពុក ធ្វើមុខក្តរឲ្យអាណិត បង្ហាញឲ្យឃើញថា វាមិនទាន់អស់សង្ឃឹមទេ។ វាប្រាប់ពុកថា ឲ្យប្រយ័ត្ន កុំទុកចិត្ត អាឱរពេក សំបុត្រធ្វើមកពីបាត់ដំបង ប្រសិនបើស្អានវាស៊ីញ៉ៅ គឺប្រាកដជាអាឱរធ្វើមកក្លែងក្លាយហើយ។ ប៉ុន្តែពុកនិយាយប្រាប់ខ្ញុំថា គាត់បានទៅរកលោកទាយ ខែ ឆ្នាំមុន និង ខ្ញុំ ឃើញថាវាមិនមែនជាគូព្រេងខ្ញុំទេ ថ្ងៃក្រោយខ្ញុំត្រូវមានប្តីជាជនបរទេស និង ឲ្យពុកប្រយ័ត្នខ្លួនមែនទែន ព្រោះគាត់ជិតដល់ពេលអស់អាយុហើយ ។ ពេលនេះពុកកំពុងឈឺស្រាប់ផង ដល់ឮថាគាត់ជិតស្លាប់អញ្ចឹង ខ្ញុំរឹតតែព្រួយចិត្តទ្វេមួយជាពីរ។

មើលទៅពុក ក្អានឃើញបានធូរស្រាលបន្តិចសោះ សមនឹងកើតមានរឿងពិបាកចិត្តផង គាត់ក៏កាន់តែដាបទៅ។ ទ្រូងក្តៅដូចគេបំពក់ភ្លើង ក្អកធ្លាក់ឈាមមកទាំងដុំៗ...ម៉ែដូចជាមិនសូវភ័យព្រួយប៉ុន្មានទេ ដែលជាហេតុធ្វើឲ្យខ្ញុំទុកចិត្តសួកថា ពុកគង់នឹងជាសះស្បើយមិនខាន។ ខ្ញុំឆ្ងល់គិតមិនយល់ ហេតុអ្វីបានជាពុកប្រែប្រួលចរិតប្លែកពីមុនខ្លាំងម្ល៉េះ? ចាប់តាំងពីពេលធ្លាក់ខ្លួនឈឺមក គាត់ប្រែជាសញ្ជឹង ហើយនាប់ខឹងច្រឡោតណាស់។ កាលណាមានមនុស្សប្រុសឡើងមកលើផ្ទះ គាត់ធ្វើមុខមាំភ្លាមមួយរំពេច សម្លឹងសម្លក់មើលខ្ញុំសព្វគ្រប់ តាំងពីសម្លៀកបំពាក់ និង កាយវិការឡើងទៅ ហាក់ដូចជាចាំតែខ្វាមចាប់ទោសកំហុស។ ម្តងនោះ ភ្ញៀវកំពុងជជែកគ្នាជាមួយពុក ខ្ញុំសម្ងំនៅក្នុងបន្ទប់ពីរនាក់ហ៊ុន ប្រឡែងគ្នាសើចលាន់ឮទៅដល់ក្រៅ លុះភ្ញៀវលាទៅវិញមិនទាន់ចេញផុតរបងផង គាត់ក៏ចូលមកក្នុងបន្ទប់ បើកភ្នែកធំៗហើយ និយាយថា :

- ល្អណាស់ហើយ ស្រីក្រមុំដូចឯង ដែលសើចឲ្យអ្នកក្រៅឮអញ្ចឹងនោះ... ក្រែងម៉ែឯងធ្លាប់ប្រដៅដែរហ្អែថា នៅមុខប្រុសឈ្មោលមិនត្រូវធ្វើឫកអញ្ចឹងទេ ហើយក៏មិនត្រូវធ្វើជាអៀនរត់គេច ចង់ឲ្យគេដើរតាមខ្លួននោះដែរ។ ឯងចង់ធ្វើឲ្យអញខ្មាស់គេ ចង់ឲ្យគេមើលងាយ ដូចស្រីដើរហ៊ីហាតាមផ្សារអញ្ចឹងហ្អែ។

ខ្ញុំមិនអស់ចិត្តសោះ គ្រាន់តែកំហុសប៉ុណ្ណឹង មិនគួរគាត់ខឹងខ្លាំងដល់ម្ល៉ឹងទេ។ ខ្ញុំស្រក់ទឹកភ្នែកជ្រោក ខឹងញ័រដៃ ក៏គ្រវែងចោលប្រអប់ដែលកាន់នៅដៃ ត្រូវកញ្ចក់ទូបែកខ្ចាយ។ ពុកស្ទុះចូលមកទះស្មាខ្ញុំមួយដៃផាំង! ខ្ញុំដើរបឈរនិយាយតឹងសរសៃកទៅរកគាត់វិញ៖

~ ពុកមិនដែលវាយខ្ញុំទេ មិនដែលស្តីឲ្យខ្ញុំទេ តឡូវពុកវាយខ្ញុំ! ពុកដេរខ្ញុំ! ពុកលែងស្រឡាញ់ខ្ញុំហើយឬ? ចាប់តាំងពីថ្ងៃហ្នឹងទៅ ខ្ញុំក៏លែងស្រឡាញ់ពុកឯងដែរ។

ពុកដើរចេញទៅវិញ ទាញទ្វារបិទក្តាំង មិនចាំស្តាប់ខ្ញុំនិយាយដល់ចប់ឡើយ។ ខ្ញុំខឹងខ្លាំងមែនទែន លែងគិតខុសត្រូវអ្វីទាំងអស់។ ខ្ញុំទាត់បំបែកកញ្ចក់ទូ វាយបំបាក់កៅអី ទាញបណ្តាច់មុង លាន់តូងតាង ផ្អើលពេញផ្ទះ ដើម្បីសងសឹកនឹងការដែលពុកវាយខ្ញុំ។ បន្ទាប់មក ខ្ញុំគិតថានឹងរត់ទៅនៅវាំងវិញឲ្យបាត់ លែងឲ្យម៉ែឱ្យឃើញមុខតែម្តង។ ខ្ញុំបើកហិបឈើប្រមូលយកគ្រឿងអលង្ការ សំពត់អាវ ជាហ៊ុ និង របស់ប្រើប្រាស់ផ្ទាល់ខ្លួនទាំងអស់ រេចក្តងសារុងចាស់មួយ... ប៉ុន្តែខ្ញុំគ្មានលុយមួយសេនសោះ ព្រោះប្រាក់ខែវាំងនោះ ត្រូវគេកាត់យកអស់រាល់ខែ នៅឃ្លាទៅមុខទៀតណាស់ ទំរាំផុតលុយដំពាក់, ធ្វើម្តេចខ្ញុំនឹងរត់ទៅកើត បើអត់មានលុយសោះយ៉ាងនេះ? ខ្ញុំបែកគំនិតជីកកាយថតតុដែលចំណាំឃើញគាត់អង្គុយធ្វើការ រកឃើញប្រអប់ក្រដាសមួយដែលមានដាក់ប្រាក់កាក់បួន និង លុយបួនរៀល។ ពេលនេះទើបខ្ញុំដឹងច្បាស់ថា ពុកតែមានសល់លុយច្រើនដូចដែលខ្ញុំធ្លាប់ស្មាននោះទេ។ តើគាត់បានប្រាក់ពីណា សម្រាប់ចិញ្ចឹមខ្ញុំ, សម្រាប់ទិញរបស់ប្រើប្រាស់, ថ្នាំជក់, ទឹកអប់ ដើម្បីបំពេញចិត្តខ្ញុំរាល់ថ្ងៃ។ ខ្ញុំស្រមៃឃើញយ៉ាងច្បាស់នូវសប្បុរសធម៌ដ៏ធំធេងដែលពុកបានធ្វើចំពោះខ្ញុំ ហើយដែលពីមុនមកខ្ញុំពុំធ្លាប់បានដឹងទាល់តែសោះ។ ខ្ញុំនឹក អាណិតគាត់ខ្លោចចិត្ត សុខចិត្តដាក់លុយទៅក្នុងប្រអប់វិញ ក្រវាត់បង្ខូចទៅកៀនជញ្ជាំង ហើយប្រះដេកទៅលើក្រែ យំឮ៉ីកឮ្យលនឹកស្តាយមិនគួរធ្វើឲ្យឪពុកម្តាយពិបាកចិត្តដោយសារខ្លួន។

ល្ងាចនោះ ពូប៉ុល ធ្វើដំណើរពីព្រែកថ្មី នាំដំណឹងដ៏ក្រៀមក្រំមកប្រាប់ថា ជីតាខ្ញុំឈ្មោះ ស្វាយ នោះ ស្លាប់ទៅហើយ ដែលជាហេតុធ្វើឲ្យយើងភ្លេចអស់រឿងទាស់ទែងគ្នាក្នុងគ្រួសារ ហើយសំរេចថាព្រឹកស្អែកនេះ យើងនឹងទៅធ្វើបុណ្យសព តាស្វាយ ទាំងអស់គ្នា....។

យាយកែម អង្គុយធ្វើម្ខខស្រពោនព្រមដង្ហក្រមោចតែម្នាក់ឯង តគរវល់យកចិត្តទុកដាក់នឹងបងប្អូន ញាតិមិត្តដែលមកជួបជុំគ្នាពេញផ្ទះឡើយ។ ឃើញយើងទៅដល់ គាត់ញញឹមសួត ហើយនាំយើងដើរតម្រង់ទៅរកចេតិយដំកល់ធាតុក្រួសារ ដែលគេទើបនឹងយកសំណល់ នៃសាកសពប្តីគាត់មកទុកនៅទីនេះដែរ។ ខ្ញុំយំអណ្តែតអណ្តកបណ្តើរ អុជធូបដោតនៅមុខចេតិយបណ្តើរ រួចឡើងទៅលើផ្ទះដើម្បីស្តាប់យាយគាត់និយាយរៀបរាប់ប្រាប់ពីបុព្វហេតុនៃមរណភាពរបស់តាស្វាយ។

យើងមកដល់យឺតពេលបន្តិច មិនបានឃើញមុខខ្មោចតាទេ ព្រោះគេបូជាហើយស្រេចតាំងពីម្សិលមិញម្ល៉េះ។ យាយកែម ពីងគេឲ្យជួយរុះរានហាលផ្ទះ ដើម្បីយកគ្រឿងឈើទៅប្រគេនលោកវត្តកោះអន្លង់ចិន សម្រាប់ជាកុសលបញ្ញទៅឲ្យខ្មោចប្តីគាត់។ យើងសម្រេចចិត្តថានឹងនៅជំនួយយាយពីរ-បីថ្ងៃ ចាំគាត់អន់ព្រួយចិត្តសឹមត្រឡប់មកវិញ។ មរណភាពនៃជីតាខ្ញុំ ធ្វើអ្វីៗប្រែប្រួលទាំងអស់ ទីធ្លាដែលធ្លាប់តែស្អាតរលីងនោះ កំប្រែជាមានស្មៅដុះទ្រុបទ្រុល គោក្របីត្រូវគេលែងចោលឲ្យដើរអាវាសែពាសវាលពាសកាល មាត់ដើរកកាយដីស្អានភ័យព្រួយឡើយ ពីព្រោះស្អានឧណាមើលថែទាំសំអាតអ្វីទៀតទេ។

ពេលយប់ខ្ញុំដេកជាមួយយាយ ដើម្បីកំដរគាត់កុំឲ្យស្ងាត់ពេក។ ព្រឹកមួយនោះ ខ្ញុំដើរបពីដេកឡើងតាំងពីព្រលឹមស្រាងៗដឹងថា ស្តៅទាំងសង្ហាងត្រជាក់ស្រិតហាក់ដូចជាទទឹកទឹក លុះស្ទាបមើលឃើញសុទ្ធតែឈាម ខ្ញុំភ័យស្លុតនឹកស្មានថាសត្វអ្វីខាំ ក៏ប្រញាប់ដាស់យាយឲ្យភ្ញាក់ឡើង ដើម្បីប្រាប់គាត់ពីការភិតភ័យរបស់ខ្ញុំ។ យាយបន្ទោសខ្ញុំថាជាក្មេងស្តើ ហើយគាត់ប្រាប់ឲ្យខ្ញុំនៅស្ងៀមឈប់និយាយ ពីព្រោះខ្ញុំធំពេញក្រមុំហើយ ហើយក៏ដល់ពេលត្រូវ “ចូលម្លប់” ដែរ។ គ្រាន់តែប្រសៅចុះអស់ពីលើផ្ទះភ្លាម យាយយករឿងនេះទៅប្រាប់ម៉ែ និង ម៉ងខ្ញុំ ឲ្យបានដឹងគ្រប់គ្នា រួចបន្ទាប់មកគេលើកកន្លែងខ្ញុំដេកទៅដាក់ក្នុងបន្ទប់ឯខាងក្រោយ ឆ្ងាយពីភ្នែកអ្នកផង។ គេទូន្មានឲ្យខ្ញុំតាំងចិត្តសួគបូត កុំឲ្យខ្ញុំចេញពីបន្ទប់នេះក្នុងរយៈពេលមួយខែ កុំឲ្យបរិភោគត្រី សាច់ និង អ្វីៗទាំងអស់ដែលខ្ញុំធ្លាប់ចូលចិត្តកាលពីមុន។ មានតែស្រីៗទេដែលអាចចេញ ចូលកន្លែងខ្ញុំបាន ប៉ុន និង ហ៊ុន ជាបងប្អូនជីដូនមួយខ្ញុំនោះ មានការៈត្រូវលើកយកម្ហូបម្ហា និង ទឹកសម្រាប់ងូត មកឲ្យខ្ញុំដល់ក្នុងបន្ទប់តែម្តង។ ខ្ញុំធ្លាក់ខ្លួនឈឺសៀវស្រាញ ពុកទៅរកគ្រូមើលឃើញថាត្រូវខ្មោចធ្វើគាត់រៀបចំធ្វើពែ យកទៅសែនថ្វាយអ្នកតាដើមស្រឡៅ ដែលល្បីថាមានមហិទ្ធិឫទ្ធិខ្លាំងពូកែណាស់។

រស់នៅក្នុងកន្លែងឃុំឃាំងដូចមនុស្សជាប់ទោសអញ្ចឹង ពេលវេលាហាក់ដូចជាធ្វើដំណើរទៅមុខយឺតខុសធម្មតាគួរឲ្យធុញទ្រាន់ស្ទើរប្រេះច្រេងស្លាប់ ហើយត្រណមពិបាកទ្រាំជាងគេ គឺការហាមឃាត់មិនឲ្យបរិភោគត្រីសាច់នេះឯង ម្ល៉ោះហើយជួនកាលខ្ញុំចូលទៅក្នុងចង្ក្រានបាយ លួចបានត្រីអាំងយកមកបរិភោគមិនឲ្យនរណាដឹងឡើយ។

ទីបំផុត ខ្ញុំក៏បានរួចទុក្ខទោសចេញពីម្លប់មកវិញ។ ស្ត្រីក្រមុំក្នុងភូមិនាំគ្នាផ្ញើលមកមើលខ្ញុំ ហើយសរសើរថាខ្ញុំស្អាតណាស់ ដែលជាហេតុធ្វើឲ្យខ្ញុំអៀនខ្លួនមុខក្រហម រកហារមាត់និយាយថាមើចមិនកើត។ គេទូន្មាន ខ្ញុំជាថ្មីឲ្យបោះបង់ចោលនូវទម្លាប់ឆ្នាសកាចសាហាវ ដើម្បីធ្វើខ្លួនឲ្យបានក្លាយទៅជាស្ត្រីថ្លៃថ្នូរក្រឹមត្រូវនៅពេលអនាគត។ រាល់យប់មុនពេលចូលដំណេក យាយ និង ម៉ែ អុជចង្កៀងប៉ភ្លឺមើលសាស្ត្រា ច្បាប់ស្រី ច្បាប់កូនចៅ និង ច្បាប់ផ្សេងៗ ឲ្យខ្ញុំស្តាប់ ប៉ុន្តែខ្ញុំតគរវល់យកចិត្តទុកដាក់ស្តាប់ឡើយ ព្រោះវាគ្មានកន្លែងណា គួរឲ្យពិរោះដក់ចិត្តទាល់តែសោះ។

ម៉ែធ្វើដំណើរមកភ្នំពេញជាត់ពីរថ្ងៃ ដើម្បីមកទូលម្ចាស់ក្បត្រីកុំឲ្យលោកទន្ទឹងខ្លាំងពេក ដោយគរលោកថាខ្ញុំឈឺធ្ងន់ណាស់ ហើយពេលត្រឡប់មកវិញ គាត់ថែមទាំងខ្ចីគ្រឿងអលង្ការ និង សំពត់អាវជាំមួយសម្រាប់មកផ្ញើខ្ញុំផង។ ប៉ុន្តែពុកមានគំនិតមួយ គាត់ទៅប្រាប់តាចាស់ម្នាក់ជាអ្នកចូលរូបអារក្សថា ឲ្យខ្ញុំទៅរាំថ្វាយ អ្នកតាដើមស្រឡៅម្តង ព្រោះលោកឆ្លាប់បានជួយខ្ញុំឲ្យសះស្បើយជាជម្ងឺ។ អ្នកស្រុកសប្បាយចិត្តណាស់ ឮថាពួកល្ខោនហួងមកវ៉ា គេស្រុះគ្នាសង់រោងបោសសំអាតទីដីងតខ្ទមអ្នកតា ព្រមទាំងរៀបចំសែនព្រេនតាម ទំនៀមទម្លាប់។

តូបអ្នកតា គឺជាខ្ទមតូចមួយសង់បន្តបលើសសរបួននៅកណ្តាលព្រៃ ដែលគេអាចដើរចូលមកបានតាម ផ្លូវតែមួយគត់ កាត់កណ្តាលចំការចេក។ អ្នកភូមិព្រែកថ្មី និង ឫស្សីស្រុក នាំគ្នាមកជួបជុំអ៊ូអរពេញព្រៃ លុះឃើញពុកម៉ែ និង បងប្អូនខ្ញុំ ដើរហែហមនាំខ្ញុំទៅដល់ គេកយតន់មើលខ្ញុំស្លៀកពាក់ជាអ្នករបាំ ពាក់គ្រឿងអលង្ការ ហើយជញ្ជក់មាត់សរសើរគ្រប់គ្នា។ នៅមុខខ្ទមអ្នកតា គេកាប់ឈើសង់ធ្វើជារោងរបាំក្បែរដីដំបូក។ តារូបអារក្សអង្គុយលើកន្ទេល ដៃសំពះ ភ្នែកបិទមមីរ... ខ្ញុំវែកគេវែកឯងចូលទៅដល់មុខ ឃើញគេតម្រៀបគ្រឿងសំណែនច្រើនគ្រៀបគ្រាពីមុខខ្ទមអ្នកតា ដោយមានដុតធូបហុយទ្រលោម។ ពួកក្មេងកម្លោះគេស្ងៃគ្រ ចិត្តយកគ្រឿងភ្លេងមកលេងកំដរពិធីលៀងអារក្សនេះ ដោយពុំយកលុយកាក់ឡើយ។

រូបអារក្សធ្វើមាត់ជិបអូចៗសូត្រមន្តអាគម រាងកាយញាក់ទទ្រើកដូចមនុស្សក្រុនរងា។ បន្ទាប់មកភ្លេងក៏ចាប់លេងបទឆាបញ្ចោះ រតេរតួតស្អានត្រូវបែបបទបន្តិចសោះ ប៉ុន្តែម៉ែច្រានខ្លាំងពេក ខ្ញុំក៏ចេញរាំទាំងទើសទាល់។ ស្រាប់រូបអារក្សស្រែកវ៉ាស! ខ្ញុំភ្ញាក់ស្ទើរលោះព្រលឹង ឈរច្រឹងភ្លេចរាំមួយសន្ទុះធំ...គឺអ្នកតាចូលមកសណ្ឋិតក្នុងខ្លួនតានេះហើយ។ ភ្លេងលេងរឹតតែញាប់ឡើងៗ ហើយខ្ញុំក៏រឹតតែប្រយ័ត្នប្រយែងខ្លាចខុសណាស់ដែរ ព្រោះតានេះបើកភ្នែកក្រហមស្តែសម្លក់ខ្ញុំតបប៉ិចសោះ ព្រមទាំងលោតចាក់តួកក្រមាច់ក្រមើមដូចមនុស្សឆ្កួត។ មនុស្សដែលឈរមើលទាំងប៉ុន្មាន លើកដៃសំពះសុំស្រណុកសុខសប្បាយ អារក្សនោះក៏និយាយដៅវ្យថា:

- មិនអីទេ, កុំភ័យយើងជួយថែរក្សាហើយ!
មួយសន្ទុះក្រោយមក តានេះធ្វើមឹងមាំងដូចមនុស្សទើបនឹងដើរពីដេក ហើយនិយាយថា “គេចេញទៅ រីឯហើយ”។

លុះចប់សព្វគ្រប់ហើយ យើងក៏លាយាយតែម ត្រឡប់មកភ្នំពេញវិញ។ នៅពេលដើរពីផ្ទះពុកចុះទូក ពុកចង្អុលប្រាប់ដីមានដាំដើមស្វាយ ដែលជាចំណែកមត៌កខ្មោចលោកអ៊ុមហាសេនាប្រគល់ឲ្យខ្ញុំ។ គាត់គិតថាកាលណាខ្ញុំឈប់នៅវាំង គាត់នឹងមកសង់ផ្ទះនៅទីនេះវិញ។

ពូប៉ុល ចែវទូកជូនរហូតមកដល់ភ្នំពេញ ប៉ុន្តែយើងដើរមិនទាន់ដល់ផ្ទះផង ស្រាប់តែជួបនឹងស្រីម៉ាឡាយូម្នាក់ខ្វាក់ភ្នែកទាំងសង្ខាង នៅក្មេងនៅឡើយ ដែលពុកធ្លាប់ជួបនៅជ្រោយចង្វាម្តង ហើយដែលធ្លាប់ល្បីខាងធ្វើស្នេហ៍ជូនលោកស្រីនៅភ្នំពេញ។ គាត់ស្គាប់ខ្លុំ ហើយរៀបរាប់រឿងខ្លុំគ្មានខុសក្រង់ណាបន្តិចសោះ ដែលជាការគួរឲ្យឆ្ងល់ពេកណាស់។ បណ្តោយឲ្យគាត់ធ្វើអីតាមចិត្តចង់លមើល តើគាត់ទាយឆុត ឬមិនឆុត។ គាត់និយាយប្រាប់ខ្លុំថា ស្រីនៅក្នុងវាំងដែលបានគាប់ក្បូរនឹងហ្លួង ក៏ដោយសារបានស្នេហ៍ពីគាត់យកទៅប្រើប្រាស់, ម៉មនូ ដំណឹល្បាញដែលប្រជាក្រូវហ្លួងស្អប់វិញនោះ ក៏ព្រោះតែម៉មនូ ពុំបានឲ្យលុយគាត់ជ្រាំរយរៀល ដូចពាក្យសន្យា។

មីងខ្វាក់បង្គាប់ឲ្យខ្លុំអង្គុយចុះទៅលើដុំថ្មមានក្រាលកន្ទេលពីលើ យកអំបោះដៅមកចងកដៃខ្លុំ ដើម្បីការពារកុំឲ្យខ្មោចព្រាយបៀតបៀនបាន ហើយគាត់អុជទៀនធូបដាក់លើជើងពាន ព្រមទាំងសូត្រមន្តអាគម ឱ្បឹបៗ រួចទើបនិយាយមកកាន់ខ្លុំថា:

- អ្នកមានសត្រូវច្រើនណាស់ ចូរប្រយ័ត្នខ្លួនឲ្យមែនទែន គឺពួកម៉មឃុន នៅក្នុងវាំង គេចង់ឈ្នានីសអ្នកគ្រប់គ្នា។

គាត់ប្រគល់ទឹកអប់ និង ម្សៅឲ្យខ្លុំព្រមទាំងផ្តាំថា ចាំដល់វាំងសឹមប្រើដើម្បីឲ្យគេអាណិតស្រឡាញ់។ ខ្លុំរៀបចំខ្លួនហៀបនឹងត្រឡប់ទៅវាំងវិញ ស្រាប់តែលេចឃើញយាយអភ័ម្នាក់ ដែលម្ចាស់ក្បាត្រីបញ្ជូនឲ្យមកមើលខ្លុំតាមបញ្ហ្លង។ យាយនេះខ្លុំស្គាល់គាត់ច្បាស់ណាស់ ហើយនៅពេលឃើញខ្លុំ គាត់ហាក់ដូចជាសប្បាយរីករាយរកអ្វីមកប្រៀបឲ្យស្មើពុំបាន។ គាត់អង្គុយលើកន្ទេលជិតខ្លុំ ហៅខ្លុំសុទ្ធតែកូន, គាត់លូកដៃអង្អែលជង្គង់ខ្លុំ, អង្អែលស្មា, លូកស្ទាបរហូតដល់ពោះ, ស្រាប់តែភ្ញាក់ស្លាត់មាត់:

- កូនអើយ! មីណាមាត់អាក្រក់វាទៅទួលហ្លួងថា កូនឯងផើម !
យើងស្រឡាំងកាំងគ្រប់គ្នា ទាល់តែយាយនេះនិយាយពន្យល់សព្វគ្រប់ទើបបាត់ឆ្ងល់ បែរជានឹកឃើញហួសចិត្តចង់សើចទៅវិញ គឺមានលេចឮសំដីទៅដល់ត្រចៀកហ្លួងថា ការដែលបាត់ខ្លុំយូរ មិនឃើញត្រឡប់ទៅវាំងវិញយ៉ាងនេះព្រោះខ្លុំផើម ចង់លាក់មិនឲ្យគេដឹង។ រឿងនេះវាកើតឡើងដោយសារតែមានប្រុសកម្លោះចេះតែឈូឆរឡើងចុះផ្ទះខ្លុំរាល់ថ្ងៃ ប៉ុន្តែហ្លួងមិនទាន់ជឿទើបប្រើគេឲ្យមកមើលឃើញថាខ្លុំតមានកំហុសដូចគេថាទេ ឲ្យនាំខ្លុំត្រឡប់ទៅវាំងវិញ។

ខ្លុំលាពុក និង ម៉ែ ហើយឡើងជិះរទេះជាមួយយាយអភ័រ ដោយយក ហ៊ុន ទៅតាមជាមួយផង។ មួយសន្ទុះក្រោយមកយើងក៏បានមកដល់ទ្វារព្រលប់នៃរាជវាំង ដែលផុតពីនេះទៅ គេហាមមិនឲ្យមនុស្សប្រុសចេញចូលជាដាច់ខាត លើកលែងតែក្រុមវាំងចាស់ៗ និង ហោយប់រើហ្លួង។

ខ្លុំរត់ទៅគាល់ម្ចាស់ក្បាត្រី ដើម្បីបង្ហាញខ្លួនឲ្យលោកឃើញថាខ្លុំមកដល់វិញហើយ លោកវាក់ទាក់ទទួលខ្លុំបន្តិចដែរ។ លោកប្រាប់ខ្លុំឲ្យរៀបចំខ្លួនដើម្បីចូលវេនគាល់បំរើហ្លួងជាបន្ទាន់ ព្រោះហ្លួងទន្ទឹងដួរខ្លុំយូរណាស់ហើយ។ ខ្លុំត្រូវតែចូលទៅកាន់បន្ទប់ដេកមួយភ្លែតជាចាំបាច់ ដើម្បីលុបលាង និង តែងខ្លួន។ ខ្លុំដុតទឹក, ដួរសំពាត់, ជួរផាហ៊ី និង លាបទឹអប់, លាបម្សៅដែលក្រូម៉ាឡាយូឲ្យមក រួចស្រែចទើបចុះដើរតម្រង់ទៅរកប្រាសាទបាញ់យ៉ុង ទុកហ៊ុនឲ្យនៅបោសប្រាសសំអាតបន្ទប់តែម្នាក់ឯង។

ទៅដល់ក្នុងថែវ មានបោយក្លីក្លីម្នាក់ឥតមើលឃើញខ្លុំទេ ស្មានថាស្ងាត់នៅម្នាក់ឯង វាឆ្លុះកញ្ចក់លើកដៃទំនងដូចជាកាន់ថាស ហើយដើរទៅដើរមក ហាត់រៀនរបៀបលើកទៅថ្វាយហ្លួងឲ្យបានសម គួរឲ្យចង់សើចពេកណាស់។ ខ្លុំក្អកក្រហែមពីចម្ងាយដើម្បីឲ្យវាដឹងខ្លួន វាភ្ញាក់ប៉ុនគេចោល ស្រាចាប់ក្រណាត់មកជូតកញ្ចក់ធ្វើព្រងើយ។ ដល់ឃើញខ្លុំដើរទៅជិត វាពិតប្រជ្រៀតខ្លួនជាប់នឹងជញ្ជាំង ដើម្បីទុកផ្លូវឲ្យខ្លុំដើរ។ លុះខ្លុំដើរហួសបន្តិច វាក៏សៀកខ្លួនរត់គេចទៅណាបាត់។

ខ្លុំឈប់នៅមុខកញ្ចក់ ឆ្លុះមើលរូបខ្លួនឯងតាំងពីក្បាលរហូតដល់ចុងជើង រួចលូកដៃទៅក្រោយកញ្ចក់ ទាញយកក្រដាសចិនពណ៌ក្រហមមកលាបបបូរមាត់ញញឹមស្នេញស្នាញតែម្នាក់ឯង ស្រាប់តែលេចឃើញហ្លួងបើកទ្វារ ឈរទ្រឹងស្ងៀមនៅមុខបន្ទប់ ខ្លុំក៏បែរទៅលុតជង្គង់ថ្វាយបង្គំលោកភ្លាម លោកឈ្លោកសម្លឹងមើលខ្លុំយ៉ាងយូរ ទើបប្រាប់ឲ្យខ្លុំចូលទៅក្នុងបន្ទប់ដែលពេញចង្អៀតទៅដោយអស់អ្នក-អស់នាង ចូលវេនគាល់បំរើ។ លោកនិយាយរបៀបលេងសើចមកកាន់ខ្លុំថា:

- នែ ឯងទំនងដូចជាដើមមែនទេ?
- ក្រាបទូល ខ្លុំម្ចាស់អត់ដឹងទេ។
- ថាឯងកើតដំបៅនោះ តើដំបៅត្រង់ណា? បង្ហាញអញមើល។

ខ្ញុំទាញលើកសំពត់បន្ទិច បង្ហាញស្នាមបួសទ្រនិចនៅត្រង់កំភួនជើង។ ហ្លួងសម្លឹងមើលមួយសន្ទុះ ទើបនិយាយបន្តទៅទៀត :
- ប៉ុណ្ណឹងមិនអីទេ, អញស្មានថាឯងកើតដំបៅរលេះរលួយពេញខ្លួន។

និយាយហើយ លោកឡើងទៅផ្ទំលើត្រែ បង្គាប់ឲ្យគេរៀបចំខ្សៀអាភៀនថ្វាយ។ ផ្លិតនៅពីលើក្រឡាបន្ទំ បក់ទៅបក់មក សាយភាយក្លិនអាភៀនឈ្ងុយពេញបន្ទប់ដ៏ស្ងាត់ជ្រងំ ហាក់ដូចជាមនុស្សទាំងអស់គ្នានៅក្នុងបន្ទប់នេះ ដេកលក់អស់ទៅហើយ។

ខ្ញុំថយចេញទៅអង្គុយនៅក្រៅបន្ទប់ រង់ចាំក្រែងហ្លួងប្រើឲ្យធ្វើអ្វីទៀត។ មីស៊ុន មីរ៉ន និង មីស្អាត បានឡើងហាន: គាប់ព្រះទ័យហ្លួងខ្លាំងណាស់ គេមិនសូវរាក់ទាក់នឹងខ្ញុំទេ ហើយទំនងដូចជាច្រណែនឈ្នានីសនឹងខ្ញុំទៀតផង។ មីស៊ុនចេញតាមមកនិយាយពេបជ្រាយឲ្យខ្ញុំ:

- អញកោតឯងណាស់, ហ៊ានបង្ហាញកំភួនជើងឲ្យហ្លួងមើល! ប្រសិនបើអញវិញ អញខ្មាសគេងាប់ហើយ!។
- ចុះត្រង់ឯងស្រាតសំពត់ឲ្យហ្លួងមើលស្ទើៗផ្សេងទៀតនោះ មេចក៏មិនថាខ្មាសគេផង?
ត្រូវមួយផ្តែ វាជាត់មាត់ដូចគេចុក បើកភ្នែកធំៗសម្លក់ភ្លែរ។
- មីសាវ៉ាមានី! វាទៅពួនឯណាជាត់ទៅហើយ? (ហ្លួងស្រែកសួរពីក្នុងបន្ទប់) ។ ខ្ញុំស្ទុះចូលទៅក្នុងបន្ទប់វិញ ព្រមទាំងស្រែកឆ្លើយតប:
- ព្រះពរម្ចាស់!
- ណោះ, (ហ្លួងនិយាយ ព្រមទាំងហុចខ្សៀអាភៀនជំមួយឲ្យខ្ញុំ) យកខ្សៀនេះទៅឲ្យ នាងដកម៉ៃ គេធ្វើឲ្យស្រួល ហើយចាំយកមកវិញភ្លាមណា!

ខ្ញុំថ្វាយបង្គំរួចចេញទៅវិញ ចាប់ខ្សៀដាក់លើលើស្មា ប៉ុន្តែពេលនោះព្រលប់ធំមេឃងងឹតដាសទៅហើយ ខ្ញុំក៏ហៅក្មេងម្នាក់ឲ្យវាជូនទៅ ពីព្រោះផ្ទះអ្នកដកម៉ៃ នៅខាងចុងស្ពានច្បារឆ្ងាយឯណោះ។ ធ្វើរួចខ្ញុំយកមកថ្វាយហ្លួងវិញ ស្រាប់តែលោកប្រើឲ្យខ្ញុំយកខ្សៀទីពីរទៅធ្វើទៀត....ហើយខ្សៀទីបី...ហើយខ្សៀទីបួន..... រហូតដល់ខ្សៀទីប្រាំ។ ខ្ញុំចេះតែធ្វើតាមបង្គាប់ ដើរទៅដើរមកត្រឡប់ត្រឡិន មិននឹកឃើញហត់ មិនបានចាប់ភ្លឺកឆ្ងល់អ្វីទាំងអស់។ លុះត្រឡប់មកវិញជាលើកទីប្រាំ ខ្ញុំឃើញអស់អ្នក-អស់នាង អង្គុយព័ទ្ធជុំវិញហ្លួង សើចកាច់កាច់សុរងគ្រប់គ្នា មីមួយនោះវាលើកដៃចង្អុលខ្ញុំព្រមទាំងសើចហៀរទឹកភ្នែក មើលទៅហ្លួងអង្គុយលើត្រែ ដៃលើកខ្សៀអាភៀនសើចសប្បាយជាមួយគេឯងដែរ។ ពេលនេះទើបខ្ញុំភ្ញាក់ខ្លួនដឹងថា ហ្លួងចង់លេងកំប្លែង។ កំប្លែងរបៀបនេះ វាដូចជាជ្រុលបន្ទិច! ខ្សៀអត់ខ្លុចសោះ លោកប្រើឲ្យខ្ញុំដើរ បួន-ប្រាំត្រឡប់ លេងទទេ ខ្ញុំឈឺចិត្តស្ទើរស្រក់ទឹកភ្នែក ប៉ុន្តែខំទប់ធ្វើជាសើចលេងនឹងគេដែរ។

ក្នុងពេលជាបន្តមកទៀត កាលណាឃើញខ្ញុំ ហ្លួងចេះតែញញឹម ដែលជាហេតុធ្វើឲ្យមិត្តភក្តិទាំងប៉ុន្មាន គេរឹតតែច្រណែនឈ្នានីសខ្លាំងឡើងៗជាលំដាប់។ ពេលនេះ បើខ្ញុំចេះឆ្លៀត ខ្ញុំនឹងបានឡើងធ្វើជាក្តឯក ល្មោនហ្លួងមិនខាន ប៉ុន្តែខ្ញុំដឹងច្បាស់ថា ហានៈនេះម្ចាស់ក្សត្រីលោកក្សាសម្រាប់តែទុកឲ្យមីសួន ក្តួយសម្លាញ់ចិត្តរបស់លោកម្នាក់ប៉ុណ្ណោះ ម្ល៉ោះហើយខ្ញុំមិនខ្ចីរវល់ប្រកួតប្រជែងយកឈ្នះនរណាឡើយ។

ដូច្នេះ ការរស់នៅក្នុងវាំងវាគ្មានប្រយោជន៍អ្វីទៀតទេសម្រាប់រូបខ្ញុំ ហើយដែលខ្ញុំចេះតែទ្រាំនៅតទៅទៀត ក៏ព្រោះតែខ្ញុំផ្តាប់ដឹងជីវភាពនេះ ហើយណាមួយពុក-ម៉ែ ក៏ចេះតែថាឲ្យខ្ញុំទ្រាំៗសិនទៅដែរ។

ការដែលហ្លួងឧស្សាហ៍លេងសើចជាមួយខ្ញុំ បានធ្វើឲ្យក្រុមអ្នកច្រណែនឈ្នានីសគេសង្ស័យថាខ្ញុំប្រើស្នេហ៍ប្រើមន្តអាគមទាក់ទាញចិត្តហ្លួងដើម្បីជែងយកឈ្នះអ្នកដែលកំពុងតាប់ភ្ជរ។

ថ្ងៃមួយ ខ្ញុំឃើញទាន់ មីប៉ុន លបចូលមករុះរើអីវ៉ាន់ក្នុងបន្ទប់ខ្ញុំ យកសំពត់កញ្ចាស់ទៅបោកបក់លើទូ ហើយយកខ្នើយចាក់ជររបស់ខ្ញុំមកជាន់ញីនឹងជើង ដើម្បីបន្សាបស្នេហ៍។ ខ្ញុំធ្វើជាមិនឃើញ មិនដឹង មិនឮ អ្វីទាំងអស់ ប៉ុន្តែខ្ញុំសង្កេតឃើញថា ចាប់តាំងពីថ្ងៃនោះមក ហ្លួងមិនសូវលេងសើចនឹងខ្ញុំទៀតឡើយ។

ខ្ញុំហាក់ដូចជារស់នៅក្រមង់ក្រមោចតែម្នាក់ឯងដាច់ឡែកពីគេ, កាហ៊ុន ប្អូនជីដូនមួយខ្ញុំនេះ វានៅក្មេងពេក មិនអាចយល់ទុក្ខធុរៈខ្ញុំបានទេ។ មិត្តភក្តិទាំងអស់ សុទ្ធសឹងជាមនុស្សអាក្តាន់យម គិតតែប្រយោជន៍ផ្ទាល់ខ្លួនម្នាក់ៗម្ល៉ោះហើយខ្ញុំជឿថា គ្មាននរណាមួយគេរាប់អានខ្ញុំដោយស្មោះត្រង់ឡើយ។ ខ្ញុំឃើញពួកគេប្រជុំគ្នាជាក្រុមតូចៗ ជក់អាភៀន លេងបៀ ជជែកគ្នាព្រោកប្រាជ្ញពីរឿងប្រុស ពីរឿងរៀបការ, សូម្បីមើក្មេងតូចៗមិនទាន់ដុះដោះនៅឡើយ ក៏វាចំណាប់ណាស់ដែរ។ បើនិយាយពីដំណាក់ម្ចាស់ក្សត្រីវិញ ខ្ញុំញញើតលែងហ៊ានទៅបៀត ព្រោះកន្លែងនោះនរណាចង់ធ្វើអីក៏បានស្រេចនឹងចិត្ត ហើយបើទុកជាខ្ញុំទៅ ក៏គេមិនសូវរាក់ទាក់រកខ្ញុំប៉ុន្មានដែរ។ បើនរណាមួយចង់ឲ្យម្ចាស់ក្សត្រីជួយទាល់តែហ៊ានឲ្យលោកចំណេញ ដូចជាព្រមឲ្យលោកកាត់យកប្រាក់ខែមួយចំណែក ឬ ប្រគល់របស់អ្វីដែលហ្លួងប្រទានមកឲ្យទៅលោក។

ពេលនោះមានស្ត្រីម្នាក់ដែលពីមុនមកខ្ញុំពុំធ្លាប់យកចិត្តទុកដាក់សោះ បែរមករកវាប់អានខ្ញុំយ៉ាងស្មោះត្រង់បំផុត។ វាឈ្មោះ រឿង មិនចេះរ៉ាំរែកអ្វីទេ មួយថ្ងៃៗឃើញតែដើរត្រេកត្រតពេញវាំង ចាំក្រែងលោមាននរណាគេប្រើឲ្យធ្វើអ្វី

បន្តិចបន្តួចប៉ុណ្ណោះ។ វាស្មានបង្កើលទីពឹង និង ស្មានសង្ឃឹមថាបានក្លាយខ្លួនទៅជាអស់អ្នក-អស់នាង អ៊ីនឹងគេឡើយ។ រឿង មានចរិតសួតបួត មិនចេះលោភលន់ ហើយមានមាឌធំមាំ ទំនងជាអាយុវាច្រើនជាងខ្ញុំទៅទៀតក៏មិនដឹង។ ពេលហាត់រាំរាល់ព្រឹក រឿង តែងមកអង្គុយស្ងៀមស្ងាត់តែម្នាក់ឯង នៅកៀនជញ្ជាំងឆ្ងាយពីទស្សនីកជនផងទៃទៀត សម្លឹងមើលខ្ញុំឥតពាក្រិចភ្នែក ឥតរវល់យកចិត្តទុកដាក់ នឹងនរណាផ្សេងទៀតទេ...។

បន្ទាប់មក វាតែងដើររ៉ើរ៉ែក្បែរបន្ទប់ខ្ញុំដេក ឧស្សាហ៍រាក់ទាក់ជាមួយខ្ញុំ និង ទិញនំចំណីផ្គាប់ផ្គុន ហ៊ុន ខ្លាំងណាស់ ហើយយើងក៏ចាប់ស្គាល់គ្នាតាំងពីពេលនោះមក។ វាភ្លក្លែងភ្លែរប្រាប់ខ្ញុំថា វានៅដេកក្នុងថែវជាប់នឹងរបងវត្តព្រះកែវនោះពិបាកណាស់ វាសុំមកនៅជាមួយខ្ញុំផង។ ខ្ញុំក៏យល់ព្រមឲ្យវាមកនៅដោយសុទ្ធចិត្ត ព្រោះបន្ទប់ខ្ញុំទូលាយគួរសមដែរ ណាមួយបានវាគ្រាន់ជាគ្នាជួយកំដរកុំឲ្យស្ងាត់ពេក។ វាជញ្ជូនមុង កន្ទេល និង បង្ខិចខោអាវមកដាក់នៅក្នុងបន្ទប់ដែលជាហេតុធ្វើឲ្យអ្នកឯទៀតគេផ្អើលមកមើលគ្រប់គ្នា ខ្លះថែមទាំងនិយាយចំអែចំអន់របៀបផ្តេសផ្តាសទៀតផង។ មិនដឹងជាចង្រៃអ្វី ខ្ញុំចេះតែនឹករង្កៀសចិត្តចំពោះការទទួលឲ្យ រឿង មកនៅជាមួយខ្ញុំហាក់ដូចជាដឹងថា ពាក្យចំអែចំអន់របស់មិត្តភក្តិទាំងនេះ ពិតជាមានសំអាងទៅលើអ្វីមួយជាក់លាក់។

ល្ងាចនេះមិនត្រូវរនេខ្ញុំគាល់បំរើប្លែងនៅឯប្រាសាទបាញ់យុំងទេ។ ហ៊ុន ក៏ទៅយកបាយពីផ្ទះមកឲ្យខ្ញុំបរិភោគ ហើយរឿង ក៏ចុះទៅទិញបង្អែមមកទុកឲ្យខ្ញុំលាងមាត់ទៀតផង បន្ទាប់មកវាថយទៅអង្គុយត្រង់ មាត់ទ្វារបន្ទប់ដូចឆ្កែចាំផ្ទះ ទុកឲ្យខ្ញុំបរិភោគបាយតែម្នាក់ឯង។

ភ្លើងអគ្គីសនីឆេះឡើង... ខ្ញុំដើបទៅអង្គុយនៅមាត់បង្អួច អុជបារីមួយដក់ ភ្នែកគយគន់មើលទៅបរិយាកាសខាងក្រៅដែលប្រែជាងងឹតសូង ក្រោមស្បៃខ្មៅនៃរាត្រីកាល។ ខ្ញុំងុយដេក ក៏ពិបាកដេក ពីព្រោះទើសទាល់នឹង រឿង ណាមួយខ្ញុំធ្លាប់រស់នៅតែម្នាក់ឯងតាំងពីយូរមកហើយ ដល់មកដេកជាមួយអ្នកដទៃអញ្ចឹង ដូចជាអង្គុយកណាស់។

ពួកម៉ាកដេកនៅក្នុងបន្ទប់ក្បែរខ្ញុំ គេនិយាយគ្នារសិបរសៀវ ហើយឮស្នូរជើងច្បាស់ ទំនងជាពួកវាដើរមកបន្ទប់ខ្ញុំតែម្តង ខ្ញុំស្ទុះទៅបិទភ្លើងភ្លាម ដើម្បីកុំឲ្យវាចូលមករំខាន។ ប៉ុន្តែហួសពេលទៅហើយ មីសំអាង មាឌធំគម្រាំងដូចប្រុស ដើរចូលមកធ្វើជាសុំភ្លើងអុជបារី ដកបឹតបង្ហួយផ្សែងទ្រលោម ហើយនិយាយធ្វើហឹថា:

- មីរឿង វាអង្គុយធ្វើអីនៅមាត់ទ្វារ?
- អញមិនដឹងវាអង្គុយធ្វើអីទេ (ខ្ញុំឆ្លើយតាមនិស្ស័យ ឬ ជាមនុស្សត្រង់)។
- ម៉េចក៏ឯងមិនហៅវាមក? ឯងមិនដឹងទេឬអី ឯងមានឫកពារដូចជាប្រុស បើឯងធ្វើ (ប្លន) វាមិនសមទេ កុំឲ្យអ្នកក្រៅគេដែល...ដោះស្រាយឆាប់ឡើង ឲ្យគេដឹងថានរណាធ្វើ (បង) នរណាធ្វើ (ប្លន) ។

ខ្ញុំឧស្សាហ៍ឮស្រីៗគេហៅគ្នាថា (បង) ថា (ប្លន) អញ្ចឹងជាញឹកញាប់ ប៉ុន្តែខ្ញុំយល់ន័យពាក្យនេះបានតែពាក់កណ្តាល ក៏ធ្វើជាភ្លើមិនដឹងសោះតែម្តង ដើម្បីស្រួលឈ្លេចសួរវាឲ្យអស់សេចក្តី:

- ស្មាននរណាបង ស្មាននរណាប្លន អីទេ, ម៉េចក៏ឯងសួរអញ្ចឹង?
- អូ! ឯងមិនដឹងថា មីរឿង វាចង់អីទេ? (សំអាង និយាយតិចៗ) ។
- ទេ ! អញមិនដឹងអីទេ!
- វានិយាយប្រាប់គេឯងដឹងគ្រប់គ្នា... ឯងចង់ឲ្យអញបង្រៀនឬ?
- អើ!, និយាយទៅមើល... អញស្បថចុះថា អញមិនដឹងមែនណា... (ខ្ញុំនិយាយទាំងរំដើបរំជួលក្តងចិត្ត) ។

ក្នុងក្រសែភ្នែក សំអាង ខ្ញុំអាចស្មានបានទូរសេចក្តីពិតមួយចំណែកតាំងពីមុន ហើយស្តាប់សេចក្តីពន្យល់របស់វាទៅទៀត។ ប៉ុន្តែខ្ញុំស្តាប់ពាក្យពន្យល់របស់ សំអាង យ៉ាងមកចិត្តទុកដាក់ជាទីបំផុត ទោះបើរឿងនេះវាធ្វើឲ្យខ្ញុំអៀនឡើងក្រហមមុខយ៉ាងណាក៏ដោយ។ ខ្ញុំដូចជាខឹងបន្តិច ចង់ដឹងបន្តិច...ខ្ញុំមិនចង់ធ្វើជាប្លននរណាទាំងអស់។ សំអាង វានិយាយរៀបរាប់ប្រាប់ខ្ញុំសព្វគ្រប់អស់ពេលយ៉ាងយូរ ហើយវាបញ្ជាក់ថាការនេះជាការចាំបាច់ ដែលគ្មាននរណាអាចជៀសវាងបានឡើយ។

វាបង្គាប់ឲ្យខ្ញុំកាត់ក្រចកដៃឆ្វេងរិលអស់រលីង រួចលាចេញទៅវិញដោយឆ្លៀតទូន្មានជាចុងក្រោយបំផុតថា:

- អាណិតវាផង ហៅវាមក!
ខ្ញុំដើបឈរឡើង បេះដូងលោតឌឹប... ខាក់ៗ.. ស្ទើររេះដើមទ្រូង ហើយញ័រដង្គង់ស្ទើរឈរមិននឹង។ កាហ៊ុនកំពុងជជែកគ្នារអ៊ូសៗជាមួយ រឿង នៅខាងក្រៅ, ខ្ញុំស្រែកប្រាប់ឲ្យ កាហ៊ុន វាទៅរកកន្លែងដេកឯណា ឯណាឲ្យបាត់ទៅ ខ្ញុំប្រឹងស្រែកទាំងសម្លេងញ័រ:

- រឿង ហា!
វាដើបដើរចូលមកក្នុងបន្ទប់ ព្រមទាំងនិយាយតិចៗសួរថា តើខ្ញុំហៅវាមានការអ្វី ?។
ខ្ញុំច្រានទ្វារបិទ, អុជបារីមួយដក់បង្ហួយ ដើម្បីបន្ទប់ចិត្តកុំឲ្យញាប់ញ័រខ្លាំងពេក។ បើកុំតែមានពន្លឺភ្លើង នៅក្នុងសួនច្បារចាំងចូលមកព្រាលៗតាមបង្អួច ម្ល៉ោះសមបន្ទប់ខ្ញុំងងឹតចាក់ភ្នែកមិនយល់ទេ។

- តស់, យើងរកដេក! (ខ្ញុំនិយាយរបៀបម៉ឺងម៉ាត់ ហើយដើម្បីឲ្យចំណេញពេលបន្តិច ខ្ញុំធ្វើជាឈរផ្អៀងផ្អង លាបទឹកអប់ លាបម្សៅ មួយសន្ទុះធំ) ។

វាឈរចាំខ្ញុំស្ទាក់ស្ទើរមិនព្រមបើកមុងចូលសោះ ទាល់តែខ្ញុំបើកច្រានវាចូលទៅ។

- នែ លឿនឡើង!
ខ្ញុំហុចផ្លិតឲ្យវា ហើយឡើងទៅដេកដោយរៀបដាក់ជើងមុងក្រោមពួកយ៉ាងផ្ទិតផ្ទង់។
រឿង ដេកប្រកៀកទៅកៀន បែរខ្នងមករកខ្ញុំ។ ខ្ញុំអង្គុយច្រត់ដៃសម្លឹងមើលវាយ៉ាងយកចិត្តទុកដាក់។ រឿង ស្លៀកសំពត់ លែងខ្លួនទទេ មានតែជាហ៊ីសូត្រពណ៌លឿងមួយប៉ុណ្ណោះ។ ខ្ញុំប្រៃដេកពីក្រោយខ្នងវា លូកដៃស្តាំទៅដាក់ពីក្រោមក្បាលវា និង លូកជង្គង់ទៅសំកខ្នាស់យកស្តានភាពប្រយុទ្ធ។ វាស្រមុកតិចៗ ធ្វើឫកជាដេកលក់... ខ្ញុំថើបវាសើរៗត្រង់កញ្ចឹងក ក៏វានៅតែមិនកម្រើក ខ្ញុំក៏ចាប់ទាញឲ្យវាដេកផ្ងារ រួចឡើងជិះជាប់ពីលើ។ វាធ្វើជាភ្ញាក់ រអ៊ូតិចៗថា:

- ធ្វើអីហ្នឹង?

ខ្ញុំឈោកដាក់មុខផ្ទាល់ទៅលើស្មាវា... វាលូកដៃមកអង្អែលដោះខ្ញុំ ប៉ុន្តែខ្ញុំក្តិចម៉ាត់ ដែលជាហេតុធ្វើឲ្យវាភ្ញាក់ព្រើត។ ខ្ញុំនិយាយខ្សឹបដាក់ត្រចៀកវាថា:

- នៅឲ្យស្ងៀម អញមិនចូលចិត្តឲ្យ លូកលាន់អញទេ។

វាមិននិយាយតបថាដូចម្តេចឡើយ... ខ្ញុំដើរតួធ្វើប្រុស លូកដៃកៀសជាហ៊ីចេញ ស្ទាបអង្អែលដោះវា ដែលប្រែជាក្តៅឧណ្ហៗ.... ខ្ញុំអាចស្តាប់ឮចង្វាក់បេះដូងយើងទាំងពីរលោតញាប់រន្ធើន។ ហាក់ដូចជាមានភ្លើងដុតរោលទ្រូងខ្ញុំឲ្យក្រហល់ក្រហាយ ញ័រងចិត្តខ្ញុំឲ្យរឹតតែក្លាហានថែមឡើងទៀត។ ខ្ញុំឱបវិញ ថើបញក់ញី ប៉ុន្តែ រឿង ចេះតែលាក់មុខច្រានខ្ញុំចេញ ព្រមទាំងនិយាយថា:

~ បងឯងធ្វើអីអញ្ចឹង?

ខ្ញុំមិនឆ្លើយ គិតតែពីរវរស្រាតសំពត់វាអស់រលីងពីខ្លួន។ រឿង យំអណ្តឹតអណ្តក់ ជាហេតុធ្វើឲ្យខ្ញុំរឹតតែក្រពុលមុខខ្លាំងឡើង។ ខ្ញុំលូចដៃដែលទើបនឹងកាត់ក្រចកហើយថ្មីៗ ទៅអង្អែលយោនីវា ចាប់ច្បូតរោមទន់ល្អើយដូចសរសៃសូត្រដោយកាយវិការញ័រទន្ទ្រើក តាមកម្លាំងតណ្ហាដែលកំពុងឆេះរោលរាលពេញបន្ទុកក្តាងទ្រូង។

ត្របកភ្នែកខ្ញុំបិទបើកយ៉ាងញាប់ ចិត្តអន្ទះអន្ទែង ហាក់ដូចជាកំពុងរង់ចាំព្រឹត្តិការណ៍មួយដ៏ចម្លែក ដែលនឹងកើតមានឡើងក្នុងពេលបន្តិចទៀតនេះ... តើ សំអាង វានិយាយពិតមែនឬ?

សូរសម្លេងចាប៉ីរសាត់មកពីឆ្ងាយ លាយឡំនឹងសម្លេងពួកក្មេងស្រីដំទង់នៅក្នុងសួនច្បារដែលស្រែកច្រៀងបន្ទរតាមភ្លេងពិរោះគួរចាប់ចិត្ត។ ខ្យល់ដំនោរបក់នាំក្លិនផ្កាដែលទើបនឹងរីកដោយសារទឹកសន្សើម មកផ្សព្វផ្សាយគន្ធពិភោរឲ្យក្រអូបឈ្ងុយពេញបន្ទប់ខ្ញុំ...។

ចាប់តាំងពីរាត្រីដ៏ឆ្អែតលិលានោះ រឿងរឹតតែស្រឡាញ់ និង គោរពខ្លាំងថែមឡើងទៀត។ វាបំរើខ្ញុំយ៉ាងស្មោះត្រង់បំផុត ខ្ញុំទៅណាមួយដំហាន ក៏វាទៅតាមជាប់ជានិច្ច គឺវាប្រចណ្ឌខ្ញុំណាស់ ហាក់ដូចវានេះជាប្រពន្ធខ្ញុំមែនទែនអញ្ចឹង។ មិនយូរប៉ុន្មាន រឿងនេះក៏ល្បីសុះសាយពេញវាំង ថែមទាំងលេចឮទៅដល់ម៉ែ និង យាយកែមទៀតផង។ គាត់រលេះរលាំងធ្វើដំណើរមកវាំងដើម្បីទូន្មានខ្ញុំ ហើយគាត់ព្រមានថាបើខ្ញុំនៅតែធ្វើផ្តេសផ្តាសអញ្ចឹងទៀត គាត់នឹងយកខ្ញុំទៅផ្ទះវិញ ឈប់ឲ្យនៅវាំងរហូត។

តឡូវខ្ញុំអាចមើលឃើញច្បាស់ថា ស្ត្រីនៅក្នុងវាំងសុទ្ធតែលេងល្បែងស្នេហាកូនជីងនេះទាំងអស់គ្នា កម្រមាននរណាជៀសវាងផុតណាស់។ ពួកអ្នកលេងកូនជីងនេះ ក្រានតែក្រឡេកភ្លាម ក៏អាចស្គាល់ភ្លាម ពីព្រោះ ម្នាក់ៗតែងមានឫកពារទៅតាមការដែលគេប្រកាន់ធ្វើជាប្រុស ឬ ជាស្រី។

ស្ត្រីណាដែលដើរតួជោរធ្វើជាស្រី មានឫកពារទន់ភ្លន់ ចេះផ្តាប់ផ្តួនគក់ច្របាច់ ឯស្រីដែលធ្វើជាប្រុសវិញ គេធ្វើឫកសង្ហាដូចប្រុសមែនទែន ប្រើអំណាចទៅលើប្រពន្ធ គេចង់ទៅដេកនៅជាមួយប្រពន្ធណាមួយក៏បាន មានស្រីមួយចំពួកទៀតដែលដើរតួចម្រុះ ចង់ធ្វើជាស្រីក៏បាន ជាប្រុសក៏បាន។ ម្ចាស់ក្បត្រីស្ថិតនៅក្នុងចំពួក នេះឯង លោកចង់ធ្វើបងឬ ធ្វើប្អូន ស្រេចតែចិត្តលោកនឹកឃើញ គឺថាខ្លួនលោកនេះតែម្តង ដែលជាអ្នកផ្តល់ឧទាហរណ៍អាក្រក់ឲ្យយើងយកតម្រាប់តាម។ ហេតុនេះហើយបានជាពួកអ្នករបាំក្មេងៗ ដែលនៅហាត់រាំជាមួយលោក ឆាប់ត្រាប់ការណាស់។ ដូចយ៉ាងមីប៉ោជាដើម វានៅក្មេងណូក ហើយស្អាតដូចទេវតា, រាល់យប់តែងដើរក្រឡឹងមកជិតកន្លែងខ្ញុំដេក ដើម្បីបង្ហាញឲ្យឃើញថាវាអាច... បានហើយ។ ប្រសិនបើខ្ញុំចង់ ខ្ញុំអាចហៅប្រពន្ធប៉ុន្មាននាក់ឲ្យមកដេកក៏ដរក៏បានដែរ ហាក់ដូចខ្ញុំនេះជានាម៉ឺនធំ មានប្រពន្ធច្រើនរាប់មិនអស់អញ្ចឹង។

រឿងរ៉ាវមិនល្អវាកើតសាយភាយពេញវាំងទាំងមូល ស្តេចស្រីអាយុដប់ពីរឆ្នាំក៏ដូចអាយុសែសិបឆ្នាំ អ្នកចម្រៀងរហូតដល់ស្មុំហួង សុទ្ធតែលេងកូនដឹងទាំងអស់គ្នា ពីព្រោះទំនៀមទម្លាប់នេះ ចាំពីស្រុកសៀម មកដល់វាំងស្តេចខ្មែរតាំងពីច្រើនឆ្នាំមកហើយ។ ពួកកម្លោះៗនៅក្នុងទីក្រុង ដែលបានដឹងចរិយាមារយាទស្រីក្នុងវាំង គេពេបជ្រាយខ្លាំងណាស់។

ហ្លួងក៏មានការសង្ស័យក្នុងរឿងនេះបន្តិចបន្តួចដែរ ប៉ុន្តែលោកមិនសូវរីរវល់ ព្រោះលោកចាស់ជ្រុលទៅហើយ បើនិយាយដោយខ្លី យើងគ្មានភ័យខ្លាចនរណាមកនាំនៅទេ ម្ចាស់ក្សត្រីជាអ្នកឲ្យឧទាហរណ៍ យើងគ្រាន់តែជាអ្នកយកតម្រាប់តាមប៉ុណ្ណោះ។

ប៉ុន្តែមានមីឆ្កួតម្នាក់ឈ្មោះ ចាន់ជ្រៀប វាធ្វើឲ្យបែកការណ៍រឿងនេះ បណ្តាលឲ្យចលាចលផ្អើលណា ផ្អើលណី។ ចាន់ជ្រៀប នេះជាអ្នកបំរើសាសនិព្វង វាឆ្កួតមែន ប៉ុន្តែមិនដែលបង្កើតឲ្យមានគ្រោះថ្នាក់អ្វីជាធំដុំ ទើបគេចេះតែទុកឲ្យវានៅក្នុងវាំងរហូតមក។ ថ្ងៃមួយ វាទៅឃើញទាន់ម្ចាស់ក្សត្រី និង សំអាង ជាអ្នកដើមគំនិតបង្រៀនខ្ញុំ ស្រាតនន្តលទាំងពីរនាក់ កំពុងឱបរឹតគ្នានៅក្នុងមុង វាក៏នាំយករឿងនេះទៅរ៉ាយរ៉ាប់ ប្រាប់ក្រុមវាំង និង អ្នកបំរើ ក្រៅគ្នា។ ទទួលពេលនោះ លោកមហាមន្ត្រីដើរត្រួតត្រាមើលទាហានយាមល្បាត មកដល់ឮមីឆ្កួតវាកំពុងបរិហារឿងយ៉ាងនេះ គាត់ក៏ប្រើទាហានឲ្យចាប់យកទៅថ្វាយម្ចាស់ក្សត្រី។

តាមពិត ក្នុងចិត្តលោកមហាមន្ត្រី គាត់រីករាយណាស់ដែលឱកាសហុចឲ្យគាត់មានពេលនឹងយករឿងអាក្រក់ទៅទូលហ្លួង ក្នុងបំណងកាច់ផ្តួលម្ចាស់ក្សត្រី ដើម្បីនៅសល់តែគាត់ម្នាក់ឯងជាធំ ត្រួតត្រាវាំងទាំងមូល។ ម្ចាស់ក្សត្រីខ្លាចលោកមហាមន្ត្រី និង ប្រពន្ធគាត់ ជាងហ្លួងទៅទៀត ពីព្រោះសព្វថ្ងៃនេះគឺអ្នកទាំងពីរនេះហើយ ដែលមានអំណាចត្រួតត្រាលើអស់ស្រីក្នុងវាំង។ លោកខឹងនឹងគេ ប៉ុន្តែធ្វើអីគេមិនកើត ក៏បែរជាស្រោចកំហឹងមកលើមនុស្សឆ្កួត ប្រើពួកខ្ចីបំរើលោក ឲ្យវាយធ្វើបាបគ្នាស្ទើរស្លាប់ស្ទើររស់។

គេវាយធ្វើបាបស្រីអភ័ព្វនៅជាន់ខាងក្រោមបន្ទប់ខ្ញុំ ពួកស្រីពេជ្ឈឃាតធ្វើទារុណកម្មយ៉ាងឃោរឃៅ ឥតមានចិត្តត្រាប្រណីបន្តិចបន្តួចសោះ គឺប្រាកដជាគេចង់វាយសម្លាប់គ្នាតែម្តង លុះវាសន្លប់បាត់ស្មារតី គេនាំគ្នាចេញអស់ទៅវិញទុកចោលស្រីរងគ្រោះឲ្យនៅដេកស្តូកស្តឹងម្នាក់ឯងលើកំពារ។ ខ្ញុំរង់ចាំមើលរហូតដល់ថ្ងៃត្រង់ មិនឃើញមាននរណាត្រឡប់មកវិញ ក៏ដួសបាយមួយចានកាន់ចុះយកទៅឲ្យវាបរិភោគ។ វាញញឹមទទួលខ្ញុំធ្វើមុខស្លី ហើយបរិភោគបាយឃ្មុម។ ហាក់ដូចជាគ្មានដឹងរឿងហេតុអ្វីទាំងអស់។ មួយសន្ទុះក្រោយមក ម្ចាស់ក្សត្រីត្រឡប់មកវិញ ឃើញមនុស្សទោសនៅរស់នៅឡើយ លោកក៏ស្រែកឡឡាសូរថា នរណាហ៊ានយកបាយមកឲ្យវាស៊ី ស្រាប់តែមានមីមួយនោះលបមើលឃើញវាទូលម្ចាស់ក្សត្រីថា ខ្ញុំជាអ្នកយកបាយឲ្យអ្នកទោសស៊ី។

- អីយ៉ា! មីសារ៉ាម៉ានី វាហ៊ានដល់ម្លឹង? (ម្ចាស់ក្សត្រីច្រឡោតកូង ប៉ុន្តែលោកម្ចាប់កំហឹងបាន ដើរចេញទៅវិញធ្វើមុខក្រញូវ) ។

ពេលនោះ បងប្រុសម្ចាស់ក្សត្រី គឺម្ចាស់ដួងមធុរ៉ា ត្រូវស្លាប់បាត់បង់ជីវិតទាំងវ័យក្មេងល្អក់។ នេះគឺជាការបាត់បង់បង្គោលទីពឹងមួយទៀតសម្រាប់រូបខ្ញុំ ពីព្រោះម្ចាស់មធុរ៉ា តែងស្រឡាញ់រាប់អានខ្ញុំដូចកូនលោកបង្កើត ហើយលោកថែមទាំងបានទូន្មានម្ចាស់ក្សត្រីជាច្រើនលើកច្រើនគ្រា ឲ្យលើកខ្ញុំធ្វើជាតួឯងផង ។ លោក ស្លាប់ដោយជម្ងឺចម្លែកមួយដែលទើបនឹងឆ្លងចូលមកដល់ស្រុកខ្មែរក្នុងពេលថ្មីៗនេះ ហើយដែលបារាំងហៅថា ជម្ងឺប៉េស្ត៍។ លោករ៉េស៊ីដង់បារាំង បង្គាប់ឲ្យពេទ្យបារាំងវះកាត់សាកសពពិនិត្យមើល ទោះបីម្ចាស់ក្សត្រីតវ៉ាយ៉ាងណា ក៏គេពុំព្រមស្តាប់។ ពេលនោះម្ចាស់ក្សត្រី និង បក្សពួកនាំគ្នាទៅនិយាយបញ្ចុះបញ្ចូលខ្សែ នៅមុំខាងក្បាងវាំង ឲ្យលើកគ្នាមកជួយតវ៉ាថែមទៀត។ ខ្ញុំរត់ឡើងទៅលើរានហាលជាមួយមិត្តភក្តិជាងដប់នាក់ ដើម្បីមើលរ៉េស៊ីដង់បារាំង អញ្ជើញមកសម្រុះសម្រួលបាតុករ។ ម្នាក់នោះហៅខ្ញុំឲ្យចូលទៅជិតវា ហើយចង្អុលប្រាប់ថា :

- សារ៉ាម៉ានី! មើលនំ បារាំងនោះនៅក្មេងសោះ ប៉ុន្តែខ្ពស់ចង្អោង គាត់ហ្មឺងអាយុយ៉ាងច្រើនណាស់ ត្រឹមដប់ប្រាំឆ្នាំប៉ុណ្ណឹង។

ខ្ញុំអើតមើលទៅខាងក្រោមតាមដៃគេចង្អុល ហើយនេះជាលើកទីមួយដែលខ្ញុំបានឃើញលោក(១១) ពេលដែលលោកឈរអែនៅមុខប្រាសាទដំកល់ព្រះឪនរាជ (១២) ។ គ្រាន់តែឃើញលោកភ្លាម ទ្រូងខ្ញុំប្រែជាញាប់ញ័រ ខ្លួនប្រាណប្រែជាស្លាំង ដូចគ្មានឈាមមួយដំណក់នៅក្នុងខ្លួន។ ខ្ញុំប្រញាប់គេចថយមកក្រោយវិញ និយាយរឿងនេះប្រាប់ សំអាង ស្រាប់តែវាផ្តុះសំណើច ព្រមទាំងនិយាយខ្លាំងៗថា:

- អើ ! អានេះគេហៅថាប្រផ្តួល! សារ៉ាម៉ានីឯង ប្រាកដជាបានប្តីបារាំងហ្មឺងហើយ។
ពួកគេបានពាក្យនេះ នាំគ្នាចំអន់បង្អាប់ខ្ញុំ ពីរ-បីថ្ងៃ បន្ទាប់មកគ្មាននរណានឹកឃើញដល់រឿងនេះទៀតឡើយ។

ពេលវេលាចេះតែកន្លងទៅមុខឥតអាក់ ដោយគ្មានកើតព្រឹត្តិការណ៍អ្វីជាសំខាន់ឡើយ...រដូវភ្លៀង នៃឆ្នាំវក ក៏កន្លងផុតទៅ។

ចាប់តាំងពីថ្ងៃមួយកើត នៃ ខែកក្តិក ខ្យល់បក់មកពីខាងជើងរហើយត្រសៀក ក្រោមផ្ទៃមេឃស្រឡះ លួលួវ ទឹកទន្លេធំកំចាប់ផ្តើមហូរត្រឡប់ជោកាន់សមុទ្រវិញ។

រៀងរាល់ឆ្នាំ តែដល់ពេលនេះ យើងនាំគ្នាចុះទៅក្តងទីតាំងដែ ដើម្បីប្រារព្ធធ្វើពិធីបុណ្យអុំទូក និង សំពះព្រះខែ។ ពួកអស់អ្នក-អស់នាង ដើរជាក្រុមតូចៗ មានយាយចាស់ទុំ និង ក្រុមវ័ង តាមអមជូនដំណើរ ជាប់ជានិច្ច។ ផ្លូវពីមាត់ទ្វារវ័ងទៅកំពង់ដែ ប្រវែងមួយចំអាមសោះ ប៉ុន្តែមនុស្សម្នាភាគច្រើនសុទ្ធតែប្រុសៗ នាំគ្នាប្រជ្រៀតឈរអមសង្ខាងផ្លូវ ដើម្បីមើលស្រីក្តងវ័ងឲ្យឃើញច្បាស់នឹងភ្នែកម្តង ព្រោះម្នាក់ៗសុទ្ធតែផ្តាប់ ឮគេនិយាយ ថាអញ្ចុះ ថាអញ្ចុះ ប៉ុន្តែកម្រមាននរណាបានឃើញណាស់។ នរណាគេទាក់ទងមានគូសង្សារនៅក្រៅវ័ង គេឆ្លៀតឱកាសនេះដើរទៅដើរមក ថែមទាំងកាច់ឫកកាច់រាង ដើម្បីទាក់ទាញចិត្តគូសង្សារគេ។ ចំណែកស្រីក្រីមត្រូវដូចយ៉ាន និង ខ្ចុំ ជាដើម យើងមករស់នៅក្តងវ័ង ព្រោះស្រឡាញ់ចង់បានកីត្តិយស ពុំមែនដើម្បីមកដើរបង្ហួតសាហាយទេ។ កាលពីរាជ្យហ្លួងសុវណ្ណកោដ្ឋ គេយកកំណាត់មកពាសជាំងសង្ខាងផ្លូវ តាំងពីទ្វារវ័ងរហូតដល់មាត់ទន្លេ ហើយមានដាក់ទាហានឲ្យឈរយាមទៀតផង។ ប្រុសៗនៅពីក្រោយផ្ទាំងកំណាត់ ត្រូវអង្គុយលុតជង្គង់ឱនមុខចុះ មិនឲ្យដើបមុខមើលពួកយើងជាដាច់ខាត។ ប៉ុន្តែក្តងរាជ្យថ្មីនេះ ប្រុសច្រឡឹមឈរដង្ហែលើចិញ្ចើមថ្នល់ វាគយគន់មើលយើងឥតកោតញញើត មើលទាល់តែយើងអៀន មិនហ៊ានដើបមុខ។

យើងដើរចុះតាមច្រាំងទន្លេ ដែលទឹកស្រកចុះអស់ច្រើនណាស់ទៅហើយ... មើលទៅម្ខាង ឃើញដំបូល ផ្ទះខ្ចុំលេចលឺមៗ បន្លំនឹងស្លឹករុក្ខជាតិ។ សសរដងកើទ្រេតទ្រោត ហាក់រកកលនឹងរលំធ្លាក់ទៅក្តងទន្លេ..... យើងដើរឆ្លងស្ពានទៅដល់លើទីតាំងដែ ដែលជាកន្លែងពិសេស គេរក្សាទុកសម្រាប់តែពួកយើង។

បន្ទប់ហ្លួងស្ថិតនៅចំកណ្តាលដែ ពាសជញ្ជាំងធ្វើពីឈើបេងរលោងស្រិល មានទុកចន្លោះជំលួមអាចដើរក្រឡឹងជុំវិញបាន។ សាឡងធំស្ថិតនៅចំពីមុខបន្ទប់ បែរមុខទៅខាងកើតឆ្ពោះទៅរកផ្ទៃទន្លេ ដែលប្រកបទៅដោយទឹករលកបោកបាចឥតឈប់ឈរ។ បុណ្យអុំទូក ប្រព្រឹត្តទៅបីថ្ងៃបីយប់ជាប់គ្នា ហើយត្រូវបញ្ចប់ក្តងថ្ងៃពេញបូណ៌មី នៃខែកក្តិក។ វេលារសៀលនៃថ្ងៃនោះ ការប្រណាំងទូកង បានទាក់ទាញរាស្ត្រនៅក្តងខេត្តជិតខាងរាជធានី ឲ្យមកប្រជ្រៀតគ្នាពេញមាត់ទន្លេ ដើម្បីមើលទស្សនីយភាពប្រចាំឆ្នាំដ៏ត្រកាលនេះ។ ពួកបារាំងអង្គុយលើទីនាំងរូបនាគ ចគក្បែរទីនាំងដែ ដែលនៅលើនោះ មានក្រុមតន្ត្រីប្រគំជាប់រហូត ដល់ពេលព្រលប់ធំទើបឈប់។

ទូកចែវបញ្ញាសទឹក កាត់តាមមុខទីនាំងដែឡើងទៅកាន់ដើមទីប្រណាំង, មួយសន្ទុះក្រោយមក ឃើញត្រឡប់មកវិញម្តងមួយកូ។ ចែវលឿនស្ទេរដោយមនុស្សប្រុសមាឌធំមាំ។ អ្នកខ្លះប្រើប្រាវ័ងឈរចែវ, ខ្លះអង្គុយអុំ, ទូកនីមួយៗផ្ទុកមនុស្សហាសិបនាក់ ឬច្រើនជាងនេះផងក៏មាន បណ្តាលឲ្យទូកធ្ងន់ពៀបសឹងនឹងលិច។ ក្បាលទូកងស្មើត មានមេក្រុមអង្គុយលើនោះ លើកដៃ លើកជើងជាចង្វាក់ និង នៅកណ្តាលទូកមានតួកម្នាក់លោតចាក់ក្បាច់ក្រមាច់ក្រមើមញ្ជាក់មុខញ្ជាក់មាត់ ដាក់ហ្លួង ដាក់ពួកនាម៉ឺន និង ដាក់ពួកយើង។ ពេលធម្មតា គេមិនអនុញ្ញាតឲ្យនរណាចាក់ពួកធ្វើឫកច្រឡឹមបែបនេះជាមួយហ្លួងជាដាច់ខាត ប៉ុន្តែពេលនេះជាពេលបុណ្យទាន ទើបហ្លួងលើកលែងទោសមិនប្រកែកប្រកាន់។ ខ្ចុំឃើញពូប៉ុល អង្គុយទំលើក្បាលទូកវត្តកោះអន្លង់ចិន កំពុងចាក់ក្បាច់ខ្លាំងដែសម្បើមណាស់។ ស្តួរច្រវាគោះទឹកលាន់ឮសូរព្រឺបៗ ធ្វើចង្វាក់លាយឡំនឹងចម្រៀងស្រែកបន្ទរ ហៃអើ! ហៃអើ!... ។

ចុងក្រោយគេបង្អស់ គឺទូកមួយធំដាក់មនុស្សពេញព្រៀប ស្រែកហ៊ោកញ្ជ្រៀវលាន់ខ្ទរមកដល់ច្រាំង ចែវទៅមុខឡើងរង្គើទឹក ដូចត្រូវព្យុះបក់បោក។

បន្ទាប់មក ទូកទាំងអស់គម្រៀបបន្តកន្ទុយគ្នា តាមបណ្តោយទីនាំងរូបនាគ ចាំទទួលយកអំណោយហ្លួង ដែលនាម៉ឺនវ័ងគេនាំយកទៅចែកឲ្យគ្រប់ៗគ្នា។ ទស្សនិកជនបំបែកគ្នាវិលទៅកាន់គេហដ្ឋានរៀងៗខ្លួន ឯពួកបារាំងក៏ត្រឡប់ទៅផ្ទះគេវិញដែរ។ កប៉ាល់ហ្លួងដែលចតនៅពីមុខទីនាំងដែ និង កប៉ាល់ជាច្រើនទៀតរបស់ពួកនាម៉ឺនសព្វមុខមន្ត្រី ចាប់អុជប្រទីបជ្វាលាភ្លឺព្រោងព្រាត មានតាក់តែងលំអជារូបផ្សេងៗ រហូតដល់សសរដងកើ ក៏មានអុជភ្លើងបំភ្លឺតាងពីក្រោមរហូតដល់ចុងកំពូល។ កាំជ្រួចភ្ញីទៀនផ្លុះ ក្តម! ក្តាំង! ភ្លឺរន្ទាល អស់មួយចំហៀងមេឃ ហើយកប៉ាលប្រទីបក៏ចាប់ផ្តើមធ្វើដំណើរទៅមុខយឺតៗ ប្រកបដោយភ្លើងតាក់តែងលំអយ៉ាងត្រកាល កណ្តាលស្បៃងដ៏ត នៃរាត្រីកាល។ អស់អ្នក-អស់នាងជាច្រើនរូប រួមទាំងខ្ចុំផង យើងនាំគ្នាឆ្លងទៅកាន់ ទីនាំងរូបនាគ និង ទូកងទៃទៀត ដែលចតនៅជាប់គ្នា។ គេចែកជារ៉ាចែកកាំជ្រួចឲ្យយើង អុជលេងយ៉ាងសប្បាយរីករាយ ប៉ុន្តែដោយជិតដល់ពេលចូលវេនគាល់បំរើហ្លួងទៅហើយ ខ្ចុំក៏ត្រឡប់មកកាន់ទីនាំងដែវិញ។ អង្គុយជជែកគ្នាលេងនៅត្រង់សាឡង ដែលហ្លួងគង់ទតមើលការប្រណាំងទូកកាលពីថ្ងៃ។

នៅទិសខាងកើតស្រាយឯណោះ ព្រះចន្ទពេញវង់នៃខែកក្តិក រះឡើងមូលក្រឡង់ ចោលកំទេចរស្មី ស្រទន់ត្រជាក់ពណ៌ប្រាក់ ចាំងឆ្លុះលើផ្ទៃទន្លេ...។

ហ្លួងចេញមកមើលកប៉ាល់លយប្រទីបតែមួយភ្លែត ក៏ត្រឡប់ចូលទៅក្នុងបន្ទប់វិញ ហើយបង្គាប់ឲ្យគេរៀបក្រយាពេលល្ងាចថ្វាយ។ ក្រុមភ្លេងពិណពាទ្យចាប់ប្រគំបទបើកឆាក ហើយស្រីៗដែលតែងខ្លួនស្រស់ប៉ព្រង អង្គុយក្បៀបគ្រានៅក្តងសាឡងធំនោះ ក៏ស្រែកច្រៀងបទសក្រវាទី យ៉ាងពិរោះលន្ឋង់ឈ្លោច កណ្តាលសភាពស្ងប់ស្ងាត់នៃរាត្រីកាល។

ហួងផ្ទំសោយអាកៀននៅក្តងបន្ទប់ មានស្រីស្អាតៗចាំបំរើ មានសម្តេងទិព្វច្រៀងបទសក្រវាទីប់ពេ ផ្សំនឹងទីនាំងផ្លៀងទៅផ្លៀងមកតាមកម្លាំងទឹករលកដូចគេយោលអង្រឹងនោះផង លោកប្រែជាដេកងុយធ្វើភ្នែកមមីរ។

បទសក្រវាទីចប់ទៅ ដោយអ្នកចម្រៀងត្រូវសំរាកបរិភោគនំចំណី និង ផឹកស្រាកំដៅពោះបន្តិចសិន ពីព្រោះពេលនេះខ្យល់ដំនោរត្រជាក់បក់បោកមកឥតឈប់ បណ្តាលឲ្យរងាព្រឺសម្បរគីងគក់។

នៅលើទូកមួយផ្សេងទៀត ប្រុសៗសម្តេងត្រលរស្រែកច្រៀងជាទំនុកឆ្លើយឆ្លងនឹងយើង ហើយបន្ទាប់មក សម្តេងប្រុសស្រីស្រែកច្រៀងចម្រុះគ្នាលាន់ឮចេញពីក្រប់ទូកពួកនាម៉ឺនហួង។

ហួងចេញមកត្រង់សាឡងជាថ្មីម្តងទៀត សម្លឹងមើលព្រះចន្ទ មើលទឹក មើលដី មើលស្រីក្មេងៗដែលនៅគាល់ក្បៀបក្រា។ លោកសម្លឹងមើលពួកយើងមួយត្រួស ឃើញខ្ញុំអង្គុយលាយឡំជាមួយអ្នកចម្រៀងដទៃទៀត ក៏សួថា:

~ យី, ឯងច្រៀងដែរឬ? អញធ្លាប់តែឮគេថា ឯងខ្ជិលច្រអូសណាស់, រួចម៉េចក៏ឯងចេះធ្វើការដែរ?

ថាហើយលោកដើរក្រឡឹងមួយដុំ ទើបបង្គាប់ឲ្យគេលើកយកអំបុកមកថ្វាយ។ គេយកអំបុកជ្រើនណាស់ មកឲ្យយើងបរិភោគ យើងខំទំពារទាល់តែរោយថ្គាមទាំងរងាញាក់ទន្ទ្រើក ទោះបីយើងមានជាហ៊ីដណ្តប់ក្រប់គ្នាយ៉ាងណាក៏ដោយ។ អំបុកសម្រាប់ហួង ធ្វើឡើងដោយស្លូវពិសេស ជុំគ្និនឈ្ងុយគួរឲ្យស្រក់ទឹកមាត់។ យើងបរិភោគអំបុកហើយ ផឹកស្រាជារាំងកំដៅពោះ និង ជក់ជារីស៊ីហ្គារផង។

ខ្ញុំអង្គុយច្រៀងមួយយប់ទល់ភ្លឺ ដើម្បីបំពេរឲ្យហួងផ្ទំលក់ស្រួល។ អស់លោកជំទាវ លោកស្រី ប្រពន្ធនាម៉ឺន នាំគ្នាឡើងមកលើទីនាំងផែដើម្បីកំដរយើង នាំជជែកពីនេះពីនោះពេលយើងឈប់ច្រៀងម្តងៗ។ រឿង វាតាមសម្លឹងមើលខ្ញុំជាប់ជានិច្ច ទំនងដូចជាប្រច័ណ្ឌពេលឃើញខ្ញុំនិយាយព្រោកប្រាជ្ញជាមួយស្រីៗដទៃទៀត។ វាយកស្ករគ្រាប់មកឲ្យខ្ញុំបរិភោគ ហើយបង្ខំឲ្យខ្ញុំទទួលយកទាល់តែបាន ដែលជាការគួរឲ្យរង្កៀសចិត្តពេកណាស់។

ទូកនីមួយៗ ច្រៀងជាបន្តបន្ទាប់គ្នា ដល់ទីបញ្ចប់ក៏បានមកដល់វេនពួកខ្ញុំច្រៀងម្តងទៀត។ ព្រះចន្ទយាង ជ្រេហួសទៅទិសខាងលិច កប់ជាត់ឯជើងមេឃ... កាំភ្លើងពេលព្រឹកជាញ់ ក្តាំង! ក្តាំង! ឮសម្តេងយ៉ាងច្បាស់រសាត់មកដល់យើង។ ផ្កាយរលត់ជាត់ស្ទើម្តងមួយៗ ផ្ទៃមេឃក៏ប្រែជាភ្លឺស្រឡះប្តិចឡើងវិញដែរ។

អ្នកចម្រៀងប្រុស-ស្រី ដែលមកច្រៀងលេងជាមួយយើងពេញបីយប់ជាប់គ្នានោះក៏លាត្រឡប់ទៅវិញ នាំយកទាំងក្តីស្តាយស្រណោះមិនអាចកណានាបាន ទៅជាមួយផង។

ការសប្បាយរីករាយត្រូវចប់ត្រឹមនេះហើយ ប៉ុន្តែហួងដូចជាពេញចិត្តនឹងរស់នៅលើទីនាំងផែ ទើបលោកសម្រេចថានឹងបន្តស្នាក់នៅទីនេះបន្តិចទៅទៀត។ នរណាអស់កម្លាំងដោយមិនបានដេកពេញបីយប់នោះ គេឡើងមកវាំងដេកសម្រាកយកកម្លាំងបន្តិចសិន។ ខ្ញុំក៏ឡើងមកជាមួយគេឯងដែរ គ្រាន់តែមកដល់បន្ទប់ ប្រះដេកភ្លាមកំលក់ភ្លាមទាល់តែព្រលប់ជំ កាហ៊ុន វាដាស់ឲ្យដើរបរិភោគបាយ ទើបភ្ញាក់ដឹងខ្លួន។ ខ្ញុំតភ្លានសោះ ប៉ុន្តែចេះតែខំលេបបង្ការកុំឲ្យភ្លានយប់ព្រលប់ ហើយមុននឹងចុះទៅចូលវេនគាល់បម្រើហួង ឯទីនាំងផែវិញ ខ្ញុំឆ្លៀតបោសច្រាសបន្ទប់និងគ្រែពួកដេកបន្តិចផង។ កំពុងតែរៀបចំបន្ទប់ ខ្ញុំស្រាប់តែនឹកភ្ញកឃើញរឿងអ្វីមួយ ញ័រឯចិត្តឲ្យគិតភ័យញាប់ញ័រដោយមិនសមហេតុសមផល។ ឃើញអញ្ចឹង កាហ៊ុនវាឆ្ងល់បើកភ្នែកធំៗ.... តើខ្ញុំភ័យពីរឿងអ្វី? ខ្ញុំគិតមិនយល់ទាល់តែសោះ... តាមបង្អួច ខ្ញុំមើលឃើញព្រះអាទិត្យលិចបាត់ឯជើងមេឃទិសខាងលិចទៅហើយ សល់តែទេចរស្មីដែលចាំងឆ្លុះលើដំបូលផ្ទះ ប្រាសាទពណ៌មាស។ ខ្យល់ដំនោរបក់បោករហើយត្រសៀក នាំសម្តេងខ្លែងឯកពីទីឆ្ងាយឮល្វើយៗ ញ៉ាំងចិត្តខ្ញុំឲ្យស្រងេះស្រងោចក្រៃលែង។ ភ្នែកមួយហួងហើរស្រែកកោកកាកមកទំលើដើមគគីរ ស្រែកបួលឆ្លងឆ្លើយគ្នាទ្រហឹងអឺងអាប់ កណ្តាលបរិយាកាសស្ងប់ស្ងាត់នៅក្តងវាំង។ សម្តេងយាយកែម ដាស់ខ្ញុំឲ្យភ្ញាក់ពីក្តីស្រមៃ ខ្ញុំដាកទៅក្រោយឃើញយាយស្លៀកពាក់ស ឈរនៅត្រង់មាត់ទ្វារ មានទឹកមុខស្រពាប់ស្រពោន។ គាត់និយាយមកកានខ្ញុំថា :

- ចៅ! ឪពុកឯងមិនស្រួលខ្លាំងហើយ វាចង់ឃើញមុខចៅឯងណាស់។ ចៅឯងសុំច្បាប់ហួង ទៅផ្ទះដើម្បីមើលថែទាំវាពីរ-បីថ្ងៃបានទេ?

ខ្ញុំដើរតាមយាយរហូតដល់ផ្ទះ ទាំងចិត្តភ្ញកភ្ញួលស្ទើរទប់ទឹកភ្នែកមិនឲ្យស្រក់ចុះមកមិនបាន។ ខ្ញុំឡើងទៅលើផ្ទះឃើញញាតិមិត្តអ្នកជិតខាងខ្លះ និង ម៉ែ អង្គុយព័ទ្ធជុំវិញពុក ដែលគេដាក់ឲ្យសំរាន្ត ភ្នែកបិទជិត ដកដង្ហើមញាប់ដង្ហក់ ដៃលើកដាក់ប្រណម្យលើដើមទ្រូង។ គាត់បើកភ្នែកឡើងឃើញខ្ញុំ ក៏ប្រឹងញញឹមហើយពោលខ្សាវៗ:

- កូនមកដល់ហើយឬអី? ពុកដឹងខ្លួនថាមិនស្រួលខ្លាំងហើយ, កូនឯងទៅសុំច្បាប់ហួងលមើល បើលោកឲ្យឈប់ក៏ឈប់ បើលោកមិនឲ្យទេក៏ហីទៅ ប៉ុន្តែ.... ពុកចង់បានកូនឯងមកនៅជិតឲ្យបានទាន់ដង្ហើម ពីព្រោះពុកមិនដឹងជាស្លាប់ពេលណាទេ...។

ខ្ញុំវារចូលទៅជិតពុក ច្របាច់ជើងគាត់ថ្នមៗ... មេឃងងឹតបន្តិចហើយ ម៉ែអុជចង្កៀងតូចមួយ យកមកដាក់ជិតពុក រួចលុតជង្គង់ លើកដៃសំពះធ្វើមាត់ដឹបអូចៗ។ ខ្ញុំចេញក្រៅដាយយ៉ាងលឿនសំដៅផែ ទាន់ឃើញហួងកំពុងស្លៀកពាក់

ខោអាវ។ ខ្ញុំអង្វរមីវ៉ែន ឲ្យវាជួយសុំហ្គួងឲ្យខ្ញុំបានទៅផ្ទះផង ពីព្រោះវាពូកែសំដី លែបខាយជាងខ្ញុំ វាក៏យល់ព្រមជួយដោយសុទ្ធចិត្ត។ វាថ្វាយបង្គំរៀបរាប់ទូលហ្គួងបន្ថែមបន្តយតាមដែលនឹកឃើញ ហ្គួងក៏ឆ្លើយតបវិញថា:

~ អើ! បើឪពុកសាវ៉ាម៉ានី ឈឺ ឲ្យវាទៅផ្ទះមើលឪពុកវាចុះ!

ខ្ញុំប្រញាប់ត្រឡប់មកផ្ទះវិញយ៉ាងរួសរាន់។ ពួកបម្រាស់ននៀលលើកន្ទេល ក្អួតផ្លាក់ឈាមទាំងដុំៗ ពួកប្រុសៗគេខំជួយទប់គាត់ណាស់ដែរ ប៉ុន្តែគាត់ចេះតែរើបំរះ ព្រមទាំងពោលពាក្យមិនសមរម្យដេរត្រូចាស់ម្នាក់, ដែលថាមកព្យាបាលគាត់ឲ្យជាសះស្បើយ តែកាលពីល្ងាច បែរជាឲ្យគាត់លេបថ្នាំអ្វីម្យ៉ាង ដែលធ្វើទុក្ខក្តៅអន្ទះអន្ទែងទ្រាំមិនបាន។ ទោះបីឃើញគាត់ឈឺធ្ងន់យ៉ាងនេះក៏ដោយ ក៏ខ្ញុំពុំបានគិតថាពុកនឹងស្លាប់ ក្នុងពេលខាងមុខនេះសោះ។

ដល់ពេលពាក់កណ្តាលអាធ្រាត្រ គាត់ដូចជាបានសម្រុំខ្លះ។ យាយ ម៉ែ ព្រមទាំងញាតិខ្លះទៀត គេស្ម័គ្រចិត្តនៅជួយកំដរហូតដល់ភ្លឺ។ ចំណែកខ្ញុំ អត់ងងុយកាលបុណ្យអុំទូកនោះ មិនទាន់មានកម្លាំងស្រួលបួលឡើងវិញផង ក៏ទៅប្រុះដេកលក់យ៉ាងស្រួលនៅលើក្រែ។ ខ្ញុំភ្ញាក់ពីដេក ថ្ងៃមិនទាន់រះពេញនៅឡើយ។ ពុកច្រត់ដៃប្រឹងងើបដើម្បីពិសារទឹកថ្នាំក្តៅហុយ ហើយនៅពេលឃើញចង្កៀង ឃើញព្រះអាទិត្យរះ គាត់ដកដង្ហើមធំនិយាយថា:

~ យ៉ាងយូរណាស់ពីរម៉ោងទៀត ខ្ញុំនឹងស្លាប់ហើយ ម៉ែវ៉ា, កូន និង បងប្អូនទាំងអស់ សូមឲ្យបងប្អូនជួយមើលខុសត្រូវប្រពន្ធកូនខ្ញុំផង។ ខ្ញុំស្តាយណាស់មិនគួរស្លាប់ទាំងពេញកម្លាំង ទាំងមិនទាន់បានរៀបចំអនាគតកូនស្រីឲ្យបានស្រួលបួល ស្លាប់ចោលប្រពន្ធឲ្យនៅរស់លំបាកវេទនា... ។

ឮគាត់និយាយអញ្ចឹង យើងទាំងអស់គ្នាក្តុកក្តួលក្នុងចិត្ត ស្រក់ទឹកភ្នែកច្រោកៗ។ ម៉ែទ្រហោយំកក់ទ្រូង រួចស្រវាអោបជង្គង់ពុក អង្វរឲ្យគាត់ឈប់និយាយ ប៉ុន្តែពុកមិនព្រមឈប់សោះ។ បន្តិចក្រោយមក គាត់ប្រឹងត្រដរងើបអង្គុយប្រាប់ឲ្យយើងជួយដុតទឹកសំអាតខ្លួនគាត់បន្តិច។ ពួកប្រុសៗជួយលើករំកិលដាក់គាត់មកលើក្តារ ស្រោចទឹក ដុសសាប៊ូ ដុះក្អែលសព្វមុខមាត់ដៃជើង រួចហើយគេផ្លាស់ឲ្យគាត់ស្លៀកសំពត់ថ្មីមួយទៀត។ ប៉ុន្តែមុននឹងសំរាន្តទៅវិញ គាត់ទារឲ្យគេសិតសក់ ទារយកទឹកមកខ្ពុលមាត់។ លុះស្អាតស្រួលបួលហើយ គាត់ញញឹមបន្តិចសំដែងការពេញចិត្ត រួចទារឲ្យគេផ្តេកគាត់ទៅកន្ទេលវិញ។

យាយកែម អង្គុយធ្វើទឹកមុខមាំ ផ្អែកខ្នងនឹងសសរ។ ក្នុងចំណោមយើងទាំងអស់គ្នា មានតែគាត់ម្នាក់ឯងគត់ដែលមិនយំ ពីព្រោះកាលពីខ្មោចតាស្លាប់ គាត់បានចំណាយទឹកភ្នែកយំស្តាយស្រណោះអស់ច្រើនណាស់ ឥតមានសល់ទឹកភ្នែកសម្រាប់យំចំពោះមរណភាព នៃកូនប្រសានេះទៀតទេ។ គាត់ហោយដៃហៅគេម្នាក់ឲ្យចូលទៅជិត ហើយប្រាប់ថាឲ្យទៅនិមន្តលោកវត្តឧណ្ណាលោម មកសូត្រធម៌កំដរអ្នកជម្ងឺ កុំឲ្យស្ងាត់ផ្ទះពេក។

ពុកស្លាមម្តងទៀត រញាក់រញ៉ែត្រដរខ្យល់ គាត់ខំប្រឹងលេចសរសៃវាមដុំវិញបំពង់ក ដើម្បីហាមាត់និយាយ ប៉ុន្តែយាយកែម យកដៃសង្កត់ដើមទ្រូងក្តៅដូចរងើកភ្លើង ប្រាន់ពុកឲ្យសម្រាន្តទៅវិញ។ នរណាម្នាក់និយាយសួរពុកថា :

- បងហ៎ា! កាលពីក្មេង បងឯងមានធ្លាប់មកលេងដល់មាន់ទេ?
ពួកងក់ក្បាលសំដែងការយល់ស្រប និង និយាយបន្តែមថា:

- ខ្ញុំដឹងថា ខ្ញុំបានប្រព្រឹត្តអំពើអបាយមុខច្រើនណាស់ ខ្ញុំបានចាប់សត្វឲ្យដល់គ្នា ខ្ញុំបានសម្លាប់មនុស្សជាពិសេសសម្លាប់ឃុនអស់ច្រើនណាស់។ សូមអ្នកដែលខ្ញុំធ្លាប់បានធ្វើអំពើល្អទៅលើគេ គេជួយស្រោចស្រង់ឲ្យខ្ញុំបានជួបប្រទះតែនឹងសេចក្តីសុខក្នុងសុគតិភព។

យាយកែម លោកសម្លឹងមើលមុខកូនប្រសារដោយក្រសែភ្នែកស្រទន់ ពោរពេញទៅដោយសប្បុរសធម៌។ គាត់កាន់ជង្គង់ពុកជាប់ ហើយពោលមួយៗថា:

- យិន! កូនឯងកុំគិតពីរឿងទុក្ខព្រួយធ្វើអ្វី គិតតែតាំងចិត្តឲ្យជ្រះថ្លាក្នុងព្រះធម៌ឡើង។ កុំគិតពីអ្នករស់ នៅមានម៉ែមានញាតិមិត្តបងប្អូននៅជួយមើលថែរក្សាជាក្មែក ជាប្រមុះ ជំនួសឯងហើយ។ ឯងទន្ទេញធម៌ ឲ្យចាំជាប់ក្នុងចិត្តជានិច្ច ដើម្បីសំអាតចិត្តឲ្យស្អាត ពីព្រោះមានតែព្រះធម៌នេះហើយដែលអាចជួយ យិតយោងឯងឲ្យបានស្គាល់សេចក្តីសុខ សុភមង្គល ក្នុងលោកខាងមុខ។

- ខ្ញុំទន្ទេញចាំហើយម៉ែ (ពុកខំឆ្លើយតបទាំងហត់ដង្ហក់)។

ព្រះសង្ឃបីអង្គនិមន្តមកដល់មាត់ទ្វាររបង, យាយរលះរលាំងងើបទៅថ្វាយបង្គំនិមន្តលោកឡើងលើផ្ទះ។ ពុកសម្រាន្តស្តូកស្តឹង បាត់មាត់បាត់ក គាត់ឥតស្តាប់ឮជាលោកសូត្រធម៌ពីអ្វីខ្លះទេ។ ស្រាប់តែគាត់ចាប់ផ្តើមត្រដរខ្យល់ម្តងទៀត ប្រកាច់រមួរនប ននៀលខ្ទេចខ្ទីអស់កន្ទេល គាត់ស្រវារាវរកយាយ ព្រមទាំងស្រែកខ្លាំងៗថា :

- យាយ ! យាយ ! ម៉ែ កុំទៅណាចោលខ្ញុំ! កុំទៅណាចោលខ្ញុំ! កុំទៅណាចោលខ្ញុំ! ។

គេចាប់រូតរាំងននយ៉ាងរហ័ស ដើម្បីជាំងកុំឲ្យព្រះសង្ឃដែលកំពុងគង់សូត្រធម៌នៅខាងម្ខាងនោះ មើលឃើញអ្នកជម្ងឺ។

ខ្ញុំចាប់ផ្តើមយល់ថា ក្នុងពេលបន្តិចទៀតខាងមុខនេះ ពុកនឹងបែកចេញពីយើងទៅអស់កាលជានិច្ច តតក្រឡប់មកវិញឡើយ។ ខ្ញុំពុំធ្លាប់ឃើញសេចក្តីស្លាប់ជាក់ច្បាស់នឹងភ្នែកដូចម្តងនេះទេ។ មុខពុកប្រែជាស្លេកស្លាំងគួរខ្លាច, ខ្លាចទាល់តែខ្ញុំមិនហ៊ានទៅជិត មិនហ៊ានទាំងមើលគាត់ទៀតផង។

សម្តេងព្រះសង្ឃសូត្រធម៌ មានសភាពលន្ឋដ៏លន្ឋោចស្រដេះស្រដោចពេកណាស់ ញ៉ាំងចិត្តយើងឲ្យរឹតតែអស់សង្ឃឹមខ្លាំងឡើងថែមទៀត។ ពុកដូចជាបានជួរបន្តិច គាត់សម្លឹងមើលមុខយើងដែលអង្គុយពាំទ្នុងុំវិញដំណេកគាត់ម្តងមួយៗហើយទារកភួយដណ្តប់ ពីព្រោះខ្យល់ដំនោះព្រឹកព្រហាមត្រជាក់ណាស់។

~ ឯមហ្អា ! (ពុកស្រែកហៅម៉ែដោយសម្លេងខ្សាវៗ) ឯង, ឯងកុំគិតដល់អញធ្វើអ្វី គិតតែខ្លួនឯង និង កូនស្រីទៅបានហើយ។ ឯងមិនចាំបាច់លក់មាសប្រាក់កូន ដើម្បីធ្វើបុណ្យខ្ចោចអញឲ្យអធិកអធមទេ ពីព្រោះបើទុកជាធ្វើបុណ្យធំដុំ ក៏វាគ្មានបានប្រយោជន៍អ្វី ក្រៅតែពីនាំឲ្យខាតលុយឥតប្រយោជន៍នោះឡើយ។ ឯងកុំលក់ផ្ទះណា យ៉ាងម៉េចៗក៏នៅសល់ដំបូលគ្រាន់ជ្រកនឹងគេដែរ... ឯណាកូនយើង? កូនមកជិតពុកបន្តិចមើល.....

ខ្ញុំដើរចូលទៅជិតទាំងរាងកាយញ័រចំប្រប់ដោយក្តីភ័យខ្លាច លុះប៉ះនឹងដៃគាត់ត្រជាក់ស្រីតដូចទឹកកក ខ្ញុំក៏ស្ទុះថយក្រោយវិញភ្លាម។

- កូន... (ពុកនិយាយ ព្រមទាំងដកដង្ហើមធំ) ។
យាយច្រានខ្ញុំចូលមកវិញ ហើយបន្ទោសថា
- ចៅឯង អីក៏ចិត្តអាក្រក់ម្លេះ ឪពុកមិនទាន់ស្លាប់ផង ឯងខ្លាចប៉ុណ្ណឹងទៅហើយ ធ្វើយ៉ាងនេះគេហៅថា កូនកតញ្ញូកើតដែរឬទេ?

ខ្ញុំអង្គុយស្ងាយល្មមតែពុកឈោងដៃចាប់មិនដល់ ឱនមុខជ្រុបយំអណ្តឹតអណ្តក់ទាំងមិនយល់ថាខ្លួនឯង យំពីរឿងអ្វីផង។

~ កូន ! (ពុកនិយាយម្តងទៀតដោយលើកដៃដាក់ប្រណម្យលើដើមទ្រូង) កូនស្តាប់សំដីពុកឲ្យច្បាស់ណា ពីព្រោះនៅលើដីនេះមានតែឪពុកទេដែលស្រឡាញ់កូន... ថ្ងៃណាមួយកូនគង់តែយល់ជម្រៅចិត្តពុកមិនខាន...។ អត់ពីឪពុកទៅ កូនកុំទុកចិត្តនរណាឲ្យសោះ ក្រៅតែពីខ្លួនឯង និង ម្តាយឯង ពីព្រោះមាមីង បងប្អូន ក៏ដោយក៏គ្មាននរណាគេស្រឡាញ់ឯងដូចម្តាយឪពុកដែរ។ កូនរៀនតាំងចិត្តឲ្យចេះចង់មាន ចង់បាន ហើយនៅប៉ើម្លឹងដួយកចិត្តទុកដាក់ធ្វើការខ្នាប់ខ្លួន កុំឈប់ទៅរាំងឲ្យសោះ ពីព្រោះក្នុងរាំងកូនមានដំបូលជ្រក និង មិនភ័យព្រួយពីរឿងអត់ឃ្លានមានស៊ី....

ម្យ៉ាងទៀតបើឯងមកនៅក្រៅ ខ្លាចក្រែងប្រុសឈ្លោលវាមើលងាយ ដោយឯងគ្មានឪពុកនៅជាបង្គោលសម្រាប់ការពារមើលខុសត្រូវ... កូនចងចាំដំបូន្មានពុកចុះ មិនខុសទេ។ ពិសេស កូនត្រូវដឹងគុណម្តាយ កុំធ្វើបាបម្តាយមេម៉ាយឲ្យពិបាកចិត្ត ឯងធំហើយត្រូវចេះកែតំនិតមាយាទឲ្យសមតាមអាយុ ឯងមិនមែនក្មេងទៀតទេ... ពុកមានតែពាក្យប៉ុណ្ណេះជាបណ្តាំចុងក្រោយបំផុតទុកឲ្យកូន មុននឹងលាកូនស្លាប់ បើកូនធ្វើតាមបណ្តាំឪពុក ពុកសប្បាយចិត្តណាស់ស្លាប់បិទភ្នែកជិតហើយ។

គាត់សម្រាន្តស្ងៀកស្តឹង បើកភ្នែកប្រឹងសម្លឹងមើលខ្ញុំ ហាក់ដូចជាគាត់ប្រុងនឹងស្ទុះមកស្រវាអោបខ្ញុំ។

- ហ៊ឹ! យិន វាស្រឡាញ់កូនណាស់, យាយកែមរអ៊ូតិចៗ ហើយច្រានខ្ញុំឲ្យខិតចូលទៅជិតពុកបន្តិចទៀត ប៉ុន្តែពុកមើលឃើញយាយបង្ហើបខ្លួន ស្មានថាគាត់ប្រឹងដើបដើរទៅណា ក៏ស្រែកអង្វរ:

- ម៉ែ, កុំទៅណាចោលខ្ញុំ ! កុំទៅណាចោលខ្ញុំ! ម៉ែ, កុំទៅណាចោលខ្ញុំ!
- អរហំ ! (យាយស្រែកខ្លាំងៗ ព្រមទាំងចាប់ដៃពុកឲ្យលើកប្រណម្យដាក់លើដើមទ្រូង).....
- អរហំ ! យិនឯង ទន្ទេញឲ្យចាំជាប់ក្នុងចិត្តទៅកូន!
- អរហំ... (ពុកទន្ទេញតាមយាយ) ។
យើងទាំងអស់គ្នាស្រែករកពុទ្ធោ ដោយលើកដៃសំពះខ្ពស់ហួសក្បាល។

ពុកផ្ងារក្បាលទៅក្រោយប្រុងត្រដរខ្យល់ម្តងទៀត... ប៉ុន្តែដង្ហើមផុតត្រឹមនេះទាំងភ្នែកបើកក្រឡែតនៅឡើយ។ ដៃដាក់ប្រណម្យជាប់លើដើមទ្រូង ម្រាមដៃប្រឹងភ្ជាប់លេចសរសៃរាម។ ម៉ែយំបោកខ្លួនលើទ្រូងពុក, យាយយកដៃទាញបិទភ្នែកសព, ចំណែកខ្ញុំខំប្រជ្រៀតទៅកៀនក្រែ ដោយមិនដឹងពីទំហំ នៃក្តីទុក្ខវេទនាដែលនឹងក្របសង្កត់មកលើខ្ញុំឡើយ។

ពុកសម្រាន្តនៅកន្លែងដដែល ប៉ុន្តែគេនិយាយថាគាត់ស្លាប់ទៅហើយ... ប្រហែលជាបន្តិចទៀតគាត់នឹងភ្ញាក់ឡើងវិញ....គាត់នឹងក្អក... គាត់នឹងនិយាយ... គាត់នឹងស្រែកហៅខ្ញុំក៏មិនដឹង។ ឱ! ប្រសិនបើ យ៉ាងនេះមែន ខ្ញុំនឹងស្ទុះទៅអោ

បគាត់ដូចកាលខ្ញុំនៅក្មេង ដែលគាត់ផ្តាប់តែលើកបីបំពេរដាក់លើភ្លៅយ៉ាងនោះដែរ! ពុក, ពុក, ខ្ញុំយំអណ្តឹតអណ្តក់នៅកៀនជញ្ជាំងតែម្នាក់ឯងឥតមាននរណាឃើញឡើយ ប៉ុន្តែពុកនៅស្ងៀមដដែល។ នេះជាលើកទីមួយ ដែលគាត់មិនឆ្លើយតបនឹងសម្តែងខ្ញុំហៅគាត់ ដែលជាហេតុធ្វើឲ្យខ្ញុំចាប់ផ្តើមយល់ថា ពុកឃ្លាតពីខ្ញុំទៅហើយ ឃ្លាតឥតមានពេលត្រឡប់មកវិញឡើយ។

ក្រោយដែលព្រះសង្ឃសូត្រធម៌ខ្មោចចប់ស្រួលបួល ម៉ែរៀបចំចង្ហាន់ប្រគេនលោកឆាន់ មានទាំងប្រអប់ម្ហូ-ស្លា សម្រាប់លោកឆាន់លាងព្រះឱស្ឋទៀតផង។ ឆាន់រួចហើយ លោកនិមន្តត្រឡប់ទៅវត្តវិញ ទើបយើងចាប់ផ្តើមរៀបចំសំអាតបុគ្គល។ សពពុកស្អាតចែសដោយទើបនឹងមុជទឹកហើយ សាច់សស្លាំង។ អ្នកភូមិជាច្រើននាក់ នាំគ្នាជួយជ្រោមជ្រែងម្នាក់មួយដៃមួយជើង... ស្មានមនរណាជឿថាពុកស្លាប់សោះ ទាល់តែមកឃើញច្បាស់នឹងភ្នែកទើបជឿ លាន់មាត់ស្តាយ។ អ្នកដែលបានឃើញតាអាចារ្យលាយថ្នាំឲ្យពុកពិសាកាលពីម្សិលមិញ គេនាំគ្នាចោទប្រកាន់ថា គឺគាត់នេះឯងដែលយកថ្នាំផ្តេសផ្តាសមកឲ្យឪពុកខ្ញុំពិសាទាល់តែស្លាប់។

គេមូរកន្ទេលកណ្តាលផ្ទះចេញ ប្រុសៗជួយលើកខ្មោចដាក់អង្គុយសណ្តូកជើងគងទៅលើជង្គង់ម៉ែ ចំណែកខាងចុងជើងដែលត្រជាក់ស្រេបនោះ គងលើជង្គង់ខ្ញុំ។ នេះជាការណីយកិច្ចចុងក្រោយបំផុតដែលខ្ញុំត្រូវបំពេញ ដើម្បីតបស្នងសងគុណឪពុក។ យើងស្រោចទឹក ដុសក្អែល រួចលាបទឹកអប់ ហើយយកកំណាត់ ទេសឯក ស មករុំព័ទ្ធ ក្រោយដែលម៉ែយកប្រាក់កាក់មួយមកបង់ក្តងមាត់សព។ បន្តិចក្រោយមក ម៉ែនាំខ្ញុំទៅកាន់ដំណាក់ផែ ដើម្បីទូលហ្លួងឲ្យបានជ្រាបពីដំណឹងដ៏ក្រៀមក្រំនេះ។ ពេលនោះស្រាប់តែមិត្តភក្តិទាំងអស់ គេបង្ហាញសមានចិត្តចំពោះខ្ញុំគួររំភើបក្រៃលែង។ វ៉ែនវាទទួលការ:ទៅទូលហ្លួងជំនួសខ្ញុំម្តងទៀត។ ហ្លួងកំពុងផ្ទំសោយអាភៀន លោកប្រទានប្រាក់ឲ្យខ្ញុំ ហុកសិបរៀល ព្រមទាំងបង្គាប់ទៅក្រុមវ៉ាងម្នាក់ ឲ្យចំណាយព្រះរាជទ្រព្យ ធ្វើម្ហូរស យកភ្លេង ទិញកំណាត់ទេសឯក និង ដេរគម្របម្ហូរសម្រាប់ប្រើក្តងពេលបុណ្យខ្មោចផង។ ហ្លួងបង្គាប់មិន ឲ្យខ្ញុំកោរសក់ និង ឲ្យខ្ញុំស្លៀកពាក់ ស ក្តងរយៈពេល មួយខែ ឬពីរខែ។

ខ្ញុំនាំម៉ែត្រឡប់មកផ្ទះវិញ ដោយហ្លួងសន្យាថា ស្អែកនេះម្ហូរសនឹងធ្វើរួចស្រេច ហើយគេនឹងដឹកយកមកឲ្យដល់ផ្ទះតែម្តង។ ផ្ទះខ្ញុំមានមនុស្សអ៊ូអរឡើងចុះតាំងពីព្រលឹមទល់ព្រលប់ ពីព្រោះម៉ែសំរេចថានឹងតាំកល់សពទុកពីរថ្ងៃទៀត។ ទោះបីពុកបានផ្តាំផ្ញើម៉ឹងម៉ាត់យ៉ាងណាក៏ដោយ ក៏ខ្ញុំមិនចង់ទុកគ្រឿងមាសប្រាក់មានតម្លៃធ្វើអ្វីដែរ។ ខ្ញុំលក់ប្រអប់ប្រាក់ពីរ យកលុយមកបង្គ្រប់ជាមួយលុយហុកសិបរៀល ដើម្បីទុកសម្រាប់ចំណាយផ្សេងៗក្តងពិធីបុណ្យ។ គ្រឿងប្រើប្រាស់របស់ពុកទាំងប៉ុន្មាន ខ្ញុំចែកចាយឲ្យបងប្អូនអស់លិង មានតាំងពី ខ្សៀវ ឈើច្រត់ប្រាក់ សម្លៀកបំពាក់ រហូតដល់តុ ទូទៀតផង។ រាល់ព្រឹកយើងនិមន្តលោកមក សូត្រធម៌ ទាល់តែឆាន់ព្រឹរួច ទើបលោកនិមន្តត្រឡប់ទៅវិញ។ អស់អ្នក-អស់នាងក្តងវ៉ាង និង កូនស្តេចខ្លះ យកអង្ករ លុយ ទៀន ធូប មកចូលកុសល ហើយមានពួកកម្លោះខ្លះដែលខ្ញុំមិនធ្លាប់ស្គាល់ទាល់តែសោះក៏យករបស់ផ្សេងៗមកចូលនឹងគេដែរ។
ថ្ងៃទីបី ជាថ្ងៃដង្ហែសពពុកទៅបូជានៅក្តងវត្តបុទុម ក្បែរស្រះស្រង់។

ចាប់តាំងពីពេលពុកស្លាប់ដោយពិសាថ្នាំគាត់នោះមក អាចារ្យក្រូផ្សំថ្នាំគាត់ពួនសម្ងំបាត់មុខ ខ្លាចក្រែងម៉ែរករឿងប្តឹងផ្តល់ ប៉ុន្តែយាយ ញ៉ាយាមពន្យល់ខ្ញុំកុំឲ្យចងពៀរនឹងតានោះធ្វើអ្វី ធ្វើម៉េចពុកបានជាស្លាប់ទៅហើយ បើទុកជាប្តឹងរកខុសត្រូវទាល់តែគាត់ជាប់គុកច្រវាក់ ក៏ពុកមិនអាចរស់មកវិញដែរ។ ខ្ញុំប្រើគេឲ្យទៅហៅគាត់មក ហើយនិយាយប្រាប់ថា:

- តាឯង យកថ្នាំផ្តេសផ្តាសមកឲ្យឪពុកខ្ញុំពិសាទាល់តែស្លាប់ ជាការត្រឹមត្រូវតែខ្ញុំប្តឹងផ្តល់រកឲ្យឃើញសខ្មៅ ប៉ុន្តែខ្ញុំចាត់ទុករឿងនេះថាជាសំណាងអាក្រក់របស់ឪពុកខ្ញុំទៅចុះ ប្រហែលពីជាតិមុនឪពុកខ្ញុំធ្លាប់បានសម្លាប់តាឯងហើយមើលទៅ បានជាជាតិនេះតាឯងតាមសងសឹកសម្លាប់គាត់វិញ។ ណ្ហើយចុះ តាកុំភ័យអី ខ្ញុំមិនប្តឹងទេ ប៉ុន្តែតាឯងធ្វើជាអាចារ្យស្រាប់ ជួយមើលចាត់ចែងបុណ្យខ្មោចឪពុកខ្ញុំផង ឮទេ?

តាអាចារ្យទទួលយល់ព្រមដោយចិត្តរីករាយ។ គាត់រៀបចំក្បួនដង្ហែ ប៉ុន្តែពួកភ្លេងវ៉ាងមកយឺតពេលពេក យើងមិនអាចចាំយូរគេទៅទៀតបាន ក៏ដាច់ចិត្តហែរចេញទៅទាំងអត់ភ្លេង។ អាចារ្យដើរពីមុខក្បួន ខ្ញុំដើរជាប់ពីក្រោយ គាត់ស្លៀកពាក់ស ទទូរសំពត់ស ដៃឆ្វេងកាន់ផ្តិលដាក់លាជលាយជាមួយប្រាក់កាក់ ដៃស្តាំលូកចាប់បាចហូរហែតាមផ្លូវ ដោយមានក្មេងមួយហ្វូងដើរតាមចាំដណ្តើមរើសយកលុយ។ ខាងក្រោយខ្នងខ្ញុំ ពួកអ្នកងារសែងត្រែស្នែង ដែលនៅលើនោះ មានដាក់ម្ហូរស និង មានព្រះសង្ឃពីរអង្គគង់អមសង្ខាង។ មិត្តភក្តិក្តងវ៉ាងខ្លះដូចជា សំអាង រឿង ឯម បូ កុំ ជាដើម ក៏បានមកជួយហែដែរ វាដើរខាងក្រោយជាមួយម៉ែ។ ពូនង ប្អូនបង្កើតរបស់ពុក ជាអ្នកបួសមុខភ្លើង។

នៅទីបញ្ចប់ យើងក៏បានមកដល់វត្តបុទុម ឃើញមានគេរៀបគខុសទុកហើយស្រេច។ យើងដើរប្រទក្សិណបីដុំ លើកម្ហូរសដាក់ទៅលើកំនរខុស បន្ទាប់មកតាអាចារ្យ និង អ្នកភ្លុកចាប់ដុតភ្លើង ហុយផ្សែងខ្មៅទ្រលោមទៅក្តងលំហអាកាស។ ខ្ញុំបែរខ្នងចេញ មិនអាចទ្រាំមើលទស្សនីយភាពដ៏ខ្ពោចផ្សានេះបានឡើយ... ម៉ែអង្គុយលើស្មៅស្រែកយំក្តែងៗ ...។

លុះដុតសុះអស់ ខ្ញុំបែរមកមើលឃើញនៅសល់តែកំទេចឆ្អឹងលាយឡំជាមួយផែះ និង រងើកភ្លើងប៉ុណ្ណោះ។ ព្រះសង្ឃនិមន្តត្រឡប់ទៅវត្តវិញ ចំណែកញាតិមិត្តទាំងអស់ និង ខ្ញុំ នាំគ្នារើសឆ្អឹងប្រមូលដាក់ក្តងកោដ្ឋមួយ ដើម្បីយកទៅដាក់ទុកក្តងចេតិយឯព្រែកថ្មី។

លុះធ្វើបុណ្យខ្មោចពុកចប់ស្រួលបួលហើយ ម៉ែអង្វរខ្ញុំថាឲ្យឈប់នៅវាំង មកនៅជាមួយគាត់វិញ ក្រាន់បានជាគ្នាជួយរកស៊ីចិញ្ចឹមជីវិត។ ប៉ុន្តែខ្ញុំរំលឹកគាត់ថា ពុកបានផ្តាំផ្តែចំមិនឲ្យខ្ញុំចេញពីវាំង ម្យ៉ាងទៀតនៅក្នុងវាំងខ្ញុំមានប្រាក់ខែបន្តិចបន្តួចដែរក្រាន់និងចិញ្ចឹមខ្លួន ដោយមិនបាច់រកស៊ីលក់ដូរនាំឲ្យនឿយខ្លួន។

ចាប់តាំងពីថ្ងៃនោះមក ហ្លួងហាក់ដូចជាមានសមានចិត្តអាណិតខ្ញុំច្រើន។ លោកបង្គាប់ឲ្យខ្ញុំដណ្តប់ផាហ៊ុស ជាសញ្ញាកាន់ទុក្ខឲ្យបានយូរ និង សន្យាថាលោកនឹងឲ្យគេសង់ផ្ទះក្បឿងបីខ្នងមួយសម្រាប់ម្តាយខ្ញុំ។ ក្រោយមកបន្តិច លោកប្រទានប្រាក់ទៅម្ចាស់ក្បត្រី ឲ្យកទៅចែកអស់អ្នក-អស់នាងក្នុងវាំងទាំងអស់ ហើយលោកសួរខ្ញុំថា តើមានបានទទួលប្រាក់រង្វាន់ប្រាំរៀល ដូចគេឯងដែរឬទេ? ខ្ញុំឆ្លើយថា បានទទួលតែបីរៀលទេ ពីព្រោះខ្ញុំបានតែបីរៀលមែន ហើយអ្នករបាំងទៀតៗក៏គេឆ្លើយដូចខ្ញុំដែរ។ តើប្រាក់នៅសល់ទាំងប៉ុន្មាន ម្ចាស់ក្បត្រីយកទៅចែកចាយឲ្យកូនចៅលោក ឬ យ៉ាងណា?... រឿងនេះធ្វើឲ្យហ្លួងមិនសប្បាយព្រះទ័យ ក៏ស្រែកឡឡាថា:

~ រ៉ាម វាគិតយ៉ាងម៉េចហ្នឹង? បើសិនជាវាខ្វះខាតលុយ មកសុំអញ អញមិនដែលថាមិនឲ្យម្តងណាសោះ រួចម៉េចក៏ថាមកកេងចំណេញលើប្រាក់បន្តិចបន្តួចរបស់ក្មេងក្នាងទៀត? ធ្វើអញ្ចឹងនាំឲ្យអ្នកមិនដឹងគេ យល់ច្រឡំថា អញនេះជាមនុស្សខូចទៅវិញ ហើយម្យ៉ាងទៀតវានាំឲ្យស្រីត្រឹមត្រូវ និង អ្នករបាំល្អៗ គេមិនសប្បាយចិត្តរត់ចោលអញអស់។

និយាយចប់ហើយ លោកប្រទានប្រាក់ជ្រាំរៀលថែមទៀតឲ្យខ្ញុំ ដែលជាហេតុធ្វើឲ្យអ្នកឯទៀតគេច្រណែនគ្រប់គ្នា។

ដល់ពេលដាច់ខែ ប្រាក់ខែខ្ញុំនៅតែត្រូវ យាយម៉ែន មេបំណុល គាត់យកអស់ដដែល គាត់ថាខ្ញុំមិនទាន់សងការប្រាក់គាត់គ្រប់ចំនួននៅឡើយ។ ស្មៅតគាត់ប្រសើរមែន ពីព្រោះគាត់មានកូនប្រុសម្នាក់ធ្វើការនៅកន្លែងបើកលុយស្រាប់ណាមួយគាត់ជាសាច់ញាតិនឹងម្ចាស់ក្បត្រី ចង់ធ្វើអ្វីក៏បានតាមចិត្ត ឥតមានកោតញញើតនរណាទេ ពីព្រោះម្ចាស់ក្បត្រីបើកដៃឲ្យហើយ។ ប៉ុន្តែឥឡូវនេះ ខ្ញុំមិនមែនលូងដដប់តត់ដូចពីដើមឯណា, ខ្ញុំមិនព្រមឲ្យនរណាប្រើស្មៅតបន្លំ រកស៊ីបិទភ្នែកខ្ញុំជាដាច់ខាត។ ខ្ញុំទៅសួរមើលថាតើប្រាក់ខែខ្ញុំ មានបានឡើងដល់ម្តៃរៀលដូចគេរាល់គ្នាដែរឬទេ? ព្រោះកាលទើបនឹងត្រឡប់មកពីបាត់ដំបងវិញភ្លាម ខ្ញុំឮហ្លួងបង្គាប់ឲ្យតម្លើងប្រាក់ខែយើងទាំងអស់គ្នា។ អ្នកឯម មេឃ្លាំងប្រាក់ បើកបញ្ជីមើលឃើញថាប្រាក់ខែខ្ញុំ នៅតែដប់រៀលដដែល។ នេះប្រាកដជាគេភ្លេចសរសេរចុះក្នុងបញ្ជីដោយចេតនាតែម្តង ដើម្បីស្រួលកេងបន្លំលើប្រាក់ខែខ្ញុំ។ ខ្ញុំដល់ចិត្ត ប្រថុយទៅទូលហ្លួងម្តងទៀត លោកក៏ប្រើឲ្យគេទៅហៅ ឯម មកគាល់។ ប៉ុន្តែស័យណាស់ ថ្ងៃនោះ អ្នកឯម មិននៅនឹងកន្លែង តាមរកមិនឃើញសោះ។ ដើម្បីជាការលួងចិត្ត ហ្លួងប្រទានប្រាក់ ម្តៃរៀល ឲ្យខ្ញុំ ហើយរឿងនេះត្រូវចប់ត្រឹមណេះ គឺប្រាក់ខែ ខ្ញុំនៅតែត្រឹមដប់រៀលរហូត។

ខែបន្ទាប់មក ខ្ញុំទៅតវ៉ានឹងអ្នកឯម ពីរឿងប្រាក់ខែម្តងទៀត គាត់និយាយថាខ្ញុំច្រឡំហើយ ប្រាក់ខែខ្ញុំឥតត្រូវឡើងទេ។ ខ្ញុំទៅទូលម្ចាស់ក្បត្រីឲ្យជួយរកយុត្តិធម៌ ប៉ុន្តែលោកធ្វើព្រងើយមិនដឹងមិនឮ។ ខ្ញុំអាចទៅទូលហ្លួងក៏បាន ប៉ុន្តែខ្ញុំមិនមែនចង់យករឿងផ្ទាល់ខ្លួនទៅរំខានលោក សុខចិត្តឲ្យគេកាត់ប្រាក់ខែមួយខែនេះទៀតចុះ។

លុយខ្លីតែហាសិបរៀលសោះ គេកាត់ប្រាក់ខែយកអស់រាល់ខែ។ មួយឆ្នាំកន្លះហើយ ក៏នៅតែមិនទាន់រួចលុយបំណុលហើយមិត្តភក្តិខ្ញុំដទៃទៀត ក៏ត្រូវគេប្រើស្មៅតអារកហុតឈាមដូចគ្នានេះដែរ។ ខ្ញុំមិនចាំបាច់ឆ្ងល់ទេ ទោះបីខ្ញុំតវ៉ាយ៉ាងណា ក៏ម្ចាស់ក្បត្រីនៅតែធ្វើត ធ្វើផ្តង់ជានិច្ច ពីព្រោះមធ្យោបាយរកស៊ីចងការប្រាក់នេះ វាអាចនាំឲ្យសាច់ញាតិលោកឆាប់បានជាត់ជំ។ ពិចារណាសព្វគ្រប់ទៅ ខ្ញុំដូចជាចាញ់ប្រាជ្ញគេ គួរឈឺចិត្តពេកណាស់។

រាល់ថ្ងៃ ម៉ែរស់នៅដោយសារបានពូខ្ញុំជួយផ្តល់ប្រាក់កាសបន្តិចបន្តួច ដល់យូរៗទៅ គាត់ជំពាក់គេច្រើនពេក ក៏លក់ផ្ទះនៅកំពង់ផែដើម្បីយកប្រាក់សងគេ។ គាត់អង្វរខ្ញុំឲ្យឈប់ទៅវាំង មកជួយរកស៊ីចិញ្ចឹមគាត់ផង ហើយនៅទីបញ្ចប់ ខ្ញុំក៏យល់ព្រមតាមពាក្យអង្វររបស់គាត់ទាំងបង្ខំចិត្ត។

ទោះបីខ្ញុំមានការជិនឆ្អន់នឹងអ្នកធំ អ្នកតូចខ្លះ នៅក្នុងវាំងក៏ដោយ ក៏ខ្ញុំលាចាកពីវាំងទៅទាំងទឹកភ្នែក ដោយក្តីស្តាយស្រណោះរបាំ ដែលខ្ញុំជាប់ចិត្តស្រឡាញ់តាំងពីក្មេងមក។ ពេលនេះហ្លួងហាក់ដូចជាពេញចិត្ត នឹងខ្ញុំណាស់ ប៉ុន្តែវាហួសពេលទៅហើយ ពីព្រោះសព្វថ្ងៃ អ្នកប្រកាន់ចិត្តស្អប់ ច្រណែនឈ្នានីសខ្ញុំ ក៏មានចំនួនច្រើនណាស់ដែរ ថ្ងៃណាមួយពួកគេអាចនឹងប្រឌិតរឿងនាំឲ្យខ្ញុំមានទុក្ខទោស ត្រូវគេវាយធ្វើបាបនឹងរំពាត់ផ្តៅ គេចាប់យកទៅឃុំឃាំងក្នុងសាលានាលិយក្បាមិនខាន។ ខ្ញុំសំរេចចិត្តរួចស្រេចហើយថាជាការល្អ គួរតែខ្ញុំឈប់នៅវាំងឲ្យបានទាន់ពេលវេលា។

ខ្ញុំរក្សារឿងនេះទុកជាសម្ងាត់រហូតទល់ថ្ងៃចុងក្រោយបំផុត មានតែ យ៉ាន ម្នាក់គត់ ដែលខ្ញុំប្រាប់ឲ្យដឹង។ ប៉ុន្តែវាមិនព្រមជឿសោះ ចេះតែថាខ្ញុំនិយាយលេង។ ចំណែកនាងរឿង “ប្អូន” ខ្ញុំនោះវិញ គាំងពីព្រលឹងថាខ្ញុំដិតឈប់នៅក្នុងវាំងមកវាស្រងូតស្រងាត់លែងរីករាយសោះតែម្តង។ ខ្ញុំខំនិយាយលួងលោមវាថា:

~ នែ រឿង, ឯងគិតឲ្យហ្មត់ចត់ទៅមើល តើសេចក្តីស្នេហារវាងស្រី និងស្រីនេះ វាបាននិយាយថាម៉េច? យើងស្រីដូចគ្នាប្រដាប់កំដូចគ្នា តើឯងចង់ឲ្យអញធ្វើម៉េចឯង? ឯងស្មានថាអញនៅតែធ្វើជាប្តីឯងអញ្ចឹង រហូតទៅឬ?

ប៉ុន្តែ រឿង និយាយពន្យល់ខ្ញុំវិញយ៉ាងច្បាស់លាស់ ពីសេចក្តីស្នេហារបស់វាចំពោះខ្ញុំ:

- ទេ! សារ៉ាម៉ានី, អ្នកយល់ខុសហើយ ខ្ញុំមិនមែនស្រឡាញ់អ្នកតាមរបៀបស្នេហាចំពោះនោះទេ ខ្ញុំស្រឡាញ់អ្នកពិតប្រាកដយ៉ាងស្មោះអស់ពីដួងចិត្ត ស្រឡាញ់ទាំងខ្ញុំខ្លួនឯងមិនដឹងថា ស្នេហានេះវាបណ្តាលមកពីអ្វីផង។ ទោះបីអ្នកត្រូវចេញពីវ៉ាងទៅមានប្តីស្រួលបួលត្រឹមត្រូវក៏ដោយ ក៏ខ្ញុំសុំទៅតាមនៅជាមួយអ្នកជានិច្ចក្តងហាន:ជាអ្នកបំរើម្នាក់ស្មោះត្រង់។

វានិយាយត្រង់មែន គឺវាសុខចិត្តឈប់នៅវ៉ាងមកតាមខ្ញុំ ហើយលោក(១៣) ក៏ធ្លាប់ស្គាល់វាដែរ មែនទេ? ពីព្រោះកាលយើងទើបនឹងរៀបការគ្នាហើយថ្មីៗ វានៅជាមួយខ្ញុំនៅឡើយ ប៉ុន្តែក្រោយមកវារអស់សង្ឃឹមក្តងចិត្ត ដោយឃើញខ្ញុំស្រឡាញ់លោកច្រើនជាងវា ទើបវាឈប់នៅជាមួយខ្ញុំ។ ទៅបានប្តីនោះអភ័ព្វទៀត ប៉ះលើមនុស្សប៉ោឡែ គេធ្វើបាបវេទនាខ្លាំងណាស់។

ខ្ញុំសំរេចចិត្តរួចហើយថាត្រូវតែឈប់នៅវ៉ាង។ ខ្ញុំជួលក្រុមវ៉ាងម្នាក់ ឲ្យលុយគាត់ពីរៀល ដើម្បីឲ្យគាត់ជួយសរសេរសំបុត្រថ្វាយបង្គំហួង។ ខ្ញុំបត់សំបុត្រជាបួន រួចតែងខ្លួនយ៉ាងស្អាតបាត ចូលទៅក្តងដំណាក់ហួងទាំងចិត្តរំភើបញាប់ញ័រក្រៃលែង។ ពេលឃើញខ្ញុំ ហួងញញឹមហើយបង្គាប់ខ្ញុំឲ្យអង្គុយជាមួយមិត្តភក្តិ ដទៃទៀតដែលត្រូវគាល់បំរើក្តងវេនទីបួន នៅចុងជើងគ្រែ ដើម្បីរៀបចំខ្សៀអាកៀន។ ខ្ញុំលើកខ្សៀដែល ស៊ុន វាងាក់អាកៀនរួចស្រេចថ្វាយលោក ប៉ុន្តែលោកឆ្លៀតលេងក់ប្លែងបន្តិចមុននឹងទទួលយកទៅសោយ។ ខ្ញុំគិត ឃើញថាពេលនេះមិនគួរនឹងថ្វាយសំបុត្រដល់លោកទេ ទើបស៊កវាលាក់ទៅក្រោមកន្ទេលសិន។

ហួងផ្តំសោយអាកៀនដោយឆ្លៀតនិយាយចំអន់លេងរើសប្តីឲ្យយើងសុទ្ធតែមនុស្ស គម កើតស្រែង ឬ អ្វីទៀតតាមតែលោកនឹកឃើញ។ លោកនិយាយថា ស៊ុន លបសាហាយនឹងក្រុមវ៉ាង ចំណែកខ្ញុំមានសាហាយម្នាក់ ជាអ្នកលេងនៅផ្សារថ្មី។ ស៊ុន យកក្បួយដៃបុកខ្ញុំ ហើយខ្សឹបថា :

- សារ៉ាម៉ានី ឮទេ? ហួងនិយាយលេងជាមួយឯងដូចជាស្មំគាប់ព្រះទ័យដែរ... កុំអាលចេញទៅណាអី ទ្រាំនៅវ៉ាងមួយឆ្នាំទៀតទៅ។

ខ្ញុំធ្វើជាមិនឮ មិនខ្វីសើចនឹងពាក្យកំប្លែងរបស់ហួងទៀតផង។
ហួងទំនងជាសង្ឃឹមអ្វីម្យ៉ាងក៏ឈប់និយាយ បែរទៅសោយអាកៀនធ្វើមុខមាំ។ ចាំដល់លោកសោយ បានពីរខ្សៀ ទើបខ្ញុំហុតយកសំបុត្រពីក្រោមកន្ទេលថ្វាយទៅលោក។ លោកជ្រួញចិញ្ចើម ហាក់ដូចជាដឹងសេចក្តីក្តងសំបុត្ររួចស្រេចអស់ទៅហើយ។ ខ្ញុំឱនមុខចុះញាប់ញ័រអស់ខ្លួនប្រាណ។

- សំបុត្រស្អីហ្នឹង? (លោកសួរខ្ញុំ ព្រមទាំងលាសំបុត្របញ្ចាំងមើលនឹងពន្លឺភ្លើង)។
- ក្រាបទូល! (ខ្ញុំឆ្លើយតបទាំងអួលដើមកស្ទើរនិយាយមិនចេញ) ខ្ញុំម្ចាស់សុំច្បាប់ឈប់។
- ថាម៉េច? (លោកស្រែកខ្លាំងៗព្រមទាំងស្ទុះងើបអង្គុយលើគ្រែ) ឈប់ទៀតហើយ ! បន្តិចឈប់ៗ, វាមានរឿងអីទៀតហើយហ៊ា?
- ទេ ក្រាបទូល! ខ្ញុំម្ចាស់ សុំឈប់ធ្វើការ សុំឈប់នៅវ៉ាងរហូតតែម្តង។
ខ្ញុំមិនហ៊ានងើបក្បាលទេ ហួងងើបដើរចុះ ដើរឡើង ដោយចិត្តអន្ទះអន្ទែង ហើយនិយាយរបៀបកាចថា:
- មានរឿងតែប៉ុណ្ណឹងទេហ្អែ? ប៉ុន្តែ មិនអីទេមីនាង ចេញទៅចុះ ឲ្យលោកមហាមន្ត្រីយកសំបុត្រលុបឈ្មោះមក ចាំអញស៊ុញ្ជៅឲ្យ ហ៊ឺះ អញអាណិតឯង ព្រោះដឹងថាឯងកំព្រាឪពុក អញសន្យាថានឹងសង់ផ្ទះឲ្យ ថាតម្លើងប្រាក់ខែឲ្យ ប៉ុន្តែឯងបែរជារត់ចោលអញទៅវិញ។ អញមិនឃាត់ឃាំងឯងទេ ពីព្រោះវាជារឿងផ្ទាល់ខ្លួនរបស់ឯង... អម្បាញ់មិញអញនិយាយលេងថា ឯងមានសាហាយ មិនស្មានថាឯងលបមានសាហាយនៅខាងក្រៅអញ្ចឹងសោះ។

លោកត្រឡប់មកផ្តំលើគ្រែវិញ លែងមាត់ លែងកេ ធ្វើមុខស្រងូត។ លោកសោយអាកៀនច្រើនណាស់ សោយហើយសោយទៀត។ វេនខ្ញុំជុតទៅហើយ ប៉ុន្តែចង់បង្ហាញឲ្យឃើញជាចុងក្រោយបំផុត នូវទឹកចិត្ត ស្ងិតស្ងាញក្តងការងារ ទើបខ្ញុំមិនទាន់ចេញមកភ្លាមជាមួយគេឯង សុខចិត្តទ្រាំនៅអង្គុយគាល់ឲ្យយូរបន្តិច។

អស់អ្នក-អស់នាងដែលបានទទួលដំណឹងថា ខ្ញុំសុំឈប់នៅវ៉ាង គេនាំគ្នាមកប្រជុំអ៊ូអរនៅមាត់ទ្វារ.... អ្នកច្រណែនឈ្នានីសនឹងខ្ញុំ គេហួចសប្បាយចិត្ត ពីព្រោះគេដឹងច្បាស់ថា ខ្ញុំឈប់នៅវ៉ាងចំលើពេលដែលហួងកំពុងសព្វព្រះទ័យនឹងខ្ញុំ។ អ្នកខ្លះទៀតនឹកគិតក្តងចិត្តថា ខ្ញុំឈប់នៅវ៉ាងព្រោះមានកូកំណាន់ចិត្តនៅខាងក្រៅ។

ស្អែកឡើងខ្ញុំត្រឡប់មកដំណាក់ម្តងទៀត សង្ឃឹមថានឹងបានទទួលសំបុត្រអនុញ្ញាតិឲ្យចេញមិនខាន។ ហួងមើលឃើញខ្ញុំដែរ ប៉ុន្តែលោកបែរជាហុចដាវីស៊ីហ្គ្រាមួយដើមមកឲ្យខ្ញុំ ធ្វើឫកហិដូចជាមិនដឹងរឿងអីសោះ។ ខ្ញុំខំទ្រាំអត់ចាំដល់ស្អែកមួយទៀត នៅតែមិនឮលោកថាម៉េចដដែល ក៏ប្រថុយទូលលោកថា អីវ៉ាន់ តុ ទូ ទាំងប៉ុន្មាន ខ្ញុំរៀបចំរួចស្រេចអស់ទៅហើយ នៅចាំតែព្រះរាជានុញ្ញាតប៉ុណ្ណោះ នឹងអាលជញ្ជូនអីវ៉ាន់ យកទៅផ្ទះ ស្រាប់តែលោកធ្វើជាភ្ញាក់:

~ អើ, ល្អហើយអញ្ចឹង ! ចាំស្អែកមកយកសំបុត្រពីអញទៅណា!

(១៣) គឺ ជាវ៉ាងជាប្តីនាង ដែលនាងកំពុងនិយាយរឿងជ្រាប់ ។

ល្ងាចនៃថ្ងៃនោះ នាយទាហានក្រុមវាំងម្នាក់ដែលជាមនុស្សទំនុកទុកចិត្តរបស់ហ្លួង តាមមករកខ្ញុំដល់បន្ទប់ ហើយនិយាយថា :

- អ្នក, ពេលនេះព្រះករុណាកំពុងសព្វព្រះទ័យនឹងអ្នកណាស់ មិនគួរអ្នកឈប់នៅវាំងសោះ... លោកប្រើខ្ញុំឲ្យមកប្រាប់ថា បើអ្នកព្រមនៅបំរើលោកតទៅទៀត លោកនឹងតម្លើងប្រាក់ខែជូន។ ស្តាយណាស់ អ្នក មិនគួរបដិសេធសប្បុរសធម៌របស់ព្រះករុណាទេ។

- ហួសពេលទៅហើយ, (ខ្ញុំប្រកែកដោយទាញហេតុផលមកវែកញែកយ៉ាងសមរម្យ) ខ្ញុំមិនអាចផ្លាស់ប្តូរគំនិតបានទេពេលនេះ បើខ្ញុំព្រមនៅតទៅទៀត ហ្លួងពិតជាមិនអាចបំភ្លេចរឿងនេះបានទេ ហើយលោកថែមទាំងគុំគួនស្អប់ខ្ញុំទៀតផង ថាខ្ញុំមិនស្មោះត្រង់នឹងលោក ព្រមនៅវាំងព្រោះតែចង់បានប្រាក់ខែច្រើន... ។

មួយម៉ោងក្រោយមក គេនាំយកសំបុត្រដែលហ្លួងស៊ីញ្ជើរួចស្រេចមកឲ្យខ្ញុំ ហើយខ្ញុំក៏ប្រញាប់រៀបចំអីវ៉ាន់ ដើម្បីស្នែកឲ្យបានចេញដំណើរពីព្រលឹម។ ខ្ញុំមិនប្រាប់នរណាឲ្យដឹងថា ខ្ញុំនឹងជញ្ជូនអីវ៉ាន់ចេញនៅម៉ោងប៉ុន្មានជាពិតប្រាកដពីព្រោះរឿងអ្នករបាំដែលធ្លាប់រស់នៅក្នុងវាំងតាំងពីក្មេងមក ហើយបែរជាឈប់ទៅវិញយ៉ាងនេះ គឺជារឿងចម្លែកមិនដែលមានទាល់តែសោះ វាអាចធ្វើឲ្យគេភ្ញាក់ផ្អើលខ្លាំងណាស់។ ម៉ែ និង បងប្អូន ពីរបីនាក់ មកជួយជញ្ជូនក្រែ ពូក កន្ទេល ទូ និង តុតូចតាច ដោយក្រុមវាំងម្នាក់ឈរចាំត្រួតពិនិត្យមើល ក្រែងខ្ញុំមានយកដោយរបស់អ្វីមួយដែលពុំមែនជារបស់ខ្លួន។ អីវ៉ាន់ខ្ញុំពុំទាន់រើយកចេញពីបន្ទប់ផង មីសួន វាជញ្ជូនរបស់វាយកមកដាក់ភ្លាមមួយរំពេច ហើយចាប់តាំងពីថ្ងៃនោះមក វាបានដូរឈ្មោះជាវីឡា ឡើងហាន:ជាស្នំឯក គាប់ព្រះទ័យហ្លួងលើសគេទាំងអស់។ ខ្ញុំមិនច្រណែននឹងវាទេ វាសនាមនុស្សម្នាក់ៗ សុទ្ធតែទេវតាលោកចារមករួចស្រេច គ្មាននរណាអាចប្រកែកប្រណាំងពុំព្រមទទួលបានឡើយ។

ខ្ញុំចេញពីព្រះរាជវាំងតាមទ្វារព្រលប់ ចេញរហូតតែមានពេលវិលត្រឡប់មកវិញឡើយ... ក្នុងវាំង នរណាក៏ដឹងដែរ រឿងហ្លួងទទួចអង្វរឲ្យខ្ញុំនៅវាំង ហើយរឿងនេះវាធ្វើឲ្យខ្ញុំនឹកភ័យព្រួយជាប់ក្នុងចិត្តជានិច្ច ទោះបីខ្ញុំឈប់នៅវាំងហើយក្តី។ រទេះមួយដឹកអីវ៉ាន់ឆ្ពោះទៅកាន់ផ្ទះថ្មី នៅក្បែរផ្សារដែលម៉ែទើបនឹងជួលបានក្រោយពេលលក់ផ្ទះឯកំពង់ផែ។ បន្ទប់ម៉ែជួលស្ថិតនៅជាន់ខាងលើ ចំណែកពូខ្ញុំម្នាក់ឈ្មោះ សំរឹត រកស៊ីធ្វើជាងកាត់សក់ ជួលនៅជាន់ខាងក្រោមជាមួយប្រពន្ធកាត់។ កាត់មានកូនស្រីម្នាក់ឈ្មោះ ស្នារ ដែលខ្ញុំអាចប្រើប្រាស់បានតាមចិត្ត ជាជំនួសការ៉ិន ព្រោះ ការ៉ិន វាត្រឡប់ទៅនៅព្រែកថ្មីវិញបាត់ទៅហើយ។

ខ្ញុំខ្លាចទីក្រុងស្មើរមិនហ៊ានអើតមើលទៅក្រៅតាមមាត់បង្អួចផង ជាពិសេស ពូ កាត់លាក់បំបាំងខ្ញុំណាស់។
ប៉ុន្តែ មិនបានប៉ុន្មានផង ស្រាប់តែលេចឃើញប្រុសកម្លោះដើរទៅមកប្រសេចប្រសាចតាមផ្លូវ អាអាក្រក់ ក៏មាន អាល្អក៏មាន។ គេចេញចូលឈរតតជាច់មកឲ្យពូខ្ញុំកាត់សក់ ហើយអ្នកដែលធ្លាប់ស្គាល់ម៉ែបន្តិចបន្តួច ក៏ខំទាក់ទងរាប់អាន ធ្វើឫកជាអាណិត ទិញរបស់របរមកជូនម៉ែជារឿយៗ ដែលជាហេតុអាចញុំាង ស្តានភាពគ្រួសារយើងឲ្យធូរស្រាលបានមួយកំរិតធំ។ ពេលនោះស្រាប់តែលេចឃើញ ឱរ ជា "សម្តាញ់អាប់" របស់ នុន ក្រឡប់មកពីបាត់ដំបងវិញដឹងថាខ្ញុំឈប់នៅវាំង វាសប្បាយចិត្តរីកមុខប៉ុនចង្កេរ។

វានិយាយប្រាប់ថា នុន មានប្រពន្ធអ្នកបាត់ដំបង រួចវាលួចសរសេរសំបុត្រទៅប្រាប់ នុន ថាកុំឲ្យនឹកមកខ្ញុំធ្វើអ្វីពីព្រោះបានរៀបចំការនឹងខ្ញុំហើយ។ អានេះចំជាខូចមែន!។

ក្នុងពេលជាមួយគ្នានេះ ក៏មានអ្នកផ្សេងទៀតជាច្រើនចូលមកស៊ីដណ្តឹងខ្ញុំដែរ ម្ល៉ោះហើយបរិយាកាសក្នុងគ្រួសារ ប្រៃជាអាប់អួររកផ្លូវដោះស្រាយមិនរួចសោះ។ យើងមិនដែលហ៊ានចេញដើរទៅណាមកណាឡើយ ដោយខ្លាចពួកកម្លោះឈរវាអស់នោះព្រួតគ្នាចាប់ធ្វើបាប។ ម៉ែនាំយកខ្ញុំមកលាក់នៅផ្ទះបងប្អូនម្នាក់ ធ្វើជារាជការហ្លួងនៅក្នុងវាំង។ គាត់នោះចាស់បន្តិចមែន ប៉ុន្តែប្រពន្ធគាត់នៅក្មេងល្អក់ឈ្មោះ មីងចែម ។ បានមកនៅផ្ទះថ្មីនេះ ខ្ញុំដូចជាធូរទ្រូងច្រើន។

មេក្រុមវាំងឈ្មោះ ទុយ នាំដំណឹងពីក្នុងវាំងមកប្រាប់ខ្ញុំដល់ផ្ទះ មីងចែម ថាហ្លួងឥតភ្លេចខ្ញុំទេ លោកឧស្សាហ៍សាកសួរគេឯងជារឿយៗពីសុខទុក្ខខ្ញុំ ហើយលោកឆ្ងល់ខ្លាំងណាស់នៅពេលឮគេនិយាយថា ខ្ញុំមិនទាន់មានប្តីនៅឡើយ។ ថ្ងៃមួយចៅហ្វាយខេត្តម្នាក់ទើបនឹងរៀបការប្រពន្ធហើយថ្មីៗ នាំគ្នាទៅថ្វាយបង្គំហ្លួង ស្រាប់តែលោកនិយាយលេងរបៀបកំប្លែងថាបើចង់រកប្រពន្ធ ឲ្យមកដណ្តឹងខ្ញុំវិញ ពីព្រោះ "សារ៉ាម៉ានី" វាក្រ ហើយកំព្រាឪពុកផង។ លោកចៅហ្វាយខេត្តប្រហែងពោះជួង ប្រកែកញាប់មាត់ថា គាត់មិនអាចលែងប្រពន្ធដែលទើបនឹងរៀបការនេះបានទេ។

ក្រោយបន្តិចមកទៀត ម្ចាស់សូរីវង្ស កូនប្រុសច្បងរបស់ហ្លួង ដែលល្បីខាងខូចខិលរកលេខដាក់គ្មាន មួយថ្ងៃៗគិតតែញ៉ែជាមួយប្រពន្ធស្តេចឪពុក និង ស្រីជាំអាវាត់អារាយនោះ ក៏តាមរកទាល់តែឃើញផ្ទះខ្ញុំដែរ។ លោកសួរខ្ញុំថា សព្វថ្ងៃរកស៊ីធ្វើការអ្វី ហើយថាលោកចង់នាំខ្ញុំឲ្យទៅនៅផ្ទះជាមួយលោក ខ្ញុំឆ្លើយថាមិនហ៊ានទៅទេ ពីព្រោះថាលោកមិនមែនជាសាច់ញាតិនឹងខ្ញុំ បើធ្វើល្អនឹងខ្ញុំពេកទៅខ្លាចក្រែងអ្នកផងគេសើច។ លោកមិនចាំឲ្យខ្ញុំនិយាយបានច្រើនទាន់ ប្រញាប់លាចេញទៅវិញភ្លាម ដោយឆ្លៀតញាក់ចិញ្ចើមរបៀបខូចបន្តិចផង។

ទោះបីម៉ែខំបំរែងដានលាក់បំពួនយ៉ាងណា ក៏ពួកកម្លោះៗតាមរកទាល់តែឃើញ ហើយម្នាក់ៗខិតខំយកចិត្តយកថ្លើមម៉ែតែរៀងខ្លួន។ នរណាធ្វើអីក៏ធ្វើទៅ នរណានិយាយថាម៉េចក៏ម៉ែចេះតែអ៊ីអើ ប៉ុន្តែគាត់មិនហ៊ានសម្រេចថាលើកខ្ញុំឲ្យទៅនរណាឡើយ ពីព្រោះថាបើឲ្យទៅអ្នកមួយ អ្នកឯទៀតច្រណែនតាមញាបាទឈ្នានីសមិនខាន។ ចំពោះខ្លួនខ្ញុំផ្ទាល់ ខ្ញុំនឹងស្រឡាញ់បុរសណាដែលអាចយកឈ្នះលើគូប្រជែងទាំងអស់បាន, ទាល់តែអ្នកដែលមានប្រាជ្ញាឈ្លាសវៃលើសគេ ទើបសមធ្វើជាប្តីខ្ញុំ។ សភាពល្ងីងជូរចត់នៃជីវិតបាន ធ្វើឲ្យខ្ញុំកើតទុក្ខតប់ប្រមល់ស្មមខ្លួន នឹកស្តាយកាលរស់នៅក្តងវាំង ព្រោះកាលនោះ សេរីភាពខ្ចាំហាក់ដូចជាទូលំទូលាយជាងសព្វថ្ងៃបន្តិច។

ពេលនោះក្រុមវាំងម្នាក់មកជួបនឹងម៉ែជាថ្មីម្តងទៀត ដើម្បីប្រាប់ថាបើខ្ញុំមិនទាន់មានប្តីទេ ហួងឲ្យហៅខ្ញុំទៅនៅវាំងវិញ លោកសន្យាថានឹងមើលថែទាំខ្ញុំដូចពីដើម ហើយលោកនឹងបំភ្លេចចោលរឿងដែលខ្ញុំគេចឈប់នៅវាំងនេះ។ ខ្ញុំមិនឆ្លើយថាព្រម ឬ មិនព្រមទេ ប៉ុន្តែខ្ញុំកាន់តែយល់ច្បាស់ហើយថា ទោះបីអត់ឃ្លានមានស៊ីយ៉ាងណា ក៏ការរស់នៅរបស់ខ្ញុំសព្វថ្ងៃ វាមានឯករាជ្យភាពពេញលេញបរិបូណ៌ច្រើនជាងនៅក្នុងវាំងដែរ។

យប់មួយ ខ្ញុំដេកយល់សប្តីឃើញពស់មួយសម្បុរសស្អុស ចេញតាមចឹកខ្ញុំជាប់។ ខ្ញុំភ័យភ្ញាក់ដឹងខ្លួន និយាយរឿងនេះប្រាប់មីងចែម ស្រាប់តែគាត់សើចញឹមៗហើយទាយទុកថា ខ្ញុំដល់ពេលជួបគូព្រេងហើយ ត្រូព្រេងនោះជាមនុស្សសម្បុរស។

ចាប់តាំងពីពេលយល់សប្តិនោះមកមិនទាន់បានមួយអាទិត្យផង ថ្ងៃមួយម៉ែនាំទៅលេងផ្ទះសម្លាញ់គាត់ ខ្ញុំក៏ប្រទះឃើញលោក ដែលគ្រាន់តែឃើញភ្លាម ខ្ញុំអាចស្គាល់ភ្លាមថាលោកប្រាកដជាកូនបាវាំងដែលខ្ញុំធ្លាប់ជួបនៅក្តងវាំងម្តងកាលពីឆ្នាំទៅនោះហើយ។ សម្លាញ់ម៉ែនិយាយប្រាប់គាត់ថា លោកស្រឡាញ់ខ្ញុំ ចង់ចូលស្តីដណ្តឹងរៀបការត្រឹមត្រូវតាមទំនៀមទម្លាប់ប្រពៃណីខ្មែរ ម៉ែនាំយករឿងនេះមកពិគ្រោះជាមួយបងប្អូន គេក៏យល់ស្របទាំងអស់គ្នាព្រមលើកខ្ញុំឲ្យមកកូនបាវាំងឈ្មោះ កម្លោះ ពីព្រោះហេតុការណ៍ទាំងប៉ុន្មានដែលកើត មានតួងពេលនេះ វាត្រូវតាមពាក្យទំនាយពីមុនមកឥតខ្ចោះ។

ជាសំណាងល្អ ខ្ញុំបានមកភពប្រសព្វនឹងលោក ដែលជាមនុស្សមានធម៌ជួយស្រោចស្រង់ខ្ញុំឲ្យចាកផុតអស់ទុក្ខវេទនាផងទាំងពួង។ លោកជាអ្នកមានអំណាចលើសគេ ជាអ្នកឈ្នះលើគូប្រជែងទាំងអស់ ដែលបានចូលមកស្តីដណ្តឹងខ្ញុំ!...។

កម្លោះ ទ្រោបខ្លួនទៅជិតចង្កៀងធ្វើក្តែកមមី ហាក់ដូចជាដោកងុយដោយសារស្តាប់រឿងដ៏ហូរហែរវែងអន្លាយរបស់ភរិយា។ តុកកែពីរនៅដំបូលផ្ទះ វាចូលឆ្លើយឆ្លងគ្នាខាងក្រៅផ្ទះស្លឹកឈើបក់រវិចតាមកម្លាំងខ្យល់ ប៉ះទង្គិចគ្នាលាន់ឮប្រារឮ!

ខ្យល់ដំនោរបក់នាំសម្លេងពិណពាទ្យដ៏សែនពិរោះលន្លង់លន្លោច មកបំពេរបំបោសអង្អែលសង្កាត់កំពង់ផៃ ឲ្យគេដេកលក់ស្កាត់ជ្រងំ។ សារ៉ាម៉ានី ស្ទុះងើបឈរបង្ហាញរាងកាយទន់ល្អតល្វែសមឥតខ្ចោះ ប្រៀបបានកិន្នរីក្តងរឿងព្រេងបុរាណខ្មែរ ហើយឧទានថា:

~ លោក! ស្លៀកពាក់ឆាប់ឡើង, ពេលនេះជិតពាក់កណ្តាលអាធ្រាត្រទៅហើយ... លោកជូនខ្ញុំទៅមើលពួកក្មេងថ្មីៗវារាំម្តងណា!

និយាយរួច នាងបោះជំហានញាប់ស្មេតម្រង់ទៅរកបន្ទប់ទឹកជាំងស្លឹកនៅក្បែរចង្រ្កានបាយ។
ពន្លឺចង្កៀងចាំងចូលព្រាលៗ ស្ទើរងងឹត ស្ទើរភ្លឺ ទៅក្តងបន្ទប់តូចនេះ ហាក់ដូចជាជួយបិទជាំង ពុំចាំបាច់ឲ្យនាងប្រយ័ត្នប្រយែងខ្លួនប៉ុន្មានឡើយ។ ដៃកាន់ផ្តិលប្រាក់ នាងដងទឹកពីក្តងពាងមកចាក់បង្ហូរស្រោចស្រប លើដងខ្លួនហៀរស្រក់ទៅលើក្តារកំរាល ហើយដុះសាប៊ូសព្វសព៌ាង្គកាយយ៉ាងញាប់ដៃ ទំនងជាប្រញាប់រួចស្រោចទឹកម្តងទៀតដើម្បីលាងសំអាតខ្លួនឲ្យជ្រះសាប៊ូ។
ហ៊ុងមួយនៅក្រោមផ្ទះ ស្រែកបញ្ចេញក្តីសប្បាយរីករាយ ដោយត្រូវទឹកត្រជាក់ធ្លាក់ទៅលើខ្លួន ហើយសម្លេងមួយទៀតដូចគ្នាបេះបិត បន្ទំឆ្លើយឆ្លងគ្នាចេញពីក្រោមផ្ទះអ្នកជិតខាង... ប្រជៀវហើរឆាបទង្គិចនឹងស្លឹកចេកលាន់ឮសូរចង្កែតកូរព្រឹក្បាល។
សារ៉ាម៉ានី ដាក់ផ្តិលទៅលើគម្របពាង ទាញយកសារុងសូតមកផ្លាស់ ដើម្បីទាញយកសំពត់ទទឹកចេញពីខ្លួន បន្ទាប់មកនាងបើកទ្វារបន្ទប់ទឹកដើរកាត់តាមចង្រ្កានបាយចូលមកក្តងផ្ទះដំរិញបណ្តើរ ជូតខ្លួននឹងក្រមាសូត្របណ្តើរ:

- អ៊ូយ! អ៊ូយ! (នាងនិយាយទាំងរងារញ័ររណ្តំថ្ពាម) ទឹកត្រជាក់ណាស់លោក! ខ្ញុំស្លៀកសំពត់អីហ៎? មីកាហ៊ុន ឆាប់ឡើង, បើកហិបយកសំពត់មកឲ្យអញស្លៀក ហើយយកចង្កៀងចូលក្តងផ្ទះទៅ!.....។

ចប់
រៀបចំបោះពុម្ពឡើងវិញដោយទស្សនាវដ្តីអង្គរវត្តនៅក្រុងប៉ារីសខែសីហា២០០៥